# វគ្គទី ៧
# លោកអគ្គលេខា
# (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

តួនាទីជាអគ្គលេខាធិការនៃ រ.ជ.រ.ប.ខ. ជាតួនាទីដ៏សំខាន់មួយនៅក្នុងរណសិរ្សទោះបីជាតួនាទីនោះ គ្មានសិទ្ធិបោះឆ្នោតក្នុងការសំរេចណាមួយរបស់គណៈកម្មាធិការប្រតិបត្តិ ឬ កូមិុច យ៉ាងណាក៏ដោយ ។ អគ្គលេខាធិការជា អ្នកសំរបសំរួលការងារទាំងអស់ទាំងផ្នែកហិរញ្ញវត្ថុ នយោបាយ ការទូត និង រដ្ឋបាល ។ អគ្គលេខាធិការជាតំណាងរបស់ រ.ជ.រ.ប.ខ. នៅចំពោះមុខអាជ្ញាធរថៃ ជាពិសេសចំពោះក្រុមយោធាថៃដែលទទួលបន្ទុកការងារកម្ពុជា ។ នៅពេលអវត្តមានរបស់ប្រធាន និង នៅក្នុងករណីដែលអនុប្រធានអសកម្ម អគ្គលេខាជាមនុស្សទីពីរនៅតាមខ្សែបញ្ជានៃចលនាតស៊ូរបស់យើង ។ តាមធម្មតា អគ្គលេខាជាមនុស្ស ជិតជិតបំផុតរបស់ប្រធាន ដែលត្រូវតែធ្វើការជាមួយគ្នាយ៉ាងស្អិតរមួត ទើបអាចទទួលជោគជ័យបាននៅក្នុងបេសកកម្មដើម្បីបុព្វហេតុជាតិ ។ ក៏ប៉ុន្តែ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដោយសារកត្តាមួយចំនួន ទំនាក់ទំនងរវាងលោកតា សឺន សាន និង លោកអគ្គលេខា នាង ជិនហាន ត្រូវបានធ្លាក់ដល់កំរិតមួយ ដែលធ្វើឲ្យបាត់បង់នូវការទុកចិត្តគ្នាទៅវិញទៅមក រហូតបង្កើតបានជាទំនាស់ផ្ទៃក្នុងដែលធ្វើឲ្យ រ.ជ.រ.ប.ខ. ក្នុងឋានៈជាចលនាតស៊ូអ្នកជាតិនិយមមិនមែនកុម្មុយនីស្តដ៏ធំទៅជាទន់ខ្សោយទៅវិញ ។ នៅទីបំផុត នៅចុងឆ្នាំ ១៩៨៧ លោក នាង ជិនហាន ក៏ត្រូវបង្ខំឲ្យបោះបង់ចោលមុខតំណែងដ៏សំខាន់នេះ ។

# ពួកជក់ខ្សៀ និង មនុស្សជាភ្នែក ជាត្រចៀករបស់លោកតា

លោក នាង ជិនហន ជាមនុស្សមានសមត្ថភាព សមនឹងទទួលមុខនាទីជាអគ្គលេខារ.ជ.រ.ប.ខ.នេះណាស់ ។ គាត់ជាមន្ត្រីពូកែខាងគ្រប់គ្រងផ្នែករដ្ឋបាលមានជំនាញយ៉ាងច្បាស់លាស់ខាងក្រដាសស្នាម ។ តាំងពីដើមដំបូង គាត់ខំព្យាយាមរៀបចំរបៀបរបបការងាររដ្ឋបាលរបស់ រ.ជ.រ.ប.ខ. ប្រហាក់ប្រហែលគ្នានឹងរបៀបរបបការងាររបស់ប្រទេសដ៏តូចមួយ ដោយមានក្បួនច្បាប់ និង ទំរង់បែបបទច្បាស់លាស់ ទោះជាសេចក្តីសំរេច ឬ ក្រឹត្យ ឬ ក្រមច្បាប់ក្តី ។ លោក នាង ជិនហន បានរៀបរៀងជាសេចក្តីសំរេចមួយចំនួន ដែលក្រោយមកត្រូវបានកែប្រែជាក្រម-ច្បាប់របស់រ.ជ.រ.ប.ខ.។ ទំនាក់ទំនងការងាររដ្ឋបាលនេះ មានគោលបំណងការពារ កុំឲ្យមានការរំលោភអំណាច និង កំណត់បទបញ្ញាសំរាប់ការងាររបស់សមូហភាព ។ គាត់ចេះរៀបចំរចនាសម្ព័ន្ធទាំងអស់របស់ការិយាល័យរ.ជ.រ.ប.ខ. ប្រចាំនៅទីក្រុងបាងកក ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់ បើមិនជាក់ស្តែងយ៉ាងហោចណាស់ក៏នៅលើក្រដាសដែរ ទាំងនេះរួមទាំងការដាក់ឲ្យនៅក្រោមឱវាទផ្ទាល់របស់គាត់នូវកូនលោកតា សឺន សាន និង មន្ត្រីជំនួយការផ្ទាល់របស់លោកតាប្រធានផង ។

ដើម្បីពង្រឹងកម្លាំងរបស់គាត់បន្ថែមទៀត បន្ទាប់ពីពួកខ្ញុំទៅដល់ទីក្រុងបាងកកភ្លាម លោក នាង ជិន ហន បានសម្រេចផែនការក្នុងការសុំឲ្យលោកតា សឺន សាន ចេញសេចក្តីសំរេចតែងតាំងអគ្គលេខារងពីរនាក់ទៀតគឺ៖ ១. លោក ប៊ុន សាយ ទទួលបន្ទុកខាងហិរញ្ញវត្ថុ និង ២. លោក ហ្គាហ្វា (Gaffar) ទទួលបន្ទុកទំនាក់ទំនងក្រៅប្រទេស (External Relations) ។ បន្ថែមលើនេះ លោក នាង ជិនហន មានភាពជិតស្និទ្ធជាមួយឧត្តមសេនីយ ដៀន ដែល ដែលជាមេទ័ពរបស់

រណោសិរ្ស និង ជាមួយលោក ហ៊ីង គន្ធុន ដែលជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និង ជាតំណាងកូម៉ិច ប្រចាំកងទ័ព ។ ឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ធុន ភាគច្រើនស្នាក់នៅក្នុងទីបញ្ជាការកងទ័ព រ.ជ.រ.ប.ខ. នៅជុំវិញអំពិលលើទឹកដីខ្មែរជាប់នឹងព្រំប្រទល់ថៃ ។ អ្នកដឹកនាំទាំងពីរនាក់នេះ ស្រឡាញ់រាប់អានគ្នាបានល្អណាស់គឺម្នាក់ទទួលបន្ទុកចាត់ការខាងផ្នែកយោធា និង ម្នាក់ទៀត ខាងការងារស៊ីវិល ។

លោក នាង ជិនហន និង លោក ហ៊ីង គន្ធុន នាំគ្នាបង្កើតជាក្រុមអ្នកជក់ខៀ ព្រោះពួកគាត់ចូលចិត្តជក់ខៀ ដោយអុចបង្ហុយថ្នាំជក់មកពីប្រទេសខាងលិច ។ លោក ហ៊ីង គន្ធុន ទទួលទានអាហារតែពីរពេលទេក្នុងមួយថ្ងៃ ដើម្បីជាទីរំលឹកដល់សម័យកំសត់កម្រក្នុងរបប ប៉ុល ពត គឺ អាហារពេលព្រឹក និង អាហារពេលល្ងាច ។ គាត់មិនទទួលទានអាហារថ្ងៃត្រង់ទេ ។ លោក ហ៊ីង គន្ធុន មិនចូលចិត្តទទួលទានបបរសទេ ព្រោះគាត់យល់ឃើញថាបបរសជាតំណាងរបប ប៉ុល ពត ។ តាមពិតទៅ លោក នាង ជិនហន ជាមនុស្សដែលគួរតែក្លាយជាអគ្គលេខាដ៏ល្អសម្រាប់រ.ជ.រ.ប.ខ.នេះណាស់ ។ ក៏ប៉ុន្តែ គាត់បំពេញតួនាទីនេះបានជោគជ័យ ឬ បរាជ័យ អាស្រ័យលើទំនាក់ទំនងរបស់គាត់ជាមួយអាជ្ញាធរថៃផង អាស្រ័យលើទំនុកចិត្តដែលគាត់ទទួលពីលោកតាប្រធានផង។ ក្នុងពេលកន្លងមក លោកអគ្គលេខាបានទទួលការស្រឡាញ់រាប់អានពីលោកតា សឺន សាន តាមរយៈទំនាក់ទំនងល្អ និង ជិតស្និទ្ធរបស់គាត់ជាមួយអ្នកស្រី សួន កាសេត ដែលជាជំនួយការដ៏ស្មោះត្រង់របស់លោកតាប្រធាន ។ អ្នកស្រី សួន កាសេត ត្រូវបានលោកតាចាត់ទុកជាភ្នែកជាត្រចៀកផ្ទាល់របស់គាត់គឺ បើអ្នកស្រីថាមនុស្សនេះល្អ លោកតាក៏ថាល្អ បើអ្នកស្រីថាអាក្រក់ លោកតាក៏ថាអាក្រក់ ។ លោក នាង ជិនហន លោកឧត្តមសេនីយ ដៀន ដែល លោក ហ៊ីង គន្ធុន លោក ហ្គាហ្វា និង លោក ប៊ុន សាយ

បានបង្កើតជាក្រុមមួយ ដែលហាក់ដូចជាអ្នកកាន់អំណាចជាក់ស្តែងនៅក្នុងជួរ រ.ជ.រ.ប.ខ. (នេះប្រសិនបើមានអំណាចមែន) នៅពេលដែលលោកតា សឺន សាន សម្រេចបាននូវការទទួលស្គាល់នៅលើឆាកអន្តរជាតិ និង មានប្រជាប្រិយភាពក្នុងចំណោមអ្នកគាំទ្រ រ.ជ.រ.ប.ខ.ទាំងឡាយ ។

## អ្វីដែលហៅថា "ទៅគោរពទង់ជាតិ"

នៅទីក្រុងបាងកក អ្នកធ្វើការក្នុងការិយាល័យរ.ជ.រ.ប.ខ. តែងនាំគ្នាមកទទួលទានអាហារពេលព្រឹក ជុំគ្នានៅជុំវិញតុបួនជ្រុងទ្រវែងមួយយ៉ាងទៀតទាត់ ។ នៅទីនោះ គេផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន ដែលគេម្នាក់ៗទទួលបានតាមរយៈការអានសារព័ត៌មាន ស្តាប់វិទ្យុអន្តរជាតិ ឬ តាមទំនាក់ទំនងខាងក្រៅដែលគេម្នាក់ៗទទួលបានរៀងៗខ្លួន ។ ពេលទទួលទានអាហារពេលព្រឹកនោះ ក៏ជាឱកាសឲ្យគេនិយាយពាក្យកំប្លុកកំប្លែងរវាងគ្នា និង គ្នាដែរ ។ ចំពោះមន្ត្រីសំខាន់ៗនៃ រ.ជ.រ.ប.ខ. ពេលទទួលទានអាហារព្រឹករួមគ្នារាល់ៗពេលនេះ ក៏ជាឱកាសឲ្យពួកគេធ្វើការវាយតម្លៃ លើកសរសើរ ឬ ធ្វើការរិះគន់ទៅលើសហការីមួយចំនួនដែរ ជាពិសេស គេតែងធ្វើការរិះគន់ចំពោះអ្នកអវត្តមាននៅពេលនោះ ។ បើនិយាយឲ្យស្រួលស្តាប់ គេនិយាយដើមគ្នា ។ បន្ទាប់ពីទទួលទានអាហារពេលព្រឹករួចហើយ គេនាំគ្នាអានសារព័ត៌មាន ជាពិសេស សារព័ត៌មានបាងកកប៉ុស្ត (Bangkok Post) ឬ ដឺណេស្ហិន (The Nation) ។ លោក នាង ជិនហន ញាប់ដៃញាប់ជើង កាត់ និង ថតចម្លងទំព័រកាសែតទាំងនោះ ទុកជាឯកសារប្រចាំថ្ងៃ(Press cutting)។

នៅវេលាម៉ោង ៨ ព្រឹកគត់ គេម្នាក់ៗចូលម្តងម្នាក់ក្នុងបន្ទប់មួយដើម្បីប្រារព្ធពិធីមួយ ដែលគេនិយាយបែបកំប្លែងលេងថា "ទៅគោរពទង់ជាតិ" ។ តាមពិត នៅពេលម៉ោង ៨ រាល់ៗព្រឹក លោកតាប្រធាន សឺន សាន តែងចូលមកដល់បន្ទប់នោះ

ដែលជាធម្មតា ជាបន្ទប់ទទួលទានអាហារផង ជាកន្លែងធ្វើការរបស់លោកតាផង ។ លោកតា អង្គុយនៅនឹងមួយកន្លែង ពិសាអាហារពេលព្រឹករបស់គាត់ ។ ម្នាក់ម្តងៗ មន្ត្រីសំខាន់ៗរបស់រណសិរ្សចូលទៅសំដែងការគួរសម ចំពោះលោកតាប្រធាន និង ធ្វើរបាយការណ៍ជូនគាត់ ចំពោះសភាពការណ៍ទាំងឡាយដែលគេបានដឹង ។ តាម ធម្មតា ប្រសិនបើលោកតាប្រធានមិនទទួលភ្ញៀវទេ លោកតាប្រធានអង្គុយរាប់ ម៉ោងនៅក្នុងបន្ទប់នោះ អានឯកសារផង ឬ ធ្វើការប្រជុំការងារជាមួយក្រុមបុគ្គលិក សំខាន់ៗផង មុននឹងដកថយទៅបន្ទប់ឯកជនរបស់គាត់វិញ ។

នៅពេលបាយថ្ងៃត្រង់លោកតាប្រធានមានវត្តមានម្តងទៀត នៅក្នុងបន្ទប់ អាហារនេះជាថ្មី ដើម្បីពិសាអាហាររួមជាមួយមន្ត្រីសំខាន់ៗដែលមានរូបខ្ញុំផង ។ លោកតាប្រធានមិនចាប់ផ្តើមទទួលទានអាហារទេ ប្រសិនបើមិនទាន់ជុំគ្នា ។ លោក តាប្រកាន់ឥរិយាបថបែបនេះ នៅពេលបាយល្ងាចដែរ ដែលកំណត់យ៉ាងទៀងទាត់ នៅម៉ោង ៧ ល្ងាច ។ ពេលបាយម្តងៗ ជាឱកាសមួយទៀត ឲ្យលោកតាប្រធាន និង សហការីរបស់គាត់ផ្លាស់ប្តូរមតិ ឬ ទស្សនៈគ្នាលើបញ្ហាមួយចំនួន រាប់តាំងពី ស្ថានការណ៍អន្តរជាតិ រហូតដល់បញ្ហាដែលកើតមាននៅក្នុងជំរុំជនភៀសខ្លួន ។ ពេលទទួលទានអាហាររួចហើយ មន្ត្រីមួយចំនួននាំគ្នាដកខ្លួនថយទៅបន្ទប់របស់ គេរៀងៗខ្លួន ។ អ្នកខ្លះ "ដេកថ្ងៃ" ជាប្រការមួយដែលលោកតាមិនចូលចិត្តទាល់តែ សោះ ។ អ្នកខ្លះ ដែលជាមនុស្សជិតស្និទ្ធរបស់លោកតា នៅបន្តអង្គុយនិយាយលេង ជាមួយលោកតាតទៅទៀតគឺ នៅពេលនោះហើយ ដែលមនុស្សជិតស្និទ្ធរបស់លោក តាផ្តល់មតិ ឬ ធ្វើការវាយតម្លៃលើលទ្ធផលការងាររបស់សហសេវិកឯទៀត ឬ បើ និយាយឲ្យស្រួលស្តាប់គឺ ជាពេលដែលមនុស្សជំនិតរបស់លោកតាប្រធាន និយាយ ដើមសហសេវិកឯទៀតឲ្យលោកតាស្អប់ ឬ ឲ្យលោកតាស្រឡាញ់ ។ លោកប្រធាន មិនចូលចិត្តសមាជិកណា ដែលដើរលេងយប់ ឬ ចូលបា ច្រៀងរាំ ឬ ផឹកស្រាជា

ដើម ។ ជាវិន័យទូទៅ ពួកយើងមិនទទួលទានគ្រឿងស្រវឹងនៅពេលបាយទេ ក៏ប៉ុន្តែក៏នៅមានសហសេវិកខ្លះ ទ្រាំពុំបានលបក្រេបស្រាវិស្គីឬស្រាបៀរដោយលួចលាក់ ។ មែនទែនទៅ លោកតាប្រធានមិនចង់ឲ្យការរស់នៅរបស់ពួកយើងនៅបាងកក មានលក្ខណៈខុសគ្នាខ្លាំងពេកពីជីវភាពរបស់យុទ្ធជន ដែលកំពុងធ្វើការតស៊ូនៅជួរមុខ ។

## ចលនាតស៊ូខ្មែរ ក្រោមការគ្រប់គ្រងរបស់យោធាថៃ

ក្រុមយោធាថៃបានរៀបចំរចនាសម្ព័ន្ធរបស់គេ ក្នុងទំនាក់ទំនងជាមួយពួកយើង និង ខ្មែរពីរក្រុមទៀតគឺៈ ក្រុម ហ៊្សុន ស៊ិន ប៉ិច និង ខ្មែរក្រហម ។ នៅកំរិតទីស្នាក់ការរ.ជ.រ.ប.ខ.ប្រចាំទីក្រុងបាងកក គេមានអង្គភាព TF 315 ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់លោកឧត្តមសេនីយ ឆាវលិត ដែលនៅពេលនោះ ត្រូវបានតម្លើងឋានៈជាឧបការី-អគ្គសេនាធិការនៃកងទ័ពជើងគោកនៅខែតុលា ១៩៨២ ថ្នាក់ឧត្តមសេនីយផ្កាយបី ។ ក្រោយមកនៅឆ្នាំ ១៩៩៦ លោកឧត្តមសេនីយ ឆាវលិត ក៏ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ។ លោកវរសេនីយ សុមេធ ទៀនផេង ដែលមានឈ្មោះសម្ងាត់ថា "លោក ម៉ុល" ជាមន្ត្រីទំនាក់ទំនងរវាងកងទ័ពថៃជាមួយ រ.ជ.រ.ប.ខ. រាយការណ៍ផ្ទាល់ទៅលោកឧត្តមសេនីយ ឆាវលិត ។ លោក ម៉ុល ជាអ្នកអនុញ្ញាតឲ្យយើងអាចធ្វើដំណើរពីបាងកកទៅទល់ដែន ឬ ពីទល់ដែនមកបាងកក ។ លោក ម៉ុល ក៏ជាអ្នកនាំប្រាក់ជំនួយប្រចាំខែមកបើកឲ្យពួកយើងដែរ ។ រាល់បញ្ហាទាំងឡាយនៅក្នុងទីស្នាក់ការរបស់យើង ត្រូវដោះស្រាយតាមរយៈការិយាល័យរបស់លោក ម៉ុល ។ លោក ម៉ុល ធ្វើជាមេធំលើក្រុម "ហ្មួណា" ដែលនៅប្រចាំការក្នុងទីស្នាក់ការរបស់យើង ។ ហ្មួណាទាំងនោះ មានរួមទាំងអ្នកបើកបរ និង អ្នកយាមកាម ឬ តាមដានពួកយើងផង ។

នៅទល់ដែន ក៏មានក្រុមការងារពីរទៀតគឺ អង្គភាព ៨០ (TF80) និង អង្គភាព ៨៣៨ (TF838) ។ អង្គភាព TF80 មានភារកិច្ចគ្រប់គ្រងលើជនភៀសខ្លួនខ្មែរទាំងអស់ ចំណែកឯអង្គភាព TF838 មានភារកិច្ចសម្របសម្រួល និង គាំទ្រគ្រប់សកម្មភាពនៃយុទ្ធជនអ្នកតស៊ូទាំងអស់ រួមទាំងភារកិច្ចត្រួតត្រាលើកម្លាំងខ្មែរប្រឆាំងវៀតណាមឯទៀតផង ។ ក្រុមការងារទាំងពីរនេះមានទីតាំងនៅទីប្រជុំជនស្រុកអារញ្ញប្រថេត ដែលនៅសម័យនោះស្ថិតនៅក្នុងខេត្តប្រាជិនបុរី (បស្ទឹមបុរី) ។ ក្រុមការងារ TF80 ជារចនាសម្ព័ន្ធបើកចំហរ មានទំនាក់ទំនងជាមួយសាធារណជនរាប់ទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិផង (NGO+UN) ។ អង្គភាព TF80 នេះ ស្ថិតនៅក្រោមអំណាចរបស់ឧត្តមបញ្ជាការនៃកងទ័ពថៃ (Thai Armed Forces Supreme Command) ។ ចំណែកឯអង្គភាព TF838 ជារចនាសម្ព័ន្ធយោធាសម្ងាត់គឺ ជាបញ្ជាការដ្ឋាននៅទល់ដែន ជាអ្នកគ្រប់គ្រងលើបណ្ដាញយោធាថៃដែលត្រូវចាត់ទៅប្រចាំការនៅតាមមូលដ្ឋានរបស់អ្នកតស៊ូខ្មែរ ។

តាមបទបញ្ជារបស់ក្រុមយោធាថៃ នៅពេលណាដែលពួកយើងត្រូវការធ្វើដំណើរទៅទល់ដែន យើងត្រូវដាក់ពាក្យសុំទៅលោក ម៉ុល តាមរយៈហួណាអ្នកបើកបរ ដែលនៅប្រចាំការជាមួយពួកយើង ។ បើលោក ម៉ុល អនុញ្ញាត គាត់នឹងផ្ញើសារទៅអង្គភាពឯទល់ដែន ។ បន្ទាប់មក ហួណាអ្នកបើកបររថយន្តនឹងបើកបររថយន្តនាំយើងទៅអារញ្ញប្រថេត ។ នៅទីនោះ អង្គភាពTF80 នឹងចេញសំបុត្រអនុញ្ញាតឲ្យយើងចូលទៅក្នុងជំរុំជនភៀសខ្លួន ។ ចំណែកឯអង្គភាពTF 838 ក៏នឹងចេញសំបុត្រអនុញ្ញាតឲ្យយើងចូលទៅក្នុងមូលដ្ឋានរបស់ពួកយើងនៅឯទល់ដែន ឬ ជូនកាលអង្គភាពនេះ ចាត់ឲ្យភ្នាក់ងារនេះធ្វើដំណើរទៅជាមួយយើង ។ ក៏ប៉ុន្តែ ប្រសិនបើយើងចង់នាំជនបរទេសជាអ្នកកាសែត ឬ ជាអង្គការក្រៅរដ្ឋាភិបាល (NGO)ទៅធ្វើទស្សនកិច្ចនៅក្នុងជំរុំជនភៀសខ្លួន ពួកយើងត្រូវទៅសុំលិខិតអនុញ្ញាតពីឧត្តមបញ្ជា

ការនែកងទ័ពថៃ ទើបអង្គភាព TF 80 អនុញ្ញាតឲ្យចូលក្នុងជំរុំជនភៀសខ្លួនបាន ។

## រដ្ឋាភិបាលចម្រុះត្រីភាគីកើត ក្រោមគំនាបយោធាថៃ

នៅសម័យដែលខ្ញុំបានមកដល់ទីក្រុងបាងកកនោះ បញ្ហាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីជាបញ្ហាមួយ ដែលភាគីពាក់ព័ន្ធកំពុងដោះស្រាយ ។ ថ្នាក់ដឹកនាំ រ.ជ.ប.រ.ខ. កំពុងស្ថិតនៅក្រោមការគាបសង្កត់ពីអាជ្ញាធរថៃ ដើម្បីឲ្យមានការព្រមព្រៀងយ៉ាងឆាប់រហ័សក្នុងការបង្កើតរដ្ឋាភិបាលចម្រុះនោះ ។ នៅក្នុងអំឡុង ខែឧសភា ១៩៨២ ទាំងមូលនោះ នាយទាហានថៃជាច្រើននាក់បានមកជួបសន្ទនាជាមួយមេដឹកនាំយើង ។ ក្នុងចំណោមនោះ ជាពិសេស មានលោកឧត្តមសេនីយ ឆាវលិត ។ រ.ជ.រ.ប.ខ.មានការខ្វល់ខ្វាយយ៉ាងខ្លាំង ដោយសារជំហររបស់រណសិរ្សពុំសូវបានទទួលការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំយោធាថៃទាំងឡាយឡើយ ។ មែនទែនទៅ នាយទាហានថៃភាគច្រើនសុទ្ធតែនៅពីក្រោយខ្មែរក្រហម ដែលប្រកាន់គោលជំហររឹងត្អឹងបំផុត ។ ពួកមេទ័ពថៃទាំងនោះសម្គាល់ថាលោកតា សឺន សាន មិនប្រកាន់គោលជំហរឲ្យបានទន់ភ្លន់សោះ ក្នុងការចរចាបង្កើតរដ្ឋាភិបាលចម្រុះនោះ ។ ពួកនាយទាហានថៃទាំងនោះយល់ថា ការប្រកាន់ឥរិយាបថរបស់លោកតាជាឧបសគ្គធ្វើឲ្យរាំងស្ទះដល់ការចរចា ។ ចំពោះលោកតា សឺន សាន លោកតាបានខឹតខំសាកល្បងបង្ហាញហេតុផលថា លោកតាមានចេតនាចូលរួមក្នុងរដ្ឋាភិបាលចម្រុះ មិនមែនមិនចង់ចូលដូចការប៉ាន់ស្មានរបស់អាជ្ញាធរយោធាថៃនោះទេ ។

នៅថ្ងៃទី ៧ ឧសភា ១៩៨២ រ.ជ.រ.ប.ខ.បានសំរេចជាគោលការណ៍ទទួលយករួចទៅហើយនូវសំណើរបស់ក្រសួងការបរទេសថៃ ដែលក្នុងនោះរួមមានទាំងគោលការណ៍ ៤ ប្រការរបស់ខ្មែរក្រហម ដែលក្នុងពេលកន្លងមក រ.ជ.រ.ប.ខ. តែងតែប្រកែកពុំព្រមទទួល ។ គោលការណ៍ទាំង ៤ ប្រការនោះគឺៈ ១- ត្រីភាគី

និយម (Tripartism) ២- ស្មើភាព និង គ្មានប្រៀបលើគ្នា (Equality and Non-preponderance) ៣- គោលការណ៍សម្រេចដោយឯកច្ឆ័ន្ទលើបញ្ហាសំខាន់ៗ (Consensus on important matters) និង ៤- រដ្ឋាភិបាលចម្រុះត្រូវបង្កើតលើមូលដ្ឋានច្បាប់នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ (CGDK must be based on legal status of Democratic Kampuchea)[147] ។ នៅក្នុងកំណត់ជំនួយស្មារតីចុះថ្ងៃទី ៧ ឧសភា ១៩៨២ ផ្ញើជូនលោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ សិទ្ធី សាវ៉េតសីលា លោកតាប្រធាន រ.ជ.រ.ប.ខ. បានបញ្ជាក់ថា លោកតាយល់ព្រមទាំងស្រុង (in toto) លើសំណើរបស់ក្រសួង ព្រមទាំងស្នើសុំកុំឲ្យមានការកែប្រែ ឬ ធ្វើវិសោធនកម្មណាមួយឡើយលើសំណើនោះ ។ មែនទែនទៅ លោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ មានការពេញចិត្តចំពោះការយល់ព្រមទទួលយករបស់រ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ សំណើកិច្ចព្រមព្រៀងនោះ ពុំត្រូវបានគេយកមកប្រើការតទៅទៀតឡើយ ព្រោះកងទ័ពថៃមានគោលជំហរផ្សេងពីក្រសួងការបរទេស ។ ប្រការដែលគួរឲ្យកត់សម្គាល់នោះគឺ ក្រសួងការបរទេសថៃ ក៏ដូចជាប្រទេសសមាជិកអាស៊ានឯទៀត ទទួលយកនូវសំណើមួយចំនួនរបស់រ.ជ.រ.ប.ខ. ក្នុងការរៀបចំរដ្ឋាភិបាលចម្រុះខ្មែរត្រីភាគី ក៏ប៉ុន្តែកងទ័ពថៃមានការយល់ឃើញផ្សេង ព្រោះពួកគេឈរនៅពីក្រោយខ្មែរក្រហម ដោយដើរតាមបន្ទាត់នយោបាយរបស់ចិន ។ ជាពិសេសក្រុមឧត្តមសេនីយ ប្រាកដជាអនុវត្តតាមកិច្ចព្រមព្រាង តេង ស៊ាវពីង-លី ខ្វាន់ យូ ដែលផ្តល់ការអនុគ្រោះដល់ខ្មែរក្រហមរួចទៅហើយ ។

នៅថ្ងៃទី ២៥ ឧសភា ១៩៨២ លោកឧត្តមសេនីយ ឆាវលិត បានមកជួបលោកតា សឺន សាន នៅម៉ោង ១២:៣០ នាទីទាំងកណ្តាលអធ្រាតដោយឥតព្រាង

[147] Memorandum by the Democratic Kampuchea Party Concerning the Declaration of the Formation of the Coalition Government of Democratic Kampuchea, op. cit.

ទុក ដែលធ្វើឲ្យយើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ឧត្តមសេនីយថៃរូបនេះនាំមកជាមួយ នូវសេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ដើម្បីសុំឲ្យលោកតា សឺន សាន ទទួលយក ។ លោកមេទ័ព ឆាវលិត ដាក់កំហិតឲ្យ រ.ជ.រ.រ.ប.ខ.ធ្វើតាម បើពុំនោះទេនឹងត្រូវទទួលទណ្ឌកម្ម ។ ថ្នាក់ដឹកនាំរ.ជ.រ.ប.ខ. បានពិនិត្យឃើញថាពង្រាងនេះ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីពង្រាងដើមនៃក្រសួងការបរទេសថៃដែលរ.ជ.រ.ប.ខ. បានទទួលយល់ព្រមរួចហើយ ។ នៅថ្ងៃព្រឹកទី ២៨ ឧសភា ១៩៨២ លោកតា សឺន សាន បានផ្ញើជូនផ្ទាល់ដៃទៅលោកឧត្តមសេនីយ ឆាវលិត នូវកំណត់សម្គាល់មួយជំរាបមេទ័ពថៃរូបនេះថាពង្រាងថ្មីនេះ មានលក្ខណៈខុសគ្នាខ្លាំងណាស់ពីសេចក្តីព្រាងសំណើដំបូងរបស់ប្រទេសថៃ (គឺសំណើនៃក្រសួងការបរទេសថៃ) ដែលយើងបានទទួលយករួចហើយ ។ លើសពីនេះទៅទៀតពង្រាងថ្មីរបស់លោក ឆាវលិត នេះ ហាក់ដូចជាមានការលំអៀងទៅតែខាងខ្មែរក្រហម ដោយមិនបានគិតគូរដល់រ.ជ.រ.ប.ខ. និង ហ្វ៊ុន ស៊ិន ប៉ិច ឡើយ និង ពុំបានគោរពដល់គោលការណ៍នយោបាយជាមូលដ្ឋាននៃរដ្ឋាភិបាលចម្រុះសោះ ។ ដើម្បីចង់បង្ហាញថា រ.ជ.រ.ប.ខ. នៅតែមានបំណងចូលរួមក្នុងរដ្ឋាភិបាលត្រីភាគីនោះ លោកតាប្រធានសរសេរថានឹងជំរាបលោក ឆាវលិត ពីដំណោះស្រាយមួយនាពេលខាងមុខដ៏ខ្លី[148] ។

ដំណោះស្រាយដែលលោកតា សឺន សាន មានបំណងលើកឡើងនោះគឺជារូបមន្តដ៏សាមញ្ញមួយ ដែលក្នុងនោះ សម្តេច នរោត្តម សីហនុ ទ្រង់នឹងត្រូវថ្វាយឋានៈជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ចំណែកឯលោកតានឹងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ (លោកតាមិនចង់មានឈ្មោះជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យទេ តែជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិ

[148] Observation of Mr. Son Sann on the Draft Proposal entitled “Declaration of the Formation of the Coalition Government of Democratic Kampuchea”as provided by Major General Chaovalit, May 27, 1982.

បាលចម្រុះ ដែលហាក់ដូចជាស្ថាប័នថ្មីមួយទៀតផ្សេងពីកម្ពុជាប្រជាធិបតេយ្យ ដែលមានឈ្មោះល្បីពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍) ក្នុងនោះលោក ខៀវ សំផន នឹងកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ។ ដើម្បីបំពេញតួនាទីរបស់ខ្លួន រដ្ឋាភិបាលចម្រុះនេះនឹងបង្កើតគណៈកម្មាធិការពីរគឺ មួយទទួលបន្ទុកកិច្ចការយោធា និង មួយទៀតខាងការទូត ។ គណៈកម្មាធិការនីមួយៗមានសមាជិកពីររូបមកពីភាគីនីមួយៗនៃភាគីទាំងបី ។ ក្នុងន័យនេះ រ.ជ.រ.ប.ខ.យល់ព្រមទទួលយកគោលការណ៍ត្រីភាគីនិយម ស្មើភាពគ្នា មិនមានប្រៀបលើគ្នា និង គោលការណ៍កុងសង់ស៊ីសលើបញ្ហាសំខាន់ៗ ។ ក៏ប៉ុន្តែពួកខ្មែរក្រហមនៅតែពុំព្រមទទួលយករូបមន្តនេះ ។ មិនតែប៉ុណ្ណោះពួកខ្មែរក្រហម បានធ្វើការគាបសង្កត់ដោយកម្លាំងយោធាមកលើ រ.ជ.រ.ប.ខ. ថែមទៀត ដើម្បីបង្ខំឲ្យរ.ជ.រ.ប.ខ.ទទួលយកតាមរូបមន្តរបស់ពួកគេ ។ នៅក្នុងអនុស្សរណៈរបស់លោកតាប្រធាន ផ្ញើជូនលោកឧត្តមសេនីយ ឆាវលិត ចុះថ្ងៃទី ១ មិថុនា ១៩៨២[149] លោកតាបានរាយការណ៍ ជូនលោកមេទ័ពថៃថាមានការប៉ះទង្គិចគ្នាចំនួនពីរដងរវាងកងទ័ពខ្មែរក្រហម និង កងទ័ព រ.ជ.រ.ប.ខ.នៅថ្ងៃទី ២១ និង ២៩ ឧសភា ១៩៨២ នៅក្នុងតំបន់ដែលជាតំបន់រំដោះរបស់ រ.ជ.រ.ប.ខ. ។ ការប៉ះទង្គិចលើកទីមួយនោះបានកើតឡើងនៅពេលក្រុមខ្មែរក្រហមចំនួន ២៥ នាក់ បានត្រូវរកឃើញ កំពុងជីករណ្តៅដើម្បីដាក់មីនក្នុងទឹកដីរបស់ រ.ជ.រ.ប.ខ. ។ ពួកខ្មែរក្រហមបានបាញ់រះមកលើកងកម្លាំង រ.ជ.រ.ប.ខ. នៅពេលដែលមេបញ្ជាការម្នាក់របស់ពួកយើង បានប្រាប់ឲ្យពួកនេះបញ្ឈប់ការជីករណ្តៅដាក់មីននោះជាបន្ទាន់ ។ លើកទីពីរមានការប៉ះទង្គិចខាងផ្លូវអាវុធរវាងក្រុមខ្មែរក្រហមចំនួន ៣០ នាក់ ដែលបានរំលោភចូលមកក្នុងទឹកដី រ.ជ.រ.ប.ខ. ជាមួយកងកម្លាំងរបស់យើង នៅតំបន់កណ្តាល ។ អនុស្សរណៈនោះ មានសេចក្តីជាអាទិ៍ថា៖ "ការ

[149] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 1, 1982.

វាយប្រហាររបស់ពួកខ្មែរក្រហមមកលើកងកម្លាំងរបស់យើង មិនមែនមានជាលើកទីមួយនោះឡើយ ។ ពួកខ្មែរក្រហមជាញឹកញាប់តែងរំលោភចូលមកទឹកដីដែលយើងកាន់កាប់ បន្ទាប់មកតែងធ្វើការវាយប្រហារដោយអាវុធ ដែលកើតមានច្រើនលើករួចទៅហើយក្នុងពេលកន្លងមក″ ។ អនុស្សរណៈនោះ បន្តទៀតថា ‶ .....ការវាយប្រហាររបស់ពួកខ្មែរក្រហមមកលើកងកម្លាំងយើងនេះ តែងតែត្រូវបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចថៃជានិច្ច ។ នៅពេលបច្ចុប្បន្ន កងទ័ពខ្មែរក្រហមកំពុងជីកដីដាក់មីន នៅចំពីមុខជំរុំរិទ្ធីសែនរបស់យើងផង ។ នៅពេលដែលយើងកំពុងតែតវ៉ាយ៉ាងឱឡារិកចំពោះឧប្បទ្ទវហេតុទាំងនេះ យើងក៏ត្រូវថ្លែងនូវការព្រួយបារម្ភរបស់យើង ចំពោះហេតុការណ៍ទាំងនេះ ដែលអាចធ្វើឲ្យមានការគាំងដំណើរដល់ការចរចាបង្កើតរដ្ឋាភិបាលចម្រុះខ្មែរនេះដែរ″ ។ ភាគីថៃពុំបានធ្វើប្រតិកម្មអ្វីឡើយចំពោះអនុស្សរណៈនេះទេ ។ ពួកថៃមិនធ្វើការឆ្លើយតបអ្វីទាំងអស់ ។ ការមិនឆ្លើយតបទាំងនេះជាវិធីមួយនៃការគាបសង្កត់ថែមទៀតដើម្បីបង្ខំឲ្យរ.ជ.រ.ប.ខ.ចូលក្នុងសម្ព័ន្ធភាពជាមួយខ្មែរក្រហម ។

នៅពេលដែលថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.នៅតែសំដែងការមិនពេញចិត្ត ចំពោះការគាបសង្កត់ទាំងនេះ រ.ជ.រ.ប.ខ.ក៏បានសម្រេចជាចុងក្រោយថានឹងទទួលយកនូវរូបមន្តណាមួយ ដែលស្នើចេញមកពីរដ្ឋាភិបាលរបស់ក្រុមប្រទេសអាស៊ាន (ASEAN) ។ ដោយទទួចភ្ជាប់ជាមួយនូវការសុំជំនួយ លោកតា សឺន សាន ធ្លាប់ថ្លែងជាសាធារណៈថា៖ ‶ សុំផ្តល់ដំបងឲ្យខ្ញុំមួយមុននឹងឲ្យខ្ញុំចូលក្នុងទ្រុងខ្លា″ លោកតា សឺន សាន ប្រៀបប្រដូចការចូលធ្វើសម្ព័ន្ធភាពជាមួយខ្មែរក្រហម ដូចគ្នានឹងការចូលក្នុងទ្រុងខ្លាយ៉ាងដូច្នោះដែរ ។ លោកតាសុំដំបងគឺសុំជំនួយឲ្យភាគីរ.ជ.រ.ប.ខ.។ លោកតាប្រធានរ.ជ.រ.ប.ខ. បានភ្ជាប់ការចូលរួមរបស់រ.ជ.រ.ប.ខ.ទៅក្នុងរដ្ឋាភិបាលចម្រុះជាមួយនឹងការផ្តល់ជំនួយដ៏រឹងមាំឲ្យដល់ចលនាតស៊ូនេះ ។ នៅក្នុងអនុស្សា

រណៈចុះថ្ងៃទី ២ មិថុនា ១៩៨២[150] ដែលមានវាយត្រាដាក់ថាសម្ងាត់ផងនោះ ហើយដែលផ្ញើជូនផ្ទាល់ទៅលោកឧត្តមសេនីយ ឆាវលិត លោកតាតវ៉ាថារ.ជ.រ.ប.ខ. មានការខកចិត្តជាខ្លាំង ព្រោះទោះបីជារ.ជ.រ.ប.ខ.ប្រកាន់យកគោលជំហរទន់ភ្លន់ និង បានធ្វើសម្បទានយ៉ាងច្រើនយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលចម្រុះនៅតែបង្កើតមិនទាន់បាន ។ ម្យ៉ាងទៀតពួកខ្មែរក្រហមនៅតែប្រកាន់ជំហររឹងត្អឹង ហើយជាមួយគ្នានោះ ហាក់ដូចជាគ្មាននរណាម្នាក់អាចជួយបន្ទន់គោលជំហររបស់ពួកនេះសោះ រីឯជំនួយក៏មិនទាន់បានផ្តល់ដល់ពួកយើង ដែលយើងកំពុងត្រូវការជាបន្ទាន់លើសមរភូមិមុខនោះ ។ លោកតាប្រធានបានស្នើដូចតទៅ៖ "១. យើងខ្ញុំនឹងទទួលយកមកពិនិត្យនូវរាល់សំណើត្រឹមត្រូវ និង យុត្តិធម៌ណាដែលចេញពីរដ្ឋាភិបាលនៃប្រទេសអាស៊ាន ហើយដែលមិនឃ្លាតឆ្ងាយពេកពីស្មារតីនៃសំណើរបស់ប្រទេសថៃនៅដើមខែ ឧសភា- ២. ដើម្បីរកដំណោះស្រាយបញ្ហាកម្ពុជា ដោយអនុលោមតាមសេចក្តីថ្លែងការណ៍នៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា (ICK) និង តាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ការទទួលយល់ព្រមរបស់ខ្ញុំចំពោះសំណើរបស់រដ្ឋាភិបាលនៃប្រទេសអាស៊ាននឹងត្រូវធ្វើឡើងស្របពេលជាមួយគ្នានឹងសេចក្តីប្រកាសរបស់រដ្ឋាភិបាលនៃប្រទេសអាស៊ាននោះ ស្តីពីការផ្តល់ជំនួយដល់ រ.ជ.រ.ប.ខ. ដូចដែលបានសន្យា ហើយនៅថ្ងៃដែលខ្ញុំចុះហត្ថលេខាលើពង្រាងដែលស្នើដោយប្រទេសអាស៊ាននោះ ថ្ងៃនោះក៏ជាថ្ងៃដែលជំនួយជាកញ្ចប់ត្រូវបានផ្តល់ដល់ រ.ជ.រ.ប.ខ. ដែរ" ។

នៅថ្ងៃទី ២ មិថុនា នោះដែរ លោកតាបានចុះហត្ថលេខាសុខចិត្តទទួលយកនូវសេចក្តីថ្លែងការណ៍ បង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលឧត្តមសេនីយ ឆាវលិត បានប្រគល់ដល់លោកតាជាថ្មីទៀត ។ ឯកសារចុះហត្ថលេខា

[150] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 2, 1982.

ទទួលយកនោះ បានត្រូវបញ្ជូនជាពិសេសទៅឧត្តមសេនីយ ឆាវលិត ដោយផ្ទាល់ ។ រូបមន្តដែលលោកតា សឺន សាន ទទួលនោះ មានគ្រោងតំណែងជាប្រធានកម្ពុជាប្រជាធិបតេយ្យថ្វាយសម្តេច សីហនុ និង អនុប្រធានជូនលោក ខៀវ សំផន ចំណែកឯលោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយគ្នានោះ ក៏មានគ្រោងបង្កើតគណៈកម្មាធិការសម្របសម្រួលចំនួន ៥ ទៀតគឺ៖ ការបរទេស ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ការពារប្រទេស វប្បធម៌ និង សិក្សាធិការ ព្រមទាំងការងារសុខាភិបាល និង សង្គមកិច្ច ។ នៅថ្ងៃទី ៣ មិថុនា ១៩៨២ លោកតា សឺន សាន នៅបន្តព្យាយាមធ្វើវិសោធនកម្មលើឯកសារដែលលោកតាយល់ព្រមរួចហើយ កាលពីមួយថ្ងៃមុននោះ ដោយស្នើឲ្យលុបពាក្យប្រធាន និង អនុប្រធានសម្រាប់សម្តេច សីហនុ និង លោក ខៀវ សំផន មកជា "ប្រមុខរដ្ឋវិញ" ។ លោកតាក៏បានស្នើទៅលោកឧត្តមសេនីយ ឆាវលិត ឲ្យកំណត់ចំនួនគណៈកម្មាធិការសម្របសម្រួលនោះពី ៥ មកតែ ២ វិញប៉ុណ្ណោះគឺ៖ ការបរទេស និង កាពារជាតិ[151] ។ បន្ថែមលើនេះទៀត នៅពេលចុះហត្ថលេខាយល់ព្រមទទួលរូបមន្ត លោកតានៅតែប្រយ័ត្នប្រយែងមិនទទួលស្គាល់ទាំងសម្តេច សីហនុ ទាំងលោក ខៀវ សំផន ថាជាអ្នកដឹកនាំភាគីដែលឥស្សរជនទាំងពីរជាតំណាងនោះ។ លោកតាទទួលស្គាល់មេដឹកនាំទាំងពីររូប នោះត្រឹមតែជាតួបុគ្គលប៉ុណ្ណោះ ។ នៅលើឯកសារដែលរៀបចំឡើងដោយឧត្តមសេនីយ ឆាវលិត ហើយដែលបញ្ជាក់ថា លោកតានឹងត្រៀមជួបដៃគូពីរអង្គទៀតគឺ សម្តេច សីហនុ និង លោក ខៀវ សំផន នោះ លោកតាបានឆូតលុបពាក្យ "មេដឹកនាំ ហ៊្វុន ស៊ិន ប៉ិច" និង "មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ចេញ រួចហើយសរសេរផ្ទាល់ដៃជំនួសវិញថា "សម្តេច សីហនុ" និង "ឯកឧត្តម ខៀវ សំផន" ដោយបំភ្លេចចោលនូវតួនាទីផ្លូវការ

[151] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, June 3, 1982.

របស់អ្នកដឹកនាំទាំងពីរ[152]។ ការធ្វើបែបនេះប្រហែលជាលោកតាយល់ថាជាការអាចជៀសវាងនូវអ្វីដែលហៅថា "ត្រីភាគីនិយម" ។ ក៏ប៉ុន្តែ តាមពិតទៅ លោកតាត្រូវបានទទួលបរាជ័យទាំងអស់ ។

កលល្បិចរបស់លោកតា ដែលពួកថៃមើលឃើញថាកំប៉ិកកំប៉ុកនោះមិនបានធ្វើឲ្យមេទ័ពថៃព្រួយបារម្ភអ្វីឡើយ ព្រោះថានៅទីបំផុត នៅថ្ងៃទី ១២ មិថុនា ១៩៨២ លោកតាសុខចិត្តទទួលយកនូវពង្រាងថ្មី ស្នើជាថ្មីដោយឧត្តមសេនីយឆាវលិត ដែលតាមរយៈនោះ ពួកខ្មែរក្រហម បានសម្រេចជោគជ័យទាំងស្រុង ដូចដែលគេប៉ងប្រាថ្នាជាយូរមកហើយ ។ សម្តេច សីហនុ ត្រូវបានជាប្រធានកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន ជាអនុប្រធានកម្ពុជាប្រជាធិបតេយ្យ រីឯលោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ រូបមន្តថ្មីនេះ មានបង្កើតគណៈកម្មាធិការសម្របសម្រួល ៤ (ដូចក្រសួង) គឺ៖ ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ការពារប្រទេស វប្បធម៌ និង អប់រំ សុខាភិបាល និង សង្គមកិច្ច បន្ថែមលើការបរទេសដែលត្រូវរៀបចំដោយលក្ខណៈពិសេស[153] ។ មែនទែនទៅ កិច្ចការបរទេសត្រូវបានរៀបចំពិសេស ឲ្យស្ថិតនៅក្រោមការកាន់កាប់ផ្ទាល់នៃពួកខ្មែរក្រហម ព្រោះគេបានរៀបចំឲ្យក្រសួងការបរទេសស្ថិតនៅក្រោមអំណាចរបស់អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ។ ដូច្នេះ ពួកខ្មែរក្រហមបានទទួលជ័យជំនះ លើសហួសពីគោលការណ៍ដែលថាស្មើភាព និង ភាពមិនមានប្រៀបលើគ្នាទៅទៀតផង ។

ដោយសារមានការគាំទ្រដ៏រឹងមាំពីប្រទេសចិន និង ពីឧត្តមសេនីយថៃដ៏មានអំណាច ពួកខ្មែរក្រហមបានសំរេចជោគជ័យក្នុងការនាំយកសម្តេច សីហនុ ឲ្យ

---

[152] Son Sann to General Chaovalit, (A kind of Memo) June 2, 1982.

[153] Samdech Norodom Sihanouk, H.E. Mr. Son Sann, H.E. Mr. Khieu Samphan, CGDK, Declaration of the Formation of the Coalition Government of Democratic Kampuchea, Kuala Lumpur, 22nd of June 1982.

ចូលក្នុងសម្ព័ន្ធភាពជាមួយពួកគេម្តងទៀត ។ ក៏ប៉ុន្តែ ការយល់ព្រមចូលរួមរបស់លោកតា សឺន សាន ក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីនេះ បានបង្ហាញឲ្យឃើញឥទ្ធិពលដ៏មហិមារបស់ចិន ក្នុងការធ្វើឲ្យពួកខ្មែរក្រហមអាចរស់រានមានជីវិតឡើងវិញខាងផ្លូវនយោបាយ ។ នៅទីបំផុត លោកតា សឺន សាន បានចុះហត្ថលេខាលើឯកសារមួយ ដែលអាចបង្ហាញដល់ដៃគូអន្តរជាតិគឺៈ ចិន អាស៊ាន ស.រ.អា និង ប្រទេសឯទៀតថាលោកតាសុខចិត្តហើយ ព្រោះលើកនេះ លោកតាសរសេរ "ជូនភាគីណាដែលពាក់ព័ន្ធ"(To whom it may concern )[154] ដែលផ្ទុយពីកាលមុនដែលលោកតាសរសេរផ្ទាល់ទៅ "ឧត្តមសេនីយ ឆាវលិត" (To General Chaovalit) ។ លក្ខខណ្ឌដែលលោកតា សឺន សាន លើកឡើងទាំងអម្បាលម៉ាន ជាពិសេស ការទាមទារសុំ ឲ្យមានភ្ជាប់នូវសេចក្តីប្រកាសផ្តល់ជំនួយរបស់ក្រុមប្រទេសអាស៊ានដល់ភាគីរ.ជ.រ.ប.ខ. នៅពេលលោកតាចុះហត្ថលេខាលើសេចក្តីប្រកាសបង្កើតរដ្ឋាភិបាលចម្រុះនោះ ក៏ត្រូវសោបរលោបអាសាបង់គឺ គ្មានបានផលប្រយោជន៍អ្វីទាំងអស់ ។ នេះក៏ជាបរាជ័យមួយសម្រាប់ថ្នាក់ដឹកនាំរបស់ក្រុមយើងដែរ ។

## លោកតាឲ្យខ្ញុំរៀបចំប្រព័ន្ធគណនេយ្យ

នៅក្នុងរយៈពេលនៃការចរចាគ្នានោះ ដែលទំហំការងារនៅក្នុងការិយាល័យរ.ជ.រ.ប.ខ.កាន់តែរីកនិងកើនឡើងឥតឈប់ឈរនោះ លោកតា សឺន សាន បានស្នើឲ្យ ហ្គាហ្វា ចែករំលែកការងារខ្លះមកឲ្យខ្ញុំជួយធ្វើ តែ ហ្គាហ្វា បានឆ្លើយថា "មូលីមានការងារច្រើនណាស់" ដោយមិនទាំងបានសួរខ្ញុំជាមុនផង តើខ្ញុំរវល់ឬយ៉ាងណានោះឡើយ។ តាមពិតទៅ ហ្គាហ្វា ពុំមានបំណងចែករំលែកការងារឲ្យខ្ញុំធ្វើទេ ព្រោះប្រហែលគេមិនចង់ឲ្យខ្ញុំដឹងអំពីការងារធំដុំអ្វីឡើយ ។ មែនទែនទៅ ចាប់ពីពេលខ្ញុំ

154 Son Sann, To Whom It May Concern, (A kind of Memo) June 12, 1982.

មកដល់ទីក្រុងបាងកក ខ្ញុំគ្មានការងារអ្វីក្រៅពីជួយបកប្រែអត្ថបទភាសាបារាំង មកភាសាខ្មែរម្តងម្កាលប៉ុណ្ណោះ ។ ជាផ្លូវការ ខ្ញុំត្រូវបានតែងតាំងជា "ធារីបេសកកម្ម" "Chargé de mission" ទទួលបន្ទុកការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅពីថ្ងៃទី ១១ មិថុនា ១៩៨២[155] ។

ក្នុងឋានៈនេះ ខ្ញុំបានទទួលការណែនាំផ្ទាល់ពីលោកតា សឺន សាន ឲ្យរៀបចំប្រព័ន្ធគណនេយ្យ និង ត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុដើម្បីធ្វើឲ្យការបែងចែក ឬ ការផ្គត់ផ្គង់ផ្នែកភស្តុភា រួមទាំងផ្នែកហិរញ្ញវត្ថុ ដល់គ្រប់អង្គភាពនានានៃរ.ជ.រ.ប.ខ. ប្រព្រឹត្តិទៅដោយតម្លាភាព ។ តាមពិត អ្វីដែលខ្ញុំធ្វើនោះគ្រាន់តែជាការគិតគូរមួយផ្នែកតែប៉ុណ្ណោះ មិនអាចយកជាការអនុវត្តន៍ជាក់ស្តែង ជាវិធានការណាមួយនោះទេ ។

នៅថ្ងៃទី ១២ មិថុនា ១៩៨២[156] ខ្ញុំបានធ្វើអនុស្សារណៈមួយជូនលោកតា សឺន សាន ដោយបង្ហាញពីទស្សនៈរបស់ខ្ញុំលើផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវមានរចនាសម្ព័ន្ធយ៉ាងដូចម្តេចខ្លះ ។ ខ្ញុំមានគំរោងបង្កើតផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុមួយ ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិគឺ លោកតា សឺន សាន និងប្រព័ន្ធគណនេយ្យមួយ ដែលមានឧបករណ៍ទ្រទ្រង់ (បញ្ជី សម្ភារៈ) និង របៀបនិតិវិធីនៃការចេញរបាយការណ៍ហិរញ្ញវត្ថុ ។ នៅក្នុងប្រព័ន្ធនោះ ខ្ញុំសាកល្បងបញ្ចូលក្បួនគណនេយ្យខាងគិតគូរតម្លៃ (Cost Accounting) ទៅក្នុងប្រព័ន្ធនៃរដ្ឋបាលសាធារណៈដែលអាចដឹងភ្លាមនូវប្រភព និង ប្រភេទនៃចំណាយ និង ចំណូល ។ លោកតា សឺន សាន បានគាំទ្រគំនិតនេះ ដោយចារផ្ទាល់ដៃថា៖ "សូមដាក់ឲ្យប្រើនូវប្រព័ន្ធនេះឲ្យបានមុនពេលជំនួយមកដល់ជៀសវាង

[155] Son Sann, Front National de Libération du Peuple Khmer, Décision no. 82/07/FNL, Territoire Khmer, 11 juin 1982.
[156] Ieng Mouly, Memo à Son Excellence le Président, Memo 82/01 IM, 12 juin 1982.

កុំឲ្យការងារកើនឡើងគរជាន់លើគ្នា...″ ។ នៅខែ កញ្ញា ១៩៨២ លោកតាប្រធានបានចុះហត្ថលេខាលើសេចក្តីសម្រេចបង្កើតថវិការ.ជ.រ.ប.ខ. និង បានតែងតាំងមន្ត្រី ៣ នាក់ ឲ្យទទួលខុសត្រូវគឺ៖ ១. លោក នាង ជិនហន ជាអណាប័កដើមខ្សែ, ២. លោក ប៊ុន សាយ ជាហិរញ្ញឹក, ៣. ខ្ញុំ (អៀង មូលី) ជាអ្នកត្រួតពិនិត្យ (Controller)។ ក៏ប៉ុន្តែប្រព័ន្ធគណនេយ្យដែលខ្ញុំបានបង្កើតនោះពុំបានត្រូវយកមកប្រើប្រាស់ឡើយ ព្រោះរ.ជ.រ.ប.ខ. ត្រូវបង្ខំចិត្តដោះស្រាយបញ្ហាស្លាប់រស់ជាបន្ទាន់ផ្សេងៗទៀត ។ តាមពិតទៅគំនិតរបស់ខ្ញុំនេះ មិនត្រូវបានសហសេវិករបស់ខ្ញុំសប្បាយចិត្ត នឹងទទួលយកនោះឡើយ ព្រោះប្រព័ន្ធនេះអាចធ្វើឲ្យប៉ះពាល់ដល់ទម្លាប់របស់គេដែលធ្លាប់មានពីមុនៗមកក៏បាន ។ ម្យ៉ាងទៀត សំណើខ្ញុំនោះអាចថាមានឧត្តមគតិល្អ ក៏ប៉ុន្តែប្រព័ន្ធនោះក៏មិនអាចអនុវត្តជាក់ស្តែងបានឡើយ ព្រោះថាតាមច្បាប់នៅប្រទេសថៃ រ.ជ.រ.ប.ខ.គ្រាន់តែជាអង្គការចាត់តាំងសម្ងាត់ ពុំមានលក្ខន្តិកៈខាងផ្លូវច្បាប់ណាមួយច្បាស់លាស់ឡើយ ។ លោក ប៊ុន សាយ និយាយប្រាប់ខ្ញុំឲ្យសាកល្បងទៅបើកគណនីផ្ទាល់ខ្លួនលមើលនោះ ខ្ញុំនឹងដឹងថាតើមានបញ្ហាអ្វីខ្លះ ព្រោះថា រហូតមកដល់ថ្ងៃនេះ ពុំទាន់មាននរណាអាចមានគណនីផ្ទាល់ខ្លួននៅក្នុងធនាគារថៃណាមួយនៅឡើយទេ ។ នៅពេលនោះ សូម្បីតែ រ.ជ.រ.ប.ខ. ក៏ត្រូវបង្ខំចិត្តប្រើប្រាស់គណនីឯកជនរបស់មិត្តភក្តិម្នាក់ ដែលជាជនជាតិថៃដើមកំណើតចិនសិនដែរ ។ តែចំពោះខ្ញុំវិញ ខ្ញុំគ្មានបញ្ហាអ្វីទេក្នុងការបើកគណនីផ្ទាល់ខ្លួននៅក្នុងធនាគារថៃនោះ ព្រោះថាមុននឹងចេញដំណើរពីប្រទេសបារាំងមកកាន់ប្រទេសថៃ ខ្ញុំបានទាក់ទងធនាគាររបស់ខ្ញុំ ជួយសម្រួលឲ្យខ្ញុំអាចបើកគណនីនៅប្រទេសថៃបាន ។ ខុសពីអ្នកឯទៀត គ្រាន់តែមកដល់ទីក្រុងបាងកកភ្លាម ខ្ញុំក៏អាចមានគណនីផ្ទាល់ខ្លួននៅធនាគារថៃយ៉ាងឆាប់រហ័ស ។ ក្រោយមក គណនីផ្ទាល់ខ្លួនរបស់ខ្ញុំនេះក៏ត្រូវយកមកប្រើប្រាស់ សម្រាប់ការងារកាកបាតក្រហម រ.ជ.រ.ប.ខ. ដែលត្រូវ

បង្កើតឡើងនៅឆ្នាំ ១៩៨៤ ។ តាំងពីពេលនោះមក ឈ្មោះខ្ញុំ និង លេខគណនីខ្ញុំ ត្រូវបានបោះពុម្ព លើក្រដាសផ្លូវការនៃកាកបាតក្រហមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ជារៀងរហូតមក ។

## ខ្ញុំថា៖ ការចូលរួមក្នុងត្រីភាគី មិនមែនជាជោគជ័យទេ

នៅថ្ងៃទី ២០ មិថុនា ១៩៨២ លោកតា សឺន សាន លោក ហ្គាហ្វា លោកស្រី សួន កាសេត និង បង ប៉ែន ថាល់ ចេញដំណើរពីទីក្រុងបាងកក ឆ្ពោះទៅទីក្រុងកូឡាឡាំពួនៃប្រទេសម៉ាឡេស៊ី ដើម្បីចូលរួមក្នុងការប្រកាសបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ជាមួយមេដឹកនាំពីររូបទៀតគឺ៖ សម្តេច សីហនុ និង លោក ខៀវ សំផន ។ នៅថ្ងៃនោះ ក៏ជាលើកទីមួយដែរ ដែលខ្ញុំសរសេរសំបុត្រទៅ ទេព ដារ៉ុង នៅឯប្រទេសបារាំង ដើម្បីឲ្យដឹងពីសភាពការណ៍នៅទីក្រុងបាងកកអស់ជាច្រើនសប្តាហ៍កន្លងមក ចាប់តាំងពីខ្ញុំមកដល់ទីក្រុងនេះ ។ ខ្ញុំរៀបរាប់អំពីការមិនទុកចិត្តគ្នា ក្នុងចំណោមថ្នាក់ដឹកនាំរបស់យើង និង អំពីការយល់ឃើញផ្ទាល់ខ្លួនរបស់ខ្ញុំ លើករណីបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសរសេរជាអាទិថា "ជីវភាពរស់នៅជាមួយលោកប្រធាន សឺន សាន មិនមែនជាការលំបាកពេកនោះទេ ប្រសិនបើយើងមិនមានមហិច្ឆតាធំធេងពេក" ។ "ខ្ញុំត្រូវបានលោកប្រធានចាត់តាំងឲ្យបង្កើតនូវប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុមួយ ដែលធ្វើឲ្យមេៗខ្លះមិនសប្បាយចិត្ត"... "សមាជិក រ.ជ.រ.ប.ខ. ទាំងអស់ត្រូវដឹងពីមូលហេតុពិតប្រាកដថាហេតុអ្វីបានជាសមាជិករ.ជ.រ.ប.ខ.សុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះ។ តាមពិតទៅ ការចូលរួមនេះជាមធ្យោបាយតែមួយគត់ ដែលអាចឲ្យ រ.ជ.រ.ប.ខ. ទទួលបាននូវជំនួយអន្តរជាតិ ដែលយើងកំពុងត្រូវការជាចាំបាច់ នៅចំពោះមុខបញ្ហាដ៏លំបាកគ្រប់យ៉ាង ទាំងខាងក្នុងទាំងខាងក្រៅ" ។ នៅក្នុងសំបុត្រទី២ ចុះ ថ្ងៃ

ទី ២៣ មិថុនា ទៅ ទេព ដារ៉ុង ជាភាសាបារាំង ខ្ញុំសរសេរថា៖"តាមយោបល់ខ្ញុំផ្ទាល់ ការចូលរួមបង្កើតរដ្ឋាភិបាលចម្រុះនេះ មិនអាចនិយាយបានថាជាជោគជ័យដ៏ត្រចះត្រចង់របស់យើងទេ ។ ក៏ប៉ុន្តែចាប់ពីពេលនេះទៅ យើងគ្រាន់តែអាចសង្ឃឹមថា នឹងមានដំណោះស្រាយនយោបាយចំពោះបញ្ហាកម្ពុជា" ។ "លោកប្រធានបានត្រូវទទួលការគាបសង្កត់ខ្លាំងណាស់ ដើម្បីទទួលយកនូវរូបមន្តនៃរដ្ឋាភិបាលចម្រុះនេះ ។ យើងនឹងរង់ចាំមើលតើយើងអាចដកខ្លួនផុតពីសភាពការណ៍បច្ចុប្បន្ន ដែលមិនអនុគ្រោះដល់យើងទាល់តែសោះ" ។ "ដារ៉ុង អាចនៅចាំបានឬទេ ដូចដែលខ្ញុំធ្លាប់ប្រាប់ ដារ៉ុង កាលពីពេលមុននោះថា នៅពេលណាដែលយើងសុខចិត្តចូលរួមជាមួយខ្មែរក្រហមនោះ ក៏ព្រោះតែលោកប្រធានមិនអាចពឹងលើ..... (ខ្ញុំចង់និយាយថា "ពឹងលើសមត្ថភាពយើង និង ពឹងលើមេដឹកនាំផ្ទៃក្នុងរបស់យើង") ។ តែទោះជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នាត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ ។ យើងត្រូវតែទទួលយកចំណុចបត់បែននេះថាជាមេរៀន ហើយត្រៀមប្រឈមនឹងហេតុការណ៍បន្ទាន់ទាំងអស់ដែលអាចកើតមាន ។ ការតស៊ូជាការលំបាក និង វែងឆ្ងាយសម្រាប់យើងទាំងអស់គ្នា"[157]។ ខ្ញុំបានប្រាប់ ដារ៉ុង ថាគណៈប្រតិភូរបស់ រ.ជ.រ.ប.ខ. នឹងត្រូវចាត់តាំងឲ្យចេញទៅស្វែងរកការគាំទ្រពីគ្រប់តំបន់ក្នុងពិភពលោក ជូនចំពោះរដ្ឋាភិបាលចម្រុះថ្មីនេះ ។

# សមាសភាពរដ្ឋាភិបាលត្រីភាគី ដែលថៃទទួលស្គាល់មុនគេ

ការចុះហត្ថលេខាប្រកាសបង្កើតរដ្ឋាភិបាល បានបើកផ្លូវឲ្យរដ្ឋាភិបាលថៃទទួលស្គាល់លោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារការទទួលស្គាល់នេះ រ.ជ.រ.ប.ខ. អាចទាក់ទងដោយចេញ

[157] Ieng Mouly [Lettre à Tep Darong] le 23-6-82.

មុខជាមួយក្រសួងការបរទេសថៃ និង ជាមួយអង្គទូតនានាដែលមានស្ថានទូតប្រចាំនៅទីក្រុងបាងកក ។ រ.ជ.រ.ប.ខ. ក៏អាចបើកគណនីផ្ទាល់របស់ខ្លួនបាន ដោយប្រើលិខិតទទួលស្គាល់ ដែលលោកឧត្តមសេនីយ ប្រេម ទិនស៊ុឡាណន្ត[158] (Prem Tinsulanond) ផ្ញើជូនលោកតា សឺន សាន ជាឯកសារសំអាង ។ ដោយសារលោក ហ្គាហ្វា ជាអ្នករៀបចំឯកសារបើកគណនី ដូច្នេះលោក ហ្គាហ្វា បានដាក់ឈ្មោះខ្លួនឯងជាមួយនឹងឈ្មោះលោក ប៊ុន សាយ និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអ្នកប្រើប្រាស់គណនីនេះ ។ នៅពេលជាមួយគ្នានោះ លោកតា សឺន សាន ក៏បានតែងតាំងលោក ហ្គាហ្វា ជាប្រធានខុទ្ទកាល័យនាយករដ្ឋមន្ត្រី បន្ថែមលើភារកិច្ចក្នុងការទាក់ទងជាអចិន្ត្រៃយ៍ជាមួយប្រទេសជាមិត្ត ជាពិសេស ជាមួយប្រទេសអាស៊ាន និង សហរដ្ឋអាមេរិក ។

លើកលែងតែលោក អ៊ឹម ឈូដេត ចេញ មន្ត្រីជាន់ខ្ពស់របស់រ.ជ.រ.ប.ខ. ដូចជាឧត្តមសេនីយ ដៀន ដែល លោក ហ៊ីង គន្ធុន លោក នាង ជិនហាន ជាដើម ហាក់ដូចជាមិនស្ទុះស្ទាចង់ចូលរួមក្នុងរដ្ឋាភិបាលនោះ ឬ ក៏មិនចង់ឲ្យមានសារសំខាន់ដល់រដ្ឋាភិបាលនេះឡើយ ។ ទាំងនេះក៏ប្រហែលជាដោយសារតែពួកគេមិនចង់ចូលរួមធ្វើជាដៃគូជាមួយខ្មែរក្រហម និង ជាមួយសម្តេច សីហនុ ។ នៅទីបំផុតឈ្មោះមន្ត្រីដែលត្រូវបញ្ចូលក្នុងបញ្ជីសមាជិករដ្ឋាភិបាល ក៏មានត្រឹមតែមន្ត្រីថ្នាក់មធ្យម ។ នៅខែ កក្កដា ១៩៨២ នៅពេលដែលរដ្ឋាភិបាលចម្រុះត្រូវប្រកាសសមាសភាពជាផ្លូវការ លោក ប៊ុន សាយ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសម្របសម្រួលខាងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោក អ៊ឹម ឈូដេត ជាសមាជិកខាងការពារជាតិ លោកវេជ្ជបណ្ឌិត ប៊ូ ខេង ជាសមាជិកខាងសុខាភិបាល និង សង្គមកិច្ច លោក ឆូយ វី សាស្ត្រាចារ្យ ជាសមាជិកខាងអប់រំជាតិ ។

---

[158] Prem Tinsulanonda (General), Prime Minister of Thailand, Letter to His Excellency Mr. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, July 29, B.E 2525 (1982).

លោកវេជ្ជបណ្ឌិត ប៊ូ ខេង និង លោក ឆូយ រី បានចូលរួមក្នុងរ.ជ.រ.ប.ខ. ជាច្រើនឆ្នាំមកហើយៗកំពុងរស់នៅក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ធុន ក្នុងជំរុំអំពិល ។ ក្រោយពេលដែលរដ្ឋាភិបាលចម្រុះបានត្រូវប្រកាស និង បង្កើតជាផ្លូវការ រដ្ឋាភិបាលនេះក៏ត្រូវបានទទួលស្គាល់ជាផ្លូវការពីអង្គការសហប្រជាជាតិ និង ពីប្រទេសជាច្រើននៅក្នុងពិភពលោក ។ សមាជិកគណៈកម្មាធិការសម្របសម្រួល ត្រូវបានទទួលស្គាល់ជារដ្ឋមន្ត្រី តាមពិធីការដែលមានឋានៈខ្ពស់ជាងមន្ត្រីឯទៀត ។ ដូច្នេះ នៅក្នុងរ.ជ.រ.ប.ខ. មន្ត្រីថ្នាក់ទាបត្រូវបានទទួលឋានៈខ្ពស់ជាង មន្ត្រីជាន់ខ្ពស់នៃរណសិរ្ស ដោយយោងតាមពិធីការរបស់រដ្ឋាភិបាល ។

# ខ្ញុំ និង បង ប៉ែន ថាល់ ទៅបំពេញបេសកកម្មនៅអាហ្វ្រិក

នៅខែ តុលា ១៩៨២ បង ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានចាត់តាំងឲ្យចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ដើម្បីស្វែងរកការគាំទ្រជូនចំពោះរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យថ្មីនេះ ។ ដើម្បីរៀបចំដំណើររបស់យើងៗត្រូវត្រឡប់ទៅទីក្រុងប៉ារីសសិន ដែលនៅទីនោះ ទើបយើងអាចទទួលយកទិដ្ឋាការ និង សំបុត្រយន្តហោះរបស់យើង ។ ខ្ញុំបានដឹងថាប្រទេសម៉ាឡេស៊ីបានជួយរៀបចំដំណើររបស់យើង ។ ពួកយើងត្រូវចេញទៅបីប្រទេសគឺ ប្រទេសនីហ្សេ (Niger) ប្រទេសហ្គាណា (Ghana) និង ប្រទេសម៉ាលី (Mali) ។ ពីទីក្រុងប៉ារីស យើងហោះទៅនីហ្សេ (Niger) តាមយន្តហោះអែរអាហ្វ្រិក (Air Afrique) ដែលមិត្តបារាំងយើងខ្លះនិយាយលេងហៅថា "យន្តហោះ អែរប្រហែល..." ព្រោះគ្រាន់តែប្រហែលៗមិនប្រាកដថាអាចហោះ ឬ អាចមិនហោះ(?)តាមកាលវិភាគរបស់ខ្លួនឡើយ ។

យើងគ្រោងទៅប្រទេសនីហ្សេមួយថ្ងៃ ។ យើងបានទៅដល់ទីក្រុងនីញ៉ាម៉េ (Niamey) ពេលល្ងាច ។ នោះគឺជាលើកទីមួយ ដែលខ្ញុំធ្វើដំណើរទៅកាន់ ទ្វីបអាហ្វ្រិក ។ នៅពេលនោះ ខ្ញុំនៅមិនទាន់ដឹងខ្លួនថាពួកយើងត្រូវធ្វើដំណើរទៅបំពេញបេសកកម្មជាអ្នកតំណាងប្រជាជាតិមួយនៅឡើយទេ ។ យើងចុះពីយន្តហោះ ដោយដើរលាយឡំជាមួយអ្នកដំណើរឯទៀតយ៉ាងសាមញ្ញបំផុត ។ យើងចេញទៅយកវ៉ាលីស ហើយជួលតាក់ស៊ីជិះឆ្ពោះទៅរកសណ្ឋាគារខ្នាតអន្តរជាតិមួយ ដែលមានអ្នកគ្រប់គ្រងជាជនជាតិបារាំង ។ នៅម៉ោងប្រហែល ៤ ល្ងាច ខ្ញុំទូរស័ព្ទទៅក្រសួងការបរទេស ដើម្បីសុំណាត់ជួបមន្ត្រីជាន់ខ្ពស់ ។ ខ្ញុំត្រូវបានទទួលការណាត់ ឲ្យជួបជាមួយមន្ត្រីជាអគ្គនាយកក្រសួងការបរទេសនៃប្រទេសនីហ្សេ (Niger) នៅថ្ងៃស្អែកពេលព្រឹក ។ ក៏ប៉ុន្តែ នៅពេលដែលខ្ញុំបានទទួលការណាត់ឲ្យជួបរួចហើយនោះ ទើបខ្ញុំនឹកឃើញថា ពួកយើងពុំមានលិខិតផ្លូវការការទូតណាមួយបញ្ជាក់ថា ពួកយើងជាអ្នកតំណាងរដ្ឋាភិបាលចម្រុះសោះឡើយ ។ ខ្ញុំនឹកហួសចិត្តថាមិនគួរធ្វេសប្រហែស មិនបានត្រៀមឯកសារដូច្នេះទេ ។ តាមពិតទៅ ខ្ញុំនៅមិនទាន់មានបទពិសោធន៍ខាងផ្នែកការទូតនៅឡើយ ។ នេះជាការងាររដ្ឋលើកទីមួយរបស់ខ្ញុំ ។ ដោយខ្ញុំបានយកជាប់ទៅជាមួយ នូវម៉ាស៊ីនអង្គុលីលេខផ្ទាល់ខ្លួនរបស់ខ្ញុំៗក៏ចាប់ផ្តើមវាយអត្ថបទលិខិតការទូត លើក្រដាសផ្លូវការរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះ ។ វាយរួចហើយ ខ្ញុំក៏ចុះហត្ថលេខាខ្លួនឯង ដោយធ្វើត្រាប់តាមហត្ថលេខាលោកតា សឺន សាន នាយករដ្ឋមន្ត្រី ។

ពួកយើងទាំងពីរនាក់ បង ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានបង្ហាញតាមកំណត់ការទូតថា ជាសមាជិកខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនទៅមន្ត្រីពិធីការនៃក្រសួងការបរទេស ។ លោកអគ្គនាយកទទួលពួកយើងយ៉ាងរាក់ទាក់ណាស់ ។ គាត់ជាមនុស្សពូកែនិយាយៗ ពីនោះពីនោះឥតឈប់

ឈរ ។ នៅលើការិយាល័យ ខ្ញុំឃើញមានគរទៅដោយកាសែតជាភាសាបារាំងរបស់បារាំងឈ្មោះឡឺម៉ុង ឌីប្លូម៉ាទិច (Le Monde Diplomatique) ។ តាមពិតទៅ ភាគច្រើនបញ្ញវន្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍ រួមទាំងរូបខ្ញុំផងចូលចិត្តអានកាសែតបារាំងនេះណាស់ ។ លោកអគ្គនាយក និយាយភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ ។ បង ប៉ែន ថាល់ ធ្វើបទអត្ថាធិប្បាយពីសភាពការណ៍ទូទៅនៅកម្ពុជា ។ គាត់សង្កត់ធ្ងន់ពីការតស៊ូរបស់ប្រជាជនកម្ពុជា ដើម្បីរំដោះចេញពីការកាន់កាប់របស់កងទ័ពវៀតណាម ។ បន្ទាប់មកបង ប៉ែន ថាល់ ទុកឲ្យខ្ញុំពន្យល់ពីយន្តការ និង សមាសភាពនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។

ជាដំបូងខ្ញុំ ពន្យល់ថា ក្រុមយើងជាក្រុមអ្នកជាតិនិយមដែលដឹកនាំដោយលោក សឺន សាន បច្ចុប្បន្នជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបញ្ជាក់ថា "ពួកយើងមានកងទ័ព មានអង្គការចាត់តាំងនយោបាយ និង មានប្រជាពលរដ្ឋផ្ទាល់ខ្លួនរបស់ពួកយើង.." "មុនពេលដែលវៀតណាមចូលមកឈ្លានពានកម្ពុជា ពួកខ្មែរក្រហមជាសត្រូវស្លាប់រស់របស់យើង ដោយសារពួកនេះបានកាប់សម្លាប់ប្រជាពលរដ្ឋយើងអស់រាប់លាននាក់" ។ "ក៏ប៉ុន្តែនៅក្រោមអំណាចវៀតណាម ប្រទេសយើងអាចនឹងរលាយចេញពីផែនដី ប្រសិនបើខ្មែរមិនរួបរួមគ្នាការពារទឹកដីទេ ។ ហេតុនេះហើយ ទើបក្រុមយើងបានចូលរួមក្នុងរដ្ឋាភិបាលចម្រុះជាមួយសម្តេច សីហនុ និង ពួកខ្មែរក្រហមតាមរូបមន្តដ៏ទូលំទូលាយមួយ ដែលក្នុងនោះភាគីនីមួយៗមានស្វ័យភាពមានកងទ័ព និង មានអង្គការចាត់តាំងនយោបាយផ្ទាល់របស់ខ្លួន" ។ "រដ្ឋាភិបាលនេះ មានក្រសួងរបស់ខ្លួនដែលមានឈ្មោះថា"គណៈកម្មាធិការសម្របសម្រួល" ។ ខ្ញុំបន្តទៀតថា៖ "នៅក្នុងគណៈកម្មាធិការនីមួយៗមានរដ្ឋមន្ត្រីមួយនាក់មកពីភាគីនីមួយៗ ។ ដូច្នេះក្នុងគណៈកម្មាធិការមួយមានរដ្ឋមន្ត្រី ៣ នាក់ ដែលម្នាក់ៗដើរតួនាទីតែក្នុងរង្វង់ភាគីរបស់ខ្លួនតែប៉ុណ្ណោះ គ្មាន

អំណាចទៅលើភាគីឯទៀតឡើយ ។ រដ្ឋមន្ត្រីរបស់ រ.ជ.រ.ប.ខ.មានអំណាចតែក្នុងជួរ រ.ជ.រ.ប.ខ. រដ្ឋមន្ត្រី ហ៊ុន ស៊ិន ប៉ិចមានអំណាចតែក្នុង ហ៊ុន ស៊ិន ប៉ិច ឯរដ្ឋមន្ត្រីរបស់ខ្មែរក្រហម ក៏មានអំណាចតែក្នុងរង្វង់ខ្មែរក្រហមដូច្នោះដែរគឺ គ្មានអំណាចទៅលើភាគីផ្សេងឯទៀតទេ ។ រដ្ឋាភិបាលចម្រុះ មានរដ្ឋមន្ត្រីការពារប្រទេស ៣ រូប រដ្ឋមន្ត្រីអប់រំ ៣ រូប រដ្ឋមន្ត្រីសេដ្ឋកិច្ច ហិរញ្ញវត្ថុ ៣ រូប រដ្ឋមន្ត្រីសុខាភិបាល និង សង្គមកិច្ច ៣ រូប ។ លើកលែងតែក្រសួងការបរទេស ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ។ នៅពីលើគណៈរដ្ឋមន្ត្រីនេះ មានគណៈរដ្ឋមន្ត្រីស្នូលមួយទៀត (Inner Cabinet)[159] ដែលរួមមានសម្តេច នរោត្តម សីហនុ ជាប្រធានកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន ជាអនុប្រធានកម្ពុជាប្រជាធិបតេយ្យ និង លោក សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ នៅទីបញ្ចប់ខ្ញុំបញ្ជាក់ថា "គោលបំណងរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ មិនមែនស្វែងរកដំណោះស្រាយយោធានោះទេ ។ កងកម្លាំងរបស់យើងទាំងអស់នឹងបង្ខំឲ្យវៀតណាមចូលមកចរចា ព្រោះថាពួកយើងកំពុងធ្វើការតស៊ូប្រយុទ្ធ ដើម្បីឲ្យមានការអនុវត្តសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ ដែលតម្រូវឲ្យវៀតណាមដកកងទ័ព ចេញពីកម្ពុជា និង ដើម្បីឲ្យមានការបោះឆ្នោតទូទៅនៅកម្ពុជា" ។

លោកអគ្គនាយកហាក់ដូចជាយកចិត្តទុកដាក់ស្តាប់ណាស់ ហើយហាក់ដូចជាទទួលយកនូវអ្វីដែលយើងបានរ៉ាយរ៉ាប់ទាំងអស់នោះ ។ លោកអគ្គនាយកបានស្នើឲ្យយើងជួបផ្ទាល់ជាមួយលោករដ្ឋមន្ត្រីក្រសួងការបរទេសទៀតផង ។ គាត់បញ្ចេញកាយវិការយ៉ាងសាមញ្ញបំផុតគឺ គាត់ដើរទៅបើកទ្វារបន្ទប់គាត់ ហើយដើរបង្ហួសទៅបើកទ្វារបន្ទប់មួយទៀត ដែលនៅជាប់ជាមួយនោះ ។ ក៏ប៉ុន្តែ លោករដ្ឋ

[159] Samdech Norodom Sihanouk, H.E. Mr. Son Sann, H.E. Mr. Khieu Samphan, CGDK, Declaration of the Formation of the Coalition Government of Democratic Kampuchea , op. cit.

មន្ត្រីមិននៅក្នុងបន្ទប់នោះទេ ។ ដូច្នេះ យើងក៏លាលោកអគ្គនាយកត្រឡប់ទៅសណ្ឋាគាររបស់ពួកយើងវិញ ដោយនឹកសង្ឃឹមថាមិត្តនីហ្សេរបស់យើងនឹងយល់ពីបញ្ហារបស់យើង និង គាំទ្រយើង ព្រោះថាសារដែលយើងនាំទៅជាមួយនោះគឺ ជាសារសន្តិភាព ។ អ្វីដែលយើងចង់បានគឺ លទ្ធិប្រជាធិបតេយ្យពិតប្រាកដសម្រាប់ប្រទេសយើង សម្រាប់ប្រជាពលរដ្ឋយើង ។ យើងមិនត្រូវការឲ្យខ្មែរក្រហមត្រឡប់មកកាន់អំណាចវិញឡើយ ។

នៅរសៀលនៃថ្ងៃដដែល ពួកយើងក៏ចេញដំណើរឆ្ពោះទៅប្រទេសហ្គាណា (Ghana) គឺ ជាប្រទេសមួយដែលប្រើភាសាអង់គ្លេស ។ យើងធ្វើដំណើរឆ្លងកាត់ប្រទេសបួគីណាហ្វាសូ (Burkina Faso) ដែលនៅសម័យនោះមានឈ្មោះថា អូតវ៉ុលតា (Haute Volta) ។ យើងធ្វើការហោះហើរមិនយូរប៉ុន្មាន ក៏ទៅដល់ទីក្រុងអាក្រា (Accra) នៃប្រទេសហ្គាណា ។ នៅពេលដែលយន្តហោះៗកាន់ តែជិតទៅដល់ ខ្ញុំសង្កេតឃើញទេសភាពពណ៌ខៀវបៃតងកាន់តែច្បាស់ឡើងៗ ដែលអាចបញ្ជាក់ថា ប្រទេសនេះមានភាពសម្បូរណ៌សប្បាយជាងប្រទេសនីហ្សេ ។ នៅពេលយន្តហោះចុះចត ខ្ញុំសង្កេតពីលើយន្តហោះឃើញរថយន្តលីម៉ូស៊ីនដ៏ប្រណិតម៉ាកម៉ែកស៊ីដែស (Mercedes) ខ្មៅមួយគ្រឿងចត ហាក់បីដូចជារង់ចាំមន្ត្រី ជាន់ខ្ពស់វីអាយភី (VIP) ណាម្នាក់នៅទីនោះ ។ នៅពេលដែលយើងកំពុងដើរចេញពីយន្តហោះលាយឡំជាមួយអ្នកដំណើរឯទៀតឆ្ពោះត្រង់ទៅបញ្ជរអន្តោប្រវេសន៍ មន្ត្រីជនជាតិហ្គាណាពីរនាក់ស្លៀកពាក់ស៊ីវិលដើរស្ទាក់មុខយើង ហើយនិយាយថា៖ "តើលោកទាំងពីរជាទូតមកពីកម្ពុជាឬ?" ខ្ញុំមិនច្បាស់ថាអ្នកណាជាទូតនោះទេ ក៏ប៉ុន្តែប្រញាប់ប្រញាល់ឆ្លើយថា "បាទ ! បាទ ! ពិតមែនហើយ" ។ រំពេចនោះ មន្ត្រីម្នាក់ក៏ប្រញាប់ប្រញាល់យកលិខិតឆ្លងដែន និង សំបុត្រយន្តហោះរបស់ពួកយើងទៅបោះត្រាទិដ្ឋាការចូល ឯមន្ត្រីម្នាក់ទៀតនាំពួកយើងចូលទៅក្នុងបន្ទប់វីអាយភី

នៅព្រលានយន្តហោះនោះ ។ មន្ត្រីទាំងពីរនាក់នោះជាមន្ត្រីពិធីការមកពីក្រសួងការបរទេសហ្គាណា ដែលមានភារកិច្ចមកទទួលពួកយើងនៅអាកាសយានដ្ឋាន ។

# ផ្លាស់ឋានៈពីជនភៀសខ្លួន ទៅជាអ្នកការទូត

នៅក្នុងបន្ទប់រីអាយភីនោះ ពួកយើងបានត្រូវរាយការណ៍ ឲ្យដឹងពីកម្មវិធីនៃការស្នាក់អាស្រ័យរបស់យើង ។ ពួកយើង ត្រូវទៅស្នាក់នៅក្នុងសណ្ឋាគារដ៏ធំខ្នាតអន្តរជាតិមួយនៅចំកណ្តាលក្រុង ដោយយើងជាអ្នកចេញលុយ ឯល្ងាចនេះពួកយើងនឹងទៅជួបជាមួយអគ្គនាយកក្រសួងការបរទេស ។ យើងត្រូវសម្រាកនៅទីក្រុងអាក្រា (Accra) មួយយប់ រួចនឹងចេញដំណើរទៅប្រទេសម៉ាលីទៀត ។ ក្រោយពេលដែលមន្ត្រីពិធីការ បានប្រមូលវ៉ាលីស និង បំពេញបែបបទអន្តោប្រវេសន៍រួចហើយ មន្ត្រីទាំងនោះក៏នាំពួកយើងឆ្ពោះទៅរករថយន្តលីម៉ូស៊ីនម៉ែកស៊ីដែស (Mercedes) ខ្មៅដែលរង់ចាំនៅខាងក្រៅស្រាប់ ។ ខ្ញុំចូលទៅអង្គុយនៅផ្នែកខាងក្រោយ ហើយរៀបចំខ្លួនឲ្យសមឋានៈ ព្រោះមិនដែលនឹកស្មានសោះថាអាចត្រូវទទួលបដិសណ្ឋារកិច្ចបែបនេះសោះ ។ តាមពិតទៅ ខ្ញុំធ្លាប់តែគិតថាខ្លួនឯងជាជនភៀសខ្លួន ឬ ត្រឹមតែជាមន្ត្រីនៃរដ្ឋាភិបាលក្រៅស្រុកមួយប៉ុណ្ណោះ មិនដែលគិតថាខ្លួនជាមន្ត្រីការទូត ដែលកំពុងតែជាអ្នកតំណាងនៃប្រជាជាតិម្តងណាឡើយ ។

នៅពេលចូលជួបជាមួយលោកអគ្គនាយក យើងនិយាយក្នុងន័យដដែលដូចយើងធ្លាប់និយាយនៅនីហ្សេយ៉ាងដូច្នោះដែរ លើកលែងតែនៅហ្គាណា យើងនិយាយជាភាសាអង់គ្លេស ។ នៅពេលទៅដល់ភ្លាមនោះ លោកអគ្គនាយក និយាយថា កាលពីអាទិត្យមុន គាត់ក៏បានទទួលគណៈប្រតិភូមកពីកម្ពុជាដែរគឺ គណៈប្រតិភូមកពីរដ្ឋាភិបាលភ្នំពេញ ។ តាមពិតទៅរបបក្រុងភ្នំពេញក៏មមាញឹក ក្នុងការស្វែងរកការគាំទ្រខាងការទូតពីប្រទេសនានានៅទ្វីបអាហ្វ្រិក (Afrique) ដែរ ។

លោកអគ្គនាយកហាក់ដូចជាចង់វង្វេងមិនច្បាស់ថាខាងណាជារដ្ឋាភិបាល ក្នុងស្រុក ខាងណាជារដ្ឋាភិបាលក្រៅស្រុកឡើយ ។ ក៏ប៉ុន្តែ ពួកយើងយល់ថា នៅទីបញ្ចប់ ប្រទេសហ្គាណាគាំទ្រខាងយើង ។ នៅពេលយប់ យើងមិនហ៊ានចេញក្រៅសណ្ឋាគារទេ ដោយសារប្រទេសហ្គាណាទើបកើតមានរដ្ឋប្រហារក្នុងពេលថ្មីៗ ។ នៅសណ្ឋាគារក៏មានកងកម្លាំងប្រដាប់អាវុធឈរយាមដែរ ។

មន្ត្រីពិធីការបានប្រាប់ពួកយើងឲ្យភ្ញាក់ពីព្រឹក ដើម្បីត្រៀមចេញទៅព្រលានយន្តហោះ នៅម៉ោងបួនហៀបភ្លឺ ។ ដូច្នេះយើងក៏ត្រៀមខ្លួន ។ បង ប៉ែន ថាល់ គាត់ជាអ្នកចូលចិត្តពិសាស្រា ។ ទោះជានៅពេលព្រឹកព្រហាម ក៏គាត់ចូលចិត្តពិសាស្រាវីស្គីសូដាទឹកកកដែរ គាត់មិនពិសាអាហារពេលព្រឹកដូចយើងតាមធម្មតាទេ ។ នៅពេលដែលយើងរង់ចាំរថយន្ត ដែលត្រូវនាំយើងទៅព្រលានយន្តហោះនោះ គាត់នៅតែបន្តពិសាស្រាវីស្គីរហូត ។ យើងរង់ចាំរថយន្តតាំងពីម៉ោង ៤ រហូតដល់ម៉ោង ៨ ព្រឹក ទើបឃើញរថយន្តមកដល់ ។ នៅពេលទៅដល់ព្រលានយន្តហោះ យើងត្រូវអង្គុយរង់ចាំក្នុងបន្ទប់ វីអាយភី បន្តទៅទៀតទម្រាំឡើងជិះយន្តហោះ ។ យើងនៅរង់ចាំអស់ជាច្រើនម៉ោង ។ បង ប៉ែន ថាល់ សប្បាយនឹងពិសាស្រាវីស្គីនេះណាស់ ដែលគេដាក់បំរើក្នុងបន្ទប់វីអាយភី ។ ពេលខ្ញុំហៅកាហ្វេ គាត់ហៅ វីស្គី ។

នៅពេលយើងឡើងជិះយន្តហោះនោះ ធាតុអាកាសហាក់ដូចជាកាន់តែក្តៅខ្លាំងឡើងដែលពិបាកនឹងទ្រាំ ។ ពួកយើងបានត្រូវអញ្ជើញឲ្យអង្គុយនៅកៅអីជួរទីមួយក្នុងឋានៈជាភ្ញៀវរបស់រដ្ឋាភិបាលហ្គាណា ។ យើងត្រូវហោះហើរ ពីហ្គាណាទៅប្រទេសកូតឌីវ័រ ឬ អាយវ្រីខូស (Ivry Coast) ដើម្បីរង់ចាំជើងយន្តហោះក្នុងរយៈពេលបីថ្ងៃ មុននឹងបន្តទៅប្រទេសម៉ាលីដែលជាបេសកកម្មចុងក្រោយរបស់ពួកយើង ។ មុននឹងទៅដល់ប្រទេសកូតឌីវ័រនោះ យើងក៏ត្រូវឆ្លង កាត់ប្រទេសអូតវ៉ុលតាម្តងទៀត ។ នៅពេលយន្តហោះចុះចត ដើម្បីទទួលអ្នកដំណើរថែមទៀត បង ប៉ែន

ថាល់ ប្រាប់ខ្ញុំថាគាត់ចេញទៅក្នុងព្រលានយន្តហោះមួយភ្លែត ដើម្បីចង់ឃើញថាតើនៅប្រទេសអូតវ៉ុលតានេះមានអ្វីលក់ខ្លះ? ខ្ញុំមិនចេញទេ ខ្ញុំនៅអង្គុយនៅនឹងកន្លែងក្នុងយន្តហោះ ។ កន្លះម៉ោងក្រោយមកបង ប៉ែន ថាល់ ត្រឡប់មកវិញ ដោយបីស្រាវីស្គីមួយដបមកផង ។ គាត់បន្តពិសាស្រារហូតពីអូតវ៉ុលតារហូតដល់យន្តហោះចុះចតនៅកូតឌីវ័រ ។

## បង ប៉ែន ថាល់ ដួលសន្លប់ តែគាត់ថាអត់ឈឺអ្វីទេ?

ដោយយើងត្រូវរង់ចាំក្នុងរយៈពេល ៣ ថ្ងៃ ទើបមានជើងយន្តហោះដឹកនាំយើងបន្តទៅប្រទេសម៉ាលីនោះ ខ្ញុំគិតថាគួរតែឆ្លៀតឱកាសចេញទៅដើរលេងនៅឯទីក្រុងអាប៊ីដហ្សង់ (Abidjan) ផងដែរ ។ យន្តហោះចុះចតដោយសុវត្ថិភាព នៅអាកាសយានដ្ឋានអាប៊ីដហ្សង់ ។ ដោយហេតុពួកយើងពុំមានទិដ្ឋាការចូលប្រទេសកូតឌីវ័រ យើងក៏ត្រូវដើរបន្តកន្ទុយគ្នាតម្រង់ទៅបញ្ជរអន្តោប្រវេសន៍ ដើម្បីសាកល្បងសុំទិដ្ឋាការនៅព្រលានយន្តហោះតែម្តង ។ ខ្ញុំដើរពីមុខបង ប៉ែន ថាល់ តាមជួរទៅមុខយ៉ាងយឺតៗ ដោយសារមានអ្នកដំណើរជាច្រើននាក់ធ្វើដំណើរទៅទីដៅតែមួយ ។ នៅពេលនោះ យើងកាន់តែខិតជិតដល់បញ្ជរនគរបាលអន្តោប្រវេសន៍ទៅហើយ ខ្ញុំឮសូរសម្លេងដួលភឹងយ៉ាងខ្លាំងនៅពីក្រោយខ្នង ។ នៅពេលបែរទៅក្រោយ ខ្ញុំឃើញបង ប៉ែន ថាល់ ដួលប្រងាងៗឥតកំរើកបាត់បង់ស្មារតីទាំងស្រុង ។ គាត់ដួលសន្លប់ព្រោះប្រហែលជាជាតិសុរាឡើងខ្លាំងបូកផ្សំនឹងធាតុអាកាសនៅទ្វីបអាហ្វ្រិកក្តៅខ្លាំងផង ធ្វើឲ្យសិរីរាង្គទ្រាំទ្រពុំបាន ។ ខ្ញុំភិតភ័យខ្លាំងណាស់ ។ ខ្ញុំស្រែកហៅរកជំនួយជាបន្ទាន់ ហើយខិតខំធ្វើចលនារាងកាយគាត់ឲ្យដឹងខ្លួនឡើងវិញ ។ ខ្ញុំស្រែកសុំឲ្យគេជួយរកតាក់ស៊ីដើម្បីដឹកគាត់ទៅពេទ្យជាបន្ទាន់ ។ នៅពេលនោះ មនុស្សជាច្រើនក៏ផ្អើលឆោឡោ ចំណែកមន្ត្រីនគរបាលក៏ជួយជ្រោមជ្រែងសម្រួលរកតាក់ស៊ីឲ្យនាំទៅ

មន្ទីរពេទ្យដែរ ។ នៅពេលដើរចេញទៅខាងក្រៅព្រលានយន្តហោះ បង ប៉ែន ថាល់ ចាប់ដឹងខ្លួនខ្លះៗហើយ ។ នៅតាមផ្លូវ ឆ្ពោះទៅទីក្រុងអាប៊ីដហ្សង់បង ប៉ែន ថាល់ ដឹងខ្លួនទាំងស្រុងតែម្តង ។ គាត់សួរខ្ញុំថា៖ "យើងជិះតាក់ស៊ីទៅណា?" ខ្ញុំឆ្លើយថា "យើងទៅពេទ្យ" ។ គាត់សួរតទៀតថា "អ្នកណាឈឺស្អី?" ខ្ញុំព្យាយាមពន្យល់គាត់ថា ពេលមុននេះបន្តិចគាត់ដួលសន្លប់មិនដឹងខ្លួន ។ ប៉ុន្តែបង ប៉ែន ថាល់ និយាយថា គាត់អត់មានឈឺអ្វីផង ។ តាមការណែនាំរបស់អ្នកបើកតាក់ស៊ី យើងធ្វើដំណើរទៅគ្លីនិកឯកជនរបស់ជនជាតិបារាំងមួយ ។ នៅពេលទៅដល់បង ប៉ែន ថាល់ មានអាការៈជាសះស្បើយទាំងស្រុង ។ នៅពេលគិលានុប្បដ្ឋាយិកាសួរបង ប៉ែន ថាល់ ឆ្លើយថាគាត់អត់មានឈឺអ្វីទេ ហើយក៏និយាយកំប្លែងលេងជាមួយនារីនោះទៅវិញ ។ មែនទែន ពួកយើងចំណាយប្រាក់ប្រមាណ ២០០ ហ្វ្រង់បារាំងចោលទទេ ដោយគ្មានបានការអ្វីទាំងអស់ ។

ពួកយើងនាំគ្នាវិលត្រឡប់មកព្រលានយន្តហោះវិញ ដើម្បីមកប្រមូលយកវ៉ាលីសរបស់យើង ។ ចូលទៅក្នុង ពួកនគរបាលអន្តោប្រវេសន៍សំដែងការងឿងឆ្ងល់ថា ហេតុអ្វីបានជាពួកយើងអាចចេញទៅក្រៅបាន ដោយគ្មានទិដ្ឋាការចូលប្រទេសកូតឌីវ័រយ៉ាងនេះ ។ ស្នងការនគរបាលនៅទីនោះនាំយើងទៅក្នុងការិយាល័យ ហើយសួរដេញដោលពួកយើងអស់រយៈពេលជាច្រើនម៉ោង ទោះបីយើងបានបង្ហាញឯកសារផ្លូវការដឹងថា ពួកយើងជាមន្ត្រីការទូត ដែលត្រូវបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ហើយកំពុងរង់ចាំជើងយន្តហោះបន្តដំណើរទៅប្រទេសម៉ាលីក៏ដោយ ។ នៅទីបំផុតលោកស្នងការបាននាំយើងទៅស្នាក់នៅសណ្ឋាគារមួយ ដែលស្ថិតនៅក្នុងបរិវេណព្រលានយន្តហោះ ដោយឲ្យយើងទទួលបន្ទុកចេញសោហ៊ុយស្នាក់នៅ ។ សណ្ឋាគារនោះជាសណ្ឋាគារអន្តរជាតិ ដែលយើងស្នាក់នៅទម្រាំមានជើងយន្តហោះទៅប្រទេសម៉ាលី ក្នុងរយៈពេលពីរយប់ ។ នៅទីនោះ យើងមិនអាចចេញទៅ

ទីក្រុងទៀតទេ តែយើងអាចដើរគយគន់ឥវ៉ាន់ល្អៗតាមហាងលក់របស់របរប្រណិត ដែលរួចពន្ធបាន ( Duty Free Shop ) ។

## យុវជនជនជាតិតូហ្គោ

នៅពេលបាយល្ងាច យើងបានប្រទះឃើញយុវជនស្បែកខ្មៅម្នាក់ ដែលកំពុងទម្រេតខ្លួនលើកៅអីក្នុងបរិវេណរង់ចាំយន្តហោះ ។ យុវជននោះ បានមកចាំជើងយន្តហោះទៅម៉ាលីដូចពួកយើងដែរ អស់រយៈពេលពីរថ្ងៃមកហើយ ។ យើងរាប់រកយុវជននោះ ដែលជាជនជាតិតូហ្គោ (Togolais) ។ ដោយក្ដីអាណិត យើងក៏នាំឲ្យទៅរួមអាហារពេលល្ងាចជាមួយពួកយើង ។ ពួកយើងឲ្យគេរួមតុជាមួយ និងបើកឲ្យទទួលទានអាហារដោយសេរី ។ ពួកយើងចូលចិត្តអាហារបារាំង មានសាច់គោចៀន (Steak) និង ដំឡូងបារាំងចៀន ។ យើងមិនបានប្រាប់យុវជននោះថា យើងជានរណាទេ ។ ប្រហែលដោយសារអត់អាហារជាច្រើនថ្ងៃមកហើយ ទើបយុវជននោះទទួលទានអាហារបានច្រើន ព្រោះថានៅក្នុងតំបន់ឆ្លងកាត់អន្តរជាតិ (Transit Area) នោះ ម្ហូបម្ហាមានតម្លៃថ្លៃណាស់ ។ ខ្ញុំមិនហ៊ានទទួលទានភេសជ្ជៈដែលមានជាតិសុរាទេ ទោះបីជាម្ហូបតម្រូវរកស្រាក្រហម ឬ ស្រាបៀក៏ដោយ ព្រោះខ្ញុំមិនចង់នាំបង ប៉ែន ថាល់ ឲ្យស្រក់ទឹកមាត់ចង់ទទួលទានស្រាទៀត ។ ដូច្នេះ ខ្ញុំក៏ហៅត្រឹមតែទឹកសុទ្ធ ។ ក៏ប៉ុន្តែផ្ទុយទៅវិញបង ប៉ែន ថាល់ ហៅស្រាបៀរ ដែលធ្វើឲ្យខ្ញុំហួសចិត្តយ៉ាងខ្លាំង ។ ខ្ញុំនឹកខឹងបង ប៉ែន ថាល់ ជាខ្លាំង ហើយគិតក្នុងចិត្តថា គួរតែបញ្ជូនគាត់ទៅប្រទេសបារាំងវិញ ទុកឲ្យខ្ញុំបន្តបេសកកម្មតែម្នាក់ឯង ។ ក៏ប៉ុន្តែ នៅចំពោះមុខយុវជនតូហ្គោឡេ ខ្ញុំក៏មិនហ៊ាននិយាយអ្វីទាំងអស់ ។

ពីរថ្ងៃបន្ទាប់មក ពួកយើងចេញដំណើរទៅប្រទេសម៉ាលី ។ មន្ត្រីពិធីការពីរនាក់នៃក្រសួងការបរទេសម៉ាលី បានមកទទួលពួកយើង ។ ពួកគេនាំយើងឆ្ពោះទៅ

បន្ទប់វីអាយភី ប្លែកពីអ្នកដំណើរឯទៀតៗ ។ នៅពេលយើងកំពុងដើរជាមួយមន្ត្រីពិធីការទៅបន្ទប់វីអាយភីនោះ យុវជនតូហ្គោឡេដែលនៅដាច់ឆ្ងាយពីក្រោយយើងប្រញាប់ប្រញាល់ស្រែកប្រាប់យើងថាៈ "អេ ! អេ ! កុំទៅខាងនោះ ខុសហើយ ! អ្នកត្រូវទៅខាងនេះវិញ" ។ ប៉ុន្តែពួកយើងធ្វើដូចជាមិនឮ ហើយក៏បន្តដំណើរជាមួយមន្ត្រីពិធីការទៅបន្ទប់ទទួលភ្ញៀវវីអាយភីតទៅទៀត ។ នៅពេលដែលពួកគេបានប្រមូលវ៉ាលីសរបស់ពួកយើង និង បំពេញបែបបទអន្តោប្រវេសន៍សម្រាប់ពួកយើងរួចហើយ មន្ត្រីពិធីការបាននិយាយប្រាប់យើងថា មានយុវជនម្នាក់កំពុងអង្គុយរង់ចាំអស់លោកឯកន្លែងយកវ៉ាលីស (Carrousel) ។ នៅពេលដែលមន្ត្រីពិធីការកំពុងប្រមូលអីវ៉ាន់ពួកយើងនោះ យុវជនម្នាក់នោះ មកបេះដៃពួកមន្ត្រីចេញដោយចោទសួរថា៖ "តើពួកលោកយកវ៉ាលីសពួកម៉ាកខ្ញុំទៅណា? ពួកលោកចង់លួចវ៉ាលីសមិត្តខ្ញុំឬ?" មន្ត្រីពិធីការនៅទីបញ្ចប់ ក៏បានប្រាប់ការពិតថា ពួកយើងជាបេសកជនការទូតខ្មែរ មកបំពេញបេសកកម្មនៅប្រទេសម៉ាលី ។ តាមពិតទៅយុវជននោះស្រឡាញ់រាប់អានពួកយើង មានភក្តីភាពចំពោះយើង ហើយការពារមិនឲ្យពួកយើងបាត់បង់វ៉ាលីសរបស់ពួកយើងតែប៉ុណ្ណោះ ។

មន្ត្រីពិធីការដែលមានភារកិច្ចជូនដំណើរពួកយើង តែងមកជួបពួកយើងក្នុងអាការៈស្រស់ស្រាយរំភើយក្នុងអារម្មណ៍គ្មានខ្វល់ពីអ្វីឡើយ ។ គាត់រាក់ទាក់ជាមួយពួកយើងណាស់ តែគាត់មិនសូវគោរពម៉ោង ពេលប៉ុន្មានឡើយ ។ បើគាត់ណាត់ជាមួយយើងម៉ោង ៨ ត្រូវគិតថា ម៉ោង ៨:៣០នាទី ឬ ម៉ោង ៩:០០ ទើបឃើញមុខ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅទីបំផុតមន្ត្រីពីធីការនោះក៏បានជួយសម្រួលឲ្យពួកយើងបានជួបសន្ទនាការងារ ជាមួយលោកអគ្គលេខាធិការនៃក្រសួងការបរទេស ។ ក្រសួងការបរទេសស្ថិតនៅក្នុងបរិវេណនៃអាគាររដ្ឋាភិបាល ដែលមានការយាមកាមយ៉ាងហ្មត់ចត់ណាស់ ។ នៅពេលជួបសន្ទនាគ្នានោះ បង ប៉ែន ថាល់ ទុក

លទ្ធភាពឲ្យខ្ញុំនិយាយតែម្នាក់ឯង ឆ្លងឆ្លើយជាមួយលោកអគ្គលេខាធិការ ។ ខ្ញុំធ្វើការពន្យល់បង្ហាញជាភាសាបារាំង ដោយបានលើកអំពីអត្ថន័យនៃការតស៊ូរបស់ពួកយើងដើម្បីរំដោះជាតិ និង ពន្យល់ពីហេតុផលថា ហេតុអ្វីបានជាមេដឹកនាំអ្នកជាតិនិយមរបស់ពួកយើង សុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ការចូលរួមនោះ ជាមធ្យោបាយបង្រួបបង្រួមកម្លាំងទាំងអស់របស់ជាតិ ។ គូសន្ទនារបស់យើង ហាក់ដូចជាមានការយល់ដឹងនូវសភាពការណ៍នៃការតស៊ូរបស់យើង ។ យើងមានសេចក្តីសង្ឃឹមថា រដ្ឋាភិបាលម៉ាលីនឹងជួយគាំទ្រយើង ។

នៅពេលរសៀលដែលយើងហៀបនឹងចេញដំណើរចេញពីប្រទេសម៉ាលី ខ្ញុំឮសម្លេងទូរស័ព្ទរោទ៍ឡើង នៅក្នុងបន្ទប់សណ្ឋាគារ ។ ខ្ញុំស្គាល់សម្លេងអ្នកហៅនោះភ្លាមគឺយុវជនតូហ្គោឡេដែលជិះយន្តហោះជាមួយពួកយើងមកពីកូដឌីវ័រ ។ យុវជននេះបានស្រាវជ្រាវព័ត៌មាន ហើយដឹងថាពួកយើងស្នាក់នៅក្នុងសណ្ឋាគារនេះ ។ គេព្យាយាមធ្វើដំណើរចម្ងាយ ២០ គ.ម ដោយថ្មើរជើង ជួនកាលដោយសុំឡានគេជិះផងមករកពួកយើង ។ យុវជននេះ ចង់ពិនិត្យឲ្យពិតប្រាកដថាយើងមានសុវត្ថិភាពមែនឬទេ? ម្យ៉ាងទៀតយុជននេះ ក៏ចង់ចំណាយពេលចុងក្រោយជាមួយពួកយើងដែរ ។ ដូច្នេះយើងក៏នាំយុវជននោះ ទៅទទួលទានបាយល្ងាចទាំងអស់គ្នាម្តងទៀត ។

នៅយប់ចុងក្រោយនោះ មន្ត្រីពិធីការនាំពួកយើងទៅទស្សនារបាំប្រពៃណីម៉ាលីដែលគេថាសំដែងដោយបវរកញ្ញាម៉ាលី ។ បវរកញ្ញាទាំងនោះមែនទែនទៅ ជានារីខ្មៅមាឌធំជាត់ៗ ។ ពួកនាងៗរាំរបាំញាក់ចង្កេះ ។ ពេលចប់រាត្រីដើរកំសាន្តយុវជនតូហ្គោឡេ ក៏បានលាពួកយើងត្រឡប់ទៅទីកន្លែងរបស់គេវិញ ។ ព្រឹកស្អែកឡើង មន្ត្រីពិធីការក៏មកទទួលពួកយើងទៅព្រលានយន្តហោះ ដើម្បីត្រឡប់ទៅប្រទេសបារាំងវិញ ។ នៅតាមផ្លូវទៅព្រលានយន្តហោះ មន្ត្រីពិធីការក្រឡេកឃើញស្ត្រី

ម៉ាលីម្នាក់កំពុងដើរតាមចិញ្ចើមផ្លូវ ។ មន្ត្រីនោះ ប្រាប់ពួកយើងថា នាងជាប្អូនជីដូនមួយ ហើយចង់រួមដំណើរជាមួយពួកយើងទៅព្រលានយន្តហោះដែរ ព្រោះមិនដែលទៅទីនោះឡើយ ។ ដូច្នេះនៅទីបំផុត យើងក៏យល់ព្រមឲ្យនារីនោះមកជិះរថយន្តជាមួយពួកយើងនៅផ្នែកខាងក្រោយទាំងបីនាក់ ។ យើងបានបញ្ចប់បេសកកម្មរបស់យើងនៅទ្វីបអាហ្វ្រិក ប្រកបដោយមនោសញ្ចេតនាសប្បាយរីករាយ និង ពេញចិត្តចំពោះអ្វីដែលយើងបានធ្វើ ។ ក្នុងដំណើរនៅអាហ្វ្រិកនេះ ខ្ញុំមានអារម្មណ៍ទទួលបាននូវអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន ចំពោះមិត្តភាព និង បដិសណ្ឋារកិច្ចដ៏រាក់ទាក់ ដែលជនជាតិអាហ្វ្រិកបានផ្តល់ដល់ពួកយើង រួមទាំងរូបភាពនៃការបំពេញការងារបែបរំភើយសប្បាយៗ យ៉ាងស្រណុកសុខស្រួលនៃមន្ត្រីអាហ្វ្រិក ។

## តាលួតត្រូវគេលួចបាញ់សម្លាប់នៅជំរុំអំពិល

នៅចុងខែ តុលា ឆ្នាំ ១៩៨២ ខ្ញុំក៏ត្រឡប់ទៅកាន់ទីក្រុងបាងកកវិញ ។ នៅក្នុងពេលអវត្តមានរបស់ពួកយើង មានហេតុការណ៍មួយចំនួនបានកើតឡើងនៅក្នុងជួររ.ជ.រ.ប.ខ. ដែលជាសញ្ញាបង្ហាញការចេញដំណើរចុះឱនថយនៃចលនានេះ ។ តាមសេចក្តីប្រកាសព័ត៌មានមួយចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨២[160] មានអំពើឃាតកម្មមួយបានកើតឡើងនៅក្នុងមូលដ្ឋានយោធារ.ជ.រ.ប.ខ. នៅអំពិលទៅលើរូបលោក សៀម សំអុន ហៅតាលួត ប្រពន្ធ និង កងការពាររបស់គាត់ ។ តាលួតជាសមាជិកស្ថាបនិកម្នាក់នៃរ.ជ.រ.ប.ខ. និង ជាប្រធានជំរុំឬទ្ធីសែន ដែលជាជំរុំធំជាងគេមួយនៅជាប់ទល់ដែនខ្មែរ-ថៃ ។ មូលដ្ឋានយោធាអំពិល ស្ថិតនៅក្រោមការត្រួតត្រារបស់ឧត្តមសេនីយ ដៀន ដែល ដែលត្រូវទទួលការចោទប្រកាន់ថា ជាអ្នករៀបចំអំពើឃាតកម្មនេះ ។ ជាប្រតិកម្មភ្លាមៗនៃកងកម្លាំងគាំទ្រតាលួត ដែលមាន

160 Front National de Libération du Peuple Khmer, Communiqué de Presse, le 15 Octobre 1982.

លោក លឿង ស៊ីណាក់ ហៅ តាមុាំង ជាមេបញ្ជាការ និង លោក ខូ ឈា ជាមេបញ្ជាការរង បានវាយប្រហារបកតបតវិញយ៉ាងខ្លាំងក្លា ។ ដឹកនាំប្រយុទ្ធដោយមេបញ្ជាការរង ខូ ឈា កងកម្លាំងនេះបានធ្វើឲ្យបញ្ជាការដ្ឋានរបស់ឧត្តមសេនីយ ដៀន ដែល ខូចខាតជាដំណំ ទាំងអាយុជីវិតមនុស្ស ទាំងសម្ភារៈ ។

ខ្ញុំធ្លាប់រស់នៅក្នុងមូលដ្ឋានយោធាអំពិលមួយរយៈដែរ មុនពេលចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ។ នៅពេលនោះ ខ្ញុំមានភារកិច្ចទៅបង្រៀនវិជ្ជាគណនេយ្យដល់ក្រុមយោធារបស់រ.ជ.រ.ប.ខ ។ នៅក្នុងឱកាសនៃការស្នាក់អាស្រ័យរបស់ខ្ញុំនៅជុំរុំអំពិលនោះ អគ្គសេនាធិការកងទ័ពបានចាត់យុទ្ធជនម្នាក់ឈ្មោះ "យក្ស" ហៅ "អាយក្សៗ" ដោយសារគេមានមាឌធំ និង ខ្មៅ ដូចយក្សឲ្យមកថែទាំខ្ញុំដូចជាយាមរក្សាសន្តិសុខ រៀបចំម្ហូបអាហារ និង បោកខោអាវជាដើម ។ អាយក្សបានត្រូវស្លាប់ដោយសារការវាយប្រហារគ្នានោះ រីឯផ្ទះសំណាក់ដែលខ្ញុំធ្លាប់ស្នាក់នៅនោះក៏ឆេះអស់ដែរ ។ ខ្ញុំមានការសោកស្តាយខ្លាំងណាស់ ចំពោះការបាត់បង់ទាំងអាយុជីវិត និង ទ្រព្យសម្បត្តិទាំងនោះ ជាពិសេសចំពោះការបាត់បង់ជីវិតរបស់អាយក្ស ដែលខ្ញុំមានការស្រឡាញ់រាប់អានយ៉ាងខ្លាំង។ ការប្រយុទ្ធគ្នានេះកើតមានឡើង ម្ខាងក្រោមការដឹកនាំដោយមេបញ្ជាការដែលមានបទពិសោធន៍ នៅលើសមរភូមិផ្ទាល់ ម្ខាងទៀតដោយមេបញ្ជាការដែលធ្លាប់បញ្ជាកងទ័ពនៃរដ្ឋាភិបាល ។

ការបាត់បង់ជីវិតរបស់តាលួត បានធ្វើឲ្យកើតមានការសង្ស័យនៅក្នុងចំណោមយុទ្ធជន ដែលធ្លាប់ប្រកាសខ្លួនឯងថាជាកងទ័ពសេរីកាតាំងពីមុនពេលរ.ជ.រ.ប.ខ. ចាប់កំណើតមកម្ល៉េះគឺ ក្នុងក្រុមដែលដំបូងកាន់អាវុធប្រឆាំងខ្មែរក្រហម ក្រោយមកប្រឆាំងវៀតណាម ។ ពួកគេសង្ស័យថា ឧត្តមសេនីយ ដៀន ដែល មានផែនការកំចាត់អ្នកតស៊ូចាស់ៗទាំងនោះម្តងមួយៗ ដើម្បីដាក់ជំនួសដោយមនុស្សថ្មីជាជំនិតរបស់គាត់វិញ និង ដើម្បីធានាក្តាប់អំណាចយោធាទាំងមូល ។ ឧប្បត្តិ

ហេតុនេះ បានបង្ខំឲ្យលោកតា សឺន សាន បញ្ឈប់បេសកកម្មនៅអង្គការសហប្រជាជាតិ ហើយធ្វើដំណើរជាបន្ទាន់ទៅទីក្រុងបាងកក រួចបង្ហួសដំណើរទៅកន្លែងកើតហេតុ ។ នៅថ្ងៃទី ១៥ តុលា ១៩៨២ លោកតាប្រធាន បានទៅធ្វើជាអធិបតីក្នុងពិធីបុណ្យបង្សុកូលបញ្ជូនកុសល ដល់អ្នកស្លាប់ទាំងអស់នោះ ។ នៅពេលនោះ លោកតា សឺន សាន ក៏បានជួបជាមួយមន្ត្រីសំខាន់ៗរបស់រ.ជ.រ.ប.ខ. មានឧត្តមសេនីយ សក់ ស៊ុតសាខន លោក ហ៊ីង គន្ធុន តាមុំាង ឬ លឿង ស៊ីណាក់ លោក ឡាយ ខែក ដើម្បីស្តាប់របាយការណ៍របស់អស់លោកទាំងនោះ ។ តាមុំាង ឬ លឿង ស៊ីណាក់ ជាមេបញ្ជាការតំបន់ ២០១ ដែលមានលោក ខូ ឈា ជាមេបញ្ជាការរង និង លោក ឡាយ ខែក ជានាយសេនាធិការ ។ តាមុំាង និង តាលួត ជាអ្នកដឹកនាំកំពូលនៃចលនាតស៊ូប្រឆាំងខ្មែរក្រហមមួយ ដែលមានឈ្មោះថា "ចលនា នេនរោង" ។ ចលនានេនរោង ជាចលនាស្នូលមួយ ដែលចូលរួមបង្កើត រ.ជ.រ.ប.ខ. ។

## បង្កើតគណកម្មាធិការ ជំនួសលោក ដៀន ដែល

ដើម្បីបន្ធូរភាពតានតឹង លោកតាប្រធាន បានសម្រេចដកឧត្តមសេនីយ ដៀន ដែល ចេញពីតំណែងនាយអគ្គសេនាធិការកងទ័ព ។ ដើម្បីជំនួស លោកតាបានតែងតាំងគណៈកម្មាធិការបណ្តោះអាសន្នមួយឲ្យដឹកនាំកងទ័ព ក្នុងនោះមាន ឧត្តមសេនីយ សក់ ស៊ុតសាខន ជាប្រធាន ឧត្តមសេនីយ ថាច់ រ៉េង ជាសមាជិក លោក ជា ឈុត សមាជិក និង លោក ហ៊ីង គន្ធុន សមាជិក[161] ។ ឧត្តមសេនីយ ថាច់ រ៉េង ធ្លាប់កាន់តំណែងជាមេបញ្ជាការនៃកងកម្លាំងពិសេស (Special Forces) នៅសម័យ លន់ នល់ ។ លោក ថាច់ រ៉េង បានមកដល់ទីក្រុងបាងកក

[161] សេចក្តីអំពាវនាវរបស់ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អគ្គមេបញ្ជាការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ អំពិល ថ្ងៃទី ១៨ ខែ តុលា ១៩៨២ ។

កាលពីខែ កញ្ញា ១៩៨២ ។ កាលខ្ញុំនៅឯប្រទេសបារាំង លោក សាយ បូរាណ ធ្លាប់និយាយប្រាប់ខ្ញុំ ថាលោក ថាច់ រ៉េង ជាទាហានមួយរូប ទោះជាពាក់ស័ក្តិធំក៏ដោយ ក៏នៅព្យាយាមទៅរៀននៅមហាវិទ្យាល័យច្បាប់ រហូតទទួលបាននូវសញ្ញាប័ត្របរិញ្ញាបត្រច្បាប់ទៀតផង ។ ដោយសារគាត់មានជំនាញប្រឆាំងទ័ពព្រៃ ឧត្តមសេនីយ ថាច់ រ៉េង ជាអ្នកគាំទ្រទ្រឹស្តីធ្វើសង្គ្រាមទ័ពព្រៃ ។ សមាជិកម្នាក់ទៀតគឺលោក ជា ឈុត (ឈ្មោះផ្លូវការ ជា រិទ្ធីឈុត) ជាប្រធានជំរុំដ៏ធំទី ២ នៅទល់ដែនគឺជំរុំនងចាន់ ។ លោក ជា ឈុត មិនធ្លាប់ធ្វើជាមេបញ្ជាការយោធាទេ កាលពីសម័យមុន តែគាត់ជាមិត្តរួមអាវុធជាមួយតាម៉ាំង និង តាលួត ។ សមាសភាពក្នុងគណៈកម្មាធិការនេះ ដែលមានឈ្មោះថា "គណៈកម្មាធិការបណ្តោះអាសន្នរបស់អគ្គសេនាធិការនៃរ.ជ.រ.ប.ខ." មានតុល្យភាពល្អរវាងនាយទាហានអាជីព និង អ្នកតស៊ូចាស់ ។ តុល្យភាពមួយ ដែលលោកតាប្រធានចង់បានជាយូរមកហើយ ។ ម្យ៉ាងទៀត លោកតាចង់ឃើញកងទ័ពរ.ជ.រ.ប.ខ. សកម្មជាងមុន និង មុតស្រួចនៅទីលានប្រយុទ្ធ ជ្រៀតចូលឲ្យបានជ្រៅទៅក្នុងទឹកដីខ្មែរ ឲ្យស្របតាមនយោបាយ និង ចក្ខុវិស័យនៃការតស៊ូរំដោះជាតិ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ឧត្តមសេនីយ ដៀន ដែល នៅតែរក្សាឥទ្ធិពលរបស់គាត់បាននៅក្នុងគណៈកម្មាធិការថ្មីនេះ តាមរយៈលោក ហ៊ីង គន្ធុន ដែលជាមិត្តភក្តិរបស់គាត់ ។ សូមបញ្ជាក់ថា នៅពេល ដែលលោកតា សឺន សាន ចុះទៅធ្វើបុណ្យបញ្ចូនកុសលបន្ទាន់នៅជំរុំអំពិល នាថ្ងៃទី ១៥ តុលា ១៩៨២ នោះ លោកឧត្តមសេនីយ ដៀន ដែល ពុំបានមកជួបលោកតាទេ ។

# ការបែកបាក់គ្នាលើកទីមួយ ក្នុងជួរ រ.ជ.រ.ប.ខ.

នៅថ្ងៃទី ១៧ តុលា ឧត្តមសេនីយ ដៀន ដែល បានសរសេរសំបុត្រផ្ទាល់ដៃផ្ញើជូនលោកតាប្រធានដែលមានសេចក្តីដូចតទៅៈ[162] "ខ្ញុំបាទសូមអភ័យទោសដោយមិនបានមកទទួល និង ជួបលោកប្រធាន មកពីខ្ញុំបាទមិនស្រួលខ្លួន មិនស្រួលចិត្ត ។ ក្នុងឱកាសដ៏អាប់អួរនេះ ខ្ញុំបាទសូមលោកប្រធានមេត្តាយោគយល់ដល់រូបខ្ញុំបាទ ឲ្យបានសំរាកខ្លះមួយរយៈសិន ។ ខ្ញុំបាទសន្យាជួយសម្របសម្រួលកិច្ចការរបស់គណៈកម្មាធិការ ដែលលោកប្រធាន និង អស់លោកតែងតាំងឲ្យអស់ពីសមត្ថភាព និង លទ្ធភាព" ។ អវត្តមានរបស់ឧត្តមសេនីយ ដៀន ដែល នៅថ្ងៃទី ១៥ តុលា ១៩៨២ ក្នុងឱកាសបុណ្យបង្សុកូលជូនជនរងគ្រោះ ជាសញ្ញាបង្ហាញពីការបែកបាក់មួយនៅក្នុងជួរកងទ័ពរ.ជ.រ.ប.ខ. ។ នៅថ្ងៃទី ១៩ តុលា ១៩៨២ ឧត្តមសេនីយ ដៀន ដែល បានផ្ញើលិខិតសរសេរផ្ទាល់ដៃជាភាសាបារាំងលាយឡំជាមួយភាសាខ្មែរជូនលោកតា សឺន សាន ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់គាត់ក្នុងការធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ[163] ។ ក្នុងលិខិតនោះ លោកឧត្តមសេនីយរូបនេះសរសេរថាៈ "ខ្ញុំបាទមិនលះបង់ការប្រយុទ្ធដើម្បី Cette noble Cause (បុព្វហេតុដ៏ឧត្តុង្គឧត្តមនេះ) ហើយសន្យាជួយឲ្យអស់ពីសមត្ថភាព ។ ខ្ញុំបាទព្រមធ្វើពលីកម្មដកខ្លួនពេលនេះ ក៏ដើម្បីប្រយោជន៍ ដើម្បីអនាគតដ៏ប្រសើររបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរយើង សូមមេត្តាជួយធ្វើយ៉ាងណាកុំឲ្យពលីកម្មរបស់ខ្ញុំបាទទៅជាឥតន័យ" ។ លោកឧត្តមសេនីយសំដែងមតិថា ការសម្រេចចិត្តរបស់លោកតាប្រធានឲ្យគាត់ឈប់ពីមុខតំណែងនេះ ដោយសារតែជឿ

[162] ដៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 17-10-82 ។

[163] ដៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 19-10-82 ។

ថា ប្រទេសផ្តល់ជំនួយយល់ថាឧត្តមសេនីយ ដៀន ដែល មានកំហុស ហើយគេនឹងផ្តល់ជំនួយនៅពេលមានការដោះដូរនោះ ។ ម្យ៉ាងទៀត លោក ដៀន ដែល ក៏បានផ្តាំផ្ញើផងដែរថា ប្រសិនបើមានមធ្យោបាយកងទ័ពរ.ជ.រ.ប.ខ. អាចបំពេញបេសកកម្មបានយ៉ាងប្រសើរ ។ ជាមួយគ្នានេះ លោកឧត្តមសេនីយ បានដាស់តឿនលោកតាប្រធានឲ្យមានការប្រុងប្រយ័ត្នក្នុងការចែកចាយអាវុធ ដោយពិនិត្យឲ្យច្បាស់លាស់ថា អ្នកណាខ្លះដែលច្បាស់លាស់ដាច់ខាត "ជាមួយរណសិរ្សយើង" ។ តាមការយល់ឃើញរបស់លោក ដៀន ដែល ការដករូបគាត់ចេញពីតំណែងនាយអគ្គសេនាធិការជាការគាបសង្កត់របស់បរទេស[164] ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍ឃាតកម្មលើរូបតាលួត នៅថ្ងៃទី ១១ តុលា ១៩៨២ នោះ ជាមូលហេតុគ្រប់គ្រាន់មួយសម្រាប់លោកតា សឺន សាន ឲ្យសម្រេចដកលោក ដៀន ដែល ព្រោះលោកតាប្រធានយល់ថាលោកឧត្តមសេនីយរូបនេះ ជាមេក្លោងមួយដែលនាំឲ្យមានការបែកបាក់នៅក្នុងចលនា ។

តាមពិតទៅ តាំងពីឆ្នាំ ១៩៧៩ រហូតមក លោកឧត្តមសេនីយ ដៀន ដែល បានពង្រឹងអំណាចរបស់លោក ជានាយអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ដោយសារការបង្កើតអង្គភាពថ្មីៗដែលមានភក្តីភាពចំពោះលោកឧត្តមសេនីយផ្ទាល់ ។ ដោយសារមានអំណាចក្នុងការបែងចែកគ្រឿងអាវុធយុទ្ធភ័ណ្ឌ និង ភស្តុភាក្នុងជួរកងទ័ព លោកឧត្តមសេនីយអាចផ្តល់ការយោគយល់ ផ្តល់ការអនុគ្រោះដល់មេបញ្ជាការណាដែលជិតដិត ឬ មានភក្តីភាពជាងអ្នកឯទៀត ។ លើសពីនេះទៅទៀត ដោយសារលោកឧត្តមសេនីយ ដៀន ដែល មានទំនាក់ទំនងជិតស្និទ្ធជាមួយលោក ហ៊ីង គន្ធុន លោក នាង ជិនហាន និង លោក ហ្គាហ្វា លោកមេទ័ពរូបនេះអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ការដឹកនាំរបស់លោកតា

[164] ដៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 19-10-82, op. cit. ។

សឺន សាន ។ ក៏ប៉ុន្តែ ដោយព្រឹត្តិការណ៍នៃឃាតកម្មលើរូបតាលួត មានសភាពធ្ងន់ធ្ងរពេកនោះ ទើបមិត្តជិតស្និទ្ធរបស់លោក ដៀន ដែល ខាងលើបានដូរគោលជំហរក្នុងកលយុទ្ធមួយ មកគាំទ្រសេចក្តីសម្រេចដកមុខតំណែងនេះវិញ ។

ម្យ៉ាងទៀត ក្រុមអ្នកគាំទ្រលោកតា សឺន សាន បានចោទលោក ដៀន ដែល ថាក្នុងឋានៈជាមេដឹកនាំម្នាក់ លោកឧត្តមសេនីយមានជីវភាពរស់នៅខ្ពស់ដាច់ឆ្ងាយពេកពីជនភៀសខ្លួន ឬ ពីយុទ្ធជនធម្មតានៃ ក.ជ.រ.ប.ខ. ។ តាមពិតទៅការរស់នៅតាមជំរុំនៅទល់ដែន មិនមែនជាការរស់នៅបែបធម្មតាឡើយ ។ លោកឧត្តមសេនីយ ដៀន ដែល ចូលចិត្តពិសាស្រា ជាពិសេសស្រាវីស្គី ដែលផ្ទុយទៅវិញលោកតា សឺន សាន បានទូន្មានឲ្យកាន់សិលប្រាំតាមធម្មព្រះពុទ្ធ និង ណែនាំឲ្យរស់នៅក្នុងភាពសាមញ្ញ ។

ការផ្លាស់ប្តូរថ្នាក់ដឹកនាំកងទ័ពនេះ បានធ្វើឲ្យមានតុល្យភាពឡើងវិញរវាងកងកម្លាំងទាំងអស់ ទាំងថ្មី ទាំងចាស់ ទាំងអ្នកតស៊ូដែលឡើងកាន់អាវុធតស៊ូដោយខ្លួនឯង ទាំងនាយទាហាន ដែលធ្លាប់បញ្ជាកងទ័ពនាសម័យសាធារណរដ្ឋ ។ លោកតា សឺន សាន នឹកសង្ឃឹមថាថ្នាក់ដឹកនាំថ្មីនៃកងទ័ព និង ជួយជំរុញឲ្យមានការឯកភាព និង ការកែប្រែក្បួនប្រយុទ្ធ ពីបែបកងទ័ពស្រុក ឲ្យទៅជាកលយុទ្ធនៃកងទ័ពព្រៃវិញ ។ នៅជំនាន់នោះ លោកតា សឺន សាន តែងស្តាប់ការបកស្រាយដដែលៗរបស់លោកឧត្តមសេនីយ ថាច់ រ៉េង អំពីគុណសម្បត្តិនៃទ្រឹស្តី "អារញ្ញសង្គ្រាម" ថាជាវិធីដ៏ល្អបំផុតក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាម ។ ក៏ប៉ុន្តែទោះបីជាគាត់សុខចិត្តដកខ្លួនថយ ឈប់កាន់តំណែងជានាយអគ្គសេនាធិការយ៉ាងណាក៏ដោយ ក៏លោក ដៀន ដែល បន្តវត្តមានរស់នៅក្នុងមូលដ្ឋានយោធានេះតទៅទៀត ។ វត្តមាននេះ ធ្វើឲ្យការងាររបស់គណៈកម្មាធិការបណ្តោះអាសន្នអគ្គសេនាធិការមានការលំបាក មិនអាចប្រព្រឹត្តិទៅដោយស្រួលៗឡើយ ។

# នគរបាលថៃ លបចុះមកឆែឆេរទីស្នាក់ការរបស់យើង

នៅខែ តុលា ១៩៨២ នោះ ក្នុងរយៈពេលដែលពួកខ្ញុំកំពុងបំពេញបេសកកម្មនៅក្រៅប្រទេសមានឧបទ្ទវហេតុមួយទៀតបានកើតឡើង ។ នគរបាលថៃ បានចុះមកឆែកឆេរទីស្នាក់ការរបស់យើងនៅក្រុងបាងកក ។ ពួកនគរបាលទាំងនោះពុំបានដឹងទេថា ពួកយើងជាចលនាតស៊ូខ្មែរដែលបានទទួលការអនុញ្ញាតពីកងយោធាថៃឲ្យមកដឹកនាំការតស៊ូនៅចំកណ្តាលរាជធានីបាងកក ។ ហេតុការណ៍នោះបានកើតឡើង នៅពេលដែល សុវណ្ណ យុវជនពិកាជើងមួយបានជួលរថតាក់ស៊ី "តុកតុក" ដឹកសុទ្ធតែវិទ្យុទាក់ទង ថកគី វ៉កគី(Talky-Walky)ពីហាងមួយ យកមកទុកនៅទីស្នាក់ការរបស់យើង ។ នគរបាលថៃ ហៅឲ្យរថតុកតុកឈប់ ដើម្បីឆែកឆេរតែរកមិនឃើញមានអ្វីដែលខុសច្បាប់ឡើយ ។ ក៏ប៉ុន្តែ នគរបាលរូបនោះសង្ស័យថាប្រហែលជាគេកំពុងរកឃើញបណ្តាញរត់អាភៀនមួយដ៏ធំ ដូច្នេះគេក៏រាយការណ៍ទៅមេរបស់គេ ។ ក្រុមនគរបាល ក៏តាមដានដឹងពីទីកន្លែងដែលពួកយើងស្នាក់នៅ ។ ទាំងយប់ ក្រុមនគរបាលដាក់រាយគ្នាព័ទ្ធទីស្នាក់ការរបស់យើង ដោយស្ងាត់ៗគ្មាននរណាម្នាក់ដឹងឡើយ ។ ព្រឹកឡើង ពេលហៀបភ្លឺក្រុមនគរបាលប្រដាប់អាវុធលោតផ្លោះរបងចូលទៅក្នុងបរិវេណនៃបវេសនដ្ឋានរបស់យើង ហើយរំពេចនោះពួកគេបានចូលទៅគ្រប់បន្ទប់ និង ត្រួតត្រាទ្វារចេញចូលទាំងអស់បានទាំងស្រុង ។ មិនយូរប៉ុន្មាន ឧត្តមសេនីយនគរបាលថៃបានមកដល់ទីកន្លែង ជាមួយនឹងអ្នកយកព័ត៌មានទូរទស្សន៍ថៃផង ។ ពួកគេសង្ឃឹមថា នឹងរកឃើញនូវក្រុមអ្នករត់អាភៀនមួយដ៏ធំនៅក្នុងទីក្រុងបាងកក ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញគេរកមិនឃើញនូវអ្វីដែលគួរឲ្យសង្ស័យនោះទេ ។ ពួកនគរបាលរកឃើញតែទីបញ្ជាការនៃចលនាតស៊ូខ្មែរដ៏ធំមួយ ។ ពួកគេធ្វើការឆែកឆេរមិនបានយូរប៉ុន្មានទេ ដោយសារមន្ត្រីរបស់រ.ជ.រ.ប.ខ.

បានទាក់ទងជាបន្ទាន់ទៅមន្ត្រីទំនាក់ទំនងនៃក្រុមយោធាថៃគឺ លោក ម៉ុល និង លោកវរសេនីយឯក ស៊ុជិន្តា ដែលជាម្ចាស់ផ្ទះជួលឲ្យពួកយើង ហើយដែលបានធ្វើអន្តរាគមន៍ភ្លាមៗ ទៅក្រុមនគរបាលថៃ ។ (សូមបញ្ជាក់ថា លោកវរសេនីយ ស៊ុជិន្តា ពេលក្រោយមក ក៏ឡើងសក្តិជាឧត្តមសេនីយ ស៊ុជិន្តា ក្រាប្រយង្គ ដែលបានចូលរួមដឹកនាំរដ្ឋប្រហារមួយទម្លាក់លោកនាយករដ្ឋមន្ត្រី ឆាទិឆាយ ឈុនហាវ៉ាន់ ពីតំណែងនៅឆ្នាំ ១៩៩១ រួចក៏បានឡើងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ នៅឆ្នាំ ១៩៩២)ឧបទ្ទវហេតុនេះ ក៏ត្រូវបញ្ចប់ភ្លាមៗនៅថ្ងៃនោះ ។ ក៏ប៉ុន្តែបណ្តាញព័ត៌មានថៃ ក៏បានផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវការសម្ងាត់ស្តីពីទីតាំងនៃទីបញ្ជាការចលនាតស៊ូខ្មែរ ដែលជាការប៉ះពាល់យ៉ាងខ្លាំងដល់សុវត្ថិភាពរបស់ពួកយើង ។ នៅទីបំផុត កងយោធាថៃបានសម្រេចជួលទីស្នាក់ការថ្មីឲ្យពួកយើង ដែលស្ថិតនៅក្នុងតំបន់បាងខេន នាជាយក្រុងបាងកក ។

## យើងរើមកនៅម៉ាយ៉ាឡាប់

ផ្ទះថ្មីរបស់ពួកយើងជាផ្ទះរបស់អតីតរដ្ឋមន្ត្រី និង នាយអគ្គសេនាធិការកងទ័ពថៃឈ្មោះលោកឧត្តមសេនីយ "ម៉ាយ៉ាឡាប់" ។ ផ្ទះនោះ ជាភូមិគ្រឹះមួយក្នុងចំណោមភូមិគ្រឹះបី ដែលស្ថិតនៅក្នុងបរិវេណតែមួយនៃគ្រួសារ "ម៉ាយ៉ាឡាប់" នៅដាច់ឆ្ងាយពីអ្នកស្រុកឯទៀត ។ អាជ្ញាធរយោធាថៃតម្រូវឲ្យយើងរើផ្ទះនៅថ្ងៃទី ១ វិច្ឆិកា ១៩៨២ ។ តាមធម្មតា នៅផ្ទះថ្មីនេះខ្ញុំត្រូវទៅរស់នៅក្នុងបន្ទប់ធំរួមមួយជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន លោកឧត្តមសេនីយ ថាច់ រ៉េង និង បងប៉ែន ថាល់ ។ ដូចមុនដែរ យើងត្រូវរើរបស់របរយើងម្នាក់ៗយកទៅជាមួយឯផ្ទះថ្មី ។ របស់របរទាំងនោះ គ្មានអ្វីប្លែកទេគឺ ខោអាវ ពូក រនាប(ព្រោះពួកយើងគ្មានគ្រែដេក

ទេ) និង ទូកៅស៊ូផ្លាស្ទិកតែប៉ុណ្ណោះ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន មានបុព្វសិទ្ធលើសយើងបន្តិច ព្រោះមានគ្រែដែកបត់មួយ ។

## ខ្ញុំចូលធ្វើការក្នុងកងទ័ព

ដោយសារមានការផ្លាស់ប្តូរបញ្ជាការយោធា ខ្ញុំក៏ត្រូវទទួលភារកិច្ចថ្មីនៅមូលដ្ឋានយោធាអំពិល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ឧត្តមសេនីយ ថាច់ រ៉េង បានស្នើឲ្យខ្ញុំធ្វើការជាមួយពួកគាត់ ។ ខ្ញុំក៏យល់ព្រមតាម ។ ដូច្នេះ នៅថ្ងៃទី ៧ វិច្ឆិកា ១៩៨២ សមាជិកទាំងអស់នៃគណៈកម្មាធិការបណ្តោះអាសន្នអគ្គសេនាធិការ បានសម្រេចតែងតាំងឲ្យខ្ញុំបានជាលេខាធិការនៃគណៈកម្មាធិការនេះ[165]។

ដោយខ្ញុំត្រូវចេញទៅរស់នៅឯជំរុំអំពិលភ្លាមៗបែបនោះ ខ្ញុំក៏អត់បានរស់នៅឲ្យបានយូរបន្តិចក្នុងផ្ទះថ្មីដែលមានម៉ាស៊ីនត្រជាក់តទៅទៀតឡើយ ។ ជំរុំអំពិលមិនមែនគ្រាន់តែជាមូលដ្ឋានយោធាទេ តែក៏ជាទីជ្រកកោននៃជនភៀសខ្លួនខ្មែររាប់ពាន់នាក់ដែរ ។ ជនរួមជាតិទាំងនោះ ដែលស្វែងរកសេរីភាព មានជំនឿថា អំពិលជាទីកន្លែងដែលគេអាចទទួល និង លើកតំកើងនូវតម្លៃនៃសិទ្ធិមនុស្ស ។ តាមពិតទៅ ជំរុំនេះស្ថិតនៅលើទឹកដីខ្មែរជាប់ និង ព្រំប្រទល់ជាមួយប្រទេសថៃ ក្នុងខេត្តបន្ទាយមានជ័យ ។ ជនភៀសខ្លួនខ្លះ សង់ទីជម្រកតែប៉ុន្មានម៉ែត្រប៉ុណ្ណោះ ពីទល់ដែន ដែលកំណត់បានដោយសារអូរតូចមួយ ។ មូលដ្ឋានអំពិល បានត្រូវរៀបចំឡើងជាភូមិសម្រាប់អ្នកស្រុករស់នៅផង ជាទីតាំងយោធាផង ។ បន្ទាយយោធា នៅដាច់ដោយឡែកពីប្រជាពលរដ្ឋស៊ីវិល លើកលែងតែក្រុមគ្រួសារមន្ត្រីសំខាន់ៗ

[165] សក់ ស៊ុតសាខន, សេចក្តីសម្រេចនៃគណៈកម្មាធិការបណ្តោះអាសន្ននៃអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ, អំពិល, ថ្ងៃទី៨ ខែ វិច្ឆិកា ១៩៨២ ។

និង នាយទាហាន ។ នៅអគ្គសេនាធិការដ្ឋាននោះ មានក្រុមអាវុធហត្ថ ក្នុងឯកសណ្ឋានប៉ារ៉ា ធ្វើការយាមកាមយ៉ាងហ្មត់ចត់ ។

អ្នកស្រុកនាំគ្នាធ្វើផ្ទះ ភាគច្រើនពី ឫស្សី និង ស្លឹក ។ មូលដ្ឋានអំពិលនេះ មានការរៀបចំជាផ្លូវថ្នល់ខ្វាត់ខ្វែង មានប្រឡាយ និង លូទឹក ព្រមទាំងបង្គន់អនាម័យផង ។ ទីកន្លែងធ្វើការ ទាំងស៊ីវិល ទាំងទាហាន មានការថែទាំយ៉ាងស្អាតសមរម្យ មានទីធ្លាធំទូលាយ អាចធ្វើការប្រជុំមីទ្ទីងសំខាន់ៗសម្រាប់មនុស្សរាប់ពាន់នាក់បាន ។ មុនទៅដល់អគ្គសេនាធិការដ្ឋាន ដែលជាទីស្នាក់នៅរបស់លោកឧត្តមសេនីយ ដៀន ដែល គេឃើញមានសំណង់ក្នុងបរិវេណធំទូលាយ ដែលមានទាំងទីលានហ្វឹកហាត់ ឬ ជាកីឡាដ្ឋានមួយផងនោះគឺ ជាសាលានាយទាហាននៃកងទ័ព រ.ជ.រ.ប.ខ. ។ សាលានេះ ជ្រើសរើសយុវជនមកអប់រំហ្វឹកហ្វឺនតាមកម្មវិធីអប់រំនាយទាហានសម័យមុនសង្គ្រាម ។ អ្នកស្រុកនៅក្នុងមូលដ្ឋាននេះ បានទទួលម្ហូបអាហារ ការថែទាំសុខភាព និង ជំនួយផ្នែកអប់រំកំរិតបឋមសិក្សាពីអង្គការសហប្រជាជាតិ និង អង្គការអន្តរជាតិក្រៅរដ្ឋាភិបាលមួយចំនួន ។ អ្នកដឹកនាំរ.ជ.រ.ប.ខ. ជាពិសេស លោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ថុន មានបំណងយកមូលដ្ឋានអំពិលនេះជាទីតាំងបង្ហាញអំពីគំរូនៃការគ្រប់គ្រងផ្នែករដ្ឋបាល នាពេលអនាគត នៅពេលប្រទេសកម្ពុជាបានត្រូវរំដោះទាំងស្រុង ។

ចាប់តាំងពីខ្ញុំចាកចេញពីប្រទេសបារាំង និង បានចូលរួមតស៊ូផ្ទាល់ជាមួយយុទ្ធជន ខ្ញុំធ្លាប់មកស្នាក់នៅជាច្រើនលើករួចទៅហើយ នៅក្នុងមូលដ្ឋានអំពិលនេះ ។ ការស្នាក់នៅរបស់ខ្ញុំ នៅអំពិលលើកចុងក្រោយគឺ តែប៉ុន្មានសប្តាហ៍ មុនពេលខ្ញុំចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ។ ពេលនោះ ខ្ញុំមានភារកិច្ចមកបង្រៀនវិជ្ជាគណនេយ្យដល់ទាហាន រ.ជ.រ.ប.ខ. ។ លើកនេះ ពេលខ្ញុំទៅដល់លោកឧត្តមសេនីយ ដៀន ដែល ឈប់ស្នាក់នៅក្នុងបរិវេណអគ្គសេនាធិការទៀតហើយ ។

គាត់ទើបសង់ផ្ទះថ្មីរបស់គាត់អំពីឈើ ដែលនៅចំពីមុខមានសួនផ្កាកូឡាបផង ។ បើប្រៀបធៀបទៅនឹងប្រជាពលរដ្ឋធម្មតា ផ្ទះលោកឧត្តមសេនីយអាចចាត់ទុកជាភូមិគ្រិះមួយបាន ដែលល្អប្លែក និង ប្រកបដោយសម្ភារៈល្អប្រណិត ។ ចាប់តាំងពីលាឈប់ពីមុខតំណែងនាយអគ្គសេនាធិការ លោកឧត្តមសេនីយចំណាយពេលភាគច្រើនរបស់គាត់ ថែទាំផ្កាកូឡាបដែលមានច្រើនប្រភេទនៅក្នុងសួន ។

នៅក្នុងបរិវេណអគ្គសេនាធិការដ្ឋាន មានផ្ទះសំណាក់មួយចំនួននៅហូរហែជាប់នឹងជាយរបង ។ នៅចំកណ្ដាល មានរោងធំមួយ ដែលអាចជាកន្លែងទទួលភ្ញៀវសំខាន់ៗ ឬ ជាកន្លែងទទួលទានអាហាររួមគ្នាផងក៏បាន ។ នៅខាងមុខរោងមានស្រះធំមួយដែលចំកណ្ដាលស្រះមានក្បូស (Kiosk) មួយ ដែលសង់តាមរចនាបថបូរាណ ។ ពេលណាយើងចូលទៅក្នុងក្បូសនោះ យើងអាចទទួលបាននូវម្លប់ត្រជាក់ ជាពិសេសខ្យល់ត្រជាក់ដែលអាចភាយចេញពីផ្ទៃទឹកស្រះនៅខាងក្រោម ។ ផ្ទះសំណាក់របស់ខ្ញុំមានសភាពថ្មោងថ្មី ដែលទើបតែធ្វើរួចហើយៗមានទំហំធំជាងផ្ទះឯទៀត ព្រោះផ្ទះសំណាក់នេះ មិនមែនសម្រាប់តែខ្ញុំម្នាក់ឯងនោះទេ តែសម្រាប់លោកឧត្តមសេនីយ ថាច់ រ៉េង និង លោកវរសេនីយ ចក់ បូរី ផង ។ ដើម្បីជួយថែរក្សាសុវត្ថិភាពរបស់ខ្ញុំៗត្រូវបានទទួលអង្គរក្សម្នាក់ឈ្មោះ ចំរើន ដែលជាខ្មែរមកពីកម្ពុជាក្រោម ។ ចំរើនធ្លាប់បំរើកងទ័ពវៀតណាមខាងត្បូងមានឋានៈជាអនុសេនីយឯក (សក្តិបី) នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ។ ចំរើនមានភារកិច្ចខាងម្ហូបអាហារ និង សំអាតសម្លៀកបំពាក់របស់ខ្ញុំ ក្រៅពីការងារផ្នែកសន្តិសុខ ។ ចំរើននិយាយភាសាវៀតណាមស្ទាត់ជំនាញណាស់ ហើយចំរើន និយាយភាសាខ្មែរដោយមានសំនៀងកម្ពុជាក្រោម ។ ខ្ញុំនៅចាំបានថា នៅពេលមួយនោះ ដែលខ្ញុំត្រូវទៅធ្វើសម្ភាសន៍ជនជាប់ឃុំឃាំងសញ្ជាតិវៀតណាមម្នាក់ ខ្ញុំបានចាត់ឲ្យចំរើនជាអ្នកបកប្រែភាសាពីភាសាវៀតណាមមកភាសាខ្មែរ ។ ពេលខ្ញុំសួរជនជាតិវៀតណាមជា

ភាសាខ្មែរ ចំរើន បកប្រែជាវៀតណាមបានល្អណាស់ តែពេលជនជាតិវៀតណាមឆ្លើយជាភាសាវៀតណាមមកខ្ញុំនោះ ចំរើនក៏គ្រាន់តែនិយាយភាសាវៀតណាមមកខ្ញុំវិញតែប៉ុណ្ណោះ ពុំបានបកជាភាសាខ្មែរមកខ្ញុំវិញឡើយ ។ តាំងពីពេលនោះមក ខ្ញុំក៏ឈប់យក ចំរើន ជាអ្នកបកប្រែឲ្យខ្ញុំតទៅទៀត ។ ក្រោយមក ចំរើន ក៏ត្រូវផ្លាស់ឲ្យទៅ នៅជាមួយវរសេនីយ ចក់ បូរី ។ ច្រើនឆ្នាំក្រោយមក ចំរើន ក៏ទទួលទិដ្ឋាការឲ្យទៅរស់នៅសហរដ្ឋអាមេរិក ។ នៅពេលដែល ចំរើន បានផ្លាស់ចេញទៅ ខ្ញុំបានទទួលអង្គរក្សថ្មីឈ្មោះ ស្រី នួន ដែលធ្លាប់ធ្វើទាហាននៃកងទ័ពពិសេសរបស់លោក ថាច់ រ៉េង កាលគាត់នៅធ្វើមេបញ្ជាការកងទ័ពពិសេស (Special Force) ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏យក ស្រី នួន មកធ្វើជាអង្គរក្សរបស់ខ្ញុំរហូតដល់គាត់ចូលនិវត្ត ។

## ក្រុមមេទ័ពថ្មី ខំបញ្ចេញថ្វីដៃ

ក្រោមការដឹកនាំរបស់គណៈកម្មាធិការអគ្គសេនាធិការថ្មី រ.ជ.រ.ប.ខ.ហាក់ដូចជាបានផ្លាស់ប្តូរទស្សនវិស័យយោធាពីរបៀបប្រយុទ្ធបែបទ័ពស្រុក មកជារបៀបទ័ពព្រៃវិញ ។ វាវៈបញ្ជា បានតម្រង់បេសកកម្មប្រយុទ្ធឆ្ពោះទៅ៖ ១.គាបសង្កត់ដើម្បីឲ្យមានការដកកងទ័ពវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជា ២. កំចាត់ជនក្បត់ទាំងអស់ដែលបំផ្លាញប្រទេស បំផ្លាញប្រពៃណី និង ទំនៀមទម្លាប់ជាតិ ហើយដែលចង់ដាក់ប្រទេសក្នុងរបបកុម្មុយនីស្ត ៣. អភិវឌ្ឍនធនធាន និង ស្ថាប័នចាំបាច់ និង សំខាន់ៗទាំងឡាយ ដើម្បីទ្រទ្រង់ឯករាជ្យជាតិ យុត្តិធម៌សង្គម និង សុខុមាលភាពរបស់ប្រជារាស្ត្រ ។ គោលដៅសំខាន់នៃរ.ជ.រ.ប.ខ.គឺ ឆ្ពោះទៅកាត់ផ្តាច់ខ្សែបណ្តាញគមនាគមន៍ និង ភស្តុភារបស់កងទ័ពវៀតណាម ធ្វើឲ្យទីតាំងនៃកងទ័ពនេះនៅឯកោផង និង ត្រូវកំទេចផង ។

តាមពិតទៅ អាជ្ញាធរថៃ ជាពិសេសលោកឧត្តមសេនីយ ឆាវលិត បានផ្តល់យោបល់ដល់កងកម្លាំងខ្មែរអ្នកជាតិនិយមមិនមែនកុម្មុយនីស្ត (ក.ជ.រ.ប.ខ. និងកងទ័ពសីហនុនិយម) ឲ្យត្រៀមរៀបចំខ្លួនទប់ទល់នឹងការវាយប្រហារក្នុងទ្រង់ទ្រាយធំរបស់កងទ័ពវៀតណាម ក្នុងរដូវប្រាំងខាងមុខ ។ នៅខែ កញ្ញា ១៩៨២ ក្នុងជំនួបជាមួយឧត្តមសេនីយ សក់ ស៊ុតសាខន និង ថាច់ រ៉េង (ខាង ក.ជ.រ.ប.ខ.) ព្រមជាមួយឧត្តមសេនីយ ទៀប បែន និង លោក តុល ឡោះ (ខាងកងទ័ពសីហនុនិយម) លោកឧត្តមសេនីយ ឆាវលិត ទូន្មានថាកងទ័ពទាំងពីរមិនត្រូវនៅស្ងៀមទេ[166] ។ លោកមេទ័ពថៃណែនាំឲ្យកងទ័ពទាំងពីរ ចេះបំបែកខ្លួននៅពេលខ្មាំងវាយសម្រុកខ្លាំង ។ លោក ឆាវលិត ផ្តល់អនុសាសន៍ថា កម្លាំង ១/៣ ត្រូវបាត់ឲ្យចេញទៅប្រតិបត្តិការនៅខាងមុខទីតាំង ត្រូវធ្វើតាមរបៀបទ័ពព្រៃ ត្រូវប្រឹងធ្វើសង្គ្រាមចិត្តសាស្ត្រ ហើយមិនត្រូវធ្វើអ្វីទៀតឡើយ ។ តាមលោកឧត្តមសេនីយ ឆាវលិត កម្លាំង ១/៣ ត្រូវបញ្ជូនចូលក្នុងប្រទេសខ្មែរ ១/៣ ត្រូវធ្វើការហ្វឹកហាត់បំពាក់បំប៉នបច្ចេកទេសយោធា និង ១/៣ ត្រូវទុករក្សាការពារមូលដ្ឋាន និងទីតាំងខាងក្រោយ ។

នៅក្នុងក្របខ័ណ្ឌនៃទស្សនវិស័យយោធាថ្មី កងទ័ព រ.ជ.រ.ប.ខ. ហាក់ដូចជាសកម្ម ចេះផ្តើមគំនិតចេញវាយប្រយុទ្ធច្រើនជាងមុន ។ គឺនៅក្នុងបរិបទយោធាថ្មីនេះហើយ ដែលខ្លួនខ្ញុំផ្ទាល់បានឃើញ និង បានធ្វើជាសាក្សីនូវអ្វីដែលហៅថាសង្គ្រាម ។ តាមពិតទៅ ខ្ញុំបានឃើញទិដ្ឋភាពទាំងពីរនៃសង្គ្រាមគឺ ទាំងចំណុចល្អ ទាំងចំណុចអាក្រក់ ។ នៅពេលមានជ័យជំនះ ចិត្តយើងពុះកញ្ជ្រោល អបអរសាទរ តែនៅពេលបរាជ័យ ចិត្តយើងក៏ភ័យរន្ធត់ញាប់ញ័រយ៉ាងដូច្នោះដែរ ។ កាលពេលមុនៗ ខ្ញុំយល់ដឹងពីចម្បាំងតែតាមឯកសារ ឬ របាយការណ៍យោធា ឬ ដោយបាន

---

[166] Sak Sutsakhan, Compte-rendu de la rencontre avec le Général Chao le 10 Septembre 1982.

ស្តាប់យុទ្ធជនដំណាលពីបេសកកម្មរបស់ពួកគេ ។ តែចាប់តាំងពីខ្ញុំចូលមកធ្វើការក្នុងជួរអគ្គសេនាធិការ ក.ជ.រ.ប.ខ. ខ្ញុំក៏ចូលទៅក្នុងបេះដូងនៃម៉ាស៊ីនសង្គ្រាមគឺសង្គ្រាមជាក់ស្តែង ទាំងទីកន្លែង ទាំងពេលវេលាតែម្តង ។ នៅពេលដែលឃើញយុទ្ធជនចេញដំណើរទៅសមរភូមិមុខ ខ្ញុំមានមោទនភាព និង ទឹកចិត្តអបអរសាទរចំពោះទឹកចិត្តក្លាហានអង់អាចរបស់គេទាំងឡាយនោះ ។ ក៏ប៉ុន្តែ នៅរាល់សមរភូមិនោះ ក៏មិនមែនមានតែជ័យជំនះនោះទេ ។ ពេលណាយុទ្ធជនត្រឡប់មកវិញដោយនាំមកនូវជ័យជំនះ យើងលោតកញ្ឆែងអបអរសាទរ លើកសរសើរពួកគេថាយុទ្ធជននៃសេរីភាព ។ នេះជាជ្រុងល្អ ជ្រុងសប្បាយរីករាយនៃសង្គ្រាម ។ ក៏ប៉ុន្តែក៏មានអ្នកស្លាប់នៅលើទីលានប្រយុទ្ធ ចោលប្រពន្ធកូននៅខាងក្រោយ ។ នៅពេលទៅជួបក្រុមគ្រួសារនៃយុទ្ធជនដែលបានពលីទាំងនោះ ខ្ញុំមានអារម្មណ៍ក្តុកក្តួលក្រៃលែងមិនអាចទប់ចិត្តដ៏ខ្លោចផ្សារនោះបានឡើយ ។ ភ្លាមៗនោះខ្ញុំយល់ថា "បញ្ជូនមនុស្សឲ្យទៅធ្វើសង្គ្រាមជារឿងស្រួលណាស់ ក៏ប៉ុន្តែការបាត់បង់អាយុជីវិតមនុស្សជារឿងទុក្ខសោកដ៏ធំធេង ជារឿងគួរឲ្យសោកស្តាយជាអតិបរិមា" ។ ក៏ប៉ុន្តែ នៅក្នុងចិត្តខ្ញុំៗក៏យល់ដែរថា សេរីភាព និង សេចក្តីថ្លៃថ្នូរមិនអាចរកបានយ៉ាងស្រួលនោះទេ ។ គេត្រូវតែបង់ថ្លៃអ្វីមួយ ដើម្បីឲ្យបានមកវិញនូវសេរីភាព និង សេចក្តីថ្លៃថ្នូរនេះ ។

នៅចុងឆ្នាំ ១៩៨២ រ.ជ.រ.ប.ខ. បានបង្កើនសកម្មភាពទ័ពព្រៃយ៉ាងខ្លាំងក្លា[167] ។ កិច្ចប្រតិបត្តិការវាយឆ្មក់ បានធ្វើឡើងនៅតំបន់ខាងកើតជាក្សាន្តនៃខេត្តព្រះវិហារ នៅតំបន់ប៉ៃលិននៃខេត្តបាត់ដំបង នៅថ្មពួក និង បន្ទាយឆ្មារនៃខេត្តបន្ទាយមានជ័យ ។ កងកម្លាំងជួ រ.ជ.រ.ប.ខ. បានវាយឆ្មក់ទៅលើទីតាំងកងទ័ពវៀតណាម នៅបន្ទាត់បុស ចម្ងាយ ២៥ គ.ម ខាងកើតមូលដ្ឋានអំពិលរបស់យើង ។

[167] Khmer People's National Liberation Front, Press Release, Khmer Territory, December 17, 1982.

នៅចុងឆ្នាំ ១៩៨២ លោក ដា ឈុត បើកកិច្ចប្រតិបត្តិការនៅយាងដង្កំ ចម្ងាយ ៧ គ.ម ខាងកើតជំរុំនងចាន់ ។ គាត់ដាក់ឈ្មោះកិច្ចប្រតិបត្តិការនោះថា "កិច្ចប្រតិបត្តិការយាងដង្កំ" ។ បន្ទាប់ពីវាយប្រយុទ្ធគ្នាអស់រយៈពេលពីរសប្តាហ៍ កងកម្លាំងរបស់លោក ដា ឈុត បានដណ្តើមយកបានទាំងស្រុងនូវទីតាំងយាងដង្កំ ។ នៅក្នុងរបាយការណ៍របស់គាត់ផ្ញើជូនលោកតាប្រធាន សឺន សាន ចុះថ្ងៃទី ២៥ មករា ១៩៨៣ លោកឧត្តមសេនីយ ថាច់ រ៉េង សរសេរថា៖ "ខែ មករា នេះ បានបញ្ជាក់ឲ្យឃើញនូវការផ្តើមគំនិតយោធារបស់យើង ក្នុងការវាយទៅលើកងទ័ពវៀតណាម ។ ក្នុងអំឡុងខែនេះ គ្រប់ជំរុំយើង បានបញ្ជូនកងកម្លាំងឲ្យចូលទៅក្នុងទឹកដីខ្មែរ[168]" ។ បន្ទាប់មកលោកឧត្តមសេនីយក៏បានធ្វើរបាយការណ៍យោធាតាមជំរុំនីមួយៗ តាមតំបន់នីមួយៗ ។

កិច្ចប្រតិបត្តិការយាងដង្កំ ក៏ជាឱកាសមួយឲ្យខ្ញុំអាចទៅធ្វើទស្សនកិច្ចនៅក្នុងភូមិខ្មែរជ្រៅក្នុងទឹកដីខ្មែរ ដែលមានលក្ខណៈខុសប្លែកពីជំរុំជនភៀសខ្លួននៅតាមទល់ដែនខ្មែរ-ថៃ ។ អស់រយៈពេលជាយូរមកហើយ ដែលខ្ញុំមានបំណងជាន់ទឹកដីខ្មែរនៅក្នុងតំបន់ ដែលយើងហៅថាតំបន់ខ្មាំងកាន់កាប់ ។ គ្រាន់តែឃើញទេសភាពនៃទឹកដីរបស់ដូនតាយើង ឃើញរាងដំបូលផ្ទះខ្មែរ ក្នុងភូមិខ្មែរ ដែលមានដាំដំណាំនានាដូចជា ចេក ល្ហុង ឬ ស្វាយ ធ្វើឲ្យចិត្តខ្ញុំពុះកញ្ជ្រោល និងកើតក្តីសង្ឃឹមក្នុងចិត្តសង្ឃឹមថាថ្ងៃណាមួយនឹងបានរំដោះ និង មករស់នៅលើទឹកដីនៃមាតុភូមិខ្ញុំមិនខាន ។ ខ្ញុំរំភើបខ្លាំងណាស់ នៅពេលដែលឃើញទង់ជាតិខៀវក្រហម និង រូបអង្គរសកំពូលបី បក់រវិចនៅលើទីតាំងដែលទើបរំដោះបាន ។ នោះគឺជាទង់ជាតិខ្មែរ ដែលយើងធ្លាប់ប្រើមុនរបបសាធារណរដ្ឋរបប លន់ នល់ នៅមុនឆ្នាំ ១៩៧០ ។ ជោគជ័យនៅយាងដង្កំ ប្រហែលជាជ័យជំនះកំពូល និង ចុងក្រោយ

[168] Thach Reng, Compte-rendu pour l'information du Président du FNLPK, le 25 janvier 1983.

របស់ក.ជ.រ.ប.ខ. ។ បណ្តាញព័ត៌មានលោកខាងលិចបានផ្សព្វផ្សាយយ៉ាងទូលំទូលាយពីជ័យជំនះនេះ ។ វិទ្យុប៊ីប៊ីស៊ី (BBC)វិទ្យុអូស្ត្រាលី វិទ្យុសម្លេងសហរដ្ឋអាមេរិក វី អូ អេ (VOA) និង បណ្តាញទីភ្នាក់ងារសារព័ត៌មានសំខាន់ៗ សុទ្ធតែបានផ្សព្វផ្សាយអនុគ្រោះដល់រ.ជ.រ.ប.ខ.ទាំងអស់ ។ លោកឧត្តមសេនីយ ថាច់ រ៉េង បានផ្តល់បទសម្ភាសន៍ផ្ទាល់ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ។ សូមបញ្ជាក់ថាចាប់តាំងពីឆ្នាំ ១៩៧៥ ដែលរបបកុម្មុយនីស្តបានឈ្នះសង្គ្រាមនៅប្រទេសទាំងបីនៃឥណ្ឌូចិនគឺៈ លាវ វៀតណាម និង កម្ពុជា វិទ្យុ វី អូ អេ បានជំនួសវិទ្យុប៉េកាំងវិញ ។ ប្រជាពលរដ្ឋស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិកកាន់តែច្រើនឡើងៗ ធ្វើឲ្យវិទ្យុនេះ មានប្រជាប្រិយភាពជាងវិទ្យុកុម្មុយនីស្តនៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ទាំងនៅជាយដែនទាំងនៅក្នុងប្រទេស ។ នៅថ្ងៃទី ៣០ ធ្នូ ១៩៨២ លោកឧត្តមសេនីយ ថាច់ រ៉េង និង លោក ជា ឈុត បាន ធ្វើជាអធិបតីនៃពិធីប្រគល់ទង់ជាតិ ជូនយុទ្ធជនដែលបានទទួលជ័យជំនះ ។

## ទ័ពយើងខ្លាំង ឬ ខ្សោយ អាស្រ័យលើលោក ឆាវលិត

កិច្ចប្រតិបត្តិការយោងជង្គំ ក៏ជាឱកាសមួយឲ្យខ្ញុំបានរៀនសូត្រអំពីភាពផុយស្រួយនៃបេសកកម្មប្រយុទ្ធរបស់យើង ។ ប្រតិបត្តិការនេះ បានធ្វើឲ្យខ្ញុំដឹងពីសមត្ថភាពយោធារបស់ពួកយើងគឺ ពឹងផ្អែកទាំងស្រុងលើការគាំទ្រផ្នែកភស្តុភាពីប្រទេសថៃ ។ លោកឧត្តមសេនីយ ឆាវលិត ជាអ្នកកាន់កាប់យ៉ាងណែន នូវវាសនារបស់យើង ។ មេទ័ពថៃរូបនេះ ដើរតួជាគន្លឹះចំពោះរាល់កិច្ចប្រតិបត្តិការយោធារបស់យើង ។ ក្នុងពេលកន្លងមក ប្រសិនបើយើងអាចទទួលជោគជ័យខ្លះៗនោះ នោះក៏អាស្រ័យលើការគាំទ្ររបស់លោក ឆាវលិត ដែរ ។ នៅក្នុងរបាយការណ៍ជូនលោកតាសឺន សាន លោកឧត្តមសេនីយ ថាច់ រ៉េង សរសេរថាៈ "ក្នុងរយៈពេលនៃកិច្ចប្រតិ

បត្តិការយាងដង្កំ អស់លោកហ្វួណាថៃគ្រប់លំដាប់ថ្នាក់ (ហ្វួណា ឬ មេកើយ ) បានធ្វើសហការយ៉ាងល្អជាមួយយើង ។ អាជ្ញាធរថៃបានឆ្លើយតបជាវិជ្ជមាន និង ភ្លាមៗចំពោះសំណើបន្ទាន់របស់យើង ។ ហ្វួណាជីវ (ឧត្តមសេនីយ ឆាវលិត) ទោះបីជាជាប់រវល់យ៉ាងណា ក៏អនុញ្ញាតឲ្យឧត្តមសេនីយ ថាច់ រ៉េង ចូលជួប ហើយ បានព្រមផ្តល់ឲ្យយើងនូវជំបងពិសេសមួយចំនួន (កាំភ្លើងពិសេស) ដែលអាចឲ្យ យើងទប់ទល់ជាមួយការវាយប្រហារលើកទី៤នៃកងទ័ពវៀតណាម" ។ តាមពិតទៅ កងទ័ពថៃ បានប្រគល់ឲ្យយើងនូវកាំភ្លើងបាញ់រថក្រោះអំប្រុស្ស (Ambrust)មួយ ចំនួន ដែលមានប្រសិទ្ធភាពល្អក្នុងការប្រយុទ្ធជាមួយរថក្រោះ ធ្វើឲ្យទាហានរបស់ យើងមានទឹកចិត្តខ្ពស់ក្នុងការប្រយុទ្ធ ។ ខ្ញុំឮគេនិយាយប្រាប់ថា កាំភ្លើងបាញ់រថ ក្រោះនោះ បានមកពីប្រទេសសឹង្ហបូរី ។ មែនទែនទៅ កាំភ្លើងបាញ់រថក្រោះ អំប្រុស្សនោះ មានប្រសិទ្ធភាពមែន ក៏ប៉ុន្តែនៅពេលអស់គ្រាប់ កាំភ្លើងនោះក៏ទៅជា អាសាឥតការ ។ ក្រោយមក បន្ទាប់ពីបានប្រើដោយជោគជ័យ ខ្ញុំឮគេថារដ្ឋាភិបាល សឹង្ហបូរីទាមទារឲ្យប្រមូលយកកាំភ្លើងនោះ ពីសមរភូមិទៅវិញ នោះប្រហែលជាមាន ប្រតិកម្មពីក្រុងហាណូយក៏មិនដឹង ។ កងទ័ពថៃ ក៏ប្រមូលយកកាំភ្លើងបាញ់រថក្រោះ នោះទាំងអស់ ដែលធ្វើឲ្យយុទ្ធជនយើងខកចិត្តយ៉ាងខ្លាំងចំពោះជំនួយក្រៅប្រទេស នេះ ។ ម្យ៉ាងទៀត ប្រសិនបើពិនិត្យឲ្យស៊ីជម្រៅតទៅទៀត ខ្ញុំអាចឃើញថាកងទ័ព ថៃមិនមែនសុទ្ធតែឆ្លើយតប ជាវិជ្ជមានចំពោះសំណើររបស់យើងនោះទេ ឧទា ហរណ៍ដូចជា៖ តាមសំណើរបស់លោកឧត្តមសេនីយ ថាច់ រ៉េង ផ្ញើជូនលោក ឧត្តមសេនីយ ឆាវលិត នៅខែ ធ្នូ ១៩៨២ នោះ យើងស្នើគ្រាប់ B40 ចំនួន ៥០០ គ្រាប់ យើងទទួលបានតែ ១០២ គ្រាប់ យើងស្នើគ្រាប់ M60 ចំនួន ៤០០គ្រាប់ យើងទទួលបានតែ ៨៥គ្រាប់ យើងស្នើគ្រាប់ DK85 ចំនួន ៤០០ គ្រាប់យើងអត់

បានទទួលមួយគ្រាប់ឡើយ[169] ។

# លោក សក់ ស៊ុតសាខន និង ក្រុមលោក ដៀន ដែល

ដោយសារវត្តមានរបស់លោកឧត្តមសេនីយ ថាច់ រ៉េង នៅលើសមរភូមិ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ហាក់ដូចជាដើរតួបន្ទាប់បន្សំទៅវិញ ។ តាមពិតទៅ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវគេទទួលស្គាល់ថាជានាយទាហានការទូតជាជាងនាយទាហានប្រយុទ្ធ ។ លោកឧត្តមសេនីយរូបនេះ ខឹតខំធ្វើការយកចិត្តទុកដាក់សម្របសម្រួល ដើម្បីអាចឲ្យធ្វើការបានជាមួយគ្រប់ភាគី ។ ចាប់តាំងពីបានមកកាន់តំណែងជាប្រធានគណៈកម្មាធិការអគ្គសេនាធិការ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ខឹតខំទាក់ទាញទឹកចិត្តនាយទាហាន និងមន្ត្រីស៊ីវិលជិតស្និទ្ធជាមួយលោកឧត្តមសេនីយ ដៀន ដែល ដែលនៅសម័យនោះហាក់ដូចជាមេក្លោង ដែលអាចទាញខ្សែញាក់ឲ្យសហការ ឬ ឲ្យប្រឆាំងនឹងសកម្មភាពរបស់គណៈកម្មាធិការអគ្គសេនាធិការនៅក្នុងមូលដ្ឋានយោធាអំពិល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ហាក់ដូចជាពឹងផ្អែកទាំងស្រុង ទៅលើកិច្ចសហការរបស់អ្នកទាំងនោះ ដើម្បីឲ្យបេសកកម្មរបស់គាត់បានជោគជ័យ ។ បើពួកមេបញ្ជាការជិតស្និទ្ធជាមួយលោក ដៀន ដែល ទាំងនោះ គេទទួលស្គាល់ គេចាត់ទុកគាត់ជាមេ គាត់ពិតជាបានសម្រេច ។ លោកឧត្តមសេនីយប្រើប្រាស់ពេលវេលាមួយភាគធំលើការងារក្រដាសស្នាម ហើយយូរៗម្តង គាត់ចេញទៅពិនិត្យសភាពការណ៍នៅទីលានខាងមុខ តាមជំរុំនានា ។

លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយទាហានមានពាក្យសំដីទន់ភ្លន់ គាត់មិនដែលប្រើពាក្យអាមឹង ចំពោះនាយទាហានណាម្នាក់ឡើយ ។ លោក

[169] Thach Reng, To General Chavalit Yongchaiyuth, (A kind of Memo) Bangkok, December 28, 1982.

ឧត្តមសេនីយ មិនចេះនិយាយដើមគេ ហើយក៏ជាបុគ្គលម្នាក់ដែលគួរឲ្យដើរជាមួយណាស់ ។ លោកឧត្តមសេនីយចូលចិត្តពិសាបារី ។ នៅពេលរួចពីការងារ គាត់ចូលចិត្តពិសាស្រាវីស្គីលាយសូដាទឹកកក ឬ ស្រាបៀរ ។ តាមរយៈការងារនៅក្នុងគណៈកម្មាធិការអគ្គសេនាធិការនេះ បន្តិចម្តងៗ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចាប់ដៃសហការជាមួយលោក ហ៊ីង គន្ធុន យ៉ាងជិតស្និទ្ធ ។

# វៀតណាមវាយបកវិញ

ជោគជ័យខាងយោធារបស់រ.ជ.រ.ប.ខ.មិនមានអាយុវែងឆ្ងាយឡើយ ដោយកងទ័ពវៀតណាមបានវាយតបវិញយ៉ាងខ្លាំងក្លា ។ ក្នុងកិច្ចប្រតិបត្តិការវាយបកវិញនេះ កងទ័ពវៀតណាម (កាលសម័យនោះ ប្រាកដជាមានកងទ័ពរដ្ឋកម្ពុជាចូលរួមពុំខានឡើយ តែខ្ញុំសរសេរនេះ ដោយយោងតាមឯកសារផ្លូវការរបស់ រ.ជ.រ.ប.ខ. ដែលមានលក្ខណៈប្រឆាំងកងទ័ពវៀតណាម) បានប្រើកម្លាំង ៦.០០០ នាក់ ប្រដាប់ដោយអាវុធធុនធ្ងន់ និង រថក្រោះ តេ៥៤ តេ៥៥ និង រថពាសដែក APC M116 ទៀតផង ។ មិនគ្រាន់តែដណ្តើមយកបានទីតាំង ដែលពួកគេបាត់បង់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែ កងទ័ពនេះក៏វាយប្រហារយ៉ាងខ្លាំងមកលើជំរុំនងចាន់ ។

ដើម្បីជួយលើកទឹកចិត្តយុទ្ធជននៅនងចាន់ ខ្ញុំត្រូវបានចាត់ឲ្យទៅស្នាក់នៅក្នុងជំរុំនោះ ជាមួយលោក ប៉ែន ធុឡា កូនពៅរបស់សម្តេច ប៉ែន នុត ។ សហការីនៅក្នុងជំរុំនិយាយថា វត្តមានរបស់យើងខ្ញុំនៅក្នុងជំរុំ អាចជួយលើកទឹកចិត្តប្រជាពលរដ្ឋ កុំឲ្យមានការភិតភ័យ ព្រោះគេជឿថា ប្រសិនបើមានហេតុការណ៍អ្វីមួយកើតឡើង ថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.ប្រាកដជាយកចិត្តទុកដាក់ជួយដោះស្រាយមើលថែទាំសុខទុក្ខរបស់ជនភៀសខ្លួន ។ និយាយតាមពិតទៅ ខ្លួនខ្ញុំផ្ទាល់មិនដឹងថា តើអាចនឹងជួយបានយ៉ាងដូចម្តេចឡើយ ។ បើអាចធ្វើបាននោះគឺ គ្រាន់តែជួយ

ផ្សព្វផ្សាយព័ត៌មានដល់បណ្ដាញសារព័ត៌មានអន្តរជាតិ អំពីការវាយប្រហារណាមួយមកលើជំរុំ និង ស្នើសុំជំនួយមនុស្សធម៌ពីអង្គការសហប្រជាជាតិ រួមទាំងសហគមន៍អន្តរជាតិ ព្រមទាំងប្រទេសជាមិត្តតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំក៏មករស់នៅបណ្ដោះអាសន្ននៅក្នុងជំរុំនងចាន់ នៅក្នុងផ្ទះសំណាក់មួយដែលនៅជាប់ផ្ទះលោក ជា ឈុត ក្នុងបរិវេណមួយ ដែលមានការយាមកាមយ៉ាងហ្មត់ចត់ជាទីបំផុត ។ នៅពេលជាមួយនោះ លោកឧត្តមសេនីយ ថាច់ រ៉េង ជាប់រវល់ជូនដំណើរអ្នកស្រី សួន កាសេត ទៅធ្វើទស្សនកិច្ចតាមជំរុំ ពីជំរុំមួយទៅជំរុំមួយ ឬ ទៅសម្រាកនៅឯក្រុងបាងកក ។

ជារៀងរាល់ថ្ងៃលោក ជា ឈុត តែងទៅត្រួតពិនិត្យទីតាំងទាំងឡាយ នៅក្រៅជំរុំតាមខ្សែត្រៀមនានានៅក្នុងទឹកដីខ្មែរ ។ ខ្ញុំក៏តែងរួមដំណើរទៅត្រួតពិនិត្យនោះ មិនដែលខានឡើយ ។ ពួកយើងមានទម្លាប់ចេញពីជំរុំឆ្ពោះទៅតំបន់ទួលផ្ទឹកដែលជាទួលតូចមួយហើយដែលក្រុមលោក ជា ឈុត មកបោះជាទីតាំងបញ្ជាការឈានមុខ ។ នៅទីនោះ មានផ្លូវថ្មើរជើងតម្រង់ទៅទឹកដីកាន់កាប់ដោយកងទ័ពវៀតណាម និង កងទ័ពរដ្ឋាភិបាលភ្នំពេញ ដែលនៅពេលនោះយើងហៅថារបប ហេង សំរិន ។ យើងតែងចេញដំណើរតាមម៉ូតូ ដោយមានកងការពារហែហម ប្រដាប់ដោយអាវុធគ្រប់ដៃ ។ ម៉ូតូមួយមានទាហានពីរនាក់ ។ លោក ជា ឈុត បើកម៉ូតូ 125cc Endura ខ្លួនឯង រីឯខ្ញុំជិះពីក្រោយឱបចង្កេះ ។ ពេលធ្វើដំណើរម្ដងៗគេឮសូរសម្លេងម៉ូតូលាន់រំពងរញ្ជួយមេឃរញ្ជួយដី មិនមែនធ្វើដំណើរលបៗស្ងាត់ៗនោះឡើយ ។ នៅសម័យនោះ អ្នកកាសែតអន្តរជាតិខ្លះ ហៅពួកយើងថាជាកងម៉ូតូទ័ពព្រៃ (Moto-riding guerilla men) ។ នៅពេលជាប់ដៃប្រយុទ្ធគ្នាម្ដងៗគឺនៅទួលផ្ទឹកនេះហើយដែលលោក ជា ឈុត ចេញមកបញ្ជាទ័ពតាមវិទ្យុទាក់ទង ។ ម្យ៉ាងទៀតគឺ នៅទួលនេះហើយដែលពួកយើង ចាំសង្កេតឃ្លាំមើលចលនារបស់កងទ័ព

បច្ចាមិត្ត ។ ដូច្នេះទួលផ្ទឹកនេះ ក៏ជាគោលដៅនៃការបាញ់ផ្លោងកាំភ្លើងធំពីសំណាក់កងទ័ពវៀតណាម និង កងទ័ព ហេង សំរិន ដែរ ។

ថ្ងៃមួយនោះ ពេលពួកយើងកំពុងស្តាប់របាយកាណ៍យោធា បច្ចាមិត្តក៏បាញ់គ្រាប់ ១០៧ មម មកលើទីតាំងរបស់យើងនៅទួលផ្ទឹក។ គ្រាប់ស្ទើរទាំងអស់សុទ្ធតែផ្ទុះនៅប្រមាណ១០០ម ឬ ២០០មពីយើង ធ្វើឲ្យបាក់មែកឈើ និង ដើមឈើតូចៗជាច្រើន ក៏ប៉ុន្តែមិនមានប៉ះពាល់អាយុជីវិតមនុស្សទេ ។ ជាមួយគ្នានោះ ក៏មានពីរគ្រាប់ធ្លាក់ចូលក្នុងបរិវេណនៃទីបញ្ជាការឈានមុខរបស់យើងដែរ ។ ក៏ប៉ុន្តែ ជាសំណាងល្អ គ្រាប់ទាំងពីរនោះមិនផ្ទុះដូចគ្រាប់ឯទៀតទេ ។ កងទ័ពរបស់លោក ជា ឈុត ហាក់ដូចជាក្លាហានណាស់ មិនមានការតក់ស្លុតចំពោះការបាញ់ផ្លោងនេះឡើយ ។ ទាហានម្នាក់ទៅរើសយកគ្រាប់រ៉ុកែតនោះ ដាក់លើជើងសិប្បនិមិត្ត ព្រោះគ្មានជើងមែនទែន ហើយសាកល្បងបាញ់បកទៅម្ចាស់ដើមវិញ។ នៅពេលដែលត្រូវចុចថ្មភ្លាម គ្រាប់នោះបញ្ចេញសម្លេងគ្រហឹមឡើង ធ្វើឲ្យពួកយើងទាំងមេទាហានទាំងកូនទាហានខំសម្លឹង ដោយមិនដាក់ភ្នែកទៅរកគ្រឿងប្រល័យមនុស្សដ៏មានមហិទ្ធិរិទ្ធនោះ ។ គ្រាប់រ៉ុកែតនោះ ក៏ស្ទុះហោះរឹងតម្រង់ទៅរកទីតាំងសត្រូវវិញក្រោមស្នូរទះដៃនៃអ្នកឈរមើលទាំងឡាយ ។ រួចមកខ្ញុំក៏ឮសូរសម្លេងផ្ទុះខ្លាំងនៅប៉ុន្មានគីឡូម៉ែត្រឯនាយពីយើង ។ ខ្ញុំនឹកថាប្រហែលអាចមានមនុស្សរបួស ឬស្លាប់មិនខានឡើយ ។ ក្រុមយើងហាក់ដូចជាមិនទាន់ស្កប់ស្កល់ ហើយនៅតែស្រេកឃ្លានស្វែងរកនូវជ័យជំនះថ្មីថែមទៀត ។ ពួកគេក៏រៀបចំបាញ់គ្រាប់ទីពីរ ។ ម្តងនេះនៅពេលចុចរួច គ្រាប់រ៉ុកែតក៏ងើបឡើង តែមិនស្ទុះហោះដូចមុនទៀតទេ ។ គ្រាប់នោះ ចាប់ផ្តើមវិលចុះវិលឡើងយ៉ាងយឺតៗ ដោយបញ្ចេញសម្លេងគ្រហឹមកំញើញយ៉ាងរន្ថើន ។ រួចគ្រាប់នោះក៏តម្រង់ក្បាលមករកពួកយើង នៅលើទួលផ្ទឹកដែលនៅជិតទីបាញ់នោះ។ មនុស្សស្ទើរទាំងអស់ នាំគ្នាស្ទុះទៅរកកន្លែងការពារយ៉ាងប្រញាប់

ប្រញាល់។ ខ្ញុំហាក់ដូចជាគ្មាននឹកភ័យខ្លាចអ្វីទ្បើយ ក៏ប៉ុន្តែខ្ញុំសង្កេតឃើញអ្នកនៅជុំវិញខ្ញុំខ្លះក្រាប ខ្លះពួននៅពីក្រោយដើមឈើធំៗ ។ ខ្ញុំចុះទៅខាងក្រោយទួល ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ពួកយើងហាក់ដូចជានាំគ្នាមកប្រជ្រៀតពួននៅទីដ៏ចង្អៀតមួយ ។ ខ្ញុំឮតែសម្លេងគ្រាប់រ៉ាវ ម៉ែមនុស្សម្នាងទៀត ហាក់ដូចជាបាត់មាត់បាត់កមិនឮនរណានិយាយស្តីអ្វីទាំងអស់ ។ ខ្ញុំជឿថាទាហានមិនតិចទេ ដែលនាំគ្នាសូត្របាលី ឬ ប្រើមន្តការពារខ្លួន ព្រមទាំងបន់ស្រន់ សំបូងសំរូង សុំឲ្យវត្ថុស័ក្តសិទ្ធិជួយយកអាសា ។ បន្ទាប់ពីតម្រង់ក្បាលម្តងទៅឆ្វេងម្តងទៅស្តាំ ព្រមជាមួយសម្លេងរ៉ាវឥតឈប់ គ្រាប់នោះ ទីបំផុត ក៏បែរក្បាលចេញពីពួកយើង ឆ្ពោះទៅទិសខាងកើតម្តងវិញ ។ គ្រាប់រ៉ុកែត បន្ថែមសម្លេងយ៉ាងខ្លាំងស្នូរ "ឈូត ឈូត ឈូត" រួចហោះចេញពីទីបញ្ជាការឈានមុខរបស់ពួកយើង ទៅបុកដើមឈើនៅខាងមុខ ធ្វើឲ្យយុទ្ធជនយើងពីរនាក់ស្លាប់ និង មួយចំនួនទៀតរងរបួស ។ នោះគឺជាគ្រោះថ្នាក់មួយដ៏ធំហើយក៏ជាបទពិសោធន៍អាក្រក់មួយសម្រាប់ខ្ញុំ ។ តាមពិតទៅ គ្រាប់រ៉ុកែតនោះនៅមានសុពលភាពអាចប្រើការបាន ក៏ប៉ុន្តែក្រុមយើងក្រោយពីបាញ់គ្រាប់រ៉ុកែតមុនរួចហើយ មិនបានផ្លាស់ថ្មថ្មី ធ្វើឲ្យកម្លាំងដែលត្រូវបង្វិលគ្រឿងនៅគូថគ្រាប់វិលមិនពេញកម្លាំង។ ខ្ញុំមានការនឹកស្រណោះអាណិតអាសូរចំពោះយុទ្ធជនដែលស្លាប់ និងរបួសទាំងនោះណាស់ ព្រោះគ្នាគ្មានបានប្រព្រឹត្តិអ្វីខុសសោះ តែត្រូវទទួលរងគ្រោះដោយសារសកម្មភាពមិត្តទៅវិញ ។

រៀងរាល់យប់ ពួកយើងតែងត្រៀមខ្លួនរង់ចាំការវាយប្រហាររបស់កងទ័ពវៀតណាមជាដ៏រាប ។ មែនទែនទៅ ត្រៀមខ្លួនរង់ចាំនោះ មានន័យថាព្រួយបារម្ភចំពោះការវាយប្រហាររបស់សត្រូវដែលនឹងកើតមានទ្បើងគ្មានកាលកំណត់ ។ នៅពេលចូលដេក សហសេវិកជាច្រើននាំគ្នាដេកទាំងសំលៀកបំពាក់ប៉ារ៉ា និង អាវុធការពារខ្លួន ។ លោក ប៉ែន ធុទ្បា ក្នុងសំលៀកបំពាក់ដូចខ្ញុំដែរគឺ អាវយឺត T-Shirt

និង ខោខាវប៊ូយ តែងហៅទាហានមកសួរនាំជានិច្ច ពីទីកន្លែងដែលត្រូវរត់ចេញ តើចេញតាមច្រកណា ទៅតាមណា នៅពេលណា មុនចូលទៅសម្រាក ។ គាត់អត់ងងុយស្ទើររាល់យប់ ។ នៅយប់មួយនោះ ក្នុងជំរុំទាំងមូល គេរាល់គ្នាផ្អើលពីការវាយប្រហាររបស់កងទ័ពវៀតណាម ។ ក្នុងមួយយប់នោះ លោក ប៉ែន ធុឡា អត់បានសម្រាន្តទាល់តែសោះ ។ ផ្ទុយទៅវិញ ខ្ញុំមិនបានខ្វាយខ្វល់អ្វីប៉ុន្មានឡើយ ហើយនៅក្នុងយប់នោះ ខ្ញុំស្រម៉ុកខ្លាំងជាងយប់មុនៗទៅទៀត ។ ជាសំណាងល្អ ពុំមានការវាយប្រហារនៅយប់នោះទេ តែក៏ជាយប់ដែលមានភាពស្ងាត់ជ្រងំជាទីបំផុត ។ ព្រឹកស្អែកឡើង ខ្ញុំត្រូវចេញដំណើរត្រឡប់ទៅបាងកកវិញ ដើម្បីបំពេញភារកិច្ចផ្សេងទៀត ។ ប៉ុន្មានថ្ងៃក្រោយពីពេលដែលខ្ញុំចេញពីជំរុំនងចាន់ផុតទៅ កងទ័ពវៀតណាមក៏ចាប់ផ្ដើមវាយប្រហារមកលើជំរុំនោះមែន ។ ក្នុងរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ កងទ័ពវៀតណាម ក៏វាយយកបានជំរុំនងចាន់ទាំងមូល ។

របាយការណ៍ផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. មានសេចក្ដីជាអាទិថា៖ "ទោះបីជាយុទ្ធជនយើង មានស្មារតីលះបង់ និង ប្ដេជ្ញាចិត្តយ៉ាងណាក៏ដោយ ក៏យុទ្ធជនយើងនៅនងចាន់ នៅទីបញ្ជាប់ត្រូវបង្ខំចិត្តដកថយ និង បោះបង់ជំរុំចោលទាំងស្រុងគឺត្រូវបរាជ័យ នៅចំពោះការវាយប្រហារក្នុងទ្រង់ទ្រាយធំលើកទី៤ នៃកងទ័ពវៀតណាម ដែលកើតមានពីថ្ងៃទី ៣១ មករា ដល់ថ្ងៃទី ១ កុម្ភៈ ១៩៨៣"[170] ។

ក្នុងរយៈពេលត្រីមាសទី១នៃឆ្នាំ ១៩៨៣ ជាមួយនឹងការវាយប្រហារនៅនងចាន់ កងកម្លាំងរបស់កងពលលេខ ៥ លេខ ៣០២ និង ៣០៩ របស់វៀតណាម បានបាញ់ផ្លោងវាយប្រហារ និង កំទេចជំរុំនានានៅ ភ្នំឆ័ត្រ ចំការគរ ព្រៃមាន់ដែល ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ព្រមទាំងសីហនុបុរីនៃកងទ័ពរាជានិយម ។ នៅក្នុងសារទូរលេខមួយផ្ញើជូនលោកអគ្គលេខាធិការអង្គការសហ

---

[170] Sak Sutsakhan, Memorandum à la haute information de Monsieur le Président du FNLPK et Commandant en chef du FANLPK, le 21 février 1983.

ប្រជាជាតិ ហ្សាវី យេ ប៉េរ៉េ ដឺ កួអែលឡា[171] ( Javier Perez de Cuellar ) លោក តា សឺន សាន បានចោទប្រកាន់ថា ការវាយប្រហាររបស់កងទ័ពវៀតណាម បានធ្វើ ឲ្យមានការបាត់បង់ជីវិត និង បាត់បង់ទីជម្រករបស់ប្រជាពលរដ្ឋស៊ីវិល ផង ។ ជាមួយគ្នានោះ ការវាយប្រហារនេះ ក៏បានបង្កឲ្យមានការទម្លាក់កំហុសដាក់គ្នាក្នុងចំណោមមេទ័ពរបស់ រ.ជ.រ.ប.ខ. ។

លោកឧត្តមសេនីយ ថាច់ រ៉េង ដែលធ្លាប់បានទទួលការលើកសរសើរដោយសារទ្រឹស្តីទ័ពព្រៃរបស់គាត់ ជាពិសេសចំពោះជោគជ័យមួយរយៈខ្លី នៅឯយាងដង្គំ បានបន្ទោសមេបញ្ជាការជំរុំអំពីបរាជ័យនេះ ព្រោះថាគាត់បានផ្តល់ព័ត៌មានច្បាស់លាស់ជាមុនអំពីពេលវេលា និង ទីកន្លែងដែលបច្ចាមិត្តបើកការវាយប្រហារ ។ មេបញ្ជាការជំរុំឆ្លើយតបវិញថាលោក ថាច់ រ៉េង ពូកែតែខាងនិយាយពេលពួកយើងជាប់ដៃប្រយុទ្ធនៅលើសមរភូមិ លោក ថាច់ រ៉េង មិនដែលនៅចូលរួមប្រយុទ្ធជាមួយពួកយើងឡើយ គាត់រវល់តែជាប់បណ្តើរអ្នកស្រី សួន កាសេត នៅតាមជំរុំ ឬ ទៅបាងកកតែប៉ុណ្ណោះ ។

## អនុប្រធានថ្មី រ.ជ.រ.ប.ខ.

ទំនងជាចេះសម្របសម្រួលគ្នាទៅវិញទៅមក មេញ្ជាការជួរមុខទាំងអស់រាប់ទាំងលោក ដៀន ដែល ផងហាក់ដូចជាព្រមទទួលយកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាមេដឹកនាំយោធារបស់ពួកគេតទៅ ។ នៅខែ ឧសភា ១៩៨៣ លោកតា ឈាន វ៉ម បានលាឈប់ពីតំណែងអនុប្រធានរ.ជ.រ.ប.ខ. ។ លោកតា

[171] Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, Cable Message to UN Secretary-General Perez de Cuellar, 9 April 1983.

សឺន សាន[172] ក៏បានតែងតាំងលោក សក់ ស៊ុតសាខន ជាអនុប្រធានទី១ និង លោក ដៀន ដែល ជាអនុប្រធានទី២ ។ បន្តិចម្តងៗ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានទទួលការទទួលស្គាល់ពីប្រទេសផ្តល់ជំនួយ ជាពិសេសពីក្រុមអាស៊ាន ។ ដោយមើលឃើញថា មេទ័ពរូបនេះធ្លាប់កាន់តំណែងជាអ្នកទទួលខុសត្រូវកំពូលចុងក្រោយ (ឋានៈស្មើប្រមុខរដ្ឋ) និង ជានាយអគ្គសេនាធិការនាសម័យសាធារណរដ្ឋផង ប្រទេសផ្តល់ជំនួយទំនងជាវាយតម្លៃថាលោកឧត្តមសេនីយ សក់ ស៊ុតសាខន អាចជាដៃគូមួយក្នុងកិច្ចប្រតិបត្តិការយោធាប្រឆាំងកងទ័ពវៀតណាម។

# អ្នកស្រី សួន កាសេត បានត្រូវអញ្ជើញឲ្យចេញពីទឹកដីថៃ

ក៏ប៉ុន្តែ លោក ថាច់ រ៉េង និង អ្នកស្រី សួន កាសេត ដែលគេទទួលស្គាល់ថាជាភ្នែកជាត្រចៀករបស់លោកតា សឺន សាន បានសម្គាល់ថា លោក សក់ ស៊ុតសាខន ជាមេដឹកនាំដ៏ទន់ខ្សោយ និង សូញសាញមិនចេះអារកាត់អ្វីឡើយ ។ អ្នកទាំងពីរនេះ តែងព្យាយាមនាំព័ត៌មានផ្ទៃក្នុង ទៅប្រាប់ស្ថានទូតបរទេសរួមទាំងព័ត៌មានអំពីកិច្ចប្រតិបត្តិការយោធា ព្រមទាំងអំពីរបៀបរបបខុសឆ្គងក្នុងការរស់នៅដូចជាការផឹកស៊ី ដើរលេងយប់ជាដើម ដែលព័ត៌មានទាំងនោះ ទោះជាការពិតក៏ដោយ ក៏អាចឲ្យស្ថានទូតបរទេសទាំងនោះមើលស្រាលដល់នាយទាហានរបស់រ.ជ.រ.ប.ខ. ដែរ ។ សកម្មភាពទំនាក់ទំនងជាមួយស្ថានទូតបរទេសជាច្រើនរបស់លោក ថាច់ រ៉េង និង អ្នកស្រី សួន កាសេត ទាំងនោះ បានធ្វើឲ្យក្រុមឧត្តមសេនីយថៃដែលត្រួតត្រាគ្រប់គ្រងចលនាតស៊ូរបស់យើងនោះមិនសប្បាយចិត្ត ។ សូមបញ្ជាក់ថា ក្នុង

[172] Son Sann, Khmer People's National Liberation Front, Décision no. 83/04/FNL, Territoire Khmer, le 2 Mai 1982.

សម័យនោះ លោក ថាច់ រ៉េង និង អ្នកស្រី សួន កាសេត មានការទាក់ទងជិតស្និទ្ធជាមួយភ្នាក់ងារសម្ងាត់របស់បារាំង និង សឹង្ហបុរី ។

នៅខែធ្នូ ១៩៨៣ អាជ្ញាធរថៃក៏បានសុំឲ្យអ្នកស្រី សួន កាសេត ចាកចេញពីប្រទេសថៃ ។ អ្នកស្រី សួន កាសេត ក៏ត្រូវបង្ខំចិត្តវិលត្រឡប់ទៅប្រទេសបារាំងវិញ ជាទីដែលអ្នកស្រីធ្លាប់ស្នាក់អាស្រ័យនៅរហូតដល់ថ្ងៃចេញមករួមធ្វើការតស៊ូនៅជួរមុខនៅឆ្នាំ ១៩៧៩ ។ ការចាកចេញរបស់អ្នកស្រី សួន កាសេត ពិតជាការបាត់បង់នូវសហការីដ៏មានតម្លៃម្នាក់របស់លោកតា សឺន សាន ។ ចំពោះពួកយើងដែលមានភក្តីភាពចំពោះលោកតាប្រធាន ការបាត់បង់នេះធ្វើឲ្យការខិតខំប្រឹងប្រែងរបស់ពួកយើង ក្នុងការពង្រឹងក្រុមការងាររបស់លោកតាធ្លាក់ថយមួយកំរឹត ។

## លោក ថាច់ រ៉េង រត់តាម អ្នកស្រី សួន កាសេត

លោក ថាច់ រ៉េង និង អ្នកស្រី សួន កាសេត មិនបានលាក់លៀមអ្វីឡើយនូវទំនាក់ទំនងស្នេហារបស់ពួកគាត់ ។ ប៉ុន្មានថ្ងៃក្រោយពីការចេញដំណើររបស់អ្នកស្រី សួន កាសេត ទៅប្រទេសបារាំង ខ្ញុំ និង លោក ថាច់ រ៉េង នាំគ្នាទៅតំបន់កណ្តាលក្រុងបាងកក ដើម្បីអាចនិយាយទាក់ទងជាមួយអ្នកស្រី សួន កាសេត តាមទូរស័ព្ទពីសណ្ឋាគារមួយ ព្រោះបើនិយាយពីកន្លែងពួកយើងស្នាក់នៅៗនៅម៉ាយ៉ាឡាប់ យើងខ្លាចពួកទាហានថៃលបស្តាប់ ។ យើងនាំគ្នាដើរទៅរកសណ្ឋាគារមួយ នៅតាមផ្លូវសុរិវង្ស ។ នៅពេលដែលលោកឧត្តមសេនីយនិយាយទូរស័ព្ទនោះ ខ្ញុំមិនអាចស្តាប់ឮនូវកិច្ចសន្ទនាគ្នានោះឡើយ ។ ក៏ប៉ុន្តែនៅពេលអ្នកទាំងពីរនិយាយគ្នាចប់ លោក ថាច់ រ៉េង និយាយមករកខ្ញុំទាំងត្រហេបត្រហបថា គាត់ត្រូវចេញពីទឹកដីថៃភ្លាមៗ ពុំអាចរង់ចាំបានឡើយ ។ នោះគឺជាលើកទីមួយហើយ ដែលខ្ញុំ

ឃើញលោកមេទ័ពកងទ័ពពិសេសរបស់របប លន់ នល់ ម្នាក់នេះបាក់ទឹកចិត្តជាទីបំផុត ព្រោះថាគាត់ធ្លាប់តែទេសនា ឲ្យពួកយើងពង្រឹងស្មារតីតស៊ូប្រយុទ្ធជានិច្ចដើម្បីរំដោះជាតិ ។ ទឹកចិត្តគាត់ធ្លាក់ទាបជាខ្លាំង ដែលបង្ខំឲ្យគាត់បោះបង់ចោលការតស៊ូទាំងស្រុង ។ គាត់បន្ទោសលោកតា សឺន សាន ថាជាមនុស្សទន់ខ្សោយជាមេដឹកនាំកំសាក ដែលមិនហ៊ានការពារកូនចៅឯង នៅចំពោះមុខការគាបសង្កត់របស់ថៃ បណ្ដោយឲ្យថៃបណ្ដេញអ្នកស្រី សួន កាសេត ចេញពីប្រទេសថៃ ។ រំពេចនោះ ខ្ញុំក៏នាំគាត់ទៅទិញសំបុត្រយន្តហោះ រួចគាត់ក៏ចេញដំណើរទៅប្រទេសបារាំង នៅល្ងាចនោះតែម្តង ។

ការសម្រេចចិត្តដ៏ប្រញាប់ប្រញាល់នោះ ជាការសម្រេចខុសដ៏ធ្ងន់ធ្ងរមួយរបស់លោក ថាច់ រ៉េង ដែលពិបាកកែសំរួលឡើងវិញណាស់ ។ ក្រោយពីលោក ថាច់ រ៉េង ចេញផុតពីទឹកដីថៃភ្លាម អាជ្ញាធរថៃក៏ចាត់វិធានការហាមឃាត់ លែងអនុញ្ញាតឲ្យវិលត្រឡប់មកជាន់ទឹកដីថៃវិញអស់រយៈពេលយ៉ាងយូរ ។ ដូច្នេះ លោកតា សឺន សាន ក៏បាត់បង់ជំនួយការខាងផ្នែកយោធា ដែលលោកតាយល់ថា មានភក្ដីភាពចំពោះលោកតាម្នាក់ថែមទៀត ។ នាយទាហានម្នាក់ ដែលជាអ្នកការពារអំណាចយោធារបស់លោកតា សឺន សាន ទប់ទល់ជាមួយក្រុមប្រឆាំង ដែលមានលោក ដៀន ដែល ជាអ្នកដឹកនាំម្នាក់ ក៏ត្រូវអវត្តមាននៅជួរមុខ និង ក៏អស់លទ្ធភាពជួយពង្រឹងលោកតាប្រធានតទៅទៀតបាន ។ នៅសម័យនោះ លោកតា សឺន សាន ចេះតែស្រែកអំពាវនាវឥតឈប់ឈរឲ្យពង្រឹងវិន័យ និង ឯកភាពក្នុងជួរ.រ.ជ.រ.ប.ខ. ព្រោះលោកតាយល់ថាករណីអ្នកស្រី សួន កាសេត និង លោក ថាច់ រ៉េង នេះបានត្រូវឧត្តមសេនីយ៍ថៃខ្លះ និង មន្ត្រីរ.ជ.រ.ប.ខ.ខ្លះបង្កើតឡើង ដើម្បីព្យាយាមកុំឲ្យលោកតាប្រធានមានលទ្ធភាព លូកដៃចូលក្នុងកិច្ចការប្រចាំថ្ងៃផ្នែកយោធាតែប៉ុណ្ណោះ ។

ចំពោះលោកតា សឺន សាន វិន័យ និង ឯកភាព បានន័យថាទាំងអស់គ្នាត្រូវតែដើរតាមការដឹកនាំរបស់លោកតាជាដាច់ខាត ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលលោកតាសង្ស័យថាមន្ត្រីខ្លះដូចជាលោក នាង ជិនហាន និង ហ្គាហ្វា បានព្យាយាមធ្វើឲ្យលោកតានៅឯកោដាច់ឆ្ងាយពីកងទ័ព និង ពីមនុស្សជំនិតៗរបស់លោកតា ។

## មហាសន្និបាតរ.ជ.រ.ប.ខ.

នៅខែ មករា ១៩៨៤ លោកតាប្រធាន ធ្វើដំណើរទៅតាមជំរុំទាំងអស់របស់ រ.ជ.រ.ប.ខ.នៅតាមទល់ដែនខ្មែរ-ថៃ ។ នៅជំរុំនីមួយៗ លោកតាស្នើសុំឲ្យប្រជាពលរដ្ឋទាំងទាហានទាំងស៊ីវិល ពិនិត្យផ្តល់នូវអាណត្តិដឹកនាំរ.ជ.រ.ប.ខ.ជូនលោកតាតទៅទៀត ។ នៅទីណាដែលលោកតាស្នើសុំ ប្រជាពលរដ្ឋ និង យុទ្ធជនតែងលើកដៃគាំទ្រជានិច្ច ។ នៅថ្ងៃទី ២៨ មករា ១៩៨៤ រ.ជ.រ.ប.ខ.បានរៀបចំប្រជុំជាមហាសន្និបាតនៅជំរុំអំពិល[173] ។ តាមពិតទៅ លោកតា សឺន សាន មានបំណងរៀបចំជាសមាជ ដែលអាចផ្តល់អំណាចធំទូលាយហើយ ដែលអាចធ្វើវិសោធនកម្មលើបទបញ្ញត្តិទាំងឡាយស្តីពីការដឹកនាំរ.ជ.រ.ប.ខ.។ ក៏ប៉ុន្តែ កាលពីខែ មេសា ឆ្នាំ ១៩៨០ សមាជទី១ បានសម្រេចថារ.ជ.រ.ប.ខ. នឹងរៀបចំសមាជលើកទី២របស់ខ្លួននៅលើទឹកដីខ្មែរ ក្រោយពីបានរំដោះចេញពីការកាន់កាប់របស់កងទ័ពវៀតណាមតែប៉ុណ្ណោះ ។ នៅមហាសន្និបាតនោះ លោកតា សឺន សាន ក៏ត្រូវបានទទួលស្គាល់ឲ្យបន្តដឹកនាំរ.ជ.រ.ប.ខ.តទៅទៀត ។ លោកតាប្រធានថ្លែងថា៖ "ដោយសារអំណាច និង បុព្វសិទ្ធិដែលប្រជាពលរដ្ឋរួមទាំងស៊ីវិល និង ទាហានផ្តល់ដល់ខ្ញុំ នោះគឺជាករណីយកិច្ច និង ការទទួលខុសត្រូវរបស់ខ្ញុំទាំងស្រុង ដើម្បីដឹកនាំរ.ជ.រ.ប.ខ.ឆ្ពោះទៅ

---

[173] KPNLF Bulletin, February 6, 1982. pp. 18-20.

សម្រេចគោលបំណង និង គោលដៅដែលបានកំណត់រួចហើយ ។ ខ្ញុំត្រូវទទួលខុសត្រូវចំពោះប្រជាជាតិខ្មែរ ទាំងនូវជោគជ័យ ទាំងនូវបរាជ័យនៃបេសកកម្មដ៏ពិសិដ្ឋដែលបងប្អូនជនរួមជាតិបានប្រគល់ឲកយខ្ញុំ" ។ នៅក្នុងឱកាសនោះ លោកតា សឺន សាន ក៏បានប្រកាសបញ្ឈប់គណៈកម្មាធិការអគ្គសេនា ហើយបានប្រកាសតែងតាំង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការពេញទី ដោយមាន លោក ព្រុំ វិត ជានាយអគ្គសេនាធិការរងទី១ ទទួលបន្ទុកកិច្ចការយោធា និង លោក ហ៊ីង គន្ធុន ជានាយអគ្គសេនាធិការរងទី២ ទទួលបន្ទុកកិច្ចការស៊ីវិល ។ មិនតែប៉ុណ្ណោះ លោកតាបានសម្រេចជោគជ័យក្នុងការសុំឲ្យមហាសន្និបាត ធ្វើវិសោធនកម្មកែសម្រួលតួនាទីរបស់គណៈកម្មាធិការប្រតិបត្តិ ហៅកាត់ថាកូម៉ិចទៀតផង ។ តាមរយៈវិសោធនកម្មនេះ លោកតា សឺន សាន ត្រូវបាន ក្លាយជាអ្នកដឹកនាំទាំងស្រុងនៃរ.ជ.រ.ប.ខ. ចំណែកឯគណៈកម្មាធិការប្រតិបត្តិ ក៏គ្រាន់តែមានតួនាទីត្រឹមជាជំនួយការរបស់ប្រធានតែប៉ុណ្ណោះ ។

ក្នុងន័យនេះគណៈកម្មាធិការប្រតិបត្តិមិនអាចសម្រេចអ្វីបានឡើយ បើគ្មានការយល់ព្រម ឬ គ្មានការផ្តល់អនុសាសន៍ពីប្រធានរ.ជ.រ.ប.ខ. ។ ដូច្នេះគណៈកម្មាធិការប្រតិបត្តិ មិនអាចបញ្ជាកងទ័ព ឬ ប្រើប្រាស់រដ្ឋបាលស៊ីវិល ឬ ដាក់ចេញនូវបន្ទាត់នយោបាយ ឬ ការណែនាំខាងការទូត ដោយគ្មានការយល់ព្រម ឬ ទទួលអនុសាសន៍ពីប្រធានរ.ជ.រ.ប.ខ.បានឡើយ ។ វិសោធនកម្មនេះ បានឃ្លាតចាកឆ្ងាយពីសេចក្តីសម្រេចដំបូង ដែលផ្តល់តួនាទីដឹកនាំកំពូលដល់គណៈកម្មាធិការប្រតិបត្តិក្នុងលក្ខណៈដឹកនាំជាសមូហភាព មកជាលក្ខណៈដឹកនាំផ្តាច់មុខ (ខ្ញុំមិននិយាយថាផ្តាច់ការទេ) របស់លោកតា សឺន សាន ទៅវិញ ។ តាមសេចក្តីសំរេចរបស់រ.ជ.រ.ប.ខ. ក្រោយពីបានប្រកាសបង្កើតជាផ្លូវការភ្លាម នៅឆ្នាំ ១៩៧៩ បានកំណត់ថាគណៈកម្មាធិការប្រតិបត្តិមានភារកិច្ចដឹកនាំរ.ជ.រ.ប.ខ.ទាំងស្រុង ។ គណៈកម្មាធិ

ការនេះជាអ្នកសម្រេចសកម្មភាពការងារទាំងអស់របស់រណសិរ្ស រួមទាំងដឹកនាំការងារខាងការទូត កំណត់បន្ទាត់នយោបាយ ប្រើប្រាស់រដ្ឋបាល និង បញ្ជាកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។

## ខ្ញុំត្រឡប់មកបាងកកវិញ ដើម្បីធ្វើកាកបាតក្រហម

បន្ទាប់ពីគណៈកម្មាធិការបណ្ដោះអាសន្ននៃអគ្គសេនាធិការ បានបញ្ចប់ភារកិច្ច ខ្ញុំក៏វិលត្រឡប់ទៅកាន់ទីស្នាក់ការធំរបស់រ.ជ.រ.ប.ខ. នៅឯទីក្រុងបាងកកវិញ ដើម្បីទៅជួយការងាររបស់លោក សឺន ស៊ូបែរ្ត៍ កូនលោកតា សឺន សាន ខាងផ្នែកកាកបាតក្រហម ដោយហេតុថា រ.ជ.ប.ខ. ទើបតែបង្កើតអង្គការមនុស្សធម៌នេះជាលើកដំបូង ។ លោក សឺន ស៊ូបែរ្ត៍ ជាប្រធាន ឯខ្ញុំធ្វើជាអគ្គលេខាធិការ និង មិនយូរប៉ុន្មាន បន្ទាប់មកខ្ញុំជាហិរញ្ញឹកនៃកាកបាតរ.ជ.រ.ប.ខ.រហូតមក។ វត្តមានរបស់ខ្ញុំនៅទីក្រុងបាងកក បានជួយពង្រឹងឡើងវិញខ្លះនូវទឹកចិត្តនៃមនុស្សជំនិតរបស់លោកតាប្រធានដែលបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការចាកចេញរបស់លោក ថាច់ រ៉េង និង លោកស្រី សួន កាសេត ។

## សម្ដេច ប៉ែន នុត ប្រដៅឲ្យពួកយើងរួបរួមគ្នា

នៅខែ កុម្ភៈ ១៩៨៤ ខ្ញុំធ្វើដំណើរទៅទីក្រុងប៉ារីស ដែលនៅទីនោះ ខ្ញុំបានជួបសម្ដេច ប៉ែន នុត អតីតនាយករដ្ឋមន្ត្រីខ្មែរ និង ជាឥស្សរជននយោបាយជាន់ខ្ពស់ដែលខ្មែរភាគច្រើនមានការគោរពកោតខ្លាច។ សម្ដេចជារដ្ឋបុរសម្នាក់ដែលធ្លាប់មានភក្ដីភាពយ៉ាងស្មោះស្ម័គ្របំផុត ចំពោះសម្ដេច សីហនុ និង ចំពោះរាជបល្ល័ង្កខ្មែរ ។ ក៏ប៉ុន្តែ ចាប់ពីពេលដែលបានរួចចេញពីរបបខ្មែរក្រហមមក សម្ដេច ប៉ែន នុត

មិនបាននៅបំរើនយោបាយសម្តេច សីហនុ ទៀតទេ ។ សម្តេចបានបញ្ជូនកូនប្រុសទាំង ៤ នាក់របស់សម្តេច ឲ្យមកបំរើរ.ជ.រ.ប.ខ.របស់លោកតា សឺន សាន ទៅវិញ ។ នៅក្នុងចិត្តរបស់ខ្ញុំៗមានមោទនភាពណាស់ ដែលបានទៅរាយការណ៍ផ្ទាល់ជូនសម្តេចអំពីលទ្ធនៃមហាសន្និបាតរ.ជ.រ.ប.ខ. ព្រមទាំងអំពីការតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការនៃក.ជ.រ.ប.ខ. និងការធ្វើវិសោធនកម្មនៃលក្ខន្តិកៈរបស់គណៈកម្មាធិការប្រតិបត្តិ (កូមិុច) ដែលត្រូវប្តូរពីភារកិច្ចដឹកនាំកំពូល មកជាជំនួយការឲ្យប្រធាន រ.ជ.រ.ប.ខ.ទៅវិញ ។ ខ្ញុំខំពន្យល់សម្តេច ប៉ែន នុត ថាការកែប្រែលក្ខន្តិកៈនេះ ធ្វើឡើងក្នុងន័យរក្សាស្ថេរភាពនៃការដឹកនាំរបស់រ.ជ.រ.ប.ខ.តែប៉ុណ្ណោះ ។ តាមពិតទៅ សម្តេច ប៉ែន នុត ជាអ្នកនយោបាយដើងចាស់មានបទពិសោធន៍យ៉ាងបរិបូណ៌ អាចធ្វើវិភាគបានម៉ត់ចត់ណាស់ ។ សម្តេច អាចប៉ាន់ប្រមាណមើលកម្លាំងរបស់ចលនាតស៊ូមិនមែនកុម្មុយនីស្តបានយ៉ាងត្រឹមត្រូវ ។ ទោះបីជាមានអាយុច្រើនយ៉ាងណាក៏ដោយ (ប្រហែលជិត ៨០ ឆ្នាំ)និង ទោះបីជាសម្តេចមានសម្លេងញ័រៗដែលជានិមិត្តសញ្ញានៃបុគ្គលិកលក្ខណៈរបស់សម្តេច ដែលខ្មែរយើងសម្គាល់ជាយូរមកហើយនោះ សម្តេច ប៉ែន នុត មានប្រសាសន៍ចំៗលើបញ្ហា ។ ជាដំបូង សម្តេចសួរថា តើឧត្តមសេនីយ ថាច់ រ៉េង នឹងវិលត្រឡប់ទៅសមរភូមិមុខវិញនៅពេលណា ។ លោក ថាច់ រ៉េង ដែលទៅជាមួយខ្ញុំនាពេលនោះ ឆ្លើយបែបមិនសូវច្បាស់លាស់ថា កំពុងរង់ចាំតែសញ្ញាភ្លើងខៀវពីបាងកកតែប៉ុណ្ណោះ ។ បើបានការអនុញ្ញាតឲ្យចូលទៅថ្ងៃណាពេលណា គាត់អាចចេញដំណើរទៅភ្លាម ព្រោះបានត្រៀមរួចជាស្រេចទៅហើយ ។

មែនទែនទៅ ចាប់តាំងពីចាកចេញពីបាងកកមក លោក ថាច់ រ៉េង បានព្យាយាមដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតថៃនៅទីក្រុងប៉ារីស តែពាក្យសុំនោះត្រូវបានបដិសេធជានិច្ច ទោះបីជាលោកតា សឺន សាន បានធ្វើអន្តរាគមន៍ជាច្រើនលើកជា

មួយក្រសួងការបរទេសថៃក៏ដោយ ។ សម្តេច ប៉ែន នុត បានឆ្លើយតបមកខ្ញុំយ៉ាងម៉ឺងម៉ាត់ក្នុងន័យជាអាទិ៍ដូចតទៅនេះ៖ "ខ្ញុំតែងនិយាយថា អស់លោកត្រូវពិនិត្យមើលការរៀបចំផ្ទៃក្នុងរបស់រណសិរ្សនីមួយៗ ។ បញ្ហាផ្ទៃក្នុងនេះ មានសារសំខាន់ណាស់ ។ បើអស់លោកមិនអាចរួបរួមគ្នា (រវាងរ.ជ.រ.ប.ខ. និង ហ៊្មុន ស៊ិន ប៉ិច)ទេ អស់លោកក៏ត្រូវតែខឹតខំកែលំអមុខមាត់របស់អស់លោក ។ អស់លោកហាក់ដូចជាមិនយល់នូវអ្វីដែលហៅថា រណសិរ្សប្រយុទ្ធ និង នូវអ្វីដែលហៅថាគណបក្សនយោបាយ ។ នៅក្នុងរណសិរ្ស គេត្រូវប្រមូលកម្លាំងឲ្យបានខ្លាំង ប្រមូលមនុស្សគាំទ្រឲ្យបានច្រើន ដោយមិនរើសអើងអ្វីឡើយ ។ ផ្ទុយទៅវិញ នៅក្នុងគណបក្សនយោបាយ គេត្រូវជ្រើសយកមនុស្ស ដែលស្មោះត្រង់តាមកំរិតនៃការទុកចិត្ត ។ ខ្ញុំនិយាយនេះ ខ្ញុំនិយាយជាទូទៅទេ មិនសំដៅតែរណសិរ្សរបស់អស់លោក ឬ ចំពោះរណសិរ្សមួយទៀតនោះទេ ។ ដើម្បីជៀសវាងការបែកបាក់ជាក្រុម ជាពួកនោះ អស់លោកត្រូវធ្វើការដើម្បីប្រជាពលរដ្ឋខ្មែរទាំងមូល ដើម្បីប្រជាជាតិខ្មែរ មិនមែនសម្រាប់តែក្រុមរបស់អស់លោកនោះឡើយ" ។

បន្ទាប់ពីជំនួបនេះ ខ្ញុំបានរាយការណ៍ភ្លាមទៅលោកតា សឺន សាន ចំពោះការមិនពេញចិត្តរបស់សម្តេច ប៉ែន នុត[174] ។ តាំងពីពេលនោះមក ខ្ញុំក៏ពុំបានដឹងពិតប្រាកដពីមូលហេតុនៃការខកខាន មិនបានយកអនុសាសន៍របស់មហាសន្និបាត រ.ជ.រ.ប.ខ. ដែលបានសម្រេចកែប្រែលក្ខន្តិកៈគណៈកម្មាធិការប្រតិបត្តិ ឬ កូមិុចឲ្យមានភារកិច្ចបន្ទាប់បន្សំនោះ មកអនុវត្តតទៅទៀតឡើយ ។ សម្តេច ប៉ែន នុត ហាក់ដូចជាមើលឃើញនូវភាពផុយស្រួយនៃការដឹកនាំក្នុងជួររ.ជ.រ.ប.ខ. ហើយសម្តេចក៏មានការចាប់អារម្មណ៍ ចំពោះការបែកបាក់ជាយថាហេតុនៃរ.ជ.រ.ប.ខ.នេះផងដែរ ។

[174] Ieng Mouly, A Son Excellence le Président du Front National de Libération du Peuple Khmer et Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Paris, le 12 mars 1984.

# យន្តការរួម រ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច

នៅខែ មេសា ១៩៨៤ កងទ័ពវៀតណាមបានធ្វើការវាយប្រហារមកលើទីតាំងរ.ជ.រ.ប.ខនៅអំពិល ដែលជាមូលដ្ឋានយោធាផង និង ជាទីជម្រកនៃប្រជាពលរដ្ឋស៊ីវិលប្រមាណ ៣៦.០០០ នាក់ផង ។ កងទ័ពវៀតណាម បានប្រើអាវុធធុនធ្ងន់បាញ់ផ្លោងចូលក្នុងជំរុំ ហើយបានវាយប្រហារក្នុងទ្រង់ទ្រាយធំ លើទីតាំងនានារបស់មូលដ្ឋានអំពិល ។ ក្រោយពីប៉ះទង្គិច និង ពើបប្រយុទ្ធអស់រយៈពេល ១០ ថ្ងៃ កងទ័ពវៀតណាមពុំអាចដណ្តើមទីតាំងរបស់រ.ជ.រ.ប.ខ.បានឡើយ ។ នេះជាជោគជ័យមួយ ដែលធ្វើឲ្យកម្លាំងការពារមូលដ្ឋានអំពិលបានទទួលការកោតសរសើរ និង ការជឿទុកចិត្ត ។ ពេលនោះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ដៀន ដែលបានទទួលស្នាដៃល្អខាងផ្នែកយោធា ធ្វើឲ្យ រ.ជ.រ.ប.ខ. បានទទួលជោគជ័យខាងផ្នែកនយោបាយផងដែរ ។

ដើម្បីសម្របសម្រួលសកម្មភាពគាំទ្រកងកម្លាំងខ្មែរតស៊ូមិនមែនកុម្មុយនីស្ត (NCR : Non Communist Resistance) គឺ រ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច ប្រទេសសមាគមអាស៊ាន បានបង្កើតក្រុមការងារមួយ (Working Group) ដែលមានតំណាងប្រទេសថៃជាប្រធាន ។ នៅពេលនោះ ប្រធានក្រុមការងារគឺលោកហ្វួណា វិស្ណុ ឬ វិស្តុ(ឈ្មោះសម្ងាត់) មែនទែន ឈ្មោះពិតប្រាកដគឺ លោកវរសេនីយឯក ស៊ូរ៉ាយុទ្ធ ជូឡាណន្ត (Surayuth Chulanond) ដែលក្រោយមកឡើងឋានៈជាឧត្តមសេនីយ មេទ័ពថៃ និង ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីក្រោយពីក្រុមយោធាបាន ធ្វើរដ្ឋប្រហារទម្លាក់លោក តាក់ស៊ិន ពីតំណែងនៅឆ្នាំ ២០០៦ ។ នៅពេលដែលប្រទេសចិនជួយគាំទ្រយ៉ាងពេញទំហឹងខាងផ្នែកយោធាដល់ក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ក្រុមការងារបានខិតខំគាំទ្រភាគីខ្មែរមិន

មែនកុម្មុយនីស្ត ។ ក្រុមនេះ បានលើកទឹកចិត្តឲ្យ រ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច បង្កើតយន្តការរួមមួយ ដើម្បីសហការគ្នាក្នុងផ្នែកប្រតិបត្តិការ យោធា ឃោសនា និង ទំនាក់ទំនងសាធារណៈ ។

កាលពេលនោះ លោកតា សឺន សាន ហាក់ដូចជាមិនសូវចង់បង្កើតយន្តការរួមនេះប៉ុន្មានទេ ព្រោះការគ្រប់គ្រងរបស់យន្តការមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកតាផង និង ម្យ៉ាងទៀត លោកតានៅមានជំនឿថារ.ជ.រ.ប.ខ.ជាចលនាតស៊ូមានរូបរាងធំធាត់ជាង ហ៊្វុន ស៊ិន ប៉ិច ។ បើបង្កើតយន្តការរួមបានន័យថាជំនួយត្រូវចែកជាពីរស្មើគ្នា នៅពេលដែលរ.ជ.រ.ប.ខ.ធំជាង ត្រូវទទួលចំណែកច្រើនជាង ។ នៅអង្គប្រជុំមួយ ខ្ញុំធ្លាប់ឮលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានខិតខំពន្យល់លោកតា សឺន សាន ឲ្យធ្វើសហការជាមួយ ហ៊្វុន ស៊ិន ប៉ិច ដោយប្រៀបប្រដូចថា៖ "បងជួយដឹកដៃប្អូនឲ្យដើរ" ក្នុងន័យបងគឺ រ.ជ.រ.ប.ខ ឯប្អូនគឺ ហ៊្វុន ស៊ិន ប៉ិច ។ នៅថ្ងៃទី ២ ឧសភា ១៩៨៤ ចលនាតស៊ូមិនមែនកុម្មុយនីស្តទាំងពីរ រ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច បានបង្កើតគណៈកម្មាធិការមួយសម្រាប់ការផ្សព្វផ្សាយតាមវិទ្យុ ។ គេបាននាំគ្នាបង្កើតវិទ្យុផ្សាយសម្លេងមួយឈ្មោះហៅថា "វិទ្យុសម្លេងខ្មែរ" ។

## ពែកមីកូ និង ម៉ាយ៉ាឡាប់

នៅថ្ងៃទី ៧ ឧសភា ១៩៨៤ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលនៅពេលនោះជាព្រះរាជតំណាងសម្តេចសីហនុ បានធ្វើជាអធិបតីនៃពីធីបង្កើតជាផ្លូវការនូវគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកកិច្ចសហការយោធា (Permanent Military Committee for Coordination) ឬហៅកាត់ថា ពែកមីកូ (Permico) ។ ពួកក្រុមការងារបានប្រគល់តួនាទីប្រធាន

ពែកមីកូ ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ក្រោយពីមានការបង្កើតពែកមីកូ នេះជាផ្លូវការមក លោកឧត្តមសេនីយ សក់ ស៊ុតសាខន លោក ហ្គាហ្វា និង សហការីមួយចំនួនទៀត បានរើផ្លាន់ចាកចេញពីទីស្នាក់ការ រ.ជ.រ.ប.ខ. នៅម៉ាយ៉ាឡាប់ទៅស្នាក់នៅទីកន្លែងថ្មី ដែលជាទីកន្លែងធ្វើការរបស់ពែកមីកូវិញ ដាច់ដោយឡែកពីពួកយើង ។ តាមពិតទៅក្រុមការងារបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ចំណាយទាំងអស់របស់ពែកមីកូ ។

តាំងពីពេលនោះមក រ.ជ.រ.ប.ខ.ត្រូវបានចែកជាពីរក្រុម ក្រុមពែកមីកូ ដែលជាទីតាំងរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាក្រុមយោធា និង ក្រុមមួយទៀត ក្រុមម៉ាយ៉ាឡាប់ ជាទីតាំងរបស់លោកតា សឺន សាន ជាក្រុម នយោបាយ ។ ក្រុមពែកមីកូ មានជីវភាពរស់នៅហ៊ឺហាហ៊ឺកហ៊ាក់ជាងក្រុមម៉ាយ៉ាឡាប់ ព្រោះពួកគេមានសេរីភាពធ្វើដំណើរចេញចូលទាំងយប់ទាំងថ្ងៃ អាចចេញទៅកំសាន្តស៊ីផឹកខាងក្រៅបានដោយសេរី ។ ចំណែកខាងក្រុមម៉ាយ៉ាឡាប់ ជីវភាព រស់នៅមានសភាពស្រគត់ស្រគំ មិនចេញក្រៅទៅផឹកស៊ីផ្តេសផ្តាស បាយរួម សម្រាករួម ហើយគ្មានប្រាក់ខែសំរាប់ចំណាយផ្ទាល់ខ្លួនម្នាក់ៗទេ ។ លោកតា សឺន សាន មិនពេញចិត្តចំពោះការចាត់ចែងរបស់ក្រុមការងារ ដែលនាំឲ្យមានការបែងចែកជាក្រុមជាពួកយ៉ាងដូច្នេះទេ ព្រោះថាការនេះអាចធ្វើឲ្យក្រុមយោធាមានលទ្ធភាពផ្តាច់ខ្លួនលែងស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់លោកតាតទៅទៀត ។ ជាមួយគ្នានោះ លោកតាប្រធានក៏មិនពេញចិត្តចំពោះក្រុមការងារ ដែលចាត់ចែងការងារដោយមិនពិគ្រោះជាមួយលោកតា ឬ ជាមួយសហការីជិតស្និទ្ធជាកូនចៅ ។ ធ្វើយ៉ាងនេះហាក់ដូចជាជួយឲ្យក្រុមយោធាអាចប្រណាំងប្រជែងដណ្តើមអំណាចដឹកនាំ រ.ជ.រ.ប.ខ. ពីលោកតាផង ។

ឯចំណែកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ហាក់ដូចជាកាន់តែលំអៀងបន្តិចម្តងៗទៅរកក្រុមប្រឆាំងគឺ ក្រុមលោក ដៀន ដែល លោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ដែលបានប្រមូលផ្តុំទៅនៅជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឯពែកមីកូ ។ តាមពិតទៅ ក្រុមប្រឆាំងជាមួយលោកតា សឺន សាន ទាំងអស់ បាននាំគ្នាទៅជ្រកក្រោមម្លប់របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន អស់ពេលជាយូរមកហើយ ។ លោកតា សឺន សាន តែងតែយល់ថាក្នុង ឋានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានសិទ្ធិទទួលខុសត្រូវទាំងស្រុងក្នុង ជួរ រ.ជ.រ.ប.ខ. រួមទាំងការទទួលខុសត្រូវខាងផ្នែកយោធាផង ។ លោកតា មិនអាចទទួលយកបានទេនូវការបែងចែកភារកិច្ច ជាពិសេស ទុកភារកិច្ចខាងផ្នែកយោធាឲ្យក្រុមយោធាកាន់កាប់ផ្តាច់ចេញពីអំណាចទាំងមូលរបស់ប្រធាន ។ ក្នុងការប៉ុនប៉ងការពារអំណាចបញ្ជាការយោធា លោកតា សឺន សាន ខិតខំស្វែងរកមធ្យោបាយគ្រប់យ៉ាងដើម្បី បញ្ចូលមនុស្សជំនិតរបស់លោកតាដូចជាឧត្តមសេនីយ ថាច់ រ៉េង ជាដើមឲ្យបានចូលក្នុងរចនាសម្ព័ន្ធកងទ័ពឡើងវិញ ។

## ទស្សនកិច្ចនៅកូរ៉េខាងត្បូង

ពីថ្ងៃទី ៥ ទៅ ៨ មិថុនា ១៩៨៤ លោកតា សឺន សាន បានទៅធ្វើទស្សនកិច្ចផ្លូវការជាលើកទី១ នៅសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងឋានៈជាសម្ព័ន្ធមិត្តម្នាក់នៃលោកសេរី លោកតាចង់ឲ្យឃើញការខុសគ្នារវាងលោកតា និង សម្តេច សីហនុ ដែលចាប់តាំងពីរដ្ឋប្រហារឆ្នាំ ១៩៧០ មក បានយកទីក្រុងព្យុងយ៉ាង កូរ៉េខាងជើង ជាទីតាំងនៃការគង់ប្រថាប់នៅក្រៅប្រទេសរបស់ព្រះអង្គ ។ ម្យ៉ាងទៀត ពួកយើងចង់បង្ហាញថា កម្ពុជាជាមិត្តជាមួយកូរ៉េទាំងមូល មិនមែនចំពោះកូរ៉េខាងជើងកុម្មុយ

នីស្តតែមួយនោះឡើយ ។ ពីទីក្រុងប៉ារីសប្រទេសបារាំង លោកតានាំលោក ថាច់ រ៉េង ទៅជាមួយក្នុងទស្សនកិច្ចនៅកូរ៉េនេះ ។ តាមពិតទៅ ស្ទើរតែនៅរាល់ទស្សនកិច្ចនានានៅក្រៅប្រទេស លោកតា សឹន សាន ចូលចិត្តបញ្ចេញលោក ថាច់ រ៉េង ពីប្រទេសបារាំង ឲ្យអមដំណើរជាមួយ ដើម្បីបង្ហាញពិភពលោកថាលោក ថាច់ រ៉េង ជាមនុស្សជំនិត និង ដើម្បីបង្ហាញថាលោកតានៅមានមន្ត្រីយោធា ដែលអាចប្រើការបាន ប្រសិនបើមានសេចក្តីត្រូវការក្នុងជួរកងទ័ព ។ ក្រៅពីលោក ថាច់ រ៉េង នៅមានអ្នកអមដំណើរឯទៀតក្នុងពេលនោះគឺ៖ លោក ប៊ុន សាយ លោក ហ្គាហ្វា ពាងម៉េត លោក សឹន ស៊ូប៊ែរ្ត៍ និង រូបខ្ញុំ អៀង មូលី ។ នៅពេលនោះ ទោះបីខ្ញុំជាសមាជិកម្នាក់នៃខុទ្ទកាល័យនាយករដ្ឋមន្ត្រីក៏ដោយ ហើយប្រហែលជាខ្ញុំមានអាយុក្មេងជាងគេ ទើបគេចាត់ឲ្យខ្ញុំទទួលភារកិច្ចជាមន្ត្រីពិធីការ ។ ដំណើរទស្សនកិច្ចនេះ ក៏ជាឱកាសលើកទី១របស់ខ្ញុំក្នុងការអមដំណើរនាយករដ្ឋមន្ត្រី ក្នុងទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ។ នៅឱកាសនោះ លោកតា សឹន សាន បានជួបពិភាក្សាការងារជាមួយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលកូរ៉េ រួមទាំងនាយករដ្ឋមន្ត្រីនៃប្រទេសជាមិត្តនេះផង ។

លោកតាប្រធានមានការពេញចិត្តណាស់ចំពោះដំណើរទស្សនកិច្ចជាផ្លូវការនេះ ។ មុនពេលគណៈប្រតិភូត្រឡប់ពីក្រុងសេអ៊ូលវិញនោះ លោកតាបានប្រកាសនៅក្នុងសន្និសីទសារព័ត៌មានមួយថា៖ "ទស្សនកិច្ចរបស់ពួកយើងនៅសាធារណរដ្ឋកូរ៉េ បានទទួលផល និង ផ្លែផ្កាល្អ" ។ តាមពិតទៅ ប្រទេសកូរ៉េខាងត្បូង បានផ្តល់ជំនួយខាងហិរញ្ញវត្ថុខ្លះដល់ចលនាតស៊ូរបស់យើង តាមរយៈស្ថានទូតកូរ៉េប្រចាំទីក្រុងបាងកក ។ ខ្ញុំបានទទួលព័ត៌មានថា ក្នុងឱកាសមួយនោះលោក ហ្គាហ្វា បានត្រូវស្ថានទូតហៅទៅទទួលប្រាក់ នៅពេលអវត្តមានលោកតា សឹន សាន ។ បានប្រាក់ដល់ដៃហើយ លោក ហ្គាហ្វា បានយកមួយចំនួនទៅចែកចាយដល់មេ

ទាហានខ្លះ ដោយគ្មានការអនុញ្ញាតពីប្រធាន និង ដោយពុំបានរាយការណ៍ជូនគាត់ឡើយ ។ ទង្វើនេះ បានធ្វើឲ្យលោកតាប្រធានក្រេវក្រោធយ៉ាងខ្លាំង ។ លោកតា សឺន សាន សម្គាល់ថាអាកប្បកិរិយាបែបនេះ ជាការខ្វះវិន័យ និង ល្មើសលើទំនុកចិត្ត ។ នោះក៏ពង្រីកការថ្នាំងថ្នាក់របស់លោកតាប្រធាន ចំពោះលោក ហ្គាហ្វា ពាង ម៉េត ថែមមួយកំរិតទៀត ។

## លោក ដៀន ដែល បញ្ជាឲ្យបោះបង់ជំរុំអំពិល

លោកតា សឺន សាន មានការបារម្ភយ៉ាងខ្លាំងចំពោះឯកភាពផ្ទៃក្នុងនៃចលនារ.ជ.រ.ប.ខ. ។ ឥទ្ធិពលរបស់លោកតាកាន់តែស្រុតចុះជាលំដាប់ ជាពិសេសក្នុងបណ្តាសមាជិកកូម៉ិច និង មេទាហានមួយចំនួន ។ រាល់ពេលប្រជុំម្តងៗ លោកតា សឺន សាន តែងតែអំពាវនាវឲ្យពង្រឹងឯកភាព និង សាមគ្គីភាពជានិច្ច ។ បន្ថែមលើសនេះទៅទៀត ឆ្នាំ ១៩៨៤ ជាឆ្នាំមួយដែលរ.ជ.រ.ប.ខ. ត្រូវទទួលរងនូវការវាយប្រហារដ៏ខ្លាំងក្លាពីសំណាក់កងទ័ពវៀតណាម ។ ប្រហែលជាដើម្បីសងសឹក ព្រោះពួកគេវាយដណ្តើមបញ្ជាការដ្ឋានក.ជ.រ.ប.ខ.នៅអំពិលមិនបាន ទើបលើកនេះ កងទ័ពវៀតណាមបានបង្កើនការវាយប្រហារកំទេចចោលទាំងអស់នូវជំរុំ រ.ជ.រ.ប.ខ. តាមជាយដែនខ្មែរ-ថៃ ។ នៅថ្ងៃទី ៨ វិច្ឆិកា ១៩៨៤ កងទ័ពនេះ បានវាយប្រហារយ៉ាងខ្លាំងទៅលើកម្លាំងប្រមូលផ្តុំរបស់កងទ័ពនងចាន់ ដែលទើបកសាងឡើងវិញ ។ បន្ទាប់មក នៅថ្ងៃទី ៨ ធ្នូ ១៩៨៤ ជំរុំណាំយឺន ត្រូវទទួលរងការវាយប្រហារ ។ ថ្ងៃទី ១១ ធ្នូ ១៩៨៤ ជំរុំសុខសាន្ត ថ្ងៃទី ២៥ ធ្នូ ជំរុំអូរបុក (ឬសន្តិសុខ) និង ជំរុំប្ញទ្ធីសែន ក៏រងការវាយប្រហារដែរ ។ ក៏ប៉ុន្តែ គោលដៅសំខាន់ជាងគេរបស់កងទ័ពវៀតណាមគឺ ជំរុំអំពិលដែលជាបញ្ជាការដ្ឋានដ៏ធំបំផុតរបស់

រ.ជ.រ.ប.ខ ហើយដែលតាំងពីខែ មេសា កន្លងមក ពួកយើងសម្គាល់ថា ជាទីតាំងដែលមានការការពាររឹងមាំ មិនអាចដណ្តើមបានដោយស្រួលៗឡើយ ។ មែនទែនទៅ ចាប់ពីថ្ងៃទី ២២ ធ្នូ មក មូលដ្ឋានអំពិលត្រូវទទួលរងការវាយប្រហារដ៏ធ្ងន់ធ្ងរ ជាទីលានបង្ហូរឈាមដ៏សាហាវមួយ ។ មកដល់ថ្ងៃទី ៦ មករា ១៩៨៥ ជំរុំ ៥ ក្នុងចំណោមជំរុំទាំង ៨ របស់ រ.ជ.រ.ប.ខ. ត្រូវបែកខ្ទេចក្រោមការវាយប្រហារ ។ ការប្រយុទ្ធគ្នានៅអំពិល ត្រូវបានបន្តរហូតដល់ថ្ងៃ ៨ មករា ១៩៨៥ នៅពេលដែលលោកឧត្តមសេនីយ ដៀន ដែល ចេញបញ្ជាឲ្យយុទ្ធជនរបស់គាត់បោះបង់ចោលជំរុំនៅម៉ោង ១១ ព្រឹក[175]។ នៅពេលរសៀល ទីបញ្ជាការនៃអគ្គសេនាធិការត្រូវបានបោះបង់ ។ ការបាត់បង់ជំរុំអំពិល ជាព្រឹត្តិការណ៍ថ្មីមួយ ដែលតម្រូវឲ្យមានការបំបែកប្រជាពលរដ្ឋស៊ីវិលចេញពីយុទ្ធជនគឺ ស៊ីវិលត្រូវជន្លៀសចូលទឹកដីថៃ ឯទាហានត្រូវពង្រាយតាមជាយដែន ។ ចាប់ពីបានទទួលមេរៀននៃការប្រយុទ្ធនៅអំពិលមក មេដឹកនាំយោធារបស់យើង កាន់តែនាំគ្នានិយាយ ឬ គិតគូរអំពីធ្វើសង្គ្រាមតាមយុទ្ធសាស្ត្រ ឬ កលយុទ្ធទ័ពព្រៃ ។

# ការងារដ៏សំខាន់នៅកាកបាតក្រហម

ចាប់តាំងពីពេលបានវិលមករស់នៅឯបាងកកវិញ ខ្ញុំមានការជាប់រវល់យ៉ាងខ្លាំងក្នុងកិច្ចការរបស់កាកបាតក្រហម រ.ជ.រ.ប.ខ. ។ នៅពេលនោះ ខ្ញុំ និង លោក សឺន ស៊ូប៊ែរ្ត៍ បានរួមរួបគ្នាធ្វើការបានល្អណាស់ ។ លោក សឺន ស៊ូប៊ែរ្ត៍ ដែលជាកូនប្រុសច្បងរបស់លោកតា សឺន សាន ក្នុងឋានៈជាប្រធានមានភារកិច្ចច្រើនខាងផ្នែកទំនាក់ទំនងសាធារណៈ ។ ចំណែកខ្ញុំៗត្រូវបានទទួលលទ្ធភាពឲ្យចាត់ចែងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុផង កិច្ចការប្រតិបត្តិផង ។ ក្នុងសម័យនោះ លោកតា សឺន សាន

[175] Khmer People’s National Liberation Front, Military Situation at Banteay Ampil, January 8, 1985 at 2 p.m.

ទទួលបាននូវការគាំទ្រពីជនរួមជាតិនៅក្រៅប្រទេសច្រើនគួរសមដែរ ។ តាមរយៈកេរ្តិ៍ឈ្មោះល្អនៅក្រៅប្រទេសរបស់លោកតាប្រធាននេះ កាកបាតក្រហមរ.ជ.រ.ប.ខ. ក៏ទទួលបាននូវការគាំទ្រខាងហិរញ្ញវត្ថុមួយចំនួន ពីសំណាក់ខ្មែរនៅបរទេស ពីសំណាក់អង្គការអន្តរជាតិនានា និង ពីមូលនិធិខ្លះផង ។

នៅចុងឆ្នាំ ១៩៨៤ កាកបាតក្រហម រ.ជ.រ.ប.ខ. ក៏បានទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិអាឡឺម៉ង់មួយឈ្មោះ ខុន រ៉ាដ អាឌិនណៅអែរ (Konrad Adenauer Foundation)[176] ។ ដោយសារជំនួយនេះ ពួកយើងបានបង្កើតពុទ្ធិកសមាគម មជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាមួយ និង មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមួយ ។ យើងមានគំនិតថា បន្ទាប់ពីបានធ្លាក់ចូលក្នុងរណ្ដៅសង្គ្រាម និង របបកុម្មុយនីស្ដផ្ដាច់ការមក យើងត្រូវកសាងព្រះពុទ្ធសាសនា វប្បធម៌ និង ទំនៀមទម្លាប់របស់ខ្មែរឲ្យរស់រានមានជីវិតឡើងវិញ ។ យើងជឿថាព្រះពុទ្ធសាសនា និង វប្បធម៌ទំនៀមទម្លាប់ខ្មែរ ជាចំណុចសញ្ញាឲ្យខ្មែរមកកពប្រសព្វជួបជុំគ្នាវិញ ក្នុងនាមជាខ្មែរដែលត្រូវបានបែកបាក់ ខូចខាត វង្វេងចូលទៅក្នុងព្រៃជ្រៅនៃមនោគមវិជ្ជាដែលបានបំបែកខ្មែរជាបក្ស ជាពួក រួចកាប់សម្លាប់គ្នានោះ ។

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជួយបណ្ដុះបណ្ដាលជាងជួសជុលគ្រឿងយន្ត (ឡាន និង ម៉ូតូ) ជាងភ្លើង ជាងជួសជុលវិទ្យុទូរទស្សន៍ ដែលជាតម្រូវការដើម្បីកសាងប្រទេសឡើងវិញ ។ ក្រៅពីនេះ យើងខិតខំឲ្យមានការបង្រៀនភាសាបរទេស ជាពិសេស អង់គ្លេស និង បន្តបន្ទាប់មក ក៏មានបន្ថែមវិជ្ជាកុំព្យូទ័រថែមទៀត ដល់បងប្អូនដែលរស់នៅក្នុងជំរុំទៀតផង ។ និយាយរួមទៅ មូលនិធិ ខុនរ៉ាដ អាឌិនណៅអែរ ដែលនៅពេលនោះ មានលោក វ៉ុលហ្គង់ ហ្វុនអែរ ហ្វា (Wolgang

---

[176] មូលនិធិអាឡឺម៉ង់នេះ ផ្ដល់ជំនួយហិរញ្ញវត្ថុ ក្នុងរង្វង់ ៣០០ ០០០ ម៉ាកអាឡឺម៉ង់ ក្នុងមួយឆ្នាំៗរហូតដល់ពេលមាតុភូមិនិវត្តន៍ ។

Von Erffa)ជាអ្នកតំណាងប្រចាំទីក្រុងបាងកក បានជួយរ.ជ.រ.ប.ខ. ក្នុងភារកិច្ចដ៏ធំធេង និង ធ្ងន់ធ្ងររបស់យើងបានល្អណាស់ ។ ដោយសារកាកបាតក្រហមរ.ជ.រ.ប.ខ.មានដំណើរការកាន់តែសកម្មឡើង ខ្ញុំ និង លោក ស៊ូបែរ្ត៍ ហាក់ដូចជាកាន់តែមានស្វ័យភាពច្រើនឡើងៗពីការិយាល័យរបស់លោកអគ្គលេខាធិការ នាង ជិនហាន ។ ខ្ញុំកាន់តែមានលទ្ធភាពក្នុងការរៀបចំសម្របសម្រួលសកម្មភាពសំខាន់ៗ ដើម្បីគាំទ្រលោកតា សឺន សាន។ ដោយយកទង់កាកបាតក្រហមមកប្រើ ខ្ញុំរកឃើញមធ្យោបាយធ្វើដំណើរក្នុងទឹកដីថៃកាន់តែស្រួលជាងមុន កាន់តែសេរីជាងមុន ។ ខ្ញុំទិញរថយន្ត មីនីប៊ុស (mini-bus)មួយ និង ជួលជនជាតិថៃម្នាក់ ដែលចេះខ្មែរបន្តិចបន្តួចជាអ្នកបើកបរ ។ ដូច្នេះ នៅទីបញ្ចប់ ខ្ញុំអាចធ្វើដំណើរទៅទីណាក៏បាន ដោយមិនចាំបាច់ឲ្យហ្លួណាថៃអមដំណើរជាមួយដូចមុនឡើយ ។

## ពួកទាហានទាមទារឯករាជ្យពីលោកតា សឺន សាន

ការបំបែកប្រជាពលរដ្ឋស៊ីវិលចេញពីយុទ្ធជន បាននាំឲ្យអ្នកដឹកនាំយោធាគឺអស់លោកមេទ័ពឧត្តមសេនីយទាំងឡាយ កើតគំនិតទាមទាររកឯករាជ្យពីលោកតា សឺន សាន ដែលនៅតែប្រកាន់ថា ក្នុងឋានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានអំណាចបញ្ជាកងទ័ព ។ តាមការរៀបចំបង្កើតរ.ជ.រ.ប.ខ. តាំងពីដើមមកប្រធានជាអគ្គមេបញ្ជាការកងទ័ព ។ ក៏ប៉ុន្តែ ដោយមានការគាបសង្កត់ពីក្រុមការងារនៅទីបំផុត លោកតាប្រធាន ក៏ត្រូវបង្ខំចិត្តតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការកងទ័ព ឯលោកឧត្តមសេនីយ ដៀន ដែល ជានាយអគ្គសេនាធិការ នៅថ្ងៃទី ១ ឧសភា ១៩៨៥ ។ ក្នុងការតែងតាំងនោះ ដើម្បីបញ្ជាក់ថា លោកតាប្រធាននៅតែជាអ្នកដឹកនាំកំពូលរបស់រ.ជ.រ.ប.ខ. នោះក្រឹត្យ

តែងតាំងសរសេរជាអាទិ៍ថាៈ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានទទួលប្រតិភូកម្មផ្ទាល់ពីប្រធានក្នុងមុខតំណែងជាអគ្គបញ្ជាការ ក.ជ.រ.ប.ខ. ។ លោកតាមានជំនឿថា អាចដកប្រតិភូកម្មនេះពេលណាក៏បាន ប្រសិនបើចង់បញ្ឈប់ឧត្តមសេនីយ សក់ ស៊ុតសាខន ពីតំណែងអគ្គបញ្ជាការកងទ័ព ។

លោកឧត្តមសេនីយ សក់ ស៊ុតសាខន កាន់តែទទួលបាននូវភាពស្របច្បាប់ក្នុងឋានៈជាមេដឹកនាំកងទ័ព តាមរយៈក្រឹត្យតែងតាំងថ្មីចុះហត្ថលេខាដោយលោកតា សឺន សាន និង ដោយមានការយល់ព្រមពីកូម៉ិចផង ។ បន្ថែមលើភារកិច្ចជាប្រធានពែកមីកូ(Permico) លោកឧត្តមសេនីយ ហាក់ដូចជាលេចធ្លោឡើងជាមេដឹកនាំម្នាក់ទៀតនៃចលនាតស៊ូមិនមែនកុម្មុយនីស្ត ក្រៅពីមេដឹកនាំធំៗពីរគឺ លោកតាសឺន សាន និង សម្តេច សីហនុ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ប្រាកដជាត្រូវលើកទឹកចិត្តឲ្យងើបឈរឡើង ដើម្បីអនុវត្តយុទ្ធសាស្ត្រយោធារបស់ក្រុមការងារ ដោយដកឃ្លាចេញក្រៅពីរដ្ឋាភិបាលចម្រុះត្រីភាគី ដែលក្រុមអាស៊ានសំឡឹងឃើញកម្លាំងទ័ពទាំងអស់ ស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្មែរក្រហម ។ ក្នុងទស្សនៈនេះ ថ្នាក់ដឹកនាំយោធារបស់ចលនាតស៊ូមិនមែនកុម្មុយនីស្ត ត្រូវបានលើកទឹកចិត្តឲ្យត្រួតត្រាលើកងទ័ពទាំងពីររបស់ រ.ជ.រ.ប.ខ. និង ហ៊្មុន ស៊ិន ប៊ុច ។

តាមពិតទៅ តាំងពីខែ ឧសភា ១៩៨៥ រៀងមក កងទ័ពត្រូវបានស្ថិតនៅឯករាជ្យរួចទៅហើយ ព្រោះកងទ័ពមានថវិកា មានបុគ្គលិក និង ភស្តុភាររបស់ខ្លួនដាច់ដោយឡែក ។ កងទ័ពបានទទួលការគាំទ្រផ្ទាល់ពីអាជ្ញាធរយោធាថៃ ជាពិសេសពីកងទ័ពជើងគោកថៃ និង ពីក្រុមការងារ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏លោកតា សឺន សាន នៅតែខំប្រឹងប្រែងរក្សាការពារការគ្រប់គ្រងរបស់លោកតាទៅលើកងទ័ពដោយបន្តព្យាយាមអំពាវនាវឲ្យគោរពឯកភាព និង វិន័យនៅក្នុងជួរទ័ពរបស់គាត់ ។ លោកតាសំឡឹងឃើញការរៀបចំថ្មីផ្នែកយោធារបស់ក្រុមការងារ ឲ្យកងទ័ព

ឯករាជ្យ ចេញពីអំណាចរបស់ ប្រធានរណសិរ្សថាជាការរៀបចំបំបែកបំបាក់មួយ ។ ដូច្នេះ លោកតាហាក់ស្ថិតនៅជាឧបសគ្គចំពោះយុទ្ធសាស្ត្ររបស់ក្រុមការងារ ។

## ក្រុម សឺន សាន និង សក់ ស៊ុតសាខន តម្លើងសម្លេងដាក់គ្នា

នៅសម័យនោះ មានការឃោសនាប្រឆាំងគ្នាយ៉ាងខ្លាំងក្លាគឺមួយមកពីក្រុមគាំទ្រលោកតា សឺន សាន និង មួយទៀតមកពីក្រុមគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ក្រុមគាំទ្រលោកតា សឺន សាន បានឃោសនាថា ក្រុមមេដឹកនាំយោធាខ្មែរមិនមែនកុម្មុយនីស្ត សុទ្ធតែជាមនុស្សខ្វះសមត្ថភាព មិនអាចរំដោះប្រទេសពីការកាន់កាប់របស់បរទេសឡើយ ។ នៅពេលលោកតា សឺន សាន ជួបជាមួយលោក សិទ្ធី សាវ៉េតសីលា រដ្ឋមន្ត្រីការបរទេសថៃនៅខែ សីហា ១៩៨៥ លោកតាប្រធាន ជំរាបលោករដ្ឋមន្ត្រីថា៖ "យើងចាំបាច់ត្រូវបង្កើនសកម្មភាពទ័ពព្រៃ ត្រូវបង្កើនចលនាសង្គ្រាមចិត្តសាស្ត្រ និង រៀបចំប្រមូលមហាជននៅក្នុងប្រទេស" ។ លោកតាគូសបញ្ជាក់ជំរាបលោករដ្ឋមន្ត្រីការបរទេសថៃថា មេដឹកនាំយោធាខាងចលនាតស៊ូមិនមែនកុម្មុយនីស្តបច្ចុប្បន្ន មិនអាចរៀបចំ និង បំពេញការងារទាំងនេះបានទេ ។ ចំពោះលោកតា សឺន សាន មានតែមនុស្សជំនិតរបស់គាត់ម្នាក់គត់គឺលោក ថាច់ រ៉េង ទើបអាចធ្វើកិច្ចការទាំងអស់ខាងលើបាន ។ ប្រឆាំងតបវិញក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានសំដែងគោលជំហរថា លោកតា សឺន សាន គ្មានគំនិតអ្វីក្រៅតែពីចង់ដកលោក សក់ ស៊ុតសាខន រួចដាក់លោក ថាច់ រ៉េង មកជំនួសជាអគ្គបញ្ជាការក.ជ.ប.រ.ខ.តែប៉ុណ្ណោះទេ ដែលនឹងនាំឲ្យមានការបែកបាក់សាមគ្គីភាពក្នុងជួរយុទ្ធជន ។ ក្រុមលោក សក់ ស៊ុតសាខន បានឃោសនាទៀតថា លោកតា សឺន សាន គិតតែផលប្រយោជន៍ផ្ទាល់ខ្លួនគឺ លើកតម្កើងតែមនុស្សណា ដែលមានភក្តីភាពចំពោះតួបុគ្គល ឬ កូនចៅក្រុមគ្រួសារ ឬ

បក្សពួករបស់លោកតា ។ នៅសម័យនោះ រូបខ្ញុំក៏ត្រូវទទួលការចោទប្រកាន់ថាជាមនុស្ស ឬ ជាដៃជើងរបស់លោកតាម្នាក់ដែរ ។

## ពួកតាៗនៅប៉ារីស គាំទ្រលោក សក់ ស៊ុតសាខន

ដោយសារមានការឃោសនាយ៉ាងទូលំទូលាយ ក្រុមលោក សក់ ស៊ុតសាខន ហាក់ដូចជាទាក់ទាញទឹកចិត្ត និង ទទួលបានការគាំទ្រពីក្រុមអ្នកនយោបាយខ្មែរចាស់ៗ ដែលជាសមាជិកនៃក្រុមប្រឹក្សាព្រឹទ្ធាចារ្យរបស់រ.ជ.រ.ប.ខ. ។ ក្រុមប្រឹក្សានោះ មានអតីតនាយករដ្ឋមន្ត្រី ៣ រូបគឺ លោកតា ស៊ឹម វ៉ា លោកតា ឈាន វ៉ម និង លោកតា ហ៊ុយ គន្ធុល ក្រៅពីនោះ សុទ្ធតែជាអតីតរដ្ឋមន្ត្រីគឺ លោកតា ចាយ ធុល លោកតា ថុន អ៊ុក លោកតា លឹម គ្រី និង លោកតា នង គិមនី ។ ព្រឹទ្ធាចារ្យទាំងអស់នោះ ធ្លាប់កាន់តំណែងនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្នុងសម័យមុនឆ្នាំ ១៩៧០ គឺ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៤០ ១៩៥០ ១៩៦០ មកម្លេះ ។

នៅថ្ងៃទី ១៩ មិថុនា ១៩៨៥ ក្រុមប្រឹក្សាព្រឹទ្ធាចារ្យ បានរួមប្រជុំនៅទីក្រុងប៉ារីស ។ អតីតនាយករដ្ឋមន្ត្រី ២ រូបគឺ លោកតា ឈាន វ៉ម និង លោកតា ហ៊ុយ គន្ធុល បានចូលរួមប្រជុំ ឯអតីតនាយករដ្ឋមន្ត្រីទី ៣ លោកតា ស៊ឹម វ៉ា មិនបានចូលរួមទេ ដោយជាប់ព្យាបាលរោគនៅមន្ទីពេទ្យ តែបានសម្តែងការគាំទ្រចំពោះអង្គប្រជុំ ។ ក្រុមព្រឹទ្ធាចារ្យទាំងនោះ បានចោទប្រកាន់ថា លោកប្រធានធ្វើកិច្ចការអ្វីៗ "តែតាមបញ្ជារបស់ក្រុមគ្រួសារ ឬ មនុស្សជំនិតរបស់លោកស្ទើរតែទាំងស្រុង"។ "ក្រុមគ្រួសារលោកតា មានអំណាចបញ្ជា រហូតដល់ទៅជ្រៀតជ្រែកក្នុងការសម្រេចចិត្ត និង ការរៀបចំនៃរ.ជ.រ.ប.ខ.ផង" ។ ក្រុមលោកតាព្រឹទ្ធាចារ្យចោទថា"អ្វីៗដែល

គេធ្វើទៅនោះ ច្រើនតែសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនរបស់មនុស្សស្មោះត្រង់ចំពោះលោកប្រធាន ជាជាងសម្រាប់សេចក្តីត្រូវការនៃរ.ជ.រ.ប.ខ"[177]។

ក្រុមប្រឹក្សាព្រឹទ្ធាចារ្យបានសម្រេចដកការគាំទ្រពីលោកតាប្រធាន សឺន សាន ជារៀងរហូតដរាបណាមិនមានការផ្លាស់ប្តូររបៀបរបបការងាររបស់គាត់ ដែលក្រុមប្រឹក្សាយល់ថាជាការងារនៅជុំវិញតែតួបុគ្គល បក្សពួក ឬ ក្រុមគ្រួសារ ។ អ្នកចូលរួមប្រជុំទាំងអស់ សុទ្ធតែបានចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មាន លើកលែងតែលោកអតីតរដ្ឋមន្ត្រី នង គិមនី ចេញ ដែលមានឈ្មោះចូលរួមប្រជុំ តែអវត្តមាននៅពេលចុះហត្ថលេខា ។ មនុស្សជំនិតរបស់លោកតា សឺន សាន យល់ឃើញថាអ្នកនាំពាក្យដ៏សំខាន់ ដែលជម្រុញឲ្យលោកព្រឹទ្ធាចារ្យទាំងនោះសម្រេចដកការគាំទ្រពីលោកតា សឺន សាន គ្មាននរណាក្រៅពីអគ្គលេខាធិការ នាង ជិនហន នោះទេ បន្ថែមលើសកម្មភាពប្រឆាំងយ៉ាងចេញមុខពីសំណាក់ក្រុមលោក ដៀន ដែល ហ៊ីង គន្ធុន និង ហ្គាហ្វា ។ លោកតាប្រធានបានព្យាយាមទាញយកការគាំទ្រពីក្រុមព្រឹទ្ធាចារ្យមកវិញ ។

នៅថ្ងៃទី ៦ កញ្ញា ១៩៨៥ លោកតាប្រធាន បានអញ្ជើញអស់លោកសមាជិកក្រុមព្រឹទ្ធាចារ្យ មកប្រជុំនៅគេហដ្ឋាននាទីក្រុងប៉ារីសរបស់លោកតា ។ លោកតា ហ៊ុយ គន្ធុល លោកតា លឹម គ្រី និង លោកតា ស៊ឹម វ៉ា មិនបានមកចូលប្រជុំទេ ។ ក្រោយពីពិភាក្សាគ្នាអស់រយៈពេលបីម៉ោងមក អង្គប្រជុំបានព្រមព្រៀងគ្នាថា លោកបណ្ឌិត ឆាយ ហាន់ចេង កូនប្រសារលោកតា សឺន សាន ត្រូវឈប់លូកដៃចូលក្នុងកិច្ចការរ.ជ.រ.ប.ខ.តទៅទៀត[178] ។ ម្យ៉ាងទៀត លោកតា សឺន សាន ត្រូវតែចាត់តាំងអ្នកដឹកនាំវ័យក្មេងម្នាក់អាយុតិចជាង ៥០ ឆ្នាំ ជាអ្នកត្រៀមដឹកនាំរ.ជ.រ.ប.

---

[177] ចាយ ធុល, ឈាន វ៉ម, ហ៊ុយ គន្ធុល, លឹម គ្រី, នង គឹមនី, ថុន អ៊ុក, ស៊ឹម វ៉ា, ឯកសារគ្មានចំណងជើង, ប៉ារីស, ១៩ មិថុនា ១៩៨៥ ។

[178] Pong Kim Koan, Procès-Verbal de la Réunion de Travail, Paris, le 6 Septembre 1985.

ខ.ដាបណ្ដើរៗតទៅ ។ លោកតា សឹន សាន ក៏យល់ព្រមតាម ។ បន្ទាប់ពីជួបប្រជុំគ្នានេះ លោកតា សឹន សាន យល់ថាសភាពតានតឹងក្នុងទំនាក់ទំនងជាមួយក្រុមព្រឹទ្ធាចារ្យ បានធូរស្រាល និង មានប្រក្រតីភាពឡើងវិញ ។ តាមពិតទៅ សមាជិកព្រឹទ្ធាចារ្យទាំងអស់នោះសុទ្ធតែជាមិត្ត ឬ ជាសហការីរបស់លោកតា សឹន សាន ជាយូរមកហើយ ។

## ស្ងាត់ៗលោក ថាច់ រ៉េង ត្រឡប់មកបាងកកវិញ

ដោយសារការទទូចសុំដដែលៗពីលោកតា សឹន សាន នៅទីបំផុត លោកឧត្តមសេនីយ ឆាវលិត ក៏អនុញ្ញាតឲ្យលោក ថាច់ រ៉េង វិលត្រឡប់មកទីក្រុងបាងកកវិញនៅខែ តុលា ១៩៨៥ ។ ក៏ប៉ុន្តែ ការវិលត្រឡប់នេះ ត្រូវចាត់ទុកជាការសម្ងាត់ មិនបើកចំហរគឺ គ្មានការដឹងឮពីក្រសួងការបរទេស ឬ គ្មានទិដ្ឋាការចេញចូលដូចធម្មតាឡើយ ។ នៅពេលគាត់មកដល់ ទាហានថៃពីរនាក់ នៅចាំទទួលនាំចេញពីយន្តហោះ តម្រង់ទៅសណ្ឋាគារតែម្ដង ។ ការស្នាក់នៅរបស់លោក ថាច់ រ៉េង នៅលើទឹកដីថៃលើកនេះ មានលក្ខណៈពិសេស និង រៀបចំឡើងដោយយោធាថៃដាច់ដោយឡែក ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលរសៀលមួយនោះ ខ្ញុំបានទទួលទូរស័ព្ទពីគាត់ ដែលហៅចេញពីសណ្ឋាគារមួយនៅទីក្រុងបាងកក ។ ដោយសារនោះជាការសម្ងាត់ ខ្ញុំមិនប្រាប់នរណាម្នាក់ទេ ។ ខ្ញុំលបចេញទៅក្រៅ ទៅរកជួបលោក ថាច់ រ៉េង ភ្លាមៗមួយរំពេច ពេលចប់កិច្ចសន្ទនាដ៏ខ្លីតាមទូរស័ព្ទនោះ ។ លោក ថាច់ រ៉េង មានទឹកមុខញញឹមពព្រាយ សប្បាយរីករាយខ្លាំងណាស់ ដោយបានវិលមកទីក្រុងបាងកកវិញ ។ គាត់បាននិយាយប្រាប់ខ្ញុំអំពីបេសកកម្មពិសេស និង ជំនួបរបស់គាត់ជាមួយលោកឧត្តមសេនីយ ឆាវលិត ។ នៅរសៀលនោះ

ខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេ ព្រោះយើងនាំគ្នានិយាយផ្លាស់ប្តូរយោបល់ពីលទ្ធភាពនៃការងារដែលត្រូវធ្វើនៅចំពោះមុខ រួចយើងនាំគ្នាទៅទទួលទានអាហារល្ងាចនៅភោជនីយដ្ឋានមួយ ដែលនៅមិនឆ្ងាយពីម៉ាយ៉ាឡាប់ ។

នៅទីស្នាក់ការរបស់ពួកយើង គ្មាននរណាម្នាក់ដឹងពីវត្តមានរបស់លោក ថាច់ រ៉េង នៅបាងកកទេ ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែមកលបជួបលោក ថាច់ រ៉េង ជាសម្ងាត់មិនដែលដាច់ ។ ក៏ប៉ុន្តែមួយអាទិត្យក្រោយមកលោក ថាច់ រ៉េង ប្រាប់ខ្ញុំឲ្យរកផ្ទះសំណាក់ឲ្យគាត់ ព្រោះគាត់មិនចង់នៅក្នុងសណ្ឋាគារតទៅទៀតទេ ។ លោក ថាច់ រ៉េង មិនបានប្រាប់ខ្ញុំពីមូលហេតុជាក់លាក់ទេ តែខ្ញុំអាចយល់បានថាក្រុមយោធាថៃ លែងទទួលបន្ទុកចេញថ្លៃស្នាក់នៅរបស់គាត់ នៅក្នុងសណ្ឋាគារតទៅទៀតហើយ ។ នៅទីបំផុត ខ្ញុំក៏ទៅជួលបន្ទប់ស្ទុឌីយោ (Studio) នៅក្នុងកុងដូមុយនីញ៉ូមនៅផ្លូវតេជោ ក្បែរមជ្ឈមណ្ឌលពាណិជ្ជកម្មនៅទីក្រុងបាងកក ដោយប្រើឈ្មោះខ្ញុំ និង ប្រើប័ណ្ណឥណទាន (Credit Card) ផ្ទាល់ខ្លួនរបស់ខ្ញុំ ។ អស់រយៈពេលជាច្រើនខែក្រោយមក ក្រុមយោធាថៃក៏យល់ព្រមឲ្យលោក ថាច់ រ៉េង ចេញមុខមកស្នាក់នៅជាមួយពួកយើង នៅម៉ាយ៉ាឡាប់ឯទីស្នាក់ការរបស់យើងឡើងវិញ ។

តាមពិតលោកតា សឺន សាន ប្រឹងប្រែងណាស់ ដើម្បីទាញយកអំណាចគ្រប់គ្រងរ.ជ.រ.ប.ខ.ឡើងវិញ ។ លោកតាព្យាយាមជានិច្ច ដើម្បីធ្វើការរៀបចំការដឹកនាំរ.ជ.រ.ប.ខ. ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកតាផ្ទាល់ ទាំងផ្នែកនយោបាយ ទាំងផ្នែកយោធា ។ ជាពិសេស លោកតាប្រធានចង់បានមនុស្សជំនិតដូចជាលោក ថាច់ រ៉េង ជាដើម មានមុខនាទីទទួលខុសត្រូវនៅក្នុងជួរកងទ័ពរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែរាល់ការខឹតខំរបស់លោកតា មិនបានទទួលជោគជ័យទេ

ប្រសិនបើគ្មានការគាំទ្រពីអាជ្ញាធរថៃ ។ នៅពេលលោកតា ជួបពិភាក្សាការងារជាមួយលោករដ្ឋមន្ត្រីការបរទេស សិទ្ធី សាវេតសិលា[179] (Siddhi Savetsila) នៅពាក់កណ្ដាលខែ សីហា ១៩៨៥ លោកតាប្រធានបានលើកយកតួអង្គបុគ្គល សឺន សាន ទៅដាក់ផុកវាយផ្ដាច់យកឈ្នះចាញ់តែម្ដង ដូចដែលលោកតាធ្លាប់ដាក់លក្ខខណ្ឌនៅឆ្នាំ ១៩៨២ នាពេលចរចាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងដូច្នោះដែរ ។ ថ្លែងទៅកាន់លោករដ្ឋមន្ត្រីថៃ លោកតាមានប្រសាសន៍ថា៖ "ខ្ញុំសូមឲ្យប្រទេសជាមិត្តទាំងអស់ ជាពិសេសអាស៊ានជួយខ្ញុំឲ្យអាចរៀបចំរ.ជ.រ.ប.ខ.ឲ្យមានវិន័យរបៀបរៀបរយឡើងវិញ ។ ប្រសិនបើសំណើខ្ញុំទាំងប៉ុន្មាន មិនបានទទួលចម្លើយដូចបំណងទេនោះ ខ្ញុំគ្មានសង្ឃឹមអ្វីក្រៅពីសុំសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះប្រទេសជាមិត្ត ដែលបានផ្ដល់ជំនួយគ្រប់ផ្នែកដល់ចលនាតស៊ូមិនមែនកុម្មុយនីស្ដ និង ខ្ញុំស្នើសុំជាចុងក្រោយឲ្យប្រទេសជាមិត្តទាំងនោះមេត្តាកុំទម្លាក់ការទទួលខុសត្រូវមកលើរូបខ្ញុំឲ្យសោះ ក្នុងករណីយដែលប្រទេសកម្ពុជាធ្លាក់ទៅក្នុងដៃកុម្មុយនីស្ដ" ។ លោកតាចង់និយាយថាបើប្រទេសអាស៊ានមិនជួយឲ្យលោកតាមានអំណាចគ្រប់គ្រាន់ ដើម្បីរៀបចំរ.ជ.រ.ប.ខ.គឺ ដោះដូរមន្ត្រីសំខាន់ៗតាមគំនិតរបស់លោកតាទេនោះ លោកតាសុំមិនទទួលខុសត្រូវទេ ប្រសិនបើក្រុមមិនមែនកុម្មុយនីស្ដ (NCR) ត្រូវទទួលបរាជ័យ ហើយប្រទេសកម្ពុជាត្រូវធ្លាក់ទៅក្នុងរបបកុម្មុយនីស្ដ ។

# ការបែកបាក់លើកទី២ ក្នុងជួរ រ.ជ.រ.ប.ខ.

ទំនងជាលោកតាយល់ថា បានទទួលសញ្ញាភ្លើងខៀវពីរដ្ឋាភិបាលថៃមួយ

[179] Coalition Government of Democratic Kampuchea, Memorandum, Meeting of H.E. Son Sann with H.E. ACM Siddhi Savetsila, Minister for Foreign Affairs of the Thai Royal Government, August 15, 1985.

អាទិត្យបន្ទាប់ពីបានជួបលោករដ្ឋមន្ត្រីការបរទេសនេះមក លោកតាប្រធានក៏កោះប្រជុំគណៈកម្មាធិការប្រតិបត្តិ (កូម៉ិច) នៅថ្ងៃទី ២២ សីហា ១៩៨៥ ។ នៅក្នុងពេលប្រជុំកូម៉ិចលើកនេះ ក្រៅពីសមាជិកពេញសិទ្ធិ ក៏មានការចូលរួមពីគ្រប់មេបញ្ជាការ ក.ជ.រ.ប.ខ. និង ប្រធានជំរុំផងដែរ ។ ក៏ប៉ុន្តែ មនុស្សសំខាន់ពីរនាក់គឺ លោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា អវត្តមាន ។ នៅពេលនោះ ខ្ញុំពុំមានសិទ្ធិចូលរួមប្រជុំទេ ។ របៀបវារៈសំខាន់នៃអង្គប្រជុំ មានចំណុចស្តីពីការរៀបចំសណ្តាប់ធ្នាប់ និង វិន័យឡើងវិញក្នុងជួរ រ.ជ.រ.ប.ខ. ។ សេចក្តីសម្រេចដ៏សំខាន់មួយក្នុងអង្គប្រជុំនោះគឺ ការដកលោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ពាងម៉េត ពីមុខតំណែងទាំងអស់ក្នុងជួរ រ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានធ្វើអន្តរាគមន៍ថា សុំកុំអាលផ្សព្វផ្សាយសេចក្តីសម្រេចនេះជាសាធារណៈ ដើម្បីទុកពេលមួយរយៈឲ្យសាមីខ្លួនទាំងពីរនាក់កែខ្លួនសិន ។

នៅថ្ងៃជាមួយគ្នានោះដែរ គណៈកម្មាធិការចំពោះកិច្ច (Ad-hoc Committee) របស់ ក.ជ.រ.ប.ខ. (KPNLAF) និង កងទ័ពជាតិសីហនុនិយម (ANS : Armée Nationale Sihanoukiste) ឬ កងទ័ពរបស់ ហ៊្វុន ស៊ិន ប៉ិច (FUNCINPEC) បានចេញសេចក្តីប្រកាសព័ត៌មានមួយស្តីពីការបង្កើតបញ្ជាការយោធារួម (Joint Military Command) មួយ ដែលមានលោកឧត្តមសេនីយ សក់ ស៊ុតសាខន (KPNLF) ជាអគ្គមេបញ្ជាការ លោកឧត្តមសេនីយ ទៀប បែន (ANS) ជាអគ្គមេបញ្ជាការរង លោកឧត្តមសេនីយ ទួន ចាយ (ANS) ជានាយអគ្គសេនាធិការ និង លោក ហ្គាហ្វា ពាងម៉េត (KPNLF) ជានាយអគ្គសេនាធិការរង[180] ។

[180] Teap Ben (Lt.Gen), Dien Del (Gen), Permanent Military Committee for Coordination, Press Release, Free Cambodia, 22 August, 1985.

ដោយសារវត្តមានរបស់លោក ថាច់ រ៉េង នៅបាងកក និង ដោយសារកូម៉ិច បានធ្វើការសម្រេចដកតំណែងមនុស្សសំខាន់ទាំងពីរគឺ លោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ការបែកបាក់ផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. ក៏កាន់តែរីកធំឡើង ។ ហ្គាហ្វា បានបះបោរតបវិញដោយចំហរ ។ ហ្គាហ្វា ធ្វើសេចក្តីថ្លែងការណ៍ ទាំងតាមទំព័រកាសែត ទាំងតាមកិច្ចសន្ទនាឯកជន ជាពិសេស តាមទំព័រទស្សនាវដ្តី ហ្វាអ៊ែស្ទេន អ៊ីកូណូមិក (FAR EARTERN ECONOMIC REVIEW) ចុះផ្សាយនៅថ្ងៃទី ២៥ តុលា ១៩៨៥ អំពាវនាវឲ្យអាស៊ានដកការគាំទ្រពីលោកតា សឺន សាន ហើយធ្វើការគាបសង្កត់ឲ្យលោកតាលាចេញពីតំណែងប្រធានរ.ជ.រ.ប.ខ. ។ សកម្មភាពប្រឆាំងរបស់ ហ្គាហ្វា នេះ បានឡើងដល់កំរិតមួយ ដែលមិនអាចផ្សះផ្សាគ្នាបានឡើយ ។

# បង ប៉ែន ថាល់ ទទួលមរណភាពនៅប៉េកាំង

នៅថ្ងៃទី ៤ ធ្នូ ១៩៨៥ លោកតា សឺន សាន បានកោះប្រជុំគណៈកម្មាធិការប្រតិបត្តិម្តងទៀត ។ លើកនេះ អង្គប្រជុំសម្រេចបណ្តេញលោក ហ៊ីង គន្ធុន និង ហ្គាហ្វា ចេញពីរ.ជ.រ.ប.ខ. តែម្តង ។ សេចក្តីសម្រេចបណ្តេញលើកនេះបានធ្វើឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន មិនសប្បាយចិត្ត ។ មួយថ្ងៃបន្ទាប់មក ទំនងជាដើម្បីបង្ហាញនូវសាមគ្គីភាពជាមួយសហការី ដែលត្រូវបណ្តេញចេញទាំងពីរនាក់នោះ លោកឧត្តមសេនីយ ក៏ធ្វើលិខិតសរសេរផ្ទាល់ដៃជូនលោកតាប្រធាន សុំលាឈប់ពីគ្រប់តំណែងទាំងអស់ក្នុងជួររ.ជ.រ.ប.ខ.គឺ៖[181] ទីប្រឹក្សាយោធារបស់ប្រធានរ.ជ.រ.ប.ខ. អនុប្រធានរ.ជ.រ.ប.ខ. និង អគ្គមេបញ្ជាការក.ជ.រ.ប.ខ ។

---

[181] សក់ ស៊ុតសាខន, (លិខិតសម្ងាត់ និង ផ្ទាល់ខ្លួន) ជូន ឯកឧត្តម សឺន សាន, ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ, ថ្ងៃទី ៥ ខែ ធ្នូ ១៩៨៥ ។

នៅ ថ្ងៃទី ៧ ធ្នូ ១៩៨៥ លោកតា សឹន សាន ចេញដំណើរទៅធ្វើទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត ។ ក្នុងចំណោមអ្នកអមដំណើរលោកតាប្រធានចំនួន ៥ នាក់ ក៏មានបង ប៉ែន ថាល់ ទៅជាមួយដែរ ។ បង ប៉ែន ថាល់ មានការបារម្ភខ្លាំងណាស់ ចំពោះការបាក់បែកផ្ទៃក្នុងរបស់ក្រុមយើង ។ គាត់និយាយមិនឈប់ជាមួយខ្ញុំថា "យើងត្រូវធ្វើអ្វីមួយ ដែលយើងអាចធ្វើបាន ដើម្បីការពារឯកភាពនៃចលនាតស៊ូរបស់យើង" ។ នៅថ្ងៃគណៈប្រតិភូចេញដំណើរ ខ្ញុំក៏ទៅជូនដំណើរឯអាកាសយានដ្ឋាន ។ នៅថ្ងៃនោះ ក៏ជាថ្ងៃចុងក្រោយដែលខ្ញុំបានឃើញបង ប៉ែន ថាល់ ដែរគឺជាថ្ងៃលាគ្នាចុងក្រោយបំផុត ។ តាមពិតទៅបង ប៉ែន ថាល់ លែងត្រឡប់មកវិញហើយៗហេតុការណ៍មួយដ៏ក្រៀមក្រំបានកើតឡើង ។ នៅពេលទៅដល់អាកាសយានដ្ឋានប៉េកាំង គណៈប្រតិភូក៏នាំគ្នាចេញពីយន្តហោះហើយ នៅពេលឥស្សរជនសំខាន់ៗកំពុងទទួលបដិសណ្ឋារកិច្ចនៅជួរខាងមុខ នៅឯក្រោយឯនេះ បង ប៉ែន ថាល់ ក៏ដួលសន្លប់បាត់ស្មារតីម្តងទៀតដូចកាលនៅអាហ្វ្រិកដែរ ។ តែម្តងនេះ គាត់ដួលក្បាលបោកផ្ទប់ទៅនឹងថ្មក្រាលនៃវាលយន្តហោះបណ្តាលឲ្យបែកក្បាល ។ វេជ្ជបណ្ឌិតចិនខំព្យាយាមរកវិធីឃាត់ឈាមយ៉ាងណា ឈាមនោះក៏មិនឈប់ហូរ ដូច្នេះបង ប៉ែន ថាល់ ក៏ទទួលមរណភាពនៅមន្ទីរពេទ្យក្រុងប៉េកាំង ប៉ុន្មានថ្ងៃក្រោយមក ។ ការបាត់បង់បង ប៉ែន ថាល់ បានធ្វើឲ្យខ្ញុំបាត់បង់នូវកល្យាណមិត្តមួយដ៏ថ្លៃថ្លា ។ គាត់មិនមែនគ្រាន់តែជាបង ដែលខ្ញុំចាត់ទុកដូចបងបង្កើតរបស់ខ្ញុំប៉ុណ្ណោះទេ តែគាត់ក៏ជាទីប្រឹក្សារកបានដោយកម្រ ។ រ.ជ.រ.ប.ខ. ក៏បាត់បង់សមាជិកម្នាក់ដ៏មានតម្លៃផងដែរ ។

# បក្សប្រហារ ដែលយើងនឹកមិនដល់

ដូចពេលមុនៗដែរ ខ្ញុំតែងចំណាយពេលរវាងទីក្រុងបាងកក និង តំបន់ទល់ដែនខ្មែរ-ថៃគឺ ចេញចូលជាញឹកញាប់ ។ ខ្ញុំតែងទៅជំរុំសាយធូ ពេលណាខ្ញុំអាចទៅបាន ។ ពេលទៅដល់ទីប្រជុំជនអារញ្ញប្រថេតមុននឹងចូលទៅជំរុំ ខ្ញុំតែងទៅឈប់នៅផ្ទះសុវត្ថិភាព (Safe house) ព្រោះនៅទីនោះ ពួកយើងមានបុគ្គលិកខ្មែរជួយធ្វើទំនាក់ទំនងជាមួយអាជ្ញាធរថៃ ដើម្បីសុំលិខិតចេញចូលជំរុំ ឬ ដើម្បីសុំច្បាប់ត្រឡប់ទៅបាងកកវិញ ពេលយើងចេញពីជំរុំ ។ ក្នុងឋានៈជាសមាជិកខុទ្ទកាល័យប្រធាន រ.ជ.រ.ប.ខ.មួយរូប និង ក្នុងឋានៈជាអតីតលេខាធិការរបស់គណៈកម្មាធិការអគ្គសេនាធិការកងទ័ព ខ្ញុំនៅមានអ្នកគោរពរាប់អានច្រើននៅអារញ្ញប្រថេតនោះ ។ម្យ៉ាងទៀត មន្ត្រីខ្មែរដែលមានភារកិច្ចទាក់ទងជាមួយអាជ្ញាធរយោធាថៃ ក៏ធ្លាប់ជាអ្នកធ្វើការក្រោមបង្គាប់ខ្ញុំផង កាលខ្ញុំនៅឯមូលដ្ឋានយោធាអំពិល ។ ដូច្នេះ ពេលមានវត្តមានរបស់ខ្ញុំម្តងៗនៅផ្ទះសុវត្ថិភាពនេះ គេទាំងអស់គ្នាយកចិត្តទុកដាក់ណាស់ ។ មន្ត្រីខ្មែររបស់យើងនោះ រត់ការលឿនទាន់ចិត្ត ក្នុងការទៅសុំលិខិតអនុញ្ញាតផ្សេងៗ ។ ក៏ប៉ុន្តែលើកនេះ ខ្ញុំឆ្ងល់យ៉ាងខ្លាំង ព្រោះទង្វើរបស់មន្ត្រីខ្មែរនោះហាក់ដូចជាខុសប្លែកពីធម្មតា ។ ខ្ញុំឆ្ងល់យ៉ាងខ្លាំង ព្រោះថាខ្ញុំរង់ចាំអស់ជិតមួយថ្ងៃទៅហើយ នៅតែមិនទាន់បានលិខិតអនុញ្ញាតឲ្យត្រឡប់ទៅបាងកកវិញ ។

ថ្ងៃនោះ គឺថ្ងៃទី ១៩ ធ្នូ ១៩៨៥ បន្ទាប់ពីបានទៅជំរុំអស់ពីរយប់ ខ្ញុំត្រូវត្រឡប់ទៅបាងកកវិញ ដូច្នេះត្រូវចូលមកសុំលិខិតអនុញ្ញាតពីអារញ្ញ ទើបអាចធ្វើដំណើរបាន ជៀសវាងការឆែកឆេរពីក្រុមយោធាថៃតាមផ្លូវ ។ ម្តងនេះមន្ត្រីខ្មែរគ្រាន់តែមកប្រាប់ខ្ញុំឲ្យនៅរង់ចាំ រួចក៏បាត់ខ្លួនរហូត ។ ទាល់តែដល់ល្ងាច ទើបមកជួបខ្ញុំម្តងទៀត ដោយយកលិខិតអនុញ្ញាតឲ្យធ្វើដំណើរមកជាមួយ ។ ភ្លាមៗនោះ

ខ្ញុំពុំបានដឹងថាមន្ត្រីខ្មែរនោះបានទទួលបញ្ជាពីការិយាល័យលោក សក់ ស៊ុតសាខន ឲ្យឈប់សហការ ឬ ធ្វើការជាមួយពួកយើងតទៅទៀត ។ នៅវេលាប្រហែលម៉ោង ១០ យប់ ទើបខ្ញុំទៅដល់បាងកក ។ នៅពេលទៅដល់ម៉ាយ៉ាឡាប់ ខ្ញុំឃើញភាពចម្លែកមួយទៀត ព្រោះទ្វារភូមិគ្រឹះត្រូវចាក់សោរ និង មានមនុស្សយាមផង ។ អ្នកយាមនោះគឺ អ្នកបំរើក្មេងៗក្នុងផ្ទះ ដែលពីមុនមកមិនដែលធ្វើការយាមកាមអ្វីទេ ។ ពេលខ្ញុំចូលផុតពីទ្វាររបង លោកឧត្តមសេនីយ ថាច់ រ៉េង ក៏ស្ទុះមកទទួលខ្ញុំ ហើយស្រែកសួរថា៖ "មូលីឯងមិនដឹងថាមានរដ្ឋប្រហារអ្វីទេឬ"? ខ្ញុំសួរថា "រដ្ឋប្រហារអ្វី?" គាត់សួរមកវិញថា "អត់បានមើលកាសែតទេឬ?" ខ្ញុំឆ្លើយថា "ទេ" ។ ទើបលោក ថាច់ រ៉េង រៀបរាប់ថាព្រឹកមិញថ្ងៃទី ១៩ ធ្នូនេះ នៅទីក្រុងបាងកកសារព័ត៌មានបានចេញផ្សាយថា ក្រុមបំបែកខ្លួនក្នុងជួររ.ជ.រ.ប.ខ.ដឹកនាំដោយឧត្តមសេនីយ សក់ ស៊ុតសាខន បានប្រកាសបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នដើម្បីសង្គ្រោះរ.ជ.រ.ប.ខ (Provisional Central Committee for the Salvation of the KPNLF) ។ នេះជាការបះបោររបស់ក្រុមឧត្តមសេនីយប្រឆាំងលោកប្រធាន សឺន សាន យ៉ាងចេញមុខ ។

មែនទែន នៅថ្ងៃ ១៧ ធ្នូ ១៩៨៥[182] ក្រុមរបស់ឧត្តមសេនីយ សក់ ស៊ុតសាខន បានផ្សព្វផ្សាយដល់អង្គការសារព័ត៌មាន និង បេសកកម្មទូតនានាប្រចាំទីក្រុងបាងកកនូវអនុស្សារណៈមួយស្តីពីប្រកាសរបស់ក្រុមលោកឧត្តមសេនីយថា បានកាន់កាប់ដឹកនាំរ.ជ.រ.ប.ខ.ទាំងមូល និង លែងស្ថិតនៅក្រោមអំណាចរបស់លោកតា សឺន សាន តទៅទៀតហើយ ។ ក៏ប៉ុន្តែសារព័ត៌មានទើបតែចេញផ្សាយនៅថ្ងៃទី ១៩ ធ្នូ តែប៉ុណ្ណោះ[183]។ នៅក្នុងវារៈបញ្ជាពិសេសរបស់គាត់ លោកឧត្តមសេនីយ

[182] Huy Kanthoul (H.E.), Khmer People's National Liberation Front, Provisional Central Committee of Salvation, A Verbal Note, December 17, 1985.
[183] Jacques Bekaert, KPNLF split by rebel faction, Bangkok Post, December 19, 1985.

សក់ ស៊ុតសាខន បានបន្ទោសលោកតា សឺន សាន និង គណៈកម្មាធិការប្រតិបត្តិ ឬ កូមីុចថា ប្រើអំណាចផ្តាច់ការ និង គិតតែបង្កជម្លោះផ្ទៃក្នុង និង គិតគូរតែកិច្ចការផ្ទាល់ខ្លួន ។ វារៈបញ្ហានោះមានន័យជាអាទិ៍ថា៖[184] "ចាប់តាំងពីបង្កើតឡើងនៅថ្ងៃទី ៩ តុលា ១៩៧៩ មក រ.ជ.រ.ប.ខ.បានបង្កើតឡើងនូវគណៈកម្មាធិការប្រតិបត្តិមួយ ដែលជាអង្គការកំពូល ដើម្បីដឹកនាំរ.ជ.រ.ប.ខ. ទាំងផ្នែកស៊ីវិល នយោបាយ និង យោធា ក្រោមការដឹកនាំរបស់ឯកឧត្តម សឺន សាន ។ ដូចបងប្អូនជនរួមជាតិបានដឹងរួចហើយថា គណៈកម្មាធិការប្រតិបត្តិបានផ្លាស់ប្តូរបន្តិចម្តងៗ ដោយសារតែទំនាស់ផ្ទាល់ខ្លួន ។ ក្នុងការសង្កេតរបស់ខ្ញុំ (សក់ ស៊ុតសាខន) គណៈកម្មាធិការប្រតិបត្តិដែលភាគច្រើន គ្មានដោះស្រាយបញ្ហាអ្វីក្រៅពីគិតតែដោះស្រាយបញ្ហាតួបុគ្គល ឬ បញ្ហាផ្ទាល់ខ្លួន បានជាប់ដៃក្នុងជម្លោះផ្ទៃក្នុងទាស់ទែងប្រមាថមាក់ងាយគ្នា ដោយឥតប្រយោជន៍ និង មិនបានអនុវត្តបទបញ្ជាវិន័យ ឬ មិនបានចំណាយពេល ដើម្បីរកដំណោះស្រាយចំពោះបញ្ហាធំៗក្នុងការតស៊ូរំដោះជាតិឡើយ ។ ដោយសារតែប្រធានប្រើអំណាចផ្តាច់ការ និង ធ្វើសេចក្តីសម្រេចលើអ្វីៗទាំងអស់តែម្នាក់ឯង.. ... ដោយសារមានញត្តិមួយចំនួនធំ និង ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា យ៉ាងល្អិតល្អន់ជាមួយអស់លោក ដែលជាឥស្សរជនខ្មែរអ្នកស្នេហាជាតិរួចមក ខ្ញុំបានសម្រេចបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ. ដើម្បីជំនួសគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. ............ដើម្បីបំបាត់ជម្លោះផ្ទៃក្នុង និង ដើម្បីកែឆ្នៃកិច្ចការរបស់រ.ជ.រ.ប.ខ.ឲ្យប្រសើរឡើងព្រមទាំងដើម្បីឲ្យសមស្របតាមទំនុកចិត្ត និង ជំនឿពីប្រទេសជាមិត្តដែលគាំទ្រយើងដែលគេបានដាក់សេចក្តីសង្ឃឹមលើរ.ជ.រ.ប.ខ.ក្នុងការតស៊ូរំដោះប្រទេសយើង" ។ នៅក្នុងសេចក្តីប្រកាសនោះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានបញ្ជាក់ថារូបលោក

[184] Sak Sutsakhan (General), Khmer People's National Liberation Armed Forces, Provisional Central Committee of Salvation of KPNLF, Special order of the Day, 20 December 1985.

ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការកណ្តាលបណ្តោះអាសន្ននេះ បានន័យថាជា "ប្រធានរ.ជ.រ.ប.ខ.ថ្មី" ។

ដូច្នេះ ពួកយើងបានដឹងពី "បក្សប្រហារ" នេះពីរថ្ងៃក្រោយដែលគេប្រកាសចេញមុខរួចទៅហើយ ។ ក្រុមមនុស្សជំនិតរបស់លោកតា សឺន សាន យល់ច្បាស់ថា ហ្គាហ្វ ប្រាកដជាអ្នកចេញមុខនាំឲ្យមាន"បក្សប្រហារ"នេះ ព្រោះថា ហ្គាហ្វ មានទំនាក់ទំនងល្អជាមួយក្រុមការងារ និង ជាមួយស្ថានទូតបរទេសមួយចំនួននៅទីក្រុងបាងកក ។ អ្នកឯទៀត គ្រាន់តែដើរតាមក្រោយតែប៉ុណ្ណោះ ។ ក្រុមមនុស្សជំនិតរបស់លោកតាប្រធានយល់ថា ហ្គាហ្វ បានយកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឲ្យលេងល្បែងឲ្យខ្លួន ។ ដើម្បីដោះស្រាយបញ្ហានេះ លោកតា សឺន សាន បានសុំជួបលោកឧត្តមសេនីយ ឆាវលិត នៅរសៀលថ្ងៃនោះ ។ លោកតាប្តេជ្ញាថានឹងបណ្តេញលោក ហ្គាហ្វ និង លោក ហ៊ីង គន្ធុន ចេញពីរ.ជ.រ.ប.ខ. តែនឹងខំព្យាយាមទាញលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឲ្យមកចូលជួរខាងលោកតាវិញ ។ លោកតា គិតថានឹងរក្សាទុកតំណែងអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដោយគ្រាន់តែដាក់លក្ខខណ្ឌខ្លះ ។

ជាប្រតិកម្មភ្លាមចំពោះ "បក្សប្រហារ" នោះ លោកតាប្រធានបានចាត់ឲ្យលោក ប៊ុន សាយ អគ្គលេខាធិការរង បញ្ជូនសារអញ្ជើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង លោក ដៀន ដែល មកជួបប្រជុំផ្ទាល់ជាមួយលោកតា នៅទីស្នាក់ការម៉ាយ៉ាឡាប់ នៅថ្ងៃទី ២០ ធ្នូ ១៩៨៥ ក្នុងឋានៈជាអគ្គមេបញ្ជាការ និង នាយអគ្គសេនាធិការក.ជ.រ.ប.ខ ។ ចំណែកឯពួកយើងម្នាក់ៗ រវល់ញាប់ដៃក្នុងពេលដែលវិបត្តិនេះចេះតែមានការវិវត្តន៍ទៅ ។ ខ្ញុំត្រូវទទួលភារកិច្ចទាក់ទងជាមួយបណ្តាញសារព័ត៌មាន ដើម្បីចែកចាយឯកសារ ឬ សេចក្តីប្រកាសសារព័ត៌មាន ។ យុទ្ធសាស្ត្ររបស់ពួកយើងនៅពេលនោះគឺ ត្រូវខឹតខំបង្ហាញពិភពលោក ឲ្យដឹងថា

ទោះជាក្រុមបំបែកខ្លួន ធ្វើសកម្មភាពយ៉ាងណាក៏ដោយ លោកតា សឺន សាន នៅតែគ្រប់គ្រងសភាពការណ៍បានគ្រប់យ៉ាងនៅក្នុងជួរ រ.ជ.រ.ប.ខ, ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ២០ ធ្នូ ១៩៨៥ យើងបានប្រកាសថា "គណៈកម្មាធិការបណ្តោះអាសន្នរបស់លោក សក់ ស៊ុតសាខន ជាការចាត់តាំងខុសច្បាប់ និងបានអំពាវនាវដល់អ្នក ដែលជាប់ជំពាក់ទាំងអស់ឲ្យផ្តាច់ខ្លួនចេញពីមេក្លោងនៃ "បក្សប្រហារ"នេះ និង ឲ្យចូលមកក្នុងជួររ.ជ.រ.ប.ខ.វិញ" ។

នៅពេលដែលបានណាត់ជួបគ្នាមកដល់ ទាំងលោក សក់ ស៊ុតសាខន ទាំងលោក ដៀន ដែល មិនបានមកបង្ហាញខ្លួនឡើយ ។ ពួកយើងខកចិត្តខ្លាំងណាស់ ដែលលោកឧត្តមសេនីយទាំងពីររូប មិនមកជួបលោកប្រធានរបស់យើង ។ ស្អែកឡើង យើងចេញសេចក្តីប្រកាសព័ត៌មានមួយច្បាប់ទៀតដែលមានសេចក្តីជាអាទិថា៖ "ឯកឧត្តម សឺន សាន និង គណៈកម្មាធិការប្រតិបត្តិ នៅតែមានសកម្មភាពជាប្រក្រតី និង កំពុងប្រើអំណាចទាំងមូល ដើម្បីគ្រប់គ្រងស្ថាប័នទាំងអស់ ទាំងស៊ីវិល ទាំងយោធានៃរណសិរ្ស" ។ នៅក្នុងសេចក្តីប្រកាសព័ត៌មាននោះ ក៏មានផ្សព្វផ្សាយផងដែរនូវការដឹងគុណថ្វាយសម្តេច សីហនុ ដែលបានប្រទានការគាំទ្ររបស់ព្រះអង្គ ចំពោះលោកតាប្រធាន ។ ពួកយើងទាំងអស់គ្នាចំណាយពេលពេញមួយថ្ងៃទី ២១ ដើម្បីរង់ចាំសញ្ញាពីលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក្នុងការជួបទល់មុខគ្នាជាមួយលោកតា សឺន សាន ។ ថ្ងៃបន្ទាប់មក លោកតាប្រធានក៏បានចាត់ឲ្យបញ្ជូនសារអញ្ជើញឧត្តមសេនីយទាំងពីររូប ឲ្យមកជួបគ្នាទៀត ។ នៅក្នុងសារលោកតាប្រធានសរសេរថា៖ "ថ្ងៃនេះ នៅសល់តែមួយថ្ងៃគត់ សំរាប់ឲ្យយើងជួបគ្នាក្នុងឋានៈជាគ្រួសារ ។ ខ្ញុំនៅរង់ចាំអស់លោក" ។ ខុសពីសារលើកមុន ដែលមានលោក ប៊ុន សាយ ជាអ្នកចុះហត្ថលេខា លើកនេះលោកប្រធាន ចុះហត្ថលេខាខ្លួនឯង ។

# ក្រុមលោក សក់ ស៊ុតសាខន ឈប់ទទួលលោកតាជាប្រធាន

ចំពោះការអញ្ជើញជាថ្មីនេះ ម្តងនេះ លោកឧត្តមសេនីយទាំងពីររូបបានបញ្ជូនសារឆ្លើយតបមកវិញ ។ ទីមួយ លោក ដៀន ដែល បានឆ្លើយថា ក្នុងឋានៈជាទាហានគាត់ ស្ថិតនៅក្រោមអំណាចរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន គាត់មិនអាចនិយាយជំនួសឧត្តមសេនីយ សក់ ស៊ុតសាខន បានឡើយ ។ ចំណែកលោកឧត្តមសេនីយ សក់ ស៊ុតសាខន វិញ បានឆ្លើយថាគាត់បានត្រៀមខ្លួនជាស្រេចដើម្បីជួបលោកតា សឺន សាន ដោយមានលក្ខខណ្ឌតទៅនេះ៖ ទី១. ជួបគ្នានៅទីកន្លែងអព្យាក្រឹត ទី ២. ភាគីនីមួយៗមានគ្នា ៥ នាក់ចូលរួម ។ តាមការឆ្លើយតបរបៀបនេះ លោកឧត្តមសេនីយទាំងពីររូបបានតាំងខ្លួនជាភាគីមួយស្មើមុខ និង ជាអង្គភាពមួយដាច់ដោយឡែកលែងចំណុះ ឬ នៅក្រោមអំណាចលោកតា សឺន សាន ទៀតហើយ ។ ចំណុចគួរភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលខាងពួកយើងអ្នកគាំទ្រលោកតាប្រធានស្មានមិនដល់នោះគឺ ចម្លើយរបស់លោកឧត្តមសេនីយទាំងពីរផ្ញើជូនលោកតា សឺន សាន[185] [186] នោះ ប្រើពាក្យតែត្រឹមតែឯកឧត្តម សឺន សាន ដោយមិនបានដាក់ឋានៈផ្លូវការជាប្រធានរ.ជ.រ.ប.ខ.ដូចមុនៗនោះឡើយ ។ ចំពោះលោកតា សឺន សាន ចម្លើយបែបនេះ មានតម្លៃស្មើនឹងការប្រមាថមាក់ងាយ ដែលមិនអាចទទួលយកបាន ។

---

[185] Sak Sutsakhan (General), Message, A Son Excellence Son Sann, le 22 décembre 1985.
[186] Dien Del (Genereal), Message, A Son Excellence Son Sann, le 22 décembre 1985.

# ខ្ញុំលួចចេញទៅអារញ្ញទាំងកណ្តាលអធ្រាត្រ

នៅពេលដែលមើលឃើញថា គ្មានទំនងជាអាចឲ្យមេដឹកនាំរ.ជ.រ.ប.ខ.ទាំងពីរនាក់អាចជួបដោះស្រាយបញ្ហាបានទេនោះ ភាគីនីមួយៗខំព្យាយាមរក្សាការគ្រប់គ្រងត្រួតត្រាលើជនភៀសខ្លួនខ្មែរដែលរស់នៅក្នុងជំរុំ ជាពិសេស ក្នុងជំរុំសាយធូដែលជាជំរុំធំជាងគេបង្អស់នៅតាមទល់ដែនខ្មែរ-ថៃ ។ ចំពោះលោកតា សឺន សាន ការគាំទ្ររបស់ប្រជាពលរដ្ឋស៊ីវិលមានតម្លៃជាអតិបរមា ។ លោកតា ត្រូវការបង្ហាញពិភពលោកថា ទោះជាមានក្រុមប្រឆាំងបំបែកខ្លួនយ៉ាងណាក៏ដោយ ក៏លោកតានៅតែជាមេដឹកនាំស្របច្បាប់របស់រ.ជ.រ.ប.ខ.ដដែល ។ ជាគោលការណ៍ ការគាំទ្រនោះ មានលក្ខណៈជាការគាំទ្រខាងនយោបាយតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏នៅតែជាការគាំទ្រដ៏សំខាន់ណាស់ ។ ជាទូទៅ ជនរួមជាតិជាជនភៀសខ្លួនទាំងនោះ រស់នៅលើទឹកដីថៃ ហើយទទួលការឧបត្ថម្ភខាងម្ហូបអាហារ និង កន្លែងស្នាក់នៅពីអង្គការសហប្រជាជាតិ ។ ការចេញចូលទៅក្នុងជំរុំមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ពួកយើង ។ មែនទែនទៅ អ្វីៗអាស្រ័យលើអាជ្ញាធរថៃទាំងអស់ ។ គេឲ្យខាងណាចូលទៅទាក់ទងនឹងជនភៀសខ្លួន ខាងនោះនឹងទទួលបានផលល្អក្នុងការគាំទ្រ ។

ចាប់តាំងពីមានការបះបោរបំបែកខ្លួននៃក្រុមលោក សក់ ស៊ុតសាខន មកពាក្យសុំចូលទៅក្នុងជំរុំជនភៀសខ្លួនរបស់យើងទាំងអម្បាលម៉ាន ពុំបានទទួលចម្លើយជាវិជ្ជមានទាល់តែសោះ ។ ដូច្នេះ ខ្ញុំត្រូវលបចេញដំណើរដោយលួចលាក់ទៅអារញ្ញប្រាថេត ទីប្រជុំជននៅជាយដែន ដើម្បីរិះរកវិធីទាក់ទងជាមួយមេៗរបស់យើង ដែលកំពុងរស់នៅក្នុងជំរុំសាយធូ ដើម្បីឲ្យអ្នកទាំងនោះបានដឹងពីសភាពការណ៍ និង សម្របសម្រួលកិច្ចការទប់ទល់ជាមួយក្រុមប្រឆាំងផង ។ ជាមួយនឹងវត្តមានរបស់ខ្ញុំ នៅជាយដែន ខ្ញុំអាចជួយផ្តល់គំនិត ឬ ផ្តល់មតិ ដើម្បីកុំឲ្យគ្នីគ្នា

យើងនៅក្នុងជំរុំចាញ់បោកការឃោសនារបស់ក្រុមលោក សក់ ស៊ុតសាខន ។ មន្ត្រីអន្តរជាតិភាគច្រើនដែលបំរើការងារនៅសាយធូ ច្រើនមានលំនៅស្ថាននៅអារញ្ញប្រាថេត ។ ពួកគេអាចចេញចូលជំរុំភៀសខ្លួនបានដោយសេរី ។ ធម្មតាពួកនេះ គេចេញពីអារញ្ញនៅពេលព្រឹក ហើយវិលត្រឡប់មកវិញនៅពេលល្ងាច ។ ក្នុងចំណោមមន្ត្រីបំរើការឲ្យអង្គការអន្តរជាតិទាំងនោះ ខ្ញុំក៏មានមិត្តភក្តិមួយចំនួន ដែលខ្ញុំអាចពឹងពាក់បាន ។ ខ្ញុំពឹងពួកគេឲ្យនាំយកសំបុត្រខ្ញុំផ្ញើទៅជូនមេៗ និង អ្នកទទួលខុសត្រូវនៅក្នុងជំរុំរបស់យើង និង នាំយកសំបុត្ររបស់ពួកគេមកឲ្យខ្ញុំវិញ ដោយជៀសវាងកុំឲ្យពួកឃោជាថៃចាប់បាន ។ ដូច្នេះ វត្តមានរបស់ខ្ញុំ នៅអារញ្ញប្រាកដជាអាចសម្រួលទំនាក់ទំនងរវាងជំរុំ និង ទីស្នាក់ការកណ្តាលរបស់យើងនៅបាងកកបាន ។

ជាការសម្ងាត់ ខ្ញុំក៏លបចេញដំណើរពីបាងកកទៅអារញ្ញប្រាថេត នៅពាក់កណ្តាលអធ្រាត្រ ដោយមិនឲ្យហួណា ដែលនៅឃាមពួកយើងដឹងឡើយ ។ នៅពេលទៅដល់អារញ្ញប្រាថេតភ្លាម ខ្ញុំប្រញាប់តម្រង់ទៅផ្ទះអ្នកស្រី អែរណា ហង់រីកសុន (Erna Henrikson) ដែលជាមន្ត្រីនៃស្នងការអង្គការសហប្រជាជាតិខាងជនភៀសខ្លួន (UNHCR) ដែលជាមិត្តចាស់ និង ស្មោះត្រង់បំផុតរបស់ខ្ញុំ ។ អែរណា ត្រូវបានជនភៀសខ្លួនស្គាល់ស្ទើរទាំងអស់ ហើយហៅគាត់ថា "យាយសក់ស" ។ ខ្ញុំទៅដាស់គាត់ៗក្រោកទាំងសើងមម៉ើង រួចខ្ញុំពន្យល់ពីសភាពការណ៍នៅបាងកកដែលមានការបះបោរបំបែកខ្លួនរបស់ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ព្រឹកឡើង អែរណា ចេញទៅធ្វើការនៅជំរុំខៅ-អ៊ី-ដាង ទុកខ្ញុំឲ្យនៅក្នុងផ្ទះរបស់គាត់តែម្នាក់ឯង ក្រោយពេលដែលគាត់បានរៀបចំម្ហូបអាហារទុកឲ្យខ្ញុំជាស្រេច ។ រាល់ថ្ងៃ ពេលថ្ងៃ ខ្ញុំលាក់ខ្លួនពួនអាត្មានៅក្នុងផ្ទះ អែរណា មិនចេញទៅខាងក្រៅរហេតរហូតឡើយ ។ ពេលយប់ងងឹតទើបខ្ញុំចេញទៅក្រៅផ្ទះ ។ រាល់យប់ ខ្ញុំបររថយន្ត

របស់អែរណា ដើម្បីទៅរកជួបមន្ត្រីអង្គការអន្តរជាតិ ដែលធ្វើការនៅក្នុងជំរុំសាយធូ ដើម្បីនាំសំបុត្រយកទៅផ្ញើ និង ទៅទទួលសំបុត្រពីសាយធូមកវិញ ។

នៅក្នុងសំបុត្រដែលខ្ញុំផ្ញើទៅអ្នកទទួលខុសត្រូវរបស់ពួកយើងនៅក្នុងជំរុំ គឺ អ្នកគាំទ្រលោកតា សឺន សាន ខ្ញុំបានពង្រឹងទឹកចិត្តអ្នកទាំងនោះថា លោកតាប្រធាននៅតែគ្រប់គ្រងបានយ៉ាងរឹងមាំនូវចលនាតស៊ូរបស់យើង ហើយក្រុមយើងទទួលបានការគាំទ្រយ៉ាងធំធេងពីសមាជិក សមាជិការ.ជ.រ.ប.ខ.នៅសហរដ្ឋអាមេរិក នៅអឺរ៉ុប ជប៉ុន និង នៅអូស្ត្រាលី ។ ខ្ញុំបញ្ជាក់ថា លោកតា សឺន សាន នៅតែបានការទទួលស្គាល់ពីសម្តេច សីហនុ ថាជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និង ជាប្រធានរ.ជ.រ.ប.ខ. ។ ជាមួយគ្នានោះ ខ្ញុំក៏ផ្តល់អនុសាសន៍ដល់អ្នកដឹកនាំធំៗទាំងនោះ សម្រាប់សកម្មភាពនានា ដែលត្រូវធ្វើនៅពេលខាងមុខ ។ តាមរយៈអ្នករត់សំបុត្រនោះ ខ្ញុំក៏ទទួលត្រឡប់មកវិញនូវព័ត៌មានពីជំរុំអំពីសកម្មភាពអមិត្តរបស់ក្រុមលោក សក់ ស៊ុតសាខនគឺ ការឃោសនាប្រឆាំងលោកតា សឺន សាន ផង ។ តាមរយៈការផ្លាស់ប្តូរសំបុត្រឆ្លងឆ្លើយគ្នានេះ ពួកយើងក៏បានដឹងថា ក្រុមលោក សក់ ស៊ុតសាខន បានដាក់ការគាបសង្កត់យ៉ាងខ្លាំងដល់អស់លោកមេជំរុំទាំងអស់ បង្ខំឲ្យពួកគេរត់ចោលលោកតា សឺន សាន មកចុះចូលខាងពួកឧត្តមសេនីយវិញ ។

# ទាហានថៃតាមរកខ្ញុំ

នៅពេលនោះ ក្រុមបំបែកខ្លួនរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានទទួលការគាំទ្រយ៉ាងខ្លាំងពីក្រុមយោធាថៃ ។ ក្រុមបំបែកខ្លួននេះ អាចសុំឲ្យទាហានថៃចាប់មេជំរុំ ដែលប្រឆាំងពួកគេទៅឃុំឃាំងបាន ។ ដូច្នេះ ពួកយើងខ្លះក៏មានការភ័យខ្លាច ឬ បារម្ភយ៉ាងខ្លាំង ។ មិនយូរប៉ុន្មាន វត្តមានលួចលាក់របស់ខ្ញុំនៅ

ក្នុងផ្ទះអែរណា ក៏ត្រូវបែកធ្លាយទៅដល់អង្គភាពពិសេស ៨៣៨ ។ នៅព្រឹកមួយនោះ នៅពេលដែលខ្ញុំកំពុងទទួលទានអាហារពេលព្រឹក នៅឯផ្ទះបាយឯក្រោយឯនោះខ្ញុំឮសម្លេងអែរណាស្រែកខ្លាំងពីបន្ទប់គាត់នៅខាងមុខមកថា៖ "មូលី កុំចេញពីផ្ទះបាយ នៅឲ្យស្ងៀមកុំមាត់កអ្វីឲ្យសោះ មានគេមករកមូលីឯងហើយ" ។ មែនទែនទៅ អែរណា បានក្រឡេកឃើញ ហើយស្គាល់អ្នកបររថយន្តចូលមកក្នុងបរិវេណផ្ទះគាត់ ។ គេនោះជាទាហាននៅក្នុងអង្គភាពពិសេស ៨៣៨ ។ ប៉ុន្មានវិនាទីក្រោយមក រថយន្តក៏មកឈប់នៅជិតជណ្តើរផ្ទះ រួចខ្ញុំឮគេបញ្ឈប់សម្លេងម៉ាស៊ីន។ ទាហាននោះ និយាយមករក អែរណា ជាភាសាថៃ ព្រោះ អែរណា ចេះភាសាថៃយ៉ាងស្ទាត់ជំនាញ ។ ទាហាននោះនិយាយថា គាត់គ្រាន់តែចូលមកលេងសួរសុខទុក្ខ អែរណា តែប៉ុណ្ណោះ ។ ក្រោយពីនិយាយលេងយ៉ាងខ្លីមក ទាហានថៃនោះក៏លាចេញទៅ ។ នៅទីបំផុត ដើម្បីជាការប្រុងប្រយ័ត្នខ្ពស់ ខ្ញុំសម្រេចចិត្តវិលត្រឡប់ទៅបាងកកវិញភ្លាមនៅព្រឹកនោះ ។

## នាយទាហានថៃកាន់កាប់ទ័ពយើងដោយផ្ទាល់

នៅពេលដែលខ្ញុំជាប់ដៃនៅអារញ្ញប្រាថេត នៅឯទីក្រុងបាងកកឯនោះវិញ ក្រុមការងារ និង អាជ្ញាធរយោធាថៃ ក៏បានសាកល្បងដោះស្រាយវិបត្តិរបស់ រ.ជ.រ.ប.ខ. តាមវិធីរបស់គេដែរ ។ ពួកគេនៅតែទទូចឲ្យបញ្ចូលលោក ហ្គាហ្វា និង លោក ហ៊ីង គន្ថុន ទៅក្នុងរ.ជ.រ.ប.ខ. ដែលជាចំណុចមិនឲ្យលោកតា សឺន សាន ទទួលយកបាន ។ ក្រុមការងារ និង អាជ្ញាធរយោធាថៃ ក៏នៅតែឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទទួលយកដដែលវិញនូវមុខនាទីរបស់គាត់ជាអគ្គមេបញ្ជាការនៃ ក.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ លោកតា សឺន សាន នៅតែប្រកាន់ថានឹងប្រគល់តួនាទីជាអគ្គបញ្ជាការកងទ័ពជូនលោក ស៊ុត សាខន តែក្នុងករណីមាន

លក្ខខណ្ឌខ្លះតែប៉ុណ្ណោះ ។ នៅថ្ងៃទី ២៣ ធ្នូ ១៩៨៥ នាពាក់កណ្ដាលអធ្រាត លោកតាបានជួបលោកឧត្ដមសេនីយ ឆាវលិត ដើម្បីបញ្ជាក់ជូនលោកមេទ័ពថៃនូវគោលជំហរនេះ ។ លោក ឆាវលិត បានផ្ដល់យោបល់សុំឲ្យលោកតា សឺន សាន ខិតខំរិះរកដំណោះស្រាយល្អណា ដែលអាចទទួលយកបានទាំងសងខាង ។ នៅពេលជាមួយគ្នានោះ អង្គភាព ៨៣៨ ក៏បានបញ្ជាឲ្យមេបញ្ជាការក.ជ.រ.ប.ខ. ទាំងអស់ បង្កើតគណៈកម្មាធិការយោធាបណ្ដោះអាសន្នមួយ ដែលមានគ្នា ១០ នាក់ ហៅថា "គណៈកម្មាធិការយោធា ១០ នាក់" ដែលស្ថិតនៅក្រោមការសម្របសម្រួលរបស់អាជ្ញាធរយោធាថៃ ទម្រាំមានដំណោះស្រាយវិបត្តិថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. ។

នៅថ្ងៃទី ២៤ ធ្នូ ១៩៨៥ ក្រុមលោក សក់ ស៊ុតសាខន បានបញ្ជាដល់មេទ័ព រ.ជ.រ.ប.ខ. ទាំងអស់ ឲ្យផ្ដាច់ការទាក់ទងតាមវិទ្យុជាមួយទីស្នាក់ការរបស់លោកតា សឺន សាន ។ ពាក្យចចាមអារាម បានធ្លាយឲ្យដឹងថាអាជ្ញាធរថៃ បានសម្រេចឲ្យលោកតា សឺន សាន ទទួលខុសត្រូវតែចំពោះបញ្ហានយោបាយ និងការទូតតែប៉ុណ្ណោះ ឯលោកឧត្ដមសេនីយ សក់ ស៊ុតសាខន ត្រូវទទទួលបន្ទុកជាអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ដែលមានអំណាចត្រួតត្រាទាំងផ្នែកយោធា និងផ្នែកស៊ីវិល ។ នៅថ្ងៃទី ២៥ ធ្នូ ១៩៨៥ លោកតា សឺន សាន សុខចិត្តធ្វើសម្បទានខ្លះ ។ នៅក្នុងអនុស្សារណៈមួយផ្ញើជូនលោកឧត្ដមសេនីយ ឆាវលិត លោកតាប្រធានស្នើឲ្យលោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ចេញទៅឈប់សម្រាកចំនួន ៦ ខែ ។ នៅថ្ងៃទី ២៦ ធ្នូ លោកតាសុំច្បាប់លោកឧត្ដមសេនីយ ឆាវលិត ទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូ ក៏ប៉ុន្តែគ្មានបានទទួលចម្លើយពីលោកឧត្ដមសេនីយឡើយ ។ នៅថ្ងៃទី ១ មករា ១៩៨៦ លោកតា សឺន សាន ចេញសេចក្ដីប្រកាសមួយ ដាក់គណៈកម្មាធិការបណ្ដោះអាសន្នរបស់ក្រុមលោកឧត្ដមសេនីយ សក់ ស៊ុតសាខន

ថាជាអង្គការខុសច្បាប់ រួចលោកតាធ្វើពាក្យសុំការអនុញ្ញាតពីឧត្តមសេនីយ ឆាវលិត ដើម្បីទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូម្តងទៀត ។ ជាថ្មីម្តងទៀត លោកឧត្តមសេនីយ ឆាវលិត ក៏នៅតែមិនឆ្លើយតបចំពោះសំណើរបស់យើង។ យើងរង់ចាំរហូតដល់ថ្ងៃ ៣ មករា ១៩៨៦ នាពេលល្ងាច ទើបបានទទួលចម្លើយពីខុទ្ទកាល័យរបស់លោក ឆាវលិត ថាលោកឧត្តមសេនីយបានទទួលលិខិតរបស់យើងហើយ តែក៏នៅពុំទាន់សម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតនៅឡើយទេ ។ ពួកយើងនាំគ្នាគិតថានេះជាការគាបសង្កត់មួយទៀតមកលើលោកតា សឺន សាន ។

# គេប្រើល្បិចកុំឲ្យខ្ញុំជួបលោក សូឡា

នៅថ្ងៃទី ៦ មករា លោកតាប្រធាន បានជួបជាមួយលោក ស្តេហ្វិន សូឡា (Stephen Solarz) សមាជិកសភាសហរដ្ឋអាមេរិក ដែលគេសម្គាល់ថាជាមនុស្សគាំទ្រ រ.ជ.រ.ប.ខ. យ៉ាងចេញមុខជាយូរមកហើយៗក៏ជាស្ថាបត្យករនៃការផ្តួចផ្តើមគំនិតរកដំណោះស្រាយបញ្ហាកម្ពុជាមួយរូបផង ។ លោកតា សឺន សាន បានតវ៉ាចំពោះមុខលោក សូឡា អំពីទំនាស់ផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ. និង ការគាបសង្កត់របស់ថៃ ។ បន្ទាប់ពីជំនួបជាមួយលោកសូឡារួចមក លោកតាប្រធានបានចាត់ខ្ញុំឲ្យធ្វើដំណើរទៅជំរុំសាយធូក្នុងឋានៈជាតំណាងផ្ទាល់របស់ប្រធាន ដើម្បីរង់ចាំទទួលលោក សូឡា ដែលនឹងត្រូវទៅធ្វើទស្សនកិច្ច នៅជំរុំនោះ នៅថ្ងៃស្អែកគឺថ្ងៃ ៧ មករា ១៩៨៦ ។ ម្តងនេះ អាជ្ញាធរថៃបានចេញច្បាប់អនុញ្ញាតឲ្យខ្ញុំ និង ជំនួយការម្នាក់ចូលទៅជំរុំបាន ។ នាល្ងាចថ្ងៃទី ៦ មករា នោះ ខ្ញុំក៏ចេញដំណើរពីបាងកក ឆ្ពោះទៅអារញ្ញប្រាថេត រួចឈប់សម្រាកនៅផ្ទះយាយសក់ស(Erna Henrikson)ម្តងទៀត រង់ចាំព្រឹកឡើងនឹងបន្តដំណើរទៅជំរុំសាយធូ ។

ព្រឹកថ្ងៃទី ៧ មករា ខ្ញុំក៏ទៅដល់ជំរុំសាយធូដូចបានកំណត់ ។ ពេលឃើញខ្ញុំចូលទៅដល់ក្នុងជំរុំ ពួកអ្នកគាំទ្រយើងបានអបអរសាទរទទួលយ៉ាងខ្ញៀវខ្ញារំពងអឺងកង ។ ពួកគេសប្បាយចិត្តណាស់ ដោយបានទទួលការលើកទឹកចិត្តយ៉ាងខ្លាំង នៅពេលឃើញវត្តមានរបស់យើង ព្រោះក្នុងពេលដែលយើងមិនបានចូលក្នុងជំរុំមួយរយៈនោះ ក្រុមប្រឆាំងបានធ្វើការឃោសានាវាយប្រហារ ឬ បន្តុះបង្អាប់ ឬ គាបសង្កត់យ៉ាងខ្លាំង ដោយមានការគាំទ្រពីយោធាថៃផង ។ នៅពេលដែលខ្ញុំកំពុងសំណេះសំណាលជាមួយមន្ត្រីរដ្ឋបាលរបស់យើង និង ក្នុងពេលដែលខ្ញុំកំពុងរង់ចាំជួបលោក ឡាយ ខែក ដែលនៅពេលនោះ ជាប្រធានជំរុំសម្លរ និង ជាអ្នកគាំទ្រការពារលោកតា សឺន សាន យ៉ាងដាច់ខាតម្នាក់នោះ ស្រាប់តែមានក្រុមទាហានអាវខ្មៅថៃពីរនាក់ ដើរចូលមកនិយាយប្រាប់ខ្ញុំថា លោកសក្តិ ៥ ជាមេបញ្ជាការថៃប្រចាំជំរុំចង់ជួបពិភាក្សាការងារជាមួយខ្ញុំ នៅទីបញ្ជាការរបស់គាត់ជាបន្ទាន់ ។ ខ្ញុំនឹកក្នុងចិត្តថាការដែលអាជ្ញាធរថៃចង់ជួបខ្ញុំនេះ ប្រាកដជាមានបញ្ហាសំខាន់ណាស់ហើយ ព្រោះពីមុនៗមក គេមិនដែលឲ្យខ្ញុំជួបទេ ។ ដូច្នេះ ខ្ញុំក៏ប្រញាប់ប្រញាល់ចេញទៅជួបលោកសក្តិ ៥ ទាហានអាវខ្មៅថៃ ដោយមិនទាន់ទាំងបានជួបលោក ឡាយ ខែក ផង ។

នៅពេលខ្ញុំទៅដល់ការិយាល័យរបស់លោកសក្តិ ៥ ថៃនោះ ទាហានថៃម្នាក់បានលើកទឹកត្រជាក់មួយកែវមកផ្តល់ និង សុំឲ្យអង្គុយរង់ចាំយ៉ាងគួរសមរាក់ទាក់ល្អណាស់ រួចទាហាននោះក៏ចេញទៅបាត់ទៅ ។ ខ្ញុំចេះតែអង្គុយរង់ចាំលោកសក្តិ៥ មិនហ៊ានចេញចូលទៅណាឡើយ ក៏ប៉ុន្តែខ្ញុំមិនឃើញលោកសក្តិ ៥ ចេញមុខមកសោះ ។ ខ្ញុំរង់ចាំអស់រយៈពេលប្រហែល ៤ ម៉ោង ទើបទាហានដែលឲ្យខ្ញុំអង្គុយចាំនោះ មកប្រាប់ខ្ញុំវិញថាគ្មានការងារអ្វីសំខាន់ទេ ខ្ញុំអាចចេញទៅវិញបាន ។ តាមពិតទៅ នេះគ្រាន់តែជាល្បិចកលរបស់យោធាថៃដើម្បីបញ្ចៀសខ្ញុំកុំឲ្យមានលទ្ធភាពជួបជាមួយលោក សូឡា តែប៉ុណ្ណោះ ។ ធ្វើយ៉ាងដូច្នេះ ដើម្បីបង្ហាញឲ្យលោក

សូឡា មើលឃើញថា នៅក្នុងជំរុំសាយធូគ្មានអ្នកគាំទ្រលោកតា សឺន សាន ទេ មានតែមនុស្សរបស់លោក សក់ ស៊ុតសាខន ។ នៅពេលដែលខ្ញុំនៅជាប់ក្នុងកលល្បិចរបស់ទាហានថៃនោះ លោកឧត្តមសេនីយ ដៀន ដែល ដែលជាមេដឹកនាំក្រុមប្រឆាំងម្នាក់ទៀត ដែលកំពុងរស់នៅក្នុងជំរុំសាយធូបានបញ្ជូនសារតាមវិទ្យុអំពីជ័យជំនះរបស់ក្រុមគាត់ថា អៀង មូលី ត្រូវបានទាហានថៃចាប់ឃុំឃាំងអស់រយៈពេល ៤ ម៉ោងហើយ អៀង មូលី អត់បានជួបជាមួយលោក សូឡា ទេ ។ ទោះបីជាមានការប៉ះទង្គិចយ៉ាងនេះក្តី លោកឧត្តមសេនីយ ឆាវលិត បានជំរាបដល់មន្ត្រីសហរដ្ឋអាមេរិក និង ចិនថាថៃមិនបានផ្លាស់ប្តូរនយោបាយក្នុងបញ្ហារ.ជ.រ.ប.ខ.ទេគឺ ថៃនៅតែទទួលស្គាល់លោកតា សឺន សាន ជាប្រធានរ.ជ.រ.ប.ខ. និង ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យជាដរាប ។ លោកតា សឺន សាន ក៏នៅតែបន្តទទូចសុំទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូតទៅទៀត ។

## លោកតា សឺន សាន អាចទៅធ្វើទស្សនកិច្ចនៅសាយធូ

នៅថ្ងៃទី ១៤ មករា ១៩៨៦ ពួកយើងបានដាក់ពាក្យសុំរបស់លោកតាទៅសាយធូម្តងទៀតជាលើកទី៣ ដើម្បីទៅធ្វើទស្សនកិច្ចក្នុងរយៈពេលបីថ្ងៃ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានប្រឆាំងនឹងពាក្យសុំធ្វើទស្សនកិច្ចរបស់លោកតាប្រធាននេះ ដោយធ្វើលិខិតជំទាស់មួយច្បាប់ផ្ញើជូនលោកឧត្តមសេនីយ ឆាវលិត និង មួយច្បាប់ទៀតជូនលោក សិទ្ធី សាវេតសិលា រដ្ឋមន្ត្រីការបរទេសថៃ ។ ជាមួយគ្នានោះ នៅឯជាយដែនឯនោះវិញ លោកឧត្តមសេនីយ ដៀន ដែល បានគំរាមដល់ពួកយើងថាអាចនឹងមានការប៉ះទង្គិចគ្នា ប្រសិនបើលោកតា សឺន សាន នៅតែចចេសទៅធ្វើទស្សនកិច្ចនៅសាយធូតទៅទៀត ។ ក៏ប៉ុន្តែ លើកនេះទោះជាមានការប្រឆាំង ក៏ពួកយើងត្រូវបានទទួលជោគជ័យម្តងវិញ ។ អាជ្ញាធរថៃបានសម្រេចឲ្យ

ពួកយើងអាចចូលទៅសាយធូបាន ក៏ប៉ុន្តែគេអនុញ្ញាតឲ្យតែសម្រាប់ទស្សនកិច្ចមួយថ្ងៃមិនមែនសម្រាប់បីថ្ងៃដូចយើងសុំនោះឡើយ ។ នេះជាដំណឹងដ៏ល្អសម្រាប់ពួកយើង ព្រោះថាទស្សនកិច្ចរបស់លោកតាប្រធាននៅក្នុងជំរុំនឹងលើកទឹកចិត្តដល់អ្នកគាំទ្រទាំងអស់ឡើងវិញ ។ ក៏ប៉ុន្តែក្រុមប្រឆាំងនៅតែព្យាយាមរារាំងមិនឲ្យពួកយើងអាចជួបប្រជាពលរដ្ឋ និង អ្នកគាំទ្រពួកយើងនៅឯមូលដ្ឋានបានតទៅទៀត ។

នៅថ្ងៃទី ១៥ មករា ១៩៨៦ ហ្គាហ្វា បានធ្វើដំណើរទៅអារញ្ញប្រាថេត ដើម្បីទៅចាក់សោទ្វារបន្ទប់សម្រាករបស់លោកតា សឺន សាន នៅឯផ្ទះសំណាក់សុវត្ថិភាព និង ដើម្បីប្រមែប្រមូលដកយកវិទ្យុទាក់ទងមួយគ្រឿងគត់ ដែលពួកយើងមានសម្រាប់ទាក់ទងគ្នារវាងទល់ដែន និង ទីស្នាក់ការកណ្តាលនៅទីក្រុងបាងកក ។ ហ្គាហ្វា ធ្វើបែបនេះដើម្បីរារាំងកុំឲ្យលោកតា សឺន សាន ឬ ពួកយើងមកសំណាក់ និង ទាក់ទងគ្នាជាមួយពួកយើងបាន ។ នៅទីបំផុត នៅថ្ងៃទី ១៧ មករា ១៩៨៦ គឺ មួយខែចាប់តាំងពីក្រុមឧត្តមសេនីយធ្វើការបះបោរប្រឆាំង លោកតាប្រធានបានចូលទៅជំរុំសាយធូជាថ្មីវិញ ។ នៅសាយធូ (ជំរុំនីមួយៗដែលរើមកនៅក្នុងបរិវេណសាយធូ បន្ទាប់ពីត្រូវកងទ័ពវៀតណាមវាយបាក់បែកមកនោះ នៅតែរក្សាឈ្មោះជំរុំរបស់ខ្លួនដដែលដូចជា នងចាន់ សម្លរឆ្ងាញ់ ដងរែក អូរបុកជាដើម) មានប្រជាពលរដ្ឋជាច្រើននាក់បានមក ទទួលពួកយើងយ៉ាងណែនណាន់តាន់តាប់ ។ មន្ត្រីយោធាថៃ ដែលអមដំណើរពួកយើងនៅពេលនោះ បានប្រាប់ពួកយើងថាគេបានណែនាំលោកឧត្តមសេនីយ ដៀន ដែល ដែលស្នាក់នៅក្នុងជំរុំឲ្យចេញមកទទួលលោកតាប្រធានដែរ តែលោកឧត្តមសេនីយរូបនេះ ឥតបានបង្ហាញមុខឡើយ ។ ឆ្លៀតក្នុងឱកាសនៃទស្សនកិច្ចនេះ លោកតាប្រធានរ.ជ.រ.ប.ខ.បានផ្សព្វផ្សាយឲ្យក្រុមអ្នកគាំទ្រអន្តរជាតិរបស់លោកតា ដឹងថាលោកតាមានបំណងដោះ

ស្រាយជម្លោះផ្ទៃក្នុងនេះ ក្នុងលក្ខណៈគ្រួសារ ក៏ប៉ុន្តែក្រុមប្រឆាំងហាក់ដូចជាមិនយល់ស្របតាមលោកតាទាល់តែសោះ ។

## ក្រុម សក់ ស៊ុតសាខន ចង់ឲ្យលោកតាធ្វើប្រធានកិត្តិយស

នៅថ្ងៃ ២៦ មករា ១៩៨៦ លោកឧត្តមសេនីយ ឆាវលិត បានជួបជាមួយលោកតា សឺន សាន ។ បន្ទាប់មកនៅពេលល្ងាច លោកមេទ័ពថៃរូបនេះបានឲ្យរៀបចំធ្វើការប្រជុំគ្នារវាងក្រុមយើង និង ក្រុមប្រឆាំង ដើម្បីឲ្យជជែកគ្នា តើត្រូវបញ្ចប់ជម្លោះផ្ទៃក្នុងយ៉ាងដូចម្តេច? ក្រុមយើងមានលោកតា សឺន សាន ជាអ្នកដឹកនាំដោយរួមមានជាអាទិ៖ លោក នាង ជិនហាន អគ្គលេខាធិការ លោកវរសេនីយ ព្រុំ វិត លោក ប៊ុន សាយ លោកវរសេនីយ អ៊ឹម ឈូដេត លោកឧត្តមសេនីយ ថាច់ រ៉េង លោកវរសេនីយ ឈឹម ឱមយ៉ុន លោកវរសេនីយកងទ័ពអាកាស សង្វារ ជី ឡូប៉េស និង រូបខ្ញុំ អៀង មូលី ។ ចំណែកឯក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន មានលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអ្នកដឹកនាំ បន្ទាប់មកមានលោកតា ហ៊ុយ គន្ធុល អតីតនាយករដ្ឋមន្ត្រី លោកតា ថុន អ៊ុក អតីតរដ្ឋមន្ត្រី លោក ហ្គាហ្វា លោកវរសេនីយ ចក់ បូរី លោក ប៉ែន ធុឡា និង លោកឧត្តមសេនីយ ប៉ុក សំអាន ។ លោកឧត្តមសេនីយ ឆាវលិត ចាប់ផ្តើមបើកអង្គប្រជុំ ដោយស្នើឲ្យភាគីខ្មែរទាំងពីរបំភ្លេចរឿងចាស់ រឿងដែលកន្លងផុតទៅហើយនោះ និង ឲ្យខំពិភាក្សារកដំណោះស្រាយបញ្ហាបច្ចុប្បន្ន និង អនាគត ដើម្បីបញ្ចប់ជម្លោះក្នុងបរិយាកាសជាបងជាប្អូនក្នុងគ្រួសារតែមួយ ជាពិសេស លោកមេទ័ពថៃរូបនេះប្រដៅ ឲ្យខំរកដំណោះស្រាយក្នុងឋានៈជាខ្មែរអ្នកជាតិនិយម ដែលមានភារកិច្ចរំដោះប្រទេស ។ បន្ទាប់មកលោក ឆាវលិត ក៏ចេញបាត់ទៅ ទុកឲ្យភាគីខ្មែរនិយាយគ្នា ។ លោកតាប្រធានផ្តើមការពិភាក្សា ដោយបញ្ជាក់ជាថ្មីថាលោកតានៅរក្សាប្រតិភូកម្មនៃការទទួលខុសត្រូវខាង

កងទ័ព ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដដែល និង សុខចិត្តទទួលយកការកាត់ផ្តាច់អំណាចយោធា ចេញពីកិច្ចការនយោបាយការទូត និង ហិរញ្ញវត្ថុ ។ បន្ទាប់មក លោកតាសុំឲ្យលោកអគ្គលេខាធិការ នាង ជិនហន សំដែងមតិមុនគេ ទំនងជាចង់ដឹងថាតើលោកអគ្គលេខាមានទំនោរទៅខាងណា? ដូច្នេះលោកអគ្គលេខា នាង ជិនហន មានការប្រយ័ត្នប្រយែងណាស់ក្នុងការនិយាយស្តី ។ ជាទូទៅគាត់យោងទាំងស្រុងទៅលើក្រិត្យក្រមរបស់រ.ជ.រ.ប.ខ.គឺ គូសបង្ហាញឲ្យឃើញថាការបះបោរប្រឆាំងរបស់ក្រុមឧត្តមសេនីយជាការខុសច្បាប់ ឬ ខុសធម្មនុញ្ញរបស់ រ.ជ.រ.ប.ខ. ។ ឆ្លើយតបវិញ ក្នុងនាមភាគីម្ខាងទៀត លោកតា ប៊ុន អ៊ុក មិនគ្រាន់តែមិនព្រមលើកមកជជែកអំពីសំណើខាងលើរបស់លោកតា សឺន សាន ទេ តែយកវេទិកានោះ ចោទប្រកាន់លោកតាប្រធានថា ដឹកនាំរណសិរ្សតាមរបៀបផ្តាច់ការ យកការតស៊ូរំដោះជាតិទាំងមូល ធ្វើឲ្យមានជាបក្សពួក ឬ គ្រួសារនិយម ។ លោកតា ប៊ុន អ៊ុក ស្នើលោកតា សឺន សាន ឲ្យទទួលយកមុខនាទីជាប្រធានកិត្តិយស និង សុំឲ្យគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ.របស់លោក សក់ ស៊ុតសាខន ដែលទើបបង្កើតថ្មីនេះ ជំនួសគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច តទៅ ។ នៅក្នុងការពិភាក្សានោះ ទាំងលោកតា ប៊ុន អ៊ុក ទាំងលោកតា ហ៊ុយ គន្ធុល ដែលអះអាងថាជាមិត្តរបស់លោកតា សឺន សាន ជាង ៤០ ឆ្នាំមកហើយ ទទូចថាមានតែទទួលយកលក្ខខណ្ឌទាំងពីរខាងលើទេ ទើបអាចបញ្ចប់ជម្លោះ ។ លោកតា ប៊ុន អ៊ុក អះអាងថាឋានៈប្រធានកិត្តិយសសមរម្យណាស់សម្រាប់លោកតា សឺន សាន ព្រោះខ្ពស់ផុតពីគេ ដូចសម្តេចមហាក្សត្រីយានី អេលីហ្សាបេតទី ២ នៃប្រទេសអង់គ្លេស ដើម្បីកុំឲ្យលោកតា សឺន សាន លូកដៃចូលក្នុងការងារតូចតាចរបស់ រ.ជ.រ.ប.ខ. ។ ជាទូទៅក្រុមលោកឧត្តមសេនីយ បានមើលឃើញច្បាស់ថា រ.ជ.រ.ប.ខ. មិនអាចរំដោះប្រទេសកម្ពុជាចេញពីការកាន់កាប់របស់កងទ័ពវៀតណាម

បានឡើយ ប្រសិនបើបន្តឲ្យលោកតា សឺន សាន នៅដឹកនាំចលនាតស៊ូនេះតទៅទៀត ដូច្នេះពួកគេអះអាងថាបានធ្វើការពិគ្រោះជាមួយឥស្សរជនអ្នកស្នេហាជាតិ និង អ្នកទទួលខុសត្រូវសំខាន់ៗរបស់រ.ជ.រ.ប.ខ. ហើយយល់ថាត្រូវបញ្ចប់ការដឹកនាំរបស់លោកតាប្រធាន ។

នៅពេលដល់វេនខ្ញុំត្រូវនិយាយ ខ្ញុំលើកជាសំណួរដល់ក្រុមលោក សក់ ស៊ុតសាខន ថាតើអស់លោកឈរលើមូលដ្ឋានស្របច្បាប់អ្វី ទើបអស់លោកសម្រេចថាអស់លោកអាចមកជំនួសឯកឧត្តមប្រធាន និង គណៈកម្មាធិការប្រតិបត្តិយ៉ាងដូច្នេះ? ខ្ញុំបានបញ្ជាក់ទៀតក្នុងន័យថាប្រសិនបើក្នុងអង្គការណាមួយ គេមិនគោរពលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងទេនោះ អង្គការនោះប្រាកដជាមិនអាចដំណើរការឲ្យល្អបានឡើយ ។ ក្រោយពីជជែកគ្នាអស់រយៈពេលយ៉ាងយូរមក ក្រុមលោក សក់ ស៊ុតសាខន នៅតែទាមទារឲ្យលោកតា សឺន សាន ទទួលតួនាទីជាប្រធានកិត្តិយស និង ឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន ធ្វើជាប្រធាន រ.ជ.រ.ប.ខ. ព្រមទាំងឲ្យគណៈកម្មាធិការកណ្ដាលបណ្ដោះអាសន្នសង្គ្រោះរ.ជ.រ.ប.ខ.របស់លោក សក់ ស៊ុតសាខន ជំនួសគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច ។ សំណើនេះ មានលក្ខណៈហួសហេតុពេក ដែលនាំឲ្យក្រុមខាងលោកតា សឺន សាន ទាត់ចោលទាំងស្រុង ។ សំណើនេះមានលក្ខណៈធ្ងន់ធ្ងរជាងគោលជំហររបស់អាជ្ញាធរថៃ ដែលបានគិតគូររួចហើយថា "ការងារនយោបាយ និង ការទូតត្រូវទុកជូនលោកតាប្រធាន សឺន សាន ចំណែកឯបញ្ជាការយោធាទុកជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន"។[187] ដូច្នេះភាគីទាំងពីរ ក៏មិនអាចស្វែងរកឯកភាពស្រុះស្រួលគ្នា ដើម្បីបញ្ចប់ជម្លោះនោះឡើយ ។ នៅពេលដែលលោក ឆាវលិត វិលត្រឡប់មកបិទអង្គប្រជុំភាគីខ្មែរគ្មានពាក្យអ្វីដើម្បីធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ជូនលោកមេទ័ពថៃរូបនេះបានឡើយ ។

---

[187] Ieng Mouly, Briefing on the meeting held on Saturday, January 26, 1986.

លោកឧត្តមសេនីយ ឆាវលិត សួរបញ្ជាក់លោកតា ថុន អ៊ុក ថាហេតុអ្វីបានជាមិនទុកលោកតា សឺន សាន ជាប្រធានដដែល តើខុសគ្នាយ៉ាងដូចម្តេចរវាងប្រធាន និង ប្រធានកិត្តិយស? ដោយក្រុមលោក សក់ ស៊ុតសាខន មិនចង់ពិភាក្សាតទៅទៀតនោះ លោក ឆាវលិត ទាំងមិនសប្បាយចិត្ត បានថ្លែងនៅពេលបិទនោះជាអាទិថា៖ "ដោយសារអស់លោក ដែលជាក្រុមមិនមែនកុម្មុយនីស្តមិនអាចរួបរួមគ្នាបាន ប្រទេសកម្ពុជានឹងធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តជាថ្មីទៀត ។ យើងគ្មានសង្ឃឹមថានឹងឃើញប្រទេសខ្មែរជាប្រទេសសេរីទេ ។ ដោយអស់លោកមិនអាចដោះស្រាយបញ្ហាផ្ទៃក្នុងដោយខ្លួនឯងបាននោះ សូមអស់លោករង់ចាំទទួលអនុវត្តតាមវិធានការ ដែលយើងខ្ញុំនឹងចាត់នៅពេលខាងមុខ" ។ ថ្ងៃនោះជាថ្ងៃដ៏អាម៉ាស់មួយចំពោះយើងជាខ្មែរទាំងអស់គ្នា ។

# លោក សក់ ស៊ុតសាខន សុំរៀបចំកូមិ៉ុចជាថ្មី

នៅពេលរង់ចាំសេចក្តីសម្រេចកាត់ក្តីរបស់លោក ឆាវលិត ទីបំផុត នៅថ្ងៃទី ២ កុម្ភៈ ១៩៨៦ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានមកជួបផ្ទាល់ជាមួយលោកតាប្រធាន នៅស្នាក់ការកណ្តាលរបស់ពួកយើងនៅម៉ាយ៉ាឡាប់ ។ លោកតា សឺន សាន បានជំរាបលោក សក់ ស៊ុតសាខន ថាលោកតាបានត្រៀមខ្លួនរួចហើយដើម្បីប្រគល់ភារកិច្ចជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.ជូនលោកឧត្តមសេនីយ ក៏ប៉ុន្តែក្នុងឋានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានការទទួលខុសត្រូវទាំងស្រុងខាងនយោបាយ ស៊ីវិល និង ហិរញ្ញវត្ថុ ។ លោកតា សុំឲ្យលោកឧត្តមសេនីយជួយចាត់ការឲ្យមានសណ្តាប់ធ្នាប់ និង ធ្វើឲ្យមានវិន័យឡើងវិញនៅក្នុងជួរ.ជ.រ.ប.ខ. ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅពេលនោះ មិនបានបញ្ចេញមតិថា គាំទ្រ

ឬ បដិសេធសំណើរបស់លោកតា សឺន សាន នោះទេ ក៏ប៉ុន្តែ បានសុំទុកឱកាសឲ្យគាត់ បានទៅពិភាក្សាជាមួយក្រុមគាត់ រួចសន្យាថានឹងវិលមកជួបលោកតាប្រធានម្តងទៀតនៅថ្ងៃទី ៧ កុម្ភៈ ១៩៨៦ ។ នៅពេលណាត់ជួបគ្នាមកដល់ លោកឧត្តមសេនីយ ក៏មិនបានមកជួបតាមសន្យាឡើយ ។ ពីរថ្ងៃក្រោយមកទៀត ទើបគាត់មកជួប ។ ម្តងនេះ លោកឧត្តមសេនីយគ្រាន់តែអង្គុយស្តាប់ ។ នៅពេលហៀបចេញត្រឡប់ទៅវិញ លោកឧត្តមសេនីយ ក៏ប្រគល់សំបុត្រមួយច្បាប់ជូនលោកតាប្រធាន ។ នៅក្នុងសំបុត្រនោះលោក សក់ ស៊ុតសាខន លើកសំណើ ៣ ចំណុចគឺ៖[188] ១. ទទួលស្គាល់លោកតា សឺន សាន ជាប្រធាន រ.ជ.រ.ប.ខ. ដែលមានអំណាចលើ ផ្នែកនយោបាយ និង ការទូតតែប៉ុណ្ណោះ ២. លោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវដើរតួនាទីជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ដោយមានអំណាចទាំងស្រុងលើផ្នែកយោធា និង ស៊ីវិល ៣. បង្កើតគណៈកម្មការចំពោះកិច្ចមួយដើម្បីរៀបចំជាថ្មីឡើងវិញនូវគណៈកម្មាធិការប្រតិបត្តិរ.ជ.រ.ប.ខ. ។ ចំពោះលិខិតនេះ អ្វីដែលលោកតា សឺន សាន ទទួលមិនបានគឺការដែលលោក សក់ ស៊ុតសាខន សរសេរមកប្រធានរ.ជ.រ.ប.ខ. ក្នុងឋានៈលោកឧត្តមសេនីយជាប្រធាន "គណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ" ដែលលោកតាប្រធានប្រកាសថា ខុសច្បាប់រួចទៅហើយ តាំងពីថ្ងៃទី ១ មករា ១៩៨៦ មកម្ល៉េះ ។ លើសពីនេះទៅទៀត ការកាត់ផ្តាច់មិនឲ្យលោកតា សឺន សាន ទទួលខុសត្រូវផ្នែកស៊ីវិលជារឿងមួយដែលលោកតាប្រធាននឹកមិនដល់ ព្រោះថាប្រធាន រ.ជ.រ.ប.ខ. តែងតែយកប្រជាពលរដ្ឋស៊ីវិល ជាមូលដ្ឋាននៃការគាំទ្រនយោបាយរបស់គាត់ ជាពិសេសប្រជាពលរដ្ឋស៊ីវិលនៅជំរុំសាយធូ ។ លោកតា សឺន សាន សង្កត់ធ្ងន់ថា យក

---

[188] ឧត្តមសេនីយ សក់ ស៊ុតសាខន, (លិខិត) ជូនចំពោះ ឯកឧត្តម សឺន សាន, ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ថ្ងៃទី ៩ កុម្ភៈ ១៩៨៦ ។

ប្រជាពលរដ្ឋស៊ីវិល ឲ្យស្ថិតនៅក្រោមអំណាចអគ្គមេបញ្ជាការ អាចធ្វើឲ្យបាត់បង់ជំនួយពីអង្គការសហប្រជាជាតិ ដោយសំអាងលើគោលការណ៍អព្យាក្រឹត្យនៃអង្គការនេះដែលនឹងមិនផ្តល់ ឬ នឹងកាត់ជំនួយដល់ប្រជាពលរដ្ឋស៊ីវិល ប្រសិនបើជំនួយរបស់គេធ្លាក់ដល់ដៃក្រុមប្រដាប់អាវុធ ឬ ជំរុំយោធា ។ ម្យ៉ាងទៀត ចំពោះពួកយើងដែលមានភក្តីភាពចំពោះលោកតាប្រធាន មានតែសមាជរ.ជ.រ.ប.ខ.ទេ ទើបអាចធ្វើការរៀបចំជាថ្មី នូវគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. ឬ កូម៉ិចបានគឺ មិនមែនគណៈកម្មការចំពោះកិច្ចថ្មីណាមួយដូចដែលលោក សក់ ស៊ុតសាខន ស្នើនោះឡើយ ។ ដោយសារគោលជំហរមិនគោរពប្រធាន និង គោលជំហររឹងត្អឹងរបស់លោកឧត្តមសេនីយបែបនេះ ពួកយើងយល់ថាពួកប្រឆាំងច្បាស់ជាមានអ្នកខាងក្រៅនៅពីក្រោយពុំខានឡើយគឺ អាជ្ញាធរថៃ និង ក្រុមការងារ ។

## រ.ជ.រ.ប.ខ. ធ្លាក់កាន់តែជ្រៅទៅក្នុងជ្រោះនៃវិបត្តិផ្ទៃក្នុង

នៅថ្ងៃទី ១៥ កុម្ភៈ ១៩៨៦ លោកតា សឺន សាន បានកោះប្រជុំគណៈកម្មាធិការប្រតិបត្តិ ឬ កូម៉ិច ។ ក្រោយពីបានពិភាក្សាគ្នារួចមក គណៈកម្មាធិការនេះបានសម្រេចបញ្ឈប់ជាផ្លូវការ នូវតំណែងអគ្គមេបញ្ជាការក.ជ.រ.ប.ខ.របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន[189] (តាមឯកសារផ្លូវការសេចក្តីសម្រេចនោះបានចែង ថាកូម៉ិចបានយល់ព្រមទទួលយកពាក្យសុំលាលែងតំណែងអគ្គមេបញ្ជាការរបស់លោក សក់ ស៊ុតសាខន ចុះថ្ងៃ ទី ៥ ធ្នូ ១៩៨៥ ប៉ុន្មានថ្ងៃមុនពេលដែលក្រុមលោកឧត្តមសេនីយធ្វើការបះបោរប្រឆាំងលោកតា សឺន សាន) ។ ខុសពីលោកសក់ ស៊ុតសាខន លោក ដៀន ដែល បានត្រូវដកពីតំណែងទាំងអស់គឺៈ អនុ

---

[189] Son Sann, KhmerPeople’s National Liberation Front, Décret no. 86/03/FNL, Fait le 15 Février 1986.

ប្រធាន ប្រតិភូគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកកិច្ចការយោធា និង នាយអគ្គសេនាធិការនៃ ក.ជ.រ.ប.ខ.[190] ។

នៅក្នុងឱកាសនោះដែរ កូម៉ិចនេះក៏បានសម្រេចបង្កើតគណៈកម្មាធិការយោធាមួយ[191] ដែលមាន លោក ព្រុំ វិត ជាប្រធាន លោក កែវ ជួន ជាអនុប្រធានទី១ លោក ជា ឈុត ជាអនុប្រធានទី២ លោក អ៊ឹម ឈូដេត ជាទីប្រឹក្សា និង លោក កេត រ៉េត ជានាយសេនាធិការចំពោះកិច្ច ដើម្បីដឹកនាំកងទ័ពជំនួសលោក សក់ ស៊ុត សាខន និង លោក ដៀន ដែល ។

ការបង្កើតគណៈកម្មាធិការយោធានេះ ជាសារមួយប្រាប់ទៅក្រុមប្រឆាំងថា ទ្វារនៃការសម្រុះសម្រួលគ្នាបានត្រូវបិទហើយៗជាសញ្ញាថាលោកតាប្រធាន សឺន សាន បានប្តេជ្ញាវាយបកទៅក្រុមប្រឆាំងវិញ មិនខ្លាចមានផលវិបាកអ្វី ដែលអាចកើតមាននៅពេលខាងមុខនោះទេ ។ នៅថ្ងៃទី ២១ កុម្ភៈ លោកឧត្តមសេនីយទោ ថៃឈ្មោះ កាសេម ធម្មគោល ដែលយើងហៅតាមឈ្មោះក្រៅរបស់គាត់ថា "ហួណាកេត" បានជម្រាបលោកតា សឺន សាន ថាសេចក្តីសម្រេចរបស់កូម៉ិចខាងលើនេះ បានធ្វើឲ្យមានប្រតិកម្មជាអវិជ្ជមានពីក្រុមការងារ គឺ គេមិនអាចទទួលយកបានទេ ទាំងការសម្រេចដកលោក សក់ ស៊ុតសាខន ចេញពីតំណែងអគ្គមេបញ្ជាការ ទាំងការប៉ុនប៉ងបំបាត់ក្រុមប្រឆាំង ។ បន្ទាប់មក មិនយូរប៉ុន្មានក្រុមការងារ ក៏ចាប់ផ្តើមធ្វើការគាបសង្កត់មកខាងយើងថែមទៀតមែន ។

---

[190] Son Sann, KhmerPeople's National Liberation Front, Décret no. 86/04/FNL, Fait le 15 Février 1986.
[191] Son Sann, KhmerPeople's National Liberation Front, Décret no. 86/06/FNL, Fait le 15 Février 1986.

# លោកតាទៅតវ៉ាឯប៉េកាំង តែចិនឲ្យសម្រុះសម្រួល

ចាប់តាំងពីថ្ងៃទី ១៥ ទៅ ២១ មីនា ១៩៨៦ អ្នកដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានទៅជួបជុំគ្នានៅទីក្រុងប៉េកាំងនៃប្រទេសចិន ដើម្បីពិភាក្សាគ្នាសម្រេចលើកសំណើសន្តិភាព ៨ ចំណុចសម្រាប់ដំណោះស្រាយស្វែងរកសន្តិភាពនៅកម្ពុជា ។ នៅក្នុងឱកាសនៃទស្សនកិច្ចនោះលោកតា សឺន សាន ក៏បានលើកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ.ជាមួយដៃគូពីររូបទៀតគឺ សម្តេច សីហនុ និង លោក ខៀវ សំផន ។ សម្តេចព្រះប្រធានកម្ពុជាប្រជាធិបតេយ្យ បានគាំទ្រលោកតា សឺន សាន ជាថ្មីម្តងទៀត ។ ឯលោក ខៀវ សំផន ក៏គាំទ្រដែរ ។ ជាមួយអ្នកដឹកនាំចិន លោកប្រធានក៏បានលើកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ.មកពិភាក្សាដែរ ជាពិសេសលោកតាបានតវ៉ាថាមេទ័ពថៃលោក ឆាវលិត និង ក្រុមការងារបានលើកទឹកចិត្តឲ្យលោក សក់ ស៊ុតសាខន បំបែកខ្លួនចេញពីអំណាចគ្រប់គ្រងរបស់ប្រធាន រ.ជ.រ.ប.ខ. និង ឲ្យបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ. ក្នុងន័យដើម្បីឲ្យយោធាថៃ និង ក្រុមការងារអាចយក ក.ជ.រ.ប.ខ. មកដាក់នៅក្រោមបញ្ជាផ្ទាល់របស់ខ្លួន ។ លោកតាតវ៉ាទៀតថា អាជ្ញាធរយោធាថៃបានបង្កើតគណៈកម្មការយោធាខ្មែរមួយហៅថា គណៈកម្មការមេបញ្ជាការ ១០ នាក់ ដែលមានសមាជិកភាពរបស់មេបញ្ជាការ ក.ជ.រ.ប.ខ. ទាំងអស់ចូលរួម ។ គណៈកម្មការនេះ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់លោកវរសេនីយ វិស្នុ (ស៊ូរយុទ្ធ ជូឡាណន្ត) ។ លោកតាលើកសំណួរថា តើអាជ្ញាធរយោធាថៃបង្កើតគណៈកម្មការនេះដើម្បីគោលបំណងអ្វី? បើតាមលោកតាយល់ គឺមិនមែនដើម្បីបំរើផលប្រយោជន៍របស់រដ្ឋាភិបាលចម្រុះត្រីភាគីឡើយ ។ លោកតា សឺន សាន បានជំរាបអ្នកដឹកនាំចិនថា លោកតាបានព្យាយាមអញ្ជើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង

ដៀន ដែល មកដោះស្រាយបញ្ហា ក្នុងឋានៈជាបងប្អូនក្នុងគ្រួសារតែមួយ តែឧត្តមសេនីយទាំងពីររូបនេះមិនបានជួយកសាងឯកភាពឡើងវិញឡើយ ។ លោកតាប្រធានជំរាបមេដឹកនាំចិនទៀតថា ប្រសិនបើគ្មានការលើកទឹកចិត្តពីខាងក្រៅទេនោះ មេទ័ពរ.ជ.រ.ប.ខ. ទាំងពីររូបនេះ ប្រាកដជាមិនហ៊ានប្រកាន់យកគោលជំហរប្រឆាំងបែបនេះទេ ។ លោកតា សឺន សាន បានតវ៉ាទៀតថា ចាប់តាំងពីខែ កុម្ភៈមក លោកឧត្តមសេនីយ ឆាវលិត បានបញ្ជាឲ្យផ្អាកផ្តល់ប្រាក់ឧបត្ថម្ភទាំងអស់ដល់ភាគីរបស់គាត់ ផ្ទុយទៅវិញក្រុមលោក សក់ ស៊ុតសាខន នៅតែបន្តទទួលប្រាក់ឧបត្ថម្ភជាហូរហែឥតឈប់ឈរឡើយ ។ លោកតាតវ៉ាថាសូម្បីតែជំនួយហិរញ្ញវត្ថុចិនដែលចិនផ្តល់ដល់លោកតាផ្ទាល់ ក៏ពុំបានទទួលផង ។ លោកតាប្រធានបន្ថែមទៀតថា នៅពេលដែលខ្លួនគាត់មិនអាចរកជួបលោកឧត្តមសេនីយ ឆាវលិត ផ្ទាល់នោះ ភរិយារបស់លោក ឆាវលិត ត្រឡប់ទៅជាមកបង្ខំឲ្យលោកតាយល់ព្រមលក់ដីនៃស្ថានទូតខ្មែរនៅទីក្រុងតូក្យូនាប្រទេសជប៉ុនទៅវិញ ។ ក៏ប៉ុន្តែ លោកតាប្រកែក ។ មែនទែនទៅ ខាងក្រុមខ្មែរក្រហម បានយល់ព្រមឲ្យលក់ដីស្ថានទូតនេះ ព្រោះគេយល់ថាបញ្ហានយោបាយសំខាន់ជាងបញ្ហាហិរញ្ញវត្ថុ (គេចង់និយាយថាពួកគេមិនខ្វះលុយកាក់ទេ ក៏ប៉ុន្តែការដែលគេចង់ឲ្យលក់នោះ ព្រោះគេត្រូវការឲ្យលោកឧត្តមសេនីយ ឆាវលិត ជួយគាំទ្រគេតទៅទៀត) ។ ចំណែកឯខាងភាគី សម្តេច សីហនុ ចាំតែព្រមតាម បើភាគីខ្មែរក្រហម និង រ.ជ.រ.ប.ខ. ស្រុះស្រួលគ្នាថាលក់ខាងសម្តេចក៏លក់ ។ ខាង រ.ជ.រ.ប.ខ. លោកតា សឺន សាន ប្រកាន់គោលជំហរថាមិនលក់ទេ តែខាងឧត្តមសេនីយ ដៀន ដែល ចោទប្រកាន់ថា ខាងលោកតាយល់ព្រមលក់ទៅវិញ ។ តាមពិតទៅ លោកតា សឺន សាន បានសម្រេចថាមិនព្រមឲ្យលក់ដីនេះទេ តែលោកតាបានតែងតាំងកូនប្រុសរបស់លោកតាម្នាក់ទៀតឈ្មោះ សឺន មុនា ដែលជាស្ថាបត្យករឲ្យឡើងធ្វើជាអ្នកជំនាញការ ដើម្បីធ្វើការវាយតម្លៃដី

ស្ថានទូតនៅតូក្យូមានតម្លៃពិតប្រាកដប៉ុន្មាន? ត្រង់ចំណុចនេះហើយដែលធ្វើឲ្យក្រុមប្រឆាំងលើកឡើងថា បើមិនព្រមលក់ ហេតុអ្វីបានជាចាត់អ្នកជំនាញការឲ្យទៅវាយតម្លៃដី?

តាមរបាយការណ៍នៃទស្សនកិច្ចនៅប្រទេសចិនបានឲ្យដឹងថាតាំងពីនាយកដ្ឋានកិច្ចការអាស៊ីនៃក្រសួងការបរទេស រហូតដល់លោកអគ្គលេខាបក្សកុម្មុយនីស្តចិន ហ៊ូ យ៉ៅបាង (Hu Yaobang) សុទ្ធតែបានផ្តល់មតិជូនលោកតា សឺន សាន ថា លោកតាត្រូវតែថែរក្សាឲ្យបាននូវឯកភាពផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ. ។ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសចិន លីវ ស៊ូគីង (Liu Shuquing) បានជំរាបលោកតាប្រធានថា "ក្នុងឋានៈជាមិត្តរបស់រ.ជ.រ.ប.ខ. ប្រទេសចិនមានការបារម្ភចំពោះវិបត្តិផ្ទៃក្នុងរបស់រណសិរ្សនេះណាស់ ហើយមិនអាចធ្វើអន្តរាគមន៍ ឬ កាត់សេចក្តីយ៉ាងដូចម្តេចទេ" ។ អ្វីដែលចិនអាចធ្វើបានគឺ លើកទឹកចិត្តឲ្យគ្រប់ភាគីក្នុងជម្លោះផ្ទៃក្នុងនេះរួបរួមគ្នាឡើងជៀសវាងកុំឲ្យជម្លោះនោះ ក្លាយទៅជាបំរើផលប្រយោជន៍នៃការឃោសនាប្រឆាំងចលនាតស៊ូឲ្យទៅខាងកងទ័ពឈ្លានពានវៀតណាមទៅវិញ ។ ក្នុងឋានៈជាមិត្ត ប្រទេសចិនមានសំណូមពរសូមឲ្យអ្នកដឹកនាំរដ្ឋាភិបាលចម្រុះពង្រឹងសាមគ្គីភាពរវាងគ្នានិងគ្នា និង សូមឲ្យភាគីនីមួយៗនៃរដ្ឋាភិបាលចម្រុះ ពង្រឹងសាមគ្គីភាពផ្ទៃក្នុងរបស់ខ្លួន ។ អ្នកដឹកនាំចិន ជាពិសេសលោកអនុរដ្ឋមន្ត្រីការបរទេសលើកមតិឡើងថាប្រទេសថៃជារណសិរ្សជួរមុខរបស់យើង ។ យើងត្រូវការប្រទេសថៃ ដើម្បីជាច្រកដឹកជញ្ជូនកងទ័ព និង ស្បៀងដល់យុទ្ធជនខ្មែរដែលកំពុងប្រយុទ្ធប្រឆាំងកងទ័ពបរទេសឈ្លានពាន ។ ដូច្នេះសាមគ្គីជាមួយប្រទេសថៃ ជាការចាំបាច់បំផុត ដើម្បីឲ្យសម្រេចជោគជ័យក្នុងការតស៊ូរបស់យើងទាំងអស់គ្នា ។ សរុបសេចក្តីទៅ ប្រទេសចិនបានណែនាំឲ្យលោកតា សឺន សាន ខឹតខំយកចិត្តទុកដាក់ធ្វើការឲ្យបានជិតស្និទ្ធជាមួយលោកឧត្តមសេនីយ ឆាវលិត ។

ជាគោលការណ៍ លោកតា សឹន សាន បានត្រៀមខ្លួនរួចហើយដើម្បីប្រគល់អំណាចឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន កាន់តំណែងជាអគ្គមេបញ្ជាការ ក៏ប៉ុន្តែ លោកតានៅតែព្យាយាមបញ្ចូលមនុស្សរបស់គាត់ បានចូលកាន់តំណែងសំខាន់ៗនៅក្នុងជួរកងទ័ពរ.ជ.រ.ប.ខ. ។ មុនពេលលោកតាប្រធានចេញដំណើរទៅទីក្រុងប៉េកាំង លោកតា សឹន សាន បានស្នើដល់លោកដល់លោក ឆាវលិត ថា ប្រសិនបើលោក សក់ ស៊ុត សាខន ត្រូវបានជាអគ្គមេបញ្ជាការ លោកឧត្តមសេនីយរូបនេះត្រូវធ្វើការជាមួយលោក អ៊ឹម ឈូដេត និង លោក ឈឹម ឱមយ៉ុន នៅអគ្គបញ្ជាការដ្ឋាន និង ជាមួយលោក ថាច់ រ៉េង នៅសមរភូមិមុខ ឬ នៅឯទល់ដែន ។ សំណើនេះ មានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុងកិច្ចការយោធា ដែលធ្វើឲ្យក្រុមលោក សក់ ស៊ុតសាខន មិនអាចទទួលយកបាន ។ ការដែលលោកតាប្រធានចង់នាំយកលោក ថាច់ រ៉េង មកចូលក្នុងបញ្ជាការយោធាជារឿងមិនអាចយកមកនិយាយបានឡើយសម្រាប់ក្រុមប្រឆាំង ព្រោះថាអស់ពេលជាច្រើនឆ្នាំមកហើយដែលលោក ថាច់ រ៉េង បានរិះគន់លោកឧត្តមសេនីយ សក់ ស៊ុតសាខន និងមនុស្សរបស់គាត់ អំពីអសមត្ថភាពក្នុងការដឹកនាំ និង គ្រប់គ្រងក.ជ.រ.ប.ខ.។ ម្យ៉ាងទៀត ទាំងអស់នេះ ក៏ប្រហែលជាយុទ្ធសាស្ត្រមួយរបស់លោក ឆាវលិត ដើម្បីកុំឲ្យមានកងទ័ពខ្មែរអ្នកជាតិនិយមណាមួយ ដែលមានការគាំទ្រពីប្រជាពលរដ្ឋខ្មែរអាចធ្វើការប្រយុទ្ធបានតាមផ្លូវយោធា ។ ពេលនោះ ប្រហែលជាលោក ឆាវលិត និងមិត្តភក្តិអាស៊ានយល់ថាដល់ពេលវេលា ដែលគេត្រូវស្វែងរកដំណោះស្រាយនយោបាយ មិនមែនជាការបង្កើនការវាយប្រហារតាមកម្លាំងយោធាឡើយ ។ ប្រសិនបើគេទុកឱកាសឲ្យក.ជ.រ.ប.ខ.មានឱកាសរៀបចំខ្លួន និង អាចបង្កើនសមត្ថភាពយោធាអាចកើតចេញជាស្ថានភាពយោធាមួយដែលពិបាកគ្រប់គ្រងផង ។ ផ្ទុយទៅវិញនយោបាយរបស់លោក ឆាវលិត ដែលទុកឲ្យកម្លាំងខ្មែរក្រហមនៅរស់រាន និង

សកម្មប្រយុទ្ធជានយោបាយមួយដែលធ្វើឲ្យប្រទេសចិនសប្បាយចិត្ត ។ នយោបាយបែបនោះ អាចយល់ថាខ្មែរក្រហមមិនអាចជាឧបសគ្គអ្វីធំដុំសម្រាប់ដំណោះស្រាយនយោបាយណាមួយឡើយ ព្រោះអំពើប្រល័យពូជសាសន៍របស់ពួកគេបានត្រូវពិភពលោកទាំងមូលផ្តន្ទាទោស និង ស្អប់ខ្ពើមបំផុត ម្យ៉ាងទៀតព្រោះថាខ្មែរក្រហមពឹងផ្អែកទាំងស្រុងលើជំនួយ និង ការគាំទ្រពីថៃ និង ចិនមួយរយភាគរយ ។ ថៃ និង ចិនរួមគ្នាក្នុងការប្រឆាំងនឹងការកាន់កាប់ប្រទេសខ្មែរ ដោយកងទ័ពវៀតណាម ។ ប្រសិនបើចិន និង ថៃប្រាប់ឲ្យខ្មែរក្រហមឈប់ច្បាំង ខ្មែរក្រហមពុំអាចប្រកែកបានទេ ព្រោះខ្មែរក្រហមមិនអាចសុំជំនួយពីប្រទេសណាដទៃក្រៅពីចិន និង ថៃបានឡើយ ។

ចំពោះខ្ញុំៗយល់ថា ប្រទេសថៃលេងសន្លឹកបៀចិន នៅពេលដែលមានបញ្ហាទាក់ទងនឹងសន្តិសុខផ្ទាល់របស់ថៃ ។ ថៃលេងបៀអាស៊ាន និង/ឬ សន្លឹកបៀអាមេរិក កាលណាមានបញ្ហាសន្តិសុខតំបន់ និង/ឬ សន្តិសុខពិភពលោក ។ ខ្ញុំយល់ថាការលេចចេញឡើងនូវក្រុមលោក សក់ ស៊ុតសាខន ដាច់ដោយឡែកពីរដ្ឋាភិបាលចម្រុះ គឺដោយសារកម្លាំងយោធារបស់រដ្ឋាភិបាលនេះ បានស្ថិតនៅក្រោមឥទ្ធិពលផ្តាច់មុខរបស់ខ្មែរក្រហមរួចទៅហើយ ។ ការបង្កើតក្រុមថ្មីមួយ ដែលហាក់ដូចជាមិនពាក់ព័ន្ធជាមួយខ្មែរក្រហមទេនោះ អាចឲ្យសហរដ្ឋអាមេរិកផ្តល់ជំនួយដល់ក្រុមអ្នកជាតិនិយម ឬ ចលនាតស៊ូមិនមែនកុម្មុយនីស្ត បើមិនផ្តល់ជំនួយខាងអាវុធក៏ផ្តល់ជំនួយយោធាក្រៅពីអាវុធផង ។ ចំពោះលោកឧត្តមសេនីយ ឆាវលិត អ្វីក៏ល្អទាំងអស់ឲ្យតែមានជំនួយ ព្រោះជំនួយទាំងនោះ ទាំងមកពីចិន ទាំងមកពីអាមេរិក ឬ មកពីប្រទេសលោកខាងលិចទាំងអស់ សុទ្ធតែត្រូវឆ្លងកាត់ប្រទេសថៃទាំងអស់ ។ ខ្ញុំអាចវាយតម្លៃថាជំនួយទាំងអស់ ដែលឆ្លងតាមថៃនោះត្រូវថៃកាត់យកប្រហែល ៧០% រីឯខាងខ្មែរទទួលបានតែ ៣០% តែប៉ុណ្ណោះ ។

# មានគេសរសេរខុសពីរឿងវិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ.

ចំពោះបញ្ហាវិបត្តិផ្ទៃក្នុងរវាងលោកតា សឺន សាន ជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន នោះ ក្នុងពេលថ្មីៗនេះខ្ញុំបានអានសៀវភៅមួយក្រោមចំណងជើងថា "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែររ.ជ.រ.ប.ខ." ដែលក្នុងនោះអ្នកនិពន្ធឈ្មោះ គង់ ថាន់ បានសរសេរយ៉ាងប្រថុយប្រថានថា៖ "បុព្វហេតុនៃការបែកបាក់រវាងភាគី សឺន សាន និង សក់ ស៊ុតសាខន ក្នុងជួររ.ជ.រ.ប.ខ. ដែលកើតឡើងតាំងពីឆ្នាំ១៩៨២ មកផ្សំឡើងដោយព្រឹត្តិការណ៍សំខាន់ៗច្រើន យ៉ាងមានជាអាទិ៖ ............ ឧត្តមសេនីយ សក់ ស៊ុតសាខន និង ឧត្តមសេនីយ ដៀន ដែល ធ្លាប់ស្នើលោកប្រធាន សឺន សាន ឲ្យដកលោក អៀង មូលី ចេញពីតំណែងអគ្គលេខាធិការ រ.ជ.រ.ប.ខ. តែលោកប្រធានមិនគ្រាន់តែមិនព្រមទេ តែឲ្យលោក អៀង មូលី កាន់លុយរ.ជ.រ.ប.ខ.ថែមទៀត" ។ ជាការគួរឲ្យស្តាយដែលអ្នកនិពន្ធរូបនោះ ដែលខ្ញុំស្គាល់អតីតកាលដ៏ច្បាស់ ពុំបានធ្វើការស្រាវជ្រាវឲ្យស៊ីជំរៅ ឬមកសួរខ្ញុំផ្ទាល់ ព្រោះខ្ញុំក៏អាចផ្តល់ព័ត៌មានច្បាស់លាស់ ដែលអាចនាំឲ្យសៀវភៅនោះ ក្លាយជាសៀវភៅមួយ ដែលគេអាចយកទៅប្រើការជាឯកសារយោង ឬ អាចជាទំនុកចិត្តបាន ។ តាមពិតទៅ ពុំមានទំនាស់រវាងលោកតាប្រធាន សឺន សាន និង ឧត្តមសេនីយ សក់ ស៊ុតសាខន នៅឆ្នាំ ១៩៨២ នោះទេ ។ នៅសម័យនោះ នៅពេលដែលលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានមកដល់ទឹកដីនៃតំបន់រំដោះរបស់រ.ជ.រ.ប.ខ. ក្រុមលោកឧត្តមសេនីយ ដៀន ដែល បានសម្លឹងឃើញថាលោកតា សឺន សាន មានបំណងយកលោក សក់ ស៊ុតសាខន ឲ្យមកត្រួតពីលើពួកគាត់ ឬ ឲ្យមកជំនួសផងក៏បាន ។ កាលពេលនោះ ក្រុមលោក ដៀន ដែលយល់ថាលោក សក់ ស៊ុតសាខន ជាមនុស្សរបស់លោកតា សឺន សាន ដូច្នេះគ្មាន

ទំនាស់អ្វីរវាងលោកតាប្រធាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ដូចសៀវភៅខាងលើបានលើកឡើងនោះទេ ។ ទំនាស់រវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន កើតឡើងនៅចុងឆ្នាំ ១៩៨៥ ដោយសារតែលោកតាប្រធាន បានបណ្ដេញសហការីជំនិតពីររូបរបស់លោក សក់ ស៊ុតសាខន គឺ លោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ពាងម៉េត ពីរ.ជ.រ.ប.ខ. ដែលត្រូវក្រុម លោកតា សឺន សាន ចោទប្រកាន់ថាខ្វះវិន័យ និង ធ្វើការបំបែកបំបាក់ឯកភាពផ្ទៃ ក្នុងរបស់រ.ជ.រ.ប.ខ. ។ ចំណែកឯរូបខ្ញុំ ខ្ញុំបានឡើងមកកាន់តំណែងជាអគ្គលេខាធិការរ.ជ.រ.ប.ខ នៅឆ្នាំ ១៩៨៨ គឺ នៅក្រោយពេលដែលទំនាស់នោះកើតរួចហើយ ជិតបីឆ្នាំឯណោះ ។ ដូច្នេះ ការបកស្រាយរបស់អ្នកនិពន្ធនៃសៀវភៅដែលមានចំណងជើងថា "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ដំណើរឆ្ពោះទៅរកសន្តិភាពនោះ" ជាការបកស្រាយខុសពីការពិតខ្លាំងណាស់ ។ ក្រុមលោក សក់ ស៊ុតសាខន បានព្យាយាមសុំចូលមកជំនួសខ្ញុំ នៅក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កម្ពុជា (SNC) មែនចាប់ពីចុងឆ្នាំ ១៩៩០ ក៏ប៉ុន្តែដោយសារសកម្មភាពបំបែកខ្លួន របស់ក្រុមគាត់ពីការគ្រប់គ្រងរបស់ប្រធានរ.ជ.រ.ប.ខ. ទើបលោក សក់ ស៊ុតសាខន មិនបានចូលជាសមាជិក អេស អ៊ិន ស៊ី ជារៀងរហូតមក ។ តាមពិតទៅ ប្រជាប្រិយភាពរបស់ក្រុមឧត្តមសេនីយ សក់ ស៊ុត សាខន - ដៀន ដែល បើប្រៀបធៀបទៅក្រុមលោកតា សឺន សាន នៅមានកំរិតទាប ។ ហេតុដូច្នេះ ទើបក្រុមនេះមានការលំបាកក្នុងការរើសយុទ្ធជនឲ្យចូលទៅបំរើក.ជ.រ.ប.ខ. ។ ក្នុងសៀវភៅដដែលនេះ អ្នកនិពន្ធបានសរសេរថា លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានរាយការណ៍ជូនក្រុមការងារ អំពីការលំបាករបស់ក្រុមគាត់ក្នុងការរើសទាហានឲ្យបានគ្រប់តាមការកំណត់មានជាអាទិ៍ថា៖ "ក្នុងគោលបំណងទប់ទល់មិនឲ្យប្រជាពលរដ្ឋ និង យុទ្ធជនចូលបំរើ ក.ជ.រ.ប.ខ. លោក អៀង មូលី និង លោក អ៊ឹម

ឈូដេត បានឃោសនាក្នុងខែ តុលា ១៩៨៨ ឲ្យប្រជាពលរដ្ឋរង់ចាំ ព្រោះលោកប្រធាននឹងបង្កើតស្ថាប័នស៊ីវិលឈ្មោះថា "ស្ថាប័នជាន់ខ្ពស់" ដែលមានប្រាក់ខែ និងសម្ភារៈប្រើប្រាស់គ្រប់គ្រាន់" ។ មែនទែនទៅ នៅសម័យនោះ ខ្ញុំមិនដែលបានដឹងពីការរើសទាហានឲ្យទៅបម្រើក្នុងជួរ ក.ជ.រ.ប.ខ. ទេ ដូច្នេះធ្វើដូចម្ដេចខ្ញុំអាចទប់ទល់កុំឲ្យក្រុមលោក សក់ ស៊ុតសាខន ចូលមករើសបាន? រឿងដែលអាចកើតនោះ ប្រហែលជាអាចកើតឡើងតាមរយៈយុទ្ធវិធីទប់ស្កាត់ ឬ ប្រណាំងប្រជែងគ្នានៅក្នុងចំណោមនាយទាហាន ឬ មេជំរុំនៅឯជាយដែនឯនោះទេដែលពួកគេប្រើដើម្បីយកឈ្នះរៀងៗខ្លួន ។

## លោកតា សឺន សាន ចង់ដកលោក នាង ជិន ហន

អស់រយៈពេលជាច្រើនខែ លោកតា សឺន សាន នៅតែព្យាយាមទប់ទល់នឹងការគាបសង្កត់គ្រប់ប្រភេទ ។ លោកតាប្រធាន មិនបានបោះបង់ចោលចិត្តគំនិតដែលចង់រក្សាក.ជ.រ.ប.ខ.ឲ្យស្ថិតនៅក្រោមអំណាចរបស់លោកតាទេ ។ នៅពេលនោះ ទោះបីជាលោកអគ្គលេខាធិការ នាង ជិនហន នៅបន្តធ្វើការជាមួយក៏ដោយ ក៏លោកតា សឺន សាន ហាក់ដូចជាមិនទុកចិត្តទាល់តែសោះ ព្រោះថាលោកអគ្គលេខាធិការ នៅតែបន្តទំនាក់ទំនងយ៉ាងល្អជាមួយក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង គណៈកម្មាធិការកណ្ដាលបណ្ដោះអាសន្នសង្គ្រោះរ.ជ.រ.ប.ខ. (PCCS) រហូតមក ។ មិនទុកចិត្តព្រោះថាក្រុមរបស់លោក សក់ ស៊ុតសាខន ត្រូវបានប្រកាសដោយប្រធានថាជាអង្គការចាត់តាំងខុសច្បាប់ ។ នៅក្នុងកំណត់ចំណាំសម្ងាត់មួយ លោកអគ្គលេខា នាង ជិនហន បានផ្ដល់មតិជូនលោកតាប្រធាន សូមឲ្យលោកតាវាយតម្លៃគោលជំហររបស់លោកតាឡើងវិញ ទាំងចំពោះ

មុខលោក ឆាវលិត ទាំងចំពោះក្រុមការងារ ដែលមានលោក ស៊ូរយុទ្ធ ជូឡាណន្ត ជាប្រធាន ។ ក្នុងកំណត់ចំណាំនោះ លោកអគ្គលេខាផ្តល់មតិ ជូនលោកតាប្រធាន ថា សេចក្តីសម្រេចថ្មីៗ ដែលមានការបញ្ជាប់មុខនាទីអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. របស់លោក សក់ ស៊ុតសាខន ផងនោះ មិនបានទទួលការគាំទ្រពីលោក ឧត្តមសេនីយ ឆាវលិត និង ពីក្រុមការងារទេ ។ លោកអគ្គលេខា នាង ជិនហន ផ្តល់យោបល់ថាលោកតាប្រធានគួរតែស្ថិតនៅឲ្យខ្ពស់ ផុតពីអ្នកឯទៀតក្នុងឋានៈជាមេដឹកនាំពិតប្រាកដ និង តែមួយគត់នៃរ.ជ.រ.ប.ខ. គឺនៅឲ្យផុតពីជម្លោះ ។ លោក នាង ជិនហន ស្នើថាលោកប្រធានគួរតែចេញទៅក្រៅមួយរយៈ ដូចជាធ្វើដំណើរទៅអូស្ត្រាលី ឬ ទៅទ្វីបអឺរ៉ុប ។ ទោះជាលោកតាប្រធានមានការសង្ស័យថា លោក នាង ជិនហន មិនមានភក្តីភាពចំពោះលោកតាក៏ដោយ ក៏នៅទីបញ្ចប់ លោកតា សឺន សាន យល់ព្រមតាមយោបល់របស់លោកអគ្គលេខារូបនេះដែរ ។ ដំណើរលើកដំបូងរបស់លោកតា សឺន សាន នៅប្រទេសអូស្ត្រាលីបានទទួលជោគជ័យគួរឲ្យកត់សម្គាល់ ព្រោះបានធ្វើឲ្យប្រភពព័ត៌មានអន្តរជាតិបង្វែរការផ្សព្វផ្សាយពីជម្លោះផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ មកផ្សព្វផ្សាយជាវិជ្ជមានអំពីទស្សនកិច្ចនេះទៅវិញ ។

លោកតា សឺន សាន មិនពេញចិត្តលោក នាង ជិនហន ទេ ព្រោះជាយូរឆ្នាំមកហើយលោក នាង ជិន ហន តែងតែចេញទៅសម្រាកនៅក្រៅម៉ាយ៉ាឡាប់ និង តែងតែចេញចូលពៃរមីកូ មិនដែលដាច់ ។ ម្យ៉ាងទៀត នៅពេលដែលពួកយើងមិនអាចចេញចូលជំរុំបាន លោក នាង ជិនហន អាចធ្វើដំណើរទៅទល់ដែនបាន ជាពិសេស ទៅជំរុំណាំយឹន ដោយមិនចាំបាច់មានការយល់ព្រមពីលោកតាប្រធាន ផង ។ នៅឆ្នាំ ១៩៨៣ លោកតា សឺន សាន បានចេញបញ្ជាឲ្យលោកអគ្គលេខា នាង ជិនហន សិក្សាស្រាវជ្រាវអំពីដំណោះស្រាយកម្ពុជាដូចជា៖ អំពីការចរចារួចបន្ទាប់មកអំពីការបោះឆ្នោតជាដើម ។ នៅឆ្នាំ ១៩៨៧ លោកតា សឺន សាន

បានចេញលិខិតរំលឹកថាតាំងពីឆ្នាំ ១៩៨៣ រហូតមក លោកតានៅមិនទាន់បាន ទទួលលទ្ធផលការងារនៃការស្រាវជ្រាវនោះទេ និង បានកំណត់ថ្ងៃចូលឆ្នាំខ្មែរ ១៩៨៧ ឲ្យលោក នាង ជិនហាន ប្រគល់ជូនលោកតានូវគំរោងការស្រាវជ្រាវទាំងនោះជាកំហិត ។ ទាំងនេះ ទំនងជាចំណុចស្តីបន្ទោស ដែលលោកតាប្រធានលើកឡើង សម្រាប់ជាហេតុផលមួយដើម្បីដកលោកអគ្គលេខាធិការពីតំណែងក្នុងពេលខាងមុខ ។

# មេទ័ពថៃបញ្ជាឲ្យលោក ថាច់ រ៉េង ចេញពីទឹកដីថៃ

នៅពេលដែលលោកតា សឺន សាន កំពុងធ្វើទស្សនកិច្ចនៅទ្វីបអឺរ៉ុប នៅទីក្រុងបាងកក អាជ្ញាធរថៃបានចាត់វិធានការមួយដំហានទៀត ដើម្បីកាត់ផ្តាច់លោកតា សឺន សាន ពីការងារយោធា ។ នៅថ្ងៃទី ០៩ មិថុនា ១៩៨៦ ហួណាម៉ុល (សុមេធ ទៀនផេង) បានឲ្យលោក ប៊ុន សាយ អគ្គលេខាធិការរងរ.ជ.រ.ប.ខ. នាំលោក ថាច់ រ៉េង ទៅជួបលោកឧត្តមសេនីយថៃ កាសេម ធម្មគោល ឬ ហួណាកេត នៅផ្ទះសុវត្ថិភាពស្ថិតនៅកន្លែងមួយឈ្មោះសយអារីយ៍ ឬ ប្រកអារីយ៍ នៅថ្ងៃបន្ទាប់ ។ ស្អែកឡើងនៅថ្ងៃទី ១០ មិថុនា លោក ប៊ុន សាយ ក៏នាំលោក ថាច់ រ៉េង ទៅជួបលោក កាសេម តាមកាលកំណត់ ។ ពេលទៅដល់ផ្ទះសុវត្ថិភាពនោះ ហួណាម៉ុល បានផ្តល់ដំណឹងថាលោកឧត្តមសេនីយ ជាប់រវល់ក្នុងការងារជាបន្ទាន់ មិនបានមកជួបលោក ប៊ុន សាយ និង ថាច់ រ៉េង នៅពេលនោះទេ ។ ក៏ប៉ុន្តែ លោកមេទ័ពកាសេម បានផ្តាំឲ្យលោកម៉ុលនាំសារដូចតទៅនេះមកឲ្យមន្ត្រីរ.ជ.រ.ប.ខ.ទាំងពីររូបគឺ៖[192] "សកម្មភាពពិសេស ដែលបានព្រមព្រៀងគ្នារវាងលោកប្រធាន សឺន សាន និង លោកឧត្តមសេនីយ ឆាវលិត បានដល់ទីបញ្ចប់ហើយៗមិនតែ

---

[192] Boun Say, Note à S.E. le Président du FNLPK, Document Secret, 21 Juin 1986.

ប៉ុណ្ណោះ សកម្មភាពពិសេសនោះ ក៏ជ្រុលជ្រួសហួសពីកិច្ចព្រមព្រៀងនោះផង ។ វត្តមានរបស់ឧត្តមសេនីយ ថាច់ រ៉េង បានបង្កឲ្យមានការខ្វែងមតិគ្នារវាងក្រសួងការបរទេសថៃ និង កងទ័ពថៃ ។ ក្រោយពីបានពិគ្រោះជាមួយក្រសួងមានសមត្ថកិច្ចនានាមកអាជ្ញាធរថៃ សូមឲ្យលោក ថាច់ រ៉េង ចាកចេញពីទឹកដីថៃនៅថ្ងៃទី ១២ មិថុនា ១៩៨៦" ។

សារនេះហាក់ដូចជារន្ទះបាញ់ចំពីលើលោក ថាច់ រ៉េង ។ នៅចំពោះមុខសេចក្ដីសម្រេចរបស់អាជ្ញាធរយោធាថៃ ដែលមានលក្ខណៈជាទណ្ឌកម្មដាច់ណាត់ដ៏ធ្ងន់ធ្ងរនេះ លោក ថាច់ រ៉េង មិនអាចតវ៉ាអ្វីក្រៅពីខំព្យាយាមរំលឹកថា មុនពេលចេញដំណើរ លោកតាប្រធានបានផ្ដាំផ្ញើអង្វរករឲ្យអាជ្ញាធរថៃរង់ចាំលោកតាវិលត្រឡប់មកបាងកកវិញសិន មុននឹងសម្រេចរឿងសំខាន់ៗបែបនេះ ។ ជាមួយនោះ លោក ថាច់ រ៉េង ខំអង្វរអាជ្ញាធរឲ្យអនុញ្ញាតឲ្យគាត់អាចស្នាក់នៅបានរហូតដល់ដំណាច់ខែ មិថុនា ។ ពាក្យសុំទាំងប៉ុន្មានរបស់លោកឧត្តមសេនីយ ថាច់ រ៉េង បានត្រូវប្រានចោលទាំងអស់នៅពេលរសៀលថ្ងៃនោះ ។ លើកនេះ ក្រុមយោធាថៃចាត់វិធានការកាត់ផ្ដាច់ដៃជើងរបស់លោកតា សឺន សាន ទាំងអស់ ។ លោក ថាច់ រ៉េង ក៏គ្មានជំរើសអ្វីក្រៅពីចាកចេញពីទឹកដីថៃតែប៉ុណ្ណោះ ។

## វិបត្តិផ្ទៃក្នុងបានត្រូវបញ្ចប់

នៅទីបំផុត លោកតា សឺន សាន បានត្រូវបង្ខំចិត្តបញ្ចប់វិបត្តិផ្ទៃក្នុងនេះក្នុងជួររ.ជ.រ.ប.ខ. ។ តាមក្រឹត្យចុះថ្ងៃទី ១១ មករា ១៩៨៧ លោកតាប្រធានបានធ្វើប្រតិភូកម្មឡើងវិញក្នុងការផ្ដល់អំណាចជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដោយកំរិតឲ្យលោកឧត្តមសេនីយរូបនេះទទួល

បន្ទុកតែត្រឹមការងារផ្នែកកងទ័ពតែប៉ុណ្ណោះ[193] ។ ក្រឹត្យតែងតាំងនេះ ត្រូវមានភ្ជាប់ដោយឧបសម្ព័ន្ធ ដែលមានបីចំណុចមួយផង ដែលកំណត់លក្ខខណ្ឌនៃមុខតំណែងអគ្គមេបញ្ជាការៈ ១. អគ្គមេបញ្ជាការត្រូវជួយប្រធាន រ.ជ.រ.ប.ខ. ដើម្បីរៀបចំឲ្យមានឡើងវិញនូវឯកភាពច្បាប់ទម្លាប់ និង សណ្តាប់ធ្នាប់ក្នុងក្របខ័ណ្ឌបទបញ្ជាទាំងឡាយរបស់រ.ជ.រ.ប.ខ. ជាពិសេសខាងផ្នែកយោធា ។ ២. អគ្គមេបញ្ជាការត្រូវរាយការណ៍ជូនប្រធានអំពីកិច្ចប្រតិបត្តិយោធាសំខាន់ៗ - អំពីការគ្រប់គ្រងចាត់ចែងប្រើប្រាស់មូលនិធិនៃក.ជ.រ.ប.ខ - អំពីគោលគំនិត និង យុទ្ធសាស្ត្រនៃក.ជ.រ.ប.ខ. - អំពីការបង្កើតថ្មី ឬ ការរំលាយចោលនូវកងឯកភាពណាមួយ ។ ៣. អគ្គមេបញ្ជាការត្រូវលើកសំណើជូនប្រធានអំពីការរៀបចំឡើងវិញ នូវអគ្គបញ្ជាការដ្ឋានក.ជ.រ.ប.ខ. ។ ប្រធានអាចតែងតាំង ឬ បញ្ឈប់នូវមន្ត្រីយោធាជាន់ខ្ពស់នៅក្នុងអគ្គបញ្ជាការដ្ឋាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គមេបញ្ជាការ ។ លក្ខខណ្ឌទាំងប៉ុន្មានខាងលើនេះ បានបង្ហាញឲ្យឃើញថាលោកតា សឺន សាន នៅតែអាចលូកដៃចូលក្នុងកិច្ចការយោធាបាន ។

នៅពេលបានទទួលឯកសារតែងតាំងប្រកបដោយលក្ខខណ្ឌនេះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចារផ្ទាល់ដៃត្រឡប់មកវិញជាភាសាបារាំងដែលមានន័យជាអាទិ៍ថាៈ "បានឃើញ បានដឹង ឬ និង យល់ព្រមទទួល ក៏ប៉ុន្តែលក្ខខណ្ឌ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃការតែងតាំងមុខតំណែងអគ្គមេបញ្ជាការក.ជ.រ.ប.ខ.នេះជាលក្ខខណ្ឌឯកតោភាគីដែលដាក់បង្ខំឲ្យទទួលយក ផ្ទុយពីស្មារតីនៃការចរចា ដែលភាគីទាំងពីរកំពុងធ្វើ" ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចារទៀតថា "ទទួលយកមុខនាទីអគ្គមេបញ្ជាការនេះ ក្នុងស្មារតីគោរព

[193] Son Sann, Khmer People's National Liberation Front, Decree no. 87/01/FNL (Unofficial Translation), January 11, 1987.

វិន័យ និង របៀបរៀបរយតែប៉ុណ្ណោះ" ។ លោកតា សឺន សាន មិនពេញចិត្តសោះចំពោះចំណាររនេះ ។ ពួកក្រុមយើងនាំគ្នាគិតស្មានថាច្បាស់ជាលោកអគ្គលេខាធិការនាង ជិនហាន ជាអ្នកណែនាំឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន សរសេរចំណុចជាអវិជ្ជមានទាំងនេះ ។ ការប៉ាន់ស្មានរបស់ពួកយើងនេះ រឹតតែធ្វើឲ្យលោកតាប្រធានមានការសង្ស័យខ្លាំងឡើងថែមទៀតចំពោះលោក នាង ជិនហាន ។

ទោះបីមានការតែងតាំង និង ការដាក់លក្ខខណ្ឌចំពោះតំណែងអគ្គមេបញ្ជាការរបស់លោក សក់ ស៊ុតសាខន ឲ្យទទួលតែផ្នែកយោធាយ៉ាងណាក៏ដោយ ក៏រ.ជ.រ.ប.ខ. នៅតែមិនទាន់ជម្រះបញ្ហាឲ្យជ្រះស្រឡះបាន ដោយហេតុថាភាគីនីមួយៗនៅតែទាមទារយកសិទ្ធិត្រួតត្រាលើជំរុំជនភៀសខ្លួន ។ ក៏ប៉ុន្តែ ដោយសារការតែងតាំងនេះ ភាគីម្ខាងៗក៏អាចបានចំណេញខ្លះដែរ ។ លោកតា សឺន សាន អាចប្រកាសប្រាប់ពិភពលោកថា អស់មានបញ្ហាផ្ទៃក្នុងៗជួររ.ជ.រ.ប.ខ.ទៀតហើយៗលោកតា បានធ្វើឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ នៅក្នុងចលនាតស៊ូរបស់លោកតា ។[194] ម្យ៉ាងទៀត លោកតាប្រធានអាចប្រកាសជាថ្មីថាលោកតាដឹកនាំការតស៊ូ ដោយមានកងទ័ពនៅជាមួយ មិនមែនមានតែក្បាលម៉ាស៊ីននយោបាយនោះទេ ។ ចំពោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន វិញ ការតែងតាំងជាផ្លូវការបាននាំមកនូវលក្ខណៈស្របច្បាប់គឺ លែងស្ថិតនៅក្នុងការបះបោរខុសច្បាប់ដូចមុនទៀតហើយ ។ ដូច្នេះ ការតែងតាំងជាថ្មីនេះជាការងាយស្រួលសម្រាប់លោកឧត្តមសេនីយក្នុងការទាក់ទងជាមួយអាជ្ញាធរថៃ និង ប្រទេសផ្តល់ជំនួយ ដើម្បីស្វែងរកការគាំទ្រខាងផ្នែកយោធា ។

[194] KhmerPeople's National Liberation Front, Press Communique, January 18, 1987.

# យើងមានអ្នកគាំទ្រ និង អ្នករត់ចោលជួរ

តាមពិតទៅ ចាប់តាំងពីបានទទួលការតែងតាំងជាផ្លូវការ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅតែបន្តធ្វើការដូចមុន មិនមានធ្វើការផ្លាស់ប្តូរអ្វីឡើយ ។ លើកលែងតែការបញ្ជូនរបាយការណ៍ផ្នែកយោធា ដែលផ្ញើមកជូនប្រធានរ.ជ.រ.ប.ខ.ម្តងម្កាល លោក សក់ ស៊ុតសាខន នៅតែទុកដាក់ខ្លួនជាអ្នកដឹកនាំនៃអង្គការចាត់តាំងមួយដាច់ដោយឡែកពីលោកតា សឺន សាន ។ លោកឧត្តមសេនីយនៅតែបន្តធ្វើការតែងតាំង ដោះដូរ ឬ តម្លើងតួនាទីនៃមន្ត្រីជាន់ខ្ពស់ខាងកងទ័ព ដោយមិនចាំបាច់ផ្តល់ព័ត៌មានដល់លោកតាប្រធានឡើយ ។ ដូច្នេះមេបញ្ជាការយោធាដែលមានភក្តីភាពចំពោះលោកតា សឺន សាន ក៏គ្មានជម្រើសអ្វីក្រៅតែពីធ្វើការក្រោមបញ្ជារបស់លោក សក់ ស៊ុតសាខន តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែអស់លោកមេបញ្ជាការទាំងនោះ ចេះរកវិធីមកធ្វើការជាមួយការិយាល័យលោកតា សឺន សាន ដែរ ។ គួររំលឹកថា នៅពាក់កណ្តាលខែ មករា ១៩៨៦ លោក ថាច់ រ៉េង បានឲ្យខ្ញុំដឹងនូវតុល្យការនៃកម្លាំងក.ជ.រ.ប.ខ.គឺ កម្លាំងគាំទ្រលោកតា សឺន សាន មាន ៩.៣៧២ នាក់ ឯកម្លាំងគាំទ្រលោក សក់ ស៊ុតសាខន មានតែ ៣.៨២៨ នាក់តែប៉ុណ្ណោះ ។

តាមពិតទៅ ខ្ញុំមិនដឹងថាមានកម្លាំងគាំទ្រលោកតា សឺន សាន ច្បាស់លាស់ពិតប្រាកដប៉ុន្មានទេ ។ មេបញ្ជាការដែលមានឈ្មោះថាជាអ្នកមានភក្តីភាពចំពោះការដឹកនាំរបស់លោកតា សឺន សាន នោះមាន៖ លោក កែវ ជួន លោក ព្រុំ វិតតាម៉ាំង ឬ លឿង ស៊ីណាក់ លោក ជា ឈុត លោក ជុំ ឈាង លោក ជា ឆាយា និង លោក រក្សា សំបុក ។ តាំងពីដំបូងរៀងរហូតមក ខ្ញុំតែងតែរក្សាទំនាក់ទំនងយ៉ាងល្អជាមួយអស់លោកមេបញ្ជាការទាំងនោះ ដែលបានប្តេជ្ញាដាច់ខាតថាស្មោះសរ ១០០% គាំទ្រលោកតាប្រធាន សឺន សាន ។ បន្ទាប់ពីនោះមកទៀត លោក លីវ

ណៅ ដែលនៅគ្រាដំបូងបានគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ត្រឡប់មកគាំទ្រលោកតា សឺន សាន វិញ ។ លោក ជា ឈុត និង លីវ ណៅ ធ្លាប់ត្រូវបានទទួលការចោទប្រកាន់ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិថា បានរំលោភសិទ្ធិមនុស្សនៅក្នុងជំរុំនងចាន់ និង រិទ្ធិសែន ។

នៅឆ្នាំ ១៩៨៨ លោក ជា ឈុត និង លីវ ណៅ ត្រូវអាជ្ញាធរយោធាថៃនាំយកមកឲ្យរស់នៅឯបាងកកជាមួយពួកយើង និង ហាមឃាត់មិនឲ្យវិលត្រឡប់ទៅដឹកនាំជំរុំវិញឡើយ ។ ដោយទ្រាំនឹងការឃាត់ឃាំងរបស់ថៃ មិនឲ្យវិលទៅនៅជំរុំ និង ដោយទ្រាំក្នុងការរស់នៅដាច់ឆ្ងាយពីកូនទ័ពរបស់គាត់ពុំបាន លោក ជា ឈុត ក៏សម្រេចចិត្តរំលោភលើបទបញ្ជារបស់អាជ្ញាធរថៃ លបរត់ទាំងយប់ទៅទល់ដែន រួចនាំទ័ពរបស់គាត់ទៅលាក់ខ្លួននៅក្នុងទឹកដីខ្មែរ មុននឹងទៅចូលរួមជាមួយ ហ៊្មុន ស៊ិនប៊ុច នៅឆ្នាំ ១៩៩០ ។

ប្រសិនបើគេអាចសង្កេតឃើញអ្នកគាំទ្រ និង អ្នកមានភក្តីភាពចំពោះលោកតាប្រធាន មានចំនួនច្រើនគួរសមដែរនោះ អ្នករត់ចោលពីក្រុមយើងក៏មានខ្លះដែរ ។ លោកអគ្គលេខា នាង ជិនហាន និង អគ្គលេខាធិការរងរបស់គាត់គឺ លោក ប៊ុន សាយ មានវត្តមានកាន់តែញឹកញាប់នៅឯការិយាល័យលោក សក់ ស៊ុតសាខន ហើយពួកគាត់ ចំណាយពេលកាន់តែតិចតួចៗនៅឯម៉ាយ៉ាឡាប់ ។ នៅទីបំផុត លោក ប៊ុន សាយ ក៏បានលាចេញពីតំណែងហិរញ្ញឹក និង អគ្គលេខាធិការរងនៃ រ.ជ.រ.ប.ខ. ។ ដោយសារមានការលាលែងរបស់លោក ប៊ុន សាយ លោកតា សឺន សាន បានប្រគល់ការងារផ្នែកហិរញ្ញវត្ថុឲ្យខ្ញុំជាអ្នកទទួលខុសត្រូវវិញ ។ មុននឹងចេញពីមុខតំណែង លោក ប៊ុន សាយ បានប្រគល់ជូនលោកតា សឺន សាន នូវសាច់ប្រាក់ជាដុល្លារសហរដ្ឋអាមេរិកជាច្រើនម៉ឺនដុល្លារ ។ បន្ទាប់មក លោក ប៊ុន សាយ ក៏បានចូលទៅធ្វើការជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។

ជាមួយនឹងការចាកចេញរបស់លោក ប៊ុន សាយ លោកតា សឹន សាន អាចមើលឃើញជាមុនថាលោកអគ្គលេខា នាង ជិនហន ក៏នឹងបែកចេញមិនខានឡើយ ។ ដូច្នេះលោកតាក៏ចាប់ផ្តើមពិគ្រោះយោបល់រកបេក្ខជនមកជំនួស ។

## ទីបំផុតគេហៅខ្ញុំថា៖ លោកអគ្គលេខា

លោកតាមិនអាចបញ្ឈប់លោក នាង ជិនហន ពីតំណែងបានទេ នៅពេលណាដែលមិនទាន់រកបាននូវអ្នកជំនួស ។ ប្រសិនបើមនុស្សជំនិតរបស់គាត់អាចមកជាន់លើទឹកដីថៃបាន លោកតាប្រហែលជានឹងតែងតាំងលោក ថាច់ រ៉េង ជាអគ្គលេខារ.ជ.រ.ប.ខ.មិនខានឡើយ ។ នោះជាជម្រើសដ៏ល្អសម្រាប់លោកតាប្រធាន ព្រោះលោក ថាច់ រ៉េង មានដើមកំណើតជាខ្មែរកម្ពុជាក្រោមផង និង មានបទពិសោធន៍ខាងផ្នែកយោធាផង ។ តាមពិតទៅ លោកតាប្រធានមិនបានដឹងទេថាលោក ថាច់ រ៉េង ធ្លាប់បានជេរប្រមាថ និង មើលងាយលោកតាថា ជាមេដឹកនាំគ្មានសមត្ថភាព នៅពេលដែលលោកតាមិនអាចការពារអ្នកស្រី សួន កាសេត ពីការបង្ខំរបស់ថៃ ឲ្យអ្នកស្រីចាកចេញពីទឹកដីថៃជាបន្ទាន់នោះ ។ មែនទែនទៅជាទម្លាប់ខ្ញុំមិនដែលរាយការណ៍អាក្រក់ណាមួយអំពីលោក ថាច់ រ៉េង ជូនលោកតាប្រធាន ឬកូនចៅគាត់ឲ្យបានដឹងឡើយ ។ ដោយសារលោក ថាច់ រ៉េង មិនអាចមានវត្តមាននៅលើដីថៃបានយ៉ាងនេះ ទើបលោកតា សឹន សាន សម្លឹងទៅរកលោក អ៊ឹម ឈូដេត ដែលជាច្រើនឆ្នាំមកហើយ នៅតែបន្តភក្តីភាពចំពោះលោកតាប្រធាន និងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរយោធាថៃផង ។ ក៏ប៉ុន្តែ លោក អ៊ឹម ឈូដេត ប្រកែកពុំព្រមទទួលមុខតំណែងនេះ ។ នៅពេលដែលខ្ញុំបង្ខំគាត់ឲ្យឆ្លើយពីមូលហេតុថាហេតុអ្វីបានជាមិនទទួលតួនាទីជាអគ្គលេខាលោក អ៊ឹម ឈូដេត និយាយ

ថា៖ "ខ្ញុំស្រឡាញ់លោកប្រធាន សឺន សាន ណាស់ ។ លោកជាអ្នកដឹកនាំល្អ ។ ក៏ប៉ុន្តែ ខ្ញុំមិនអាចធ្វើការជាមួយលោកប្រធានតូចបានឡើយ" ។ ចំពោះចម្លើយរបស់លោក អ៊ឹម ឈូដេត នេះ នៅពេលនោះ ខ្ញុំនៅមានការស្រពិចស្រពិលមិនច្បាស់លាស់ថានរណាមួយជា "លោកប្រធានតូច" នោះឡើយ ។ ខ្ញុំចេះតែកាត់ស្មានថាប្រហែលជាលោក សឺន ស៊ូប្តេរ ឬ លោក ថាច់ រ៉េង ។

តាមពិត លោក អ៊ឹម ឈូដេត ដឹងច្បាស់ថាលោកតា សឺន សាន គ្រាន់តែយកគាត់មកប្រើរបៀបជាអាយ៉ងតែប៉ុណ្ណោះ ព្រោះការងារសំខាន់ៗលោកតាប្រធានស្តាប់តែកូនគាត់ ស្តាប់តែលោក ថាច់ រ៉េង ឬ អ្នកស្រី សួន កាសេត តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ប្រហែលជាលោក អ៊ឹម ឈូដេត មិនមានបំណងនៅបន្តការតស៊ូតទៅទៀត ឬ ទំនងជាគាត់មានបំណងនាំគ្រួសារចេញទៅនៅប្រទេសទីបីផង ទើបគាត់ពុំព្រមទទួលមុខតំណែងជាអគ្គលេខាធិការរ.ជ.រ.ប.ខ.នេះ ។ ដោយលោក អ៊ឹម ឈូដេត ប្រកែកយ៉ាងនេះ ទើបលោកតាប្រធានស្នើប្រគល់តំណែងនេះជូនលោក ឈឹម ឱមយ៉ុន ។

លោក ឈឹម ឱមយ៉ុន ជានាយទាហានជាន់ខ្ពស់ធ្លាប់រៀនសូត្រជាមួយលោកឧត្តមសេនីយ ដៀន ដែល ដែរ និង ធ្លាប់កាន់តំណែងជាអនុពន្ធយោធារបស់សាធារណរដ្ឋខ្មែរប្រចាំទីក្រុងព្រៃនគរ រហូតដល់ថ្ងៃខ្មែរក្រហមទទួលជ័យជំនះ ។ លោក ឈឹម ឱមយ៉ុន មាននាយទាហាន ដែលភៀសខ្លួនទៅនៅប្រទេសបារាំងចំនួនច្រើនគួរសមដែរជួយគាំទ្រ ។ លោក ឈឹម ឱមយ៉ុន បានគាំទ្រលោកតា សឺន សាន ជាយូរមកហើយ ។ ក្រុមរបស់គាត់មិនសូវចូលចិត្តលោក ថាច់ រ៉េង ប៉ុន្មានទេ ព្រោះមើលឃើញថាលោក ថាច់ រ៉េង ពូកែតែទ្រឹស្តី ហើយម្យ៉ាងទៀត ក្នុងឋានៈជានាយទាហានធ្លាប់ធ្វើការជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន លោក ឈឹម ឱមយ៉ុន នៅតែរក្សាទំនាក់ទំនងល្អ និង គោរពលោក សក់ ស៊ុតសាខន ជាដរាប ។

លោក ឈឹម ឱមយ៉ុន បានត្រឡប់ទៅប្រទេសបារាំងវិញ ក្រោយពេលព្យាយាមធ្វើជាមេអណ្ដើកផ្សះផ្សាគ្នាពុំបានសម្រេចរវាងក្រុមលោកតា សឺន សាន និង សក់ ស៊ុតសាខន ។

ក្រោយពីបានទទួលសំណើពីលោកតាប្រធានមក លោក ឈឹម ឱមយ៉ុន បានសរសេរលិខិតមួយច្បាប់យ៉ាងវែងជំរាបលោកតាអំពីគំរោងការ ដែលគាត់អាចធ្វើ ប្រសិនបើកាន់តួនាទីជាអគ្គលេខាធិការរ.ជ.រ.ប.ខ. ។ អ្វីជាលក្ខខណ្ឌសំខាន់របស់លោក ឈឹម ឱមយ៉ុន នោះគឺ សុំសិទ្ធិបន្តធ្វើការជាមួយលោក សក់ ស៊ុតសាខន ក្នុងន័យផ្សះផ្សាជានាគ្នារវាងលោកតាប្រធាន និង លោកអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ។ គំនិតនេះមិនបានទទួលការគាំទ្រពីលោកតា សឺន សាន ទេ ។ លោកតាមិនចង់បានអ្នកផ្សះផ្សាជានាគ្នាអ្វីទេ ។ អ្វីដែលលោកតាប្រធានចង់បាននោះគឺអ្នកដាច់ខាត ដែលហ៊ានចេញមុខតតាំងជាមួយក្រុមប្រឆាំង ដើម្បីឲ្យអ្នកទាំងនោះទទួលយល់ព្រមស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ប្រធានតែប៉ុណ្ណោះ ។ ចំពោះលោកតា សឺន សាន ធ្វើការជិតស្និទ្ធជាមួយក្រុមប្រឆាំងបានន័យថា ស៊ីរះទាំងសងខាង ខាងនេះក៏ត្រូវ ខាងនោះក៏ត្រូវ ។ គោលជំហរបែបនេះ មិនអាចទទួលយកបានដាច់ខាត ។

ពេលវេលាចេះតែកន្លងផុតទៅអស់ជាច្រើនខែ ក្រុមលោកតាប្រធាននៅតែរកមនុស្សមកជំនួសលោក នាង ជិនហន មិនបាន ។ បញ្ហានេះ ក៏ក្លាយជាបញ្ហាចម្បង ឬ ជាការប្រញាប់ ។ បើចង់ឲ្យលោក នាង ជិនហន ចេញ ទាល់តែរកមនុស្សជំនួសឲ្យបាន ។ នៅពេលនោះ ខ្ញុំបានទទួលការទុកចិត្តទុកថ្លើមពីលោកតាប្រធានតាមរយៈទំនាក់ទំនងដ៏ល្អជាលក្ខណៈបងប្អូនរវាងខ្ញុំ និង កូនរបស់លោកតាប្រធាន គឺ លោក សឺន ស៊ូប៉ែរ្ត៍ ដែលមានអាយុបងខ្ញុំចំនួន ៨ ឆ្នាំ ។

នៅខែ មករា ១៩៨៨ លោកតា សឺន សាន បានតែងតាំងខ្ញុំជាអ្នកតំណាងរបស់ប្រធានរ.ជ.រ.ប.ខ.ទទួលបន្ទុករដ្ឋបាលស៊ីវិលប្រចាំជំរុំសាយធូ។ មុខនាទីរបស់ខ្ញុំនៅពេលនោះគឺ ជួយសម្រួលឲ្យមានរដ្ឋបាលកណ្តាលមួយសម្រាប់ជំរុំសាយធូទាំងមូល ដែលពីមុនមកមានរដ្ឋបាលបែកខ្ញែកគ្នាតាមជំរុំតូចៗទាំងឡាយ ។ ជាមួយនេះ ខ្ញុំក៏ជួយរៀបចំឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានរដ្ឋបាលកណ្តាលម្នាក់ ។ តាមរយៈការបោះឆ្នោត លោក ឡាយ ខែក ដែលគេស្គាល់ថាជាមនុស្សមានស្វាមីភក្តិបំផុតចំពោះលោកប្រធានរ.ជ.រ.ប.ខ. ត្រូវបានជាប់ជាប្រធានរដ្ឋបាលកណ្តាលជំរុំសាយធូ ។ ប្រហែលជាត្រូវបានលោក សឺន ស៊ូប៉ែរ្ត៍ ផ្តល់គំនិតជូន ទើបនៅទីបំផុត នៅខែ មិថុនា ១៩៨៨ លោកតា សឺន សាន បានសម្រេចប្រគល់តំណែងអគ្គលេខាធិការមករូបខ្ញុំ[195] ។

ខ្ញុំយល់ថាលោកតាប្រធានជឿទុកចិត្តចំពោះរូបខ្ញុំ ពីព្រោះជាយូរឆ្នាំមកហើយ ខ្ញុំបានបង្ហាញភក្តីភាពដ៏ដាច់ខាតរបស់ខ្ញុំចំពោះលោកតា ។ ម្យ៉ាងទៀតខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធ ឬ ជួយបំពេញគ្នាទៅវិញទៅមកជាមួយលោក សឺន ស៊ូប៉ែរ្ត៍ ។ ខ្ញុំអាចប៉ាន់ស្មាននៅពេលនោះថា ការតែងតាំងខ្ញុំជាអគ្គលេខាធិការ ក៏មានតម្លៃប្រហាក់ប្រហែលតែងតាំងលោក សឺន ស៊ូប៉ែរ្ត៍ ក្នុងដំណែងនេះដែរ ។

នៅពេលថ្ងៃត្រូវផ្ទេរតំណែងមកដល់ ខ្ញុំ និង លោក នាង ជិនហាន បានជួបគ្នាតែពីរនាក់នៅក្នុងការិយាល័យរបស់គាត់ ។ នៅពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះលោក នាង ជិនហាន មិនបានបញ្ចេញអាកប្បកិរិយាអមិត្តដូចដែលខ្ញុំធ្លាប់គិតក្នុងចិត្តនោះទេ ទាំងចំពោះលោកប្រធាន ទាំងចំពោះរូបខ្ញុំ ។ ផ្ទុយទៅវិញ លោក នាង ជិនហាន ជូនពរឲ្យខ្ញុំបានទទួលជោគជ័យក្នុងភារកិច្ចថ្មី និង បញ្ជាក់ជា

[195] ចាប់ពីថ្ងៃទី ២១ មិថុនា ១៩៨៨ ខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានចេញកំណត់ទូត ផ្សព្វផ្សាយដល់បេសកកម្មទូតប្រទេសជាមិត្តប្រចាំទីក្រុងបាងកក អំពីការតែងតាំងរូបខ្ញុំជាអគ្គលេខាធិការ រ.ជ.រ.ប.ខ. ។

ថ្មីថាបេសកកម្មរបស់យើងទាំងអស់គ្នា មិនមែនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ តែត្រូវលើកស្ទួយចលនាតស៊ូរ.ជ.រ.ប.ខ.ឲ្យបានជ័យជំនះ ។ និយាយចំចំណុចនេះ លោក នាង ជិនហន ហាក់ដូចជាផ្តល់មេរៀនស្នេហាជាតិដល់ខ្ញុំយ៉ាងដូច្នេះដែរ ។

ចាប់តាំងពីថ្ងៃខ្ញុំទទួលតំណែងនេះភ្លាម មិត្តភក្តិ ឬ បុគ្គលិកជំនួយការទាំងអស់ដែលនៅជុំវិញខ្ញុំ ចាប់ផ្តើមហៅខ្ញុំថា"លោកអគ្គលេខា"ភ្លាម ដែលនៅពេលនោះខ្ញុំហាក់ដូចជាមិនទាន់ចាប់អារម្មណ៍ប៉ុន្មានថា គេកំពុងនិយាយមករកខ្ញុំ ព្រោះខ្ញុំធ្លាប់តែឮគេហៅលោក នាង ជិនហន ជាទម្លាប់យូរមកហើយ ។ ទម្រាំខ្ញុំស៊ាំត្រចៀកចំពោះពាក្យ "លោកអគ្គលេខា" នេះ ខ្ញុំត្រូវចំណាយពេលអស់ជាច្រើនខែទៀត ។

ប៉ុន្មានថ្ងៃក្រោយមក ពួកយើងចេញដំណើរទៅធ្វើទស្សនកិច្ច នៅតាមជំរុំជាយដែន ។ នៅជំរុំសុខសាន្ត ដែលជាប់នឹងទឹកដីខេត្តច័ន្ទបុរីនៃប្រទេសថៃ លោកតា សឺន សាន បានបង្ហាញរូបខ្ញុំចំពោះជនភៀសខ្លួនខ្មែររាប់ពាន់នាក់ថាជាអគ្គលេខាធិការថ្មីនៃរ.ជ.រ.ប.ខ. ។ បន្ទាប់មកលោកតាប្រធាន បានណែនាំឲ្យខ្ញុំថ្លែងទៅកាន់ប្រជាពលរដ្ឋទាំងនោះ ។ ខ្ញុំក៏ចាប់ផ្តើមនិយាយទៅកាន់មនុស្សរាប់ពាន់នាក់នោះជាលើកដំបូង ដោយគូសបញ្ជាក់ពីបន្ទាត់នយោបាយរបស់រ.ជ.រ.ប.ខ.និង អំពីផែនការការងាររបស់ខ្ញុំ សម្រាប់ចលនាតស៊ូរបស់យើងនាពេលអនាគត ។ ចំពោះអ្នកស្តាប់ទាំងឡាយ សុន្ទរកថាឥតព្រាងទុករបស់ខ្ញុំនោះ បានធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះពីមុនគេមិនដែលឮខ្ញុំនិយាយជាសាធារណៈបែបនេះសោះ ។ លោក អ៊ឹម ឈូដេត ជាមនុស្សទីមួយដែលក្រោកឈរឡើងចាប់ដៃខ្ញុំ សរសើរមិនដាច់ពីមាត់ថា "បើដឹងថាចេះនិយាយ បានល្អយ៉ាងនេះពីមុនមកម្ល៉េះ មូលី ឯងសមទទួលមុខនាទីជាអគ្គលេខាធិការជាយូរមកហើយ មិនចាំបាច់ទៅរកឯណាវែងឆ្ងាយ

ឡើយ" ។ សរុបសេចក្តីមក ការចេញមុខជួបសាធារណៈជនជាលើកទីមួយរបស់ខ្ញុំ បានទទួលលទ្ធផលល្អ ។

នៅពេលដែលខ្ញុំចាកចេញពីប្រទេសបារាំង មកចូលរួមជាមួយ រ.ជ.រ.ប.ខ. នៅជួរមុខ ខ្ញុំគ្រាន់តែមានគំនិតចូលរួមធ្វើការតស៊ូធ្វើពលីកម្ម ដើម្បីបុព្វហេតុជាតិតែប៉ុណ្ណោះ ។ ខ្ញុំមិនដែលនឹកនាស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន មុខមាត់ បុណ្យសក្តិ ឬ តំណែងសំខាន់ៗនៅក្នុងចលនារ.ជ.រ.ប.ខ.នេះឡើយ ។ ខ្ញុំយល់ថាការដែលលោកតា សឺន សាន បានប្រគល់មុខតំណែងជាអគ្គលេខាធិការឲ្យខ្ញុំនេះ ពីព្រោះលោកតាគ្មានជំរើសអ្វីក្រៅពីនេះ នៅពេលដែលចលនាតស៊ូរ.ជ.រ.ប.ខ.កំពុងជាប់ជំពាក់ក្នុងជម្លោះផ្ទៃក្នុងឥតឈប់ឈរ ។ ការមិនទុកចិត្តគ្នារវាងថ្នាក់ដឹកនាំកំពូលៗ ការបែកបាក់ប្រេះស្រាំ បាននាំឲ្យចលនាតស៊ូរបស់ពួកយើង ចេះតែធ្លាក់ទន់ខ្សោយជាលំដាប់គ្មានពេលពង្រឹងឡើងវិញបានឡើយ ។ នៅសម័យនោះ គ្មានអ្នកដឹកនាំណាម្នាក់នឹកឃើញរូបមន្ត ដែលអាចឲ្យរួមរស់នៅជាមួយគ្នាបាន ក្រៅពីវិធីកំចាត់គ្នាចេញនោះឡើយ ។ ដោយសារសភាពទន់ខ្សោយរបស់យើង កត្តាខាងក្រៅចូលមកញាំញីព្រេងវាសនារបស់យើង ។ ប្រទេសខាងក្រៅ ឬ មហាអំណាចខាងក្រៅ សុទ្ធតែមានផលប្រយោជន៍របស់គេ ដែលគេត្រូវតែមាននយោបាយ ឬ គោលដៅទៅសម្រេចឲ្យបាន ដោយគេបត់បែនចុះឡើង ដែលយើងមិនអាចយល់ដឹង ។

បើងាកទៅក្រោយ ២០ ឬ ៣០ ឆ្នាំមុន ខ្ញុំពិតជាយល់ថាការចងក្រងមនុស្សឲ្យក្លាយជាចលនាតស៊ូមួយ ប្រាកដជាលំបាកក្រៃលែង ជាពិសេស ចងក្រងមនុស្សពីគំនរផេះផង់នៃភ្លើងវិនាសកម្ម ។ ខ្ញុំមិនគួរលើកកំហុស ឬ ថ្កោលទោសថ្នាក់ដឹកនាំណាមួយឡើយ ចំពោះការខ្វះខាត ឬ អំពើជាអវិជ្ជមានរបស់អស់លោកទាំងនោះ ។ តែព្រឹត្តិការណ៍ទាំងនោះ ក៏បានផ្តល់ជាបទពិសោធន៍ដ៏ពិសិដ្ឋសម្រាប់ខ្មែរជំនាន់ក្រោយ ។